**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Économiques**

**Royal university of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# ការអភិវឌ្ឍរាជធានីភ្នំពេញប្រកបដោយ សណ្តាប់ធ្នាប់ និងនិរន្តរភាព

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **ក. ណៅរ៉ុន បញ្ញាវត្តី**

**ជា ឧស្សាហ៍**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត អ៊ុន សកក្កដា**



ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៦ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Économiques**

**Royal university of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ការអភិវឌ្ឍរាជធានីភ្នំពេញប្រកបដោយ សណ្តាប់ធ្នាប់ និងនិរន្តរភាព

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **ក. ឈោរ៉ុន បញ្ញវត្តី**

**ជា ឧស្សាហ៍**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៦ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរនាក់ ឈ្មោះ **ណេរ៉ុន បញ្ញាវត្តី** និង**ជា ឧស្សាហ៍** ជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី២៦ អាហារូបករណ៍ ផ្នែកនីតិសាស្ត្រ ឆ្នាំសិក្សា ២០២០ - ២០២១។

**សូមគោរពដឹងគុណ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ**

- **លោកយាយ លោកឪពុក អ្នកម្តាយ និងអ្នកមានគុណ** ដែលបានចិញ្ចឹមបីបាច់ថែរក្សា ហើយផ្តល់នូវការអប់រំប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងទូន្មានប្រៀនប្រដៅកូនចៅឱ្យក្លាយជា កូនល្អ សិស្សល្អ មិត្តល្អ និងជាបុគ្គលល្អនៅក្នុងសង្គម។ មិនតែប៉ុណ្ណោះ លោកអ្នកមានគុណបានទំនុកបម្រុងផ្នែកស្មារតី សម្ភារ និង ឱកាសឱ្យយើងខ្ញុំទាំងពីរបានសិក្សារៀនសូត្រ ដើម្បីក្រេបជញ្ជក់យកចំណេះវិជ្ជា និងបទពិសោធន៍ ដើម្បីក្លាយខ្លួនជាបុគ្គលដែលមានតម្លៃសម្រាប់ខ្លួនឯង គ្រួសារ និងសង្គមជាតិទាំងមូល។
- **ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក-លោកស្រីសាស្ត្រាចារ្យ** និងលោកគ្រូ អ្នកគ្រូ ជាបុគ្គលិកការិយាល័យស្រាវជ្រាវ ព្រមទាំងបុគ្គលិកការិយាល័យសិក្សាគ្រប់រូបនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលតែងតែខិតខំប្រឹងប្រែងអស់កម្លាំងកាយចិត្ត ក្នុងការផ្តល់ពុទ្ធិចំណេះដឹងដល់និស្សិតគ្រប់រូប និងបានធ្វើការដឹកនាំ អភិវឌ្ឍ ពង្រឹងនូវវិន័យ បង្ហាត់បង្ហាញ និងសម្របសម្រួលកិច្ចការទាំងឡាយនៅក្នុងសាកលវិទ្យាល័យ យ៉ាងអស់ពីកម្លាំងកាយចិត្ត។
- **លោកសាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការណែនាំផ្តល់ជាគន្លឹះ យោបល់ល្អៗ ព្រមទាំងជួយកែសម្រួល និងដឹកនាំការស្រាវជ្រាវសារណាបញ្ចប់ការសិក្សាមួយនេះតាំងពីពេលចាប់ផ្តើម រហូតដល់បានសម្រេចជាស្នាដៃសៀវភៅមួយក្បាលនេះឡើងដោយជោគជ័យ។
- **រាជរដ្ឋាភិបាលកម្ពុជា** ចំពោះការដឹកនាំនាវាកម្ពុជាឱ្យមានសុខសន្តិភាព ប្រកបដោយភាពត្រឹមត្រូវ ព្រមទាំងផ្តល់ឱកាសឱ្យយើងខ្ញុំជាសិស្ស និស្សិត បានសិក្សាក្រេបជញ្ជក់យកចំណេះវិជ្ជា និងមានឱកាសបានចូលរួមអភិវឌ្ឍសង្គមជាតិនាពេលអនាគត។

ជាចុងក្រោយ យើងខ្ញុំទាំងពីរនាក់ សូមគោរពបួងសួងដល់វត្ថុស័ក្តិសិទ្ធិនៅគ្រប់ទីកន្លែងទាំងអស់នៅក្នុងលោក សូមជួយតាមថែរក្សាការពារ **ចំពោះគ្រប់លោកអ្នកមានគុណទាំងអស់** និងជាពិសេសចំពោះ **លោកសាស្ត្រាចារ្យបណ្ឌិត អ៊ុន សកក្កដា** ឱ្យជួបតែពុទ្ធពរទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** ព្រមទាំងសម្រេចបាននូវគោលបំណង ទទួលបានជោគជ័យគ្រប់ភារកិច្ចទាំងអស់ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

យើងខ្ញុំទាំងពីរនាក់ជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រឆ្នាំទី៤ ពិតជាមានសេចក្តីសោមនស្សរីករាយ និងមានមោទកភាពជាខ្លាំង ដោយមានឱកាសបានសិក្សាស្រាវជ្រាវរៀបចំនូវសារណាមួយក្រោមប្រធានបទស្តីអំពី «**ការអភិវឌ្ឍរាជធានីភ្នំពេញប្រកបដោយសណ្តាប់ធ្នាប់ និងនិរន្តរភាព**» ឱ្យលេចចេញរូបរាងជាស្ថាពរ។ សមិទ្ធផលនៃសារណានេះ ត្រូវបានចងក្រងឡើងតាមរយៈការសិក្សាស្រាវជ្រាវលើបណ្តាឯកសារពាក់ព័ន្ធទាំងឡាយរួមមាន លិខិតបទដ្ឋានគតិយុត្តជាតិ របាយការណ៍នានាដែលទាក់ទងនឹងការរៀបចំទីក្រុងពិសេសរបាយការណ៍ពីប្រភពបរទេស រួមផ្សំនឹងឯកសារស្រាវជ្រាវរបស់សាស្ត្រាចារ្យនៃជំនាញពាក់ព័ន្ធ។

ដោយយើងសង្កេតឃើញថា រាជធានីភ្នំពេញនាពេលបច្ចុប្បន្ន កំពុងតែមានសន្ទុះក្នុងការអភិវឌ្ឍយ៉ាងខ្លាំងក្លាក្នុងចំណោមបណ្តាទីក្រុងទាំងឡាយនៅអាស៊ី។ យ៉ាងណាមិញ បទពិសោធន៍នៃការរៀបចំទីក្រុងសម័យទំនើបដែលបំពេញតម្រូវការរបស់កំណើនប្រជាជនយ៉ាងគំហុកនៅកម្ពុជា ដែលជាប្រទេសកំពុងអភិវឌ្ឍនៅមានសភាពក្មេងខ្ចីនៅឡើយ ហើយការអភិវឌ្ឍដ៏ឆាប់រហ័សនេះទៀតសោត ក៏បង្កជាផលប៉ះពាល់ដល់សណ្តាប់ធ្នាប់ សោភណភាព និងបញ្ហាប្រឈមនាពេលអនាគត ដែលបញ្ហាទាំងនេះបានកើតមានឡើងរួចទៅហើយនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍជាច្រើន។ ដូច្នេះហើយ ទើបយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទទាក់ទងនឹងការអភិវឌ្ឍរាជធានីភ្នំពេញមកធ្វើជាសារណាបញ្ចប់ការសិក្សា ព្រោះថាប្រធានបទនេះពិតជាមានសារៈសំខាន់យ៉ាងខ្លាំងចំពោះយើងខ្ញុំទាំងពីរនាក់ រួមទាំងអ្នកអានឱ្យបានសិក្សាស្វែងយល់ស៊ីជម្រៅពីបច្ចេកទេស ព្រមទាំងយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍទីក្រុងភ្នំពេញឱ្យមានសណ្តាប់ធ្នាប់ សោភណភាព ផាសុកភាព និងបំពេញតម្រូវការរបស់កំណើនប្រជាជនដ៏ច្រើនសន្ធឹកសន្ធាប់នាពេលបច្ចុប្បន្នតទៅជំនាន់ក្រោយជានិរន្តរ៍។

បើទោះជាឆ្លងកាត់ការយកចិត្តទុកដាក់ និងការត្រួតពិនិត្យដោយការប្រុងប្រយ័ត្នខ្ពស់យ៉ាងណាក៏ដោយ យើងខ្ញុំជឿថាចំណុចខ្វះខាតដោយអចេតនានូវប្រការណាមួយរមែងកើតមានឡើង ដូចជាទៅលើការបកស្រាយការបកប្រែវាក្យសព្ទបច្ចេកទេសពីភាសាបរទេសមកជាភាសាជាតិ អក្ខរាវិរុទ្ធ និងការប្រើប្រាស់ប្រយោគឃ្លាឃ្លោងពាក្យពេចន៍ ជាដើម។ ដូច្នេះហើយ យើងខ្ញុំសូមអភ័យទោសជាមុននូវរាល់កំហុសឆ្គងទាំងឡាយដែលកើតមានឡើងដោយឥតព្រាងទុក ហើយយើងខ្ញុំនឹងមានសេចក្តីរីករាយក្នុងការទទួលនូវរាល់មតិរិះគន់ទាំងឡាយក្នុងន័យស្ថាបនា ដើម្បីកែលម្អឱ្យសារណានេះមានខ្លឹមសារកាន់តែប្រសើរបន្ថែមមួយកម្រិតទៀត។

ថ្ងៃព្រហស្បតិ៍ ៥ រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ២០២១

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........................................ ១

## ជំពូកទី១

## ការរៀបចំទីក្រុងឱ្យមានសណ្តាប់ធ្នាប់

**១.១. សញ្ញាណទូទៅនៃការរៀបចំក្រុង** ........................................ ៤

**១.១.១. និយមន័យ** ........................................ ៤

១.១.១.១. និយមន័យទីក្រុង ........................................ ៤

១.១.១.២. និយមន័យនិរន្តរភាព ........................................ ៥

១.១.១.៣. អ្វីទៅជារបៀបវារៈទីក្រុងថ្មី ........................................ ៦

**១.១.២. ប្រវត្តិនៃការរៀបចំទីក្រុងនៅប្រទេសកម្ពុជា** ........................................ ៦

១.១.២.១. ការវិវត្តនៃទីក្រុងអង្គរ ........................................ ៧

១.១.២.២. ការរៀបចំទីក្រុងខ្មែរនៅសម័យអង្គរ និងទំនាក់ទំនងជាមួយនឹងទស្សនៈព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា ........................................ ៨

**១.១.៣. មូលហេតុនៃការរៀបចំក្រុង** ........................................ ៩

១.១.៣.១. កំណើនប្រជាជន ........................................ ១០

១.១.៣.២. ភាពក្រីក្រ ........................................ ១០

១.១.៣.៣. គុណភាពនៃការរស់នៅ ........................................ ១០

១.១.៣.៤. ការដាក់សម្ពាធបរិស្ថាន ........................................ ១១

**១.១.៤. ការវិវត្តនៃរាជធានីភ្នំពេញ** ........................................ ១១

១.១.៤.១. ការតាំងរាជធានីនៅភ្នំពេញ ........................................ ១១

១.១.៤.២. ការពង្រីកទីក្រុងភ្នំពេញ និងល្បឿននគរូបនីយកម្ម ........................................ ១២

១.១.៤.៣. នគរូបនីយកម្មនៅក្រុងភ្នំពេញ ........................................ ១៤

**១.១.៥. ស្ថានភាពនៃការរៀបចំក្រុងបច្ចុប្បន្ន** ........................................ ១៥

១.១.៥.១. ការរៀបចំស្ថាប័ន ........................................ ១៥

១.១.៥.២. ស្ថានភាពគតិយុត្តនៃការរៀបចំក្រុងនៅប្រទេសកម្ពុជា ........................................ ១៧

១.១.៥.៣. ស្ថានភាពទីក្រុងនៅរាជធានីភ្នំពេញ ........................................ ២០

១.១.៥.៤. បញ្ហាប្រឈមសំខាន់ៗក្នុងទីក្រុង ....................................................................................................... ២៣

**១.២. ការរៀបចំរាជធានីភ្នំពេញឱ្យមានសណ្តាប់ធ្នាប់ និងសោភណភាព** ............................. ២៩

**១.២.១. ធាតុផ្សំនៃសណ្តាប់ធ្នាប់** ................................................................................................ ៣០

១.២.១.១. សន្តិសុខ ................................................................................................................ ៣០

១.២.១.២. ភាពស្ងប់ស្ងៀម ...................................................................................................... ៣១

១.២.១.៣. អនាម័យ ................................................................................................................ ៣១

**១.២.២. សោភណភាព** .................................................................................................................. ៣២

១.២.២.១. សោភណភាពពេលថ្ងៃ ........................................................................................... ៣២

១.២.២.២. សោភណភាពពេលយប់ ......................................................................................... ៣៣

**១.២.៣. ផែនការយុទ្ធសាស្ត្រ ក្នុងការរៀបចំសណ្តាប់ធ្នាប់ និងសោភណភាពនៅក្នុងរាជធានីភ្នំពេញ** ............................................................................................................................ ៣៣

១.២.៣.១. ការប្រើប្រាស់ចិញ្ចើមផ្លូវសាធារណៈ ...................................................................... ៣៣

១.២.៣.២. ការរៀបចំសណ្តាប់ធ្នាប់តាមបណ្តោយមហាវិថីអាទិភាព ........................................... ៣៤

**១.២.៤. ការប្រើប្រាស់ដីធ្លី និងសំណង់** .................................................................................... ៣៧

១.២.៤.១. បទប្បញ្ញត្តិនគរូបនីយកម្មនៃប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ ........................................ ៣៧

១.២.៤.២. លក្ខណៈស្ថាបត្យកម្ម ............................................................................................. ៤០

១.២.៤.៣. ការរៀបចំផែនការប្រើប្រាស់ដីធ្លីទីក្រុង ................................................................... ៤៣

## ជំពូកទី២

## ការអភិវឌ្ឍរាជធានីភ្នំពេញប្រកបដោយនិរន្តរភាព

**២.១. របៀបវារៈទីក្រុងថ្មី** ............................................................................................................ ៤៦

**២.១.១. វិស័យសំខាន់នៃរបៀបវារៈទីក្រុងថ្មី** ............................................................................. ៤៦

២.១.១.១. និរន្តរភាពសង្គម .................................................................................................... ៤៧

២.១.១.២. និរន្តរភាពសេដ្ឋកិច្ច ................................................................................................ ៤៩

២.១.១.៣. និរន្តរភាពបរិស្ថាន ................................................................................................. ៥១

២.១.១.៤. និរន្តរភាពនៃលំហទីក្រុង ......................................................................................... ៥៣

**២.១.២. របៀបវារៈទីក្រុងថ្មីនៅក្នុងបរិបទប្រទេសកម្ពុជា** .............................................................. ៥៤

២.១.២.១. បញ្ហានគរូបនីយកម្ម .............................................................................................. ៥៤

២.១.២.២. ដំណោះស្រាយនៃរបៀបវារៈទីក្រុងថ្មីដែលអាចអនុវត្ត នៅក្នុងបរិបទនៃប្រទេសកម្ពុជា......................៥៩
**២.២. ការអភិវឌ្ឍរាជធានីភ្នំពេញប្រកបដោយនិរន្តរភាព**.................................................... ៦៣
**២.២.១. ចក្ខុវិស័យ គោលបំណង និងគោលដៅក្នុងការអភិវឌ្ឍរាជធានីភ្នំពេញ**............ ៦៣
២.២.១.១. ចក្ខុវិស័យ ................................................................................................ ៦៣
២.២.១.២. គោលដៅ .................................................................................................៦៤
២.២.១.៣. គោលបំណង..............................................................................................៦៤
**២.២.២. ផែនការមេក្នុងការអភិវឌ្ឍរាជធានីភ្នំពេញ** ................................................... ៦៧
២.២.២.១. ផែនការប្រើប្រាស់ដីធ្លីក្នុងរាជធានីភ្នំពេញក្នុងឆ្នាំ ២០៣៥.......................................... ៦៧
២.២.២.២. ផែនការមេរៀបចំប្រព័ន្ធដឹកជញ្ជូនទីក្រុង ...........................................................៦៨
២.២.២.៣. ក្របខណ្ឌគោលនយោបាយសម្រាប់អភិវឌ្ឍទីក្រុងនិរន្តរភាពនៅកម្ពុជា...........................៦៩
**២.២.៣. វិស័យអាទិភាពទាំង៨ សម្រាប់ការអភិវឌ្ឍទីក្រុងនិរន្តរភាព**...............................៦៩
២.២.៣.១. បញ្ហាប្រឈមសំខាន់ៗក្នុងវិស័យអាទិភាព............................................................ ៧០
២.២.៣.២. សកម្មភាពអាទិភាពក្នុងការអភិវឌ្ឍទីក្រុងនិរន្តរភាព.................................................. ៧៦
២.២.៣.៣. និរន្តរភាព និងវិសមភាព ...........................................................................៨១
**២.២.៤. សំណើនៃការរៀបចំរចនាសម្ព័ន្ធស្ថាប័នអនុវត្តទីក្រុងនិរន្តរភាព និងយន្តការគាំទ្រ**. ៨៣
២.២.៤.១. គណៈកម្មការប្រឹក្សាយោបល់.............................................................................. ៨៣
២.២.៤.២. ក្រុមការងារបច្ចេកទេស ...................................................................................៨៤
**២.២.៥. ឧបសគ្គក្នុងការអភិវឌ្ឍរាជធានីភ្នំពេញ**...........................................................៨៥
២.២.៥.១. កង្វះភាពច្បាស់លាស់ក្នុងបែងចែកតួនាទី និងការទទួលខុសត្រូវ .................................៨៦
២.២.៥.២. សមត្ថភាពស្ថាប័ន និងការអនុវត្តផែនការនៅមានកម្រិត ......................................... ៨៧
២.២.៥.៣. ការផ្តល់ហិរញ្ញប្បទានពុំមាននិរន្តរភាព ............................................................. ៨៧
**សេចក្តីសន្និដ្ឋាន**..................................................................................................៨៩
**អនុសាសន៍**.........................................................................................................៩០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

យើងសង្កេតឃើញថា រាជធានីភ្នំពេញនាពេលបច្ចុប្បន្ន កំពុងតែមានសន្ទុះក្នុងការអភិវឌ្ឍយ៉ាងខ្លាំងក្លាក្នុងចំណោមបណ្តាទីក្រុងទាំងឡាយនៅអាស៊ី។ យ៉ាងណាមិញ បទពិសោធន៍នៃការរៀបចំទីក្រុងនាសម័យទំនើបដែលបំពេញតម្រូវការរបស់កំណើនប្រជាជនយ៉ាងគំហុកនៅកម្ពុជា ដែលជាប្រទេសកំពុងអភិវឌ្ឍ នៅមានសភាពក្មេងខ្ចីនៅឡើយ ហើយការអភិវឌ្ឍដ៏ឆាប់រហ័សនេះទៀតសោត ក៏បង្កជាផលប៉ះពាល់ដល់សណ្តាប់ធ្នាប់សោភណភាព និងបញ្ហាប្រឈមនាពេលអនាគត ដូចជាហេដ្ឋារចនាសម្ព័ន្ធទីក្រុង បរិស្ថានធម្មជាតិ និងជាពិសេសសុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់អ្នករស់នៅក្នុងទីក្រុង ដែលបញ្ហាទាំងអស់នេះបានកើតមានឡើងរួចទៅហើយនៅតាមបណ្តាប្រទេសជាច្រើនដែលស្ថិតនៅក្នុងដំណាក់កាលកំពុងអភិវឌ្ឍ។ បើទោះជា ល្បឿននៃការអភិវឌ្ឍក្នុងទីក្រុងភ្នំពេញទាំងផ្នែកសេដ្ឋកិច្ច និងនគរូបនីយកម្មមានសន្ទុះលឿនយ៉ាងណាក៏ដោយ ក៏ប៉ុន្តែល្បឿននៃការអភិវឌ្ឍនេះ ពុំមែនជាកត្តាកំណត់ថា ការអភិវឌ្ឍកំពុងតែឆ្ពោះទៅរកទិសដៅមួយដ៏ល្អប្រសើរនោះឡើយ។ ជាក់ស្តែងនាពេលបច្ចុប្បន្ន យើងសង្កេតឃើញថារាជធានីភ្នំពេញបាន និងកំពុងជួបប្រទះនូវបញ្ហាទីក្រុងជាច្រើន ដែលបង្កឡើងដោយសារតែការអភិវឌ្ឍដោយពុំបានគិតគូរពីផលប៉ះពាល់ដែលអាចនឹងកើតមានឡើង ហើយបើយើងសិក្សាឱ្យបានស៊ីជម្រៅ ការអភិវឌ្ឍនាពេលសព្វថ្ងៃនេះ អាចត្រឹមតែបំពេញតម្រូវការទីក្រុងបានមួយពេលតែប៉ុណ្ណោះ ពោលគឺដំណើរនៃការអភិវឌ្ឍនាពេលបច្ចុប្បន្ននឹងក្លាយទៅជាបញ្ហានាពេលខាងមុខទៅវិញ ដែលវានឹងទាមទារឱ្យមានការស្វែងរកដំណោះស្រាយជាបន្តបន្ទាប់មិនចេះចប់ មិនចេះហើយ។

ហេតុដូច្នេះហើយ រាជរដ្ឋាភិបាល ក៏ដូចជាស្ថាប័នអន្តរជាតិនានា បានព្យាយាមយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការអភិវឌ្ឍនូវទីក្រុងមួយដែលអាចបំពេញនូវតម្រូវការរបស់មនុស្សឱ្យបានពេញលេញ ស្របនឹងការធ្វើឱ្យមាននូវតុល្យភាពរវាងតម្រូវការនាពេលបច្ចុប្បន្ន និងតម្រូវការនាពេលអនាគត ដែលនេះហៅថាការអភិវឌ្ឍទីក្រុងប្រកបដោយនិរន្តរភាព។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ការស្រាវជ្រាវនៃប្រធានបទខាងលើនេះ ត្រូវបានធ្វើឡើងដោយឆ្លើយតបទៅនឹងសំណួរដូចខាងក្រោម៖

១. តើមូលហេតុចម្បងអ្វីខ្លះដែលនាំឱ្យមានការរៀបចំទីក្រុង?

២. តើស្ថានភាពនៃការរៀបចំទីក្រុងភ្នំពេញបច្ចុប្បន្នមានលក្ខណៈយ៉ាងដូចម្តេច?

៣. តើរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវវិធានការយ៉ាងណាខ្លះ ដើម្បីរៀបចំរាជធានីភ្នំពេញឱ្យមានសណ្តាប់ធ្នាប់ និងសោភណភាពល្អប្រសើរ?

៤. តើអ្វីទៅជាការអភិវឌ្ឍទីក្រុងប្រកបដោយនិរន្តរភាព? ហើយការអភិវឌ្ឍនេះមានសារៈសំខាន់យ៉ាងណាខ្លះ?

៥. តើរាជរដ្ឋាភិបាលបានបោះជំហានយ៉ាងដូចម្តេចខ្លះ ដើម្បីឱ្យរាជធានីភ្នំពេញសម្រេចបានការអភិវឌ្ឍមួយប្រកបដោយនិរន្តរភាព? តើផែនការទាំងអស់នោះបានជួបប្រទះនូវឧបសគ្គអ្វីខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវនេះ គឺយើងខ្ញុំមានបំណងឱ្យមិត្តនិស្សិត មិត្តអ្នកអាន អ្នកសិក្សាស្រាវជ្រាវ និងសាធារណជនទាំងអស់ ជាពិសេសគឺប្រជាជនដែលរស់នៅក្នុងទីក្រុង បានយល់ដឹងពីការអភិវឌ្ឍ និងរៀបចំទីក្រុងដែលពួកយើងកំពុងរស់នៅ យល់ដឹងពីសារៈសំខាន់នៃការរៀបចំផែនការក្នុងការអភិវឌ្ឍទីក្រុង ឆ្លុះបញ្ចាំងឱ្យឃើញពីបញ្ហាដែលទីក្រុងរបស់យើងកំពុងតែជួបប្រទះ ដើម្បីចូលរួមចំណែកក្នុងការដោះស្រាយបញ្ហា ស្វែងរកដំណោះស្រាយជាមួយរាជរដ្ឋាភិបាល និងចូលរួមចំណែកអភិវឌ្ឍរាជធានីដែលពួកយើងកំពុងរស់នៅ ឱ្យក្លាយជាទីក្រុងមួយដែលមានភាពស្រស់បំព្រងក្នុងរយៈកាលជាយូរអង្វែង។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវចំពោះប្រធានបទស្តីពី **«ការអភិវឌ្ឍរាជធានីភ្នំពេញប្រកបដោយសណ្តាប់ធ្នាប់ និងនិរន្តរភាព»** មួយនេះ មានទំហំ និងដែនកំណត់នៃការសិក្សាទៅលើទិដ្ឋភាពទូទៅជារួមនៃការរៀបចំរាជធានីភ្នំពេញជាក់ស្តែង ផែនការមេក្នុងការអភិវឌ្ឍរាជធានីភ្នំពេញនាឆ្នាំ២០៣៥ លិខិតបទដ្ឋានគតិយុត្តជាតិដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន គួបផ្សំនឹងបញ្ហាប្រឈមដែលកំពុងកើតមាននៅរាជធានីភ្នំពេញ ព្រមទាំង របាយការណ៍ និងរបៀបវារៈនានារបស់អង្គការអន្តរជាតិដែលកម្ពុជាបានចូលរួមជាសមាជិក។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវចងក្រងប្រធានបទមួយនេះ ពិតជាបានចូលរួមចំណែកមួយយ៉ាងសំខាន់ក្នុងការផ្តល់នូវពុទ្ធិដល់យើងខ្ញុំទាំងពីរនាក់ដែលជាអ្នកស្រាវជ្រាវរៀបចំ ក៏ដូចជាមិត្តនិស្សិត មិត្តអ្នកអាន អ្នកសិក្សាស្រាវជ្រាវ និងសាធារណជនទាំងអស់ឱ្យបានយល់ដឹងកាន់តែស៊ីជម្រៅអំពីការរៀបចំរាជធានីភ្នំពេញ ជាពិសេសគឺផែនការយុទ្ធសាស្ត្រ និងដំណើរការក្នុងការអភិវឌ្ឍរាជធានីឱ្យមានសណ្តាប់ធ្នាប់របៀបរៀបរយ មានសោភណភាពល្អពិសេសគឺ រក្សាបាននូវនិរន្តរភាពទន្ទឹមនឹងការអភិវឌ្ឍដើម្បីបំពេញតម្រូវរបស់មនុស្សដែលរស់នៅក្នុងទីក្រុងនោះ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

សមិទ្ធផលនៃសារណាមួយនេះ ត្រូវបានចងក្រងឡើងតាមរយៈការសិក្សាស្រាវជ្រាវលើបណ្តាឯកសារពាក់ព័ន្ធទាំងឡាយរួមមាន លិខិតបទដ្ឋានគតិយុត្តជាតិ របាយការណ៍ និងទិន្នន័យនានា ទាំងជាតិ និងអន្តរជាតិ ដែលទាក់ទងនឹងការរៀបចំទីក្រុង ព្រមទាំងរបាយការណ៍ពីការសិក្សាស្រាវជ្រាវចូលរួមដោយក្រសួងពាក់ព័ន្ធ

សហការជាមួយបណ្ដាស្ថាប័ន វិទ្យាស្ថាន និងអង្គការនានានៅក្នុងតំបន់ ដែលឯកសារទាំងនោះទទួលបានពីប្រភពគេហទំព័រផ្លូវការរបស់អង្គការសហប្រជាជាតិ និងក្រសួងស្ថាប័ននានា។ ក្រៅពីនេះ សារណាមួយនេះ ក៏មានប្រភពនៃការស្រាវជ្រាវពីឯកសារ និងស្នាដៃសៀវភៅរបស់លោក-លោកស្រីសាស្ត្រាចារ្យបណ្ឌិតនៃជំនាញពាក់ព័ន្ធផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ចំពោះរចនាសម្ព័ន្ធនៃការស្រាវជ្រាវ យើងខ្ញុំបានរៀបចំសារណានេះដោយចែកចេញជា ២ ជំពូក ដែលជំពូកនីមួយៗមានអត្ថន័យដូចខាងក្រោម៖

- **ជំពូកទី១ ការរៀបចំទីក្រុងឱ្យមានសណ្ដាប់ធ្នាប់ ៖** ក្នុងជំពូកនេះ យើងនិយាយអំពីសញ្ញាណទូទៅនៃការរៀបចំក្រុង ការរៀបចំរាជធានីភ្នំពេញឱ្យមានសណ្ដាប់ធ្នាប់ និងសោភណភាព ដែលក្នុងនោះរួមមានការវិវត្តនៃរាជធានីភ្នំពេញ ស្ថានភាពនៃការរៀបចំទីក្រុង និងបញ្ហាប្រឈមនាពេលបច្ចុប្បន្ន ព្រមទាំងផែនការយុទ្ធសាស្ត្រ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការប្រើប្រាស់ដីធ្លី និងសំណង់។
- **ជំពូកទី២ ការអភិវឌ្ឍរាជធានីភ្នំពេញប្រកបដោយនិរន្តរភាព ៖** នៅជំពូកនេះ យើងបរិយាយអំពីរបៀបវារៈទីក្រុងថ្មីដែលជារបៀបវារៈដ៏សំខាន់មួយ ដើម្បីសម្រេចគោលដៅអភិវឌ្ឍទីក្រុង និងសហគមន៍ប្រកបដោយនិរន្តរភាពដែលដាក់ចេញដោយអង្គការសហប្រជាជាតិ រួមទាំងចក្ខុវិស័យផែនការ ការរៀបចំស្ថាប័ន និងឧបសគ្គនានាក្នុងការអភិវឌ្ឍរាជធានីភ្នំពេញប្រកបដោយនិរន្តរភាព។

# ជំពូកទី១
# ការរៀបចំទីក្រុងឱ្យមានសណ្ដាប់ធ្នាប់

# ជំពូកទី១
# ការរៀបចំទីក្រុងឱ្យមានសណ្តាប់ធ្នាប់

## ១.១. សញ្ញាណទូទៅនៃការរៀបចំក្រុង

របត់នៃការរៀបចំទីក្រុង តែងតែមាននូវការវិវត្តខុសៗគ្នាពីមួយសម័យកាលទៅមួយសម័យកាល ដោយហេតុថាតម្រូវការសង្គមតែងតែមានការវិវត្តជានិច្ច។ កាលពីដើមឡើយ ការរៀបចំទីក្រុងគឺធ្វើឡើងដើម្បីបំពេញនូវតម្រូវការចាំបាច់ចំពោះមុខតែប៉ុណ្ណោះ។ ក៏ប៉ុន្តែនៅពេលដែលតម្រូវការទាំងនោះត្រូវបានបំពេញ មនុស្សក៏ចាប់ផ្តើមមានតម្រូវការបន្ថែមទៀតទាក់ទងទៅនឹងផ្នែកសន្តិសុខ សណ្តាប់ធ្នាប់ និងផាសុកភាព ដែលទាមទារឱ្យការរៀបចំទីក្រុងត្រូវយកចិត្តទុកដាក់ទៅលើបញ្ហាសណ្តាប់ធ្នាប់ និងសោភណភាពបន្ថែមមួយកម្រិតទៀត។ ហេតុនេះ មុននឹងឈានទៅដល់ការសិក្សាពីការរៀបចំរាជធានីភ្នំពេញឱ្យមានសណ្តាប់ធ្នាប់ យើងគួរគប្បីស្វែងយល់ពីសញ្ញាណទូទៅនៃការរៀបចំក្រុង និងស្ថានភាពទូទៅនៃរាជធានីភ្នំពេញជាមុនសិន។ នៅត្រង់ចំណុចនេះដែរ យើងនឹងលើកយកមកសិក្សាពីទ្រឹស្តីដែលរួមមាន និយមន័យទាក់ទងទៅនឹងការរៀបចំទីក្រុង ព្រមទាំងនិយមន័យដែលពាក់ព័ន្ធទៅនឹងប្រធានបទនៃនិរន្តរភាព។ បន្ទាប់មក យើងនឹងធ្វើការសិក្សាទៅលើប្រវត្តិនៃការរៀបចំទីក្រុងនៅក្នុងប្រទេសកម្ពុជាដែលយើងនឹងធ្វើការស្រាវជ្រាវទៅលើការរៀបចំទីក្រុងនាសម័យអង្គរ មូលហេតុដែលបណ្តាលឱ្យមានការរៀបចំក្រុង ហើយជាចុងក្រោយ យើងនឹងឆ្លុះបង្ហាញពីការវិវត្តនៃរាជធានីភ្នំពេញជាពិសេសទៅលើនគរូបនីយកម្មទីក្រុង និងស្ថានភាពនៃការរៀបចំក្រុងភ្នំពេញនាពេលបច្ចុប្បន្ននេះ។

### ១.១.១. និយមន័យ

#### ១.១.១.១. និយមន័យទីក្រុង

**"ទីក្រុង"** សំដៅដល់រាជធានី ក្រុង និងទីប្រជុំជន។ ទីក្រុងត្រូវបានធ្វើចំណាត់ថ្នាក់ជាទីក្រុងប្រភេទធំ ប្រភេទមធ្យម និងប្រភេទតូច ស្របតាមលក្ខខណ្ឌនៃចំនួនប្រជាជន ដង់ស៊ីតេប្រជាជន សមាមាត្រអ្នកធ្វើការមិនមែនជាកសិករ មុខងារទីក្រុង និងរចនាសម្ព័ន្ធរូបវន្តទីក្រុង។ល។[1] ម្យ៉ាង **"ក្រុង"** សំដៅលើ នគរ រាជធានី បុរី។[2]

**"នគរូបនីយកម្ម"** សំដៅដល់សិល្បៈ វិទ្យាសាស្រ្ត និងបច្ចេកទេសនៃការធ្វើផែនការរូបវន្តទីក្រុង ការអភិវឌ្ឍ ការអភិរក្ស ការគ្រប់គ្រងការអភិវឌ្ឍ ការសាងសង់ និងការកែលម្អនៅក្នុងទីក្រុង និងតំបន់ជុំវិញ ព្រមទាំងតំបន់ទទួលឥទ្ធិពល ក្នុងគោលបំណងទទួលបាននូវចីរភាព តុល្យភាព សុខុមាលភាព សោភណភាព សមធម៌ និងសមាហរណកម្ម។[3]

[1] សទ្ធានុក្រម នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពី នគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

[2] វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត

[3] សទ្ធានុក្រម នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពី នគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

**"ប្លង់គោលប្រើប្រាស់ដី ឬប្លង់គោល"** សំដៅដល់ផែនការដែលកំណត់អំពីចក្ខុវិស័យ និងយុទ្ធសាស្ត្រសរុបសម្រាប់ការអភិវឌ្ឍរូបវន្ត និងកំណត់ពីប្រភេទនៃការប្រើប្រាស់ដី ព្រមទាំងបង្ហាញពីទម្រង់ទីក្រុង បណ្តាញហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងគមនាគមន៍សំខាន់ៗនៃទីក្រុង ព្រមទាំងការធ្វើសមាហរណកម្ម។ ប្លង់គោលប្រើប្រាស់ដីត្រូវភ្ជាប់មកជាមួយនូវផែនការសកម្មភាពសម្រាប់អភិវឌ្ឍ និងអភិរក្សទីក្រុងទៅតាមលំដាប់អាទិភាពសម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង។ ប្លង់គោលប្រើប្រាស់ដី គឺជាប្លង់ដែលត្រូវបានសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយស្ថាប័នមានសមត្ថកិច្ច។[4]

**"ផែនការរូបវន្តទីក្រុង"** ជាការធ្វើសមាហរណកម្មផែនការប្រើប្រាស់ដី និងផែនការហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដើម្បីធានាការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ក្នុងទីក្រុងឱ្យមានចីរភាព តុល្យភាព សុខុមាលភាព សោភណភាព និងសមធម៌។ ផែនការរូបវន្តទីក្រុង មានប្លង់គោលប្រើប្រាស់ដី ឬប្លង់គោល ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្ម។[5]

ដោយឡែក ចំពោះនិយមន័យនៃ **"ការរៀបចំក្រុងឱ្យមានសណ្តាប់ធ្នាប់ និងសោភណភាព"** សំដៅទៅដល់ការរៀបចំរាជធានី ឬបុរីមួយដែលមិនមាននូវសកម្មភាពកសិកម្មឱ្យមានភាពល្អប្រសើរ មានសន្តិសុខ មានភាពស្ងប់ស្ងៀម និងមានអនាម័យ។[6]

### ១.១.១.២. និយមន័យនិរន្តរភាព

ដើម្បីស្វែងយល់អំពីប្រធានបទរបស់យើងឱ្យបានស៊ីជម្រៅ ជាដំបូងយើងត្រូវយល់ពីនិយមន័យនៃពាក្យ **"និរន្តរភាព"** ជាមុនសិន។ បើផ្អែកតាមវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត ពាក្យ **"និរន្តរភាព"** សំដៅលើភាពឥតចន្លោះ ភាពឥតស្រាក ភាពដែលមានជានិច្ច សេចក្តីដែលកើតមាន ឬភាពឥតឈប់ឈរ។ ម៉្យាងវិញទៀត យើងក៏អាចថាអត្ថន័យនៃពាក្យនេះអាចកំណត់ថាជា ការធានាឱ្យបាននូវភាពចម្រុះ និងផលិតភាពជាបន្តបន្ទាប់ និងការរក្សាសមត្ថភាពឱ្យស្ថិតស្ថេរ។[7] មិនតែប៉ុណ្ណោះ នៅក្នុងឆ្នាំ១៩៨៧ គណៈកម្មាធិការប្រ៊ុនទែនរបស់អង្គការសហប្រជាជាតិ បានកំណត់និយមន័យនៃពាក្យនិរន្តរភាព ថាជាការអភិវឌ្ឍដោយមានការធានានូវតម្រូវការប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋបច្ចុប្បន្ន ដោយមិនបង្កភាពអន្តរាយដល់សមត្ថភាពរបស់ប្រជាពលរដ្ឋនៅថ្ងៃអនាគតក្នុងការ

---

[4] សទ្ទានុក្រម នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពី នគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

[5] សទ្ទានុក្រម នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពី នគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

[6] សៀវភៅ នីតិនគរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២០ ទំព័រទី ១

[7] ដកស្រង់ពីគេហទំព័រ https://www.ekoloji.com/km/ekoloji/surdurulebilirlik-nedir/ ចូលមើលថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១

ឆ្លើយតបនឹងតម្រូវការរបស់ពួកគេ។[8] ជាចុងក្រោយ យើងក៏ត្រូវយល់ដែរថា និរន្តរភាព មានសសរគ្រឹះចំនួន ៣ គឺ បរិស្ថាន សង្គម និងសេដ្ឋកិច្ច។[9]

#### ១.១.១.៣. អ្វីទៅជារបៀបវារៈទីក្រុងថ្មី

ដើម្បីយល់ថាអ្វីជារបៀបវារៈទីក្រុងថ្មី ជាដំបូង យើងត្រូវតែយល់ពីគំនិតគោលរបស់របៀបវារៈនេះសិនពោលគឺត្រូវយល់ដឹងអំពីគោលដៅអភិវឌ្ឍន៍ទី១១ ដែលចែងថានឹងបង្កើតឱ្យមាននូវ "**ទីក្រុង និងសហគមន៍ដែលប្រកបដោយនិរន្តរភាព**" ដែលមានគោលបំណង "**ធ្វើឱ្យទីក្រុងនានាមានភាពរួមបញ្ចូល មានសុវត្ថិភាព ធន់រឹងមាំ និងមាននិរន្តរភាព**"។[10]

ឆ្ពោះទៅកាន់គោលបំណងនេះ របៀបវារៈទីក្រុងថ្មីត្រូវបានបង្កើតឡើងនៅក្នុងសន្និសីទឈ្មោះ Habitat III ដែលបានធ្វើឡើងនៅទីក្រុងគីតូ ប្រទេសអេក្វាឌ័រ នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦។ របៀបវារៈនេះបានបញ្ជាក់នូវទំនាក់ទំនងរវាងនិរន្តរភាព ការបង្កើតការងារ ការចិញ្ចឹមជីវិត ជីវិតដែលមានគុណភាពល្អ ជាមួយនឹងការអភិវឌ្ឍទីក្រុង គោលនយោបាយ និងយុទ្ធសាស្ត្រផ្សេងៗដែលឆ្ពោះទៅរកនិរន្តរភាព។ របៀបវារៈនេះត្រូវបានបង្កើតឡើងដោយមានការចូលរួមពីរដ្ឋសមាជិក អង្គការអន្តររដ្ឋាភិបាល ទីភ្នាក់ងារអង្គការសហប្រជាជាតិមួយចំនួន អ្នកជំនាញការគោលនយោបាយថ្នាក់ជាតិ និងថ្នាក់ស្រុក ហើយនឹងជាមួយភ្នាក់ងាររដ្ឋាភិបាលក្នុងស្រុក និងក្នុងតំបន់ អង្គការក្រៅរដ្ឋាភិបាល និងអង្គការឯកជន។

របៀបវារៈទីក្រុងថ្មីនេះកំណត់នូវស្តង់ដារ និងគោលការណ៍សម្រាប់ការរៀបចំផែនការ សំណង់ ការអភិវឌ្ឍ ការគ្រប់គ្រង និងការកែលម្អតំបន់ទីប្រជុំជន។ ស្តង់ដារ និងគោលការណ៍ទាំងនេះត្រូវបានភ្ជាប់ជាមួយនឹងសសរអនុវត្តសំខាន់ៗចំនួន ៥ គឺ៖ គោលនយោបាយជាតិ, បទប្បញ្ញត្តិសម្រាប់ទីក្រុង និងទីប្រជុំជន, ផែនការ និងការរចនាទីក្រុង, សេដ្ឋកិច្ចក្នុងស្រុក និងហិរញ្ញវត្ថុក្រុង, និងការអនុវត្តនៅថ្នាក់មូលដ្ឋាន។[11]

### ១.១.២. ប្រវត្តិនៃការរៀបចំទីក្រុងនៅប្រទេសកម្ពុជា

នៅត្រង់ចំណុចនេះ យើងនឹងលើកយកពីអច្ឆរិយភាពនៃការរៀបចំទីក្រុងអង្គរ ជាទីក្រុងមួយដែលមានការរៀបចំប្រកបដោយលក្ខណៈបច្ចេកទេស និងវិទ្យាសាស្ត្រ ដែលពិភពលោក ទាំងអ្នកបុរាណវិទូ និងអ្នកតារាវិទូកំពុងតែមានភាពស្ញប់ស្ញែងចំពោះស្ថាបត្យកម្ម និងនគរូបនីយកម្មនាសម័យនោះ។ តាមរយៈសំណង់ស្ថាបត្យកម្មដែលបានបន្សល់ទុក និងស្លាកស្នាមដែលនៅសេសសល់សព្វថ្ងៃ បុរាណវិទូបានធ្វើការសិក្សាស្រាវជ្រាវឃើញថា

---

[8] ដកស្រង់ពីគេហទំព័រអង្គការសហប្រជាជាតិ https://bit.ly/sustainability_united-nation ចូលមើលថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១

[9] ដកស្រង់ពីគេហទំព័រ https://www.un.org/ecosoc/en/sustainable-development ចូលមើលថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១

[10] ដកស្រង់ពីគេហទំព័រ https://sdgs.un.org/goals/goal11 ចូលមើលថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១

[11] សៀវភៅ New Urban Agenda Illustrated , អង្គការ UN-Habitat បោះពុម្ពឆ្នាំ២០២០

ប្រមាណជា ៣សតវត្សរ៍ ក្រោយរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ អ្នកដំណើរជនជាតិចិនម្នាក់ ឈ្មោះ **ជីវតាក្វាន់ (ជូតាក្វាន់)** បានសរសេរថា "**លោកឮគេថា ក្រុងអង្គរពីដើមជាក្រុងដ៏ល្អមួយ ហើយស្អាតបំផុតនៅលើលោក**"។[12]

### ១.១.២.១. ភាពវិវត្តន៍នៃទីក្រុងអង្គរ

បើនិយាយពីទីក្រុងនាសម័យនោះ គឺមានលក្ខណៈខុសពីការរៀបចំទីក្រុងនាពេលបច្ចុប្បន្ន។ បុព្វបុរសខ្មែរបានរៀបចំបុរី ដោយផ្តោតទៅលើនយោបាយកសិកម្ម ផ្អែកលើរបៀបចាត់ចែងប្រព័ន្ធទឹកជាមូលដ្ឋាន ដោយហេតុថាទីក្រុងអង្គរ ក៏ដូចជាអាណាចក្រខ្មែរទាំងមូលពឹងផ្អែកទៅលើវិស័យកសិកម្មដែលជាសរសៃឈាមពុំអាចខ្វះបាន។ ការរៀបចំប្រទេសដែលកើតឡើងនៅក្នុងសម័យព្រះបាទឥន្ទ្រវរ្ម័នទី១ នៅរាជធានីហរិហរាល័យ អាស្រ័យដោយស្ថានភាព អំណាច ស្ថិរភាព ប្រទេសមានកម្លាំងគ្រប់គ្រាន់ រួមផ្សំនឹងលក្ខណៈដ៏មុតមាំរបស់ជំនឿសាសនា។ នយោបាយទឹកនៅជំនាន់ព្រះបាទឥន្ទ្រវរ្ម័នទី១ មានលក្ខណៈផុសផុលខ្លាំងក្លា មានព្រែកជីកខ្វាត់ខ្វែងជាប្រព័ន្ធ និងមានបារាយណ៍ឥន្ទ្រតដាក ព្រមទាំងគូទឹកផ្សេងៗជាគោល។ ទឹកទាំងនោះគឺសម្រាប់បម្រើឱ្យវិស័យកសិកម្មពាសពេញនគរបានពេញមួយឆ្នាំ ជាពិសេសគឺនៅរដូវប្រាំង ដែលកត្តាទាំងអស់នេះហើយទើបបណ្តាលឱ្យសេដ្ឋកិច្ចប្រទេសមានការរីកចម្រើន ដោយសារការយកចិត្តទុកដាក់លើនយោបាយទឹកក្នុងការរៀបចំនគរនាពេលនោះ។

ក្រោយមក ព្រះបាទយសោវរ្ម័នទី១ ជាបុត្ររបស់ព្រះបាទឥន្ទ្រវរ្ម័នទី១ បានឡើងគ្រងរាជ្យបន្ត និងក្លាយជាស្ថាបនិកដំបូងគេក្នុងប្រវត្តិសាស្ត្រខ្មែរដែលបានកសាងទីក្រុងថ្មី គឺទីក្រុងអង្គរ ឬក្រុងយសោធរបុរៈ (ឆ្នាំ៨៨៩ ដល់ឆ្នាំ៩៩០)។[13] ព្រះរាជាមានគោលបំណងក្នុងការរៀបចំរាជធានីឱ្យទៅជាទីក្រុងមួយដ៏អស្ចារ្យ និងអច្ឆរិយៈពោលគឺ ជាទីក្រុងមួយដែលមានប្លង់ម៉ត់ចត់ ហើយមានន័យទូលំទូលាយស្របទៅតាមលក្ខណៈលោកធាតុនៃព្រហ្មញ្ញសាសនា។ ព្រះរាជាបន្តមកទៀត បានរៀបចំក្រុងយសោធរបុរៈឱ្យកាន់តែមានភាពប្រសើរឡើង តួយ៉ាង ព្រះបាទរាជេន្ទ្រវរ្ម័ន បានវិលត្រឡប់មកពីកោះកេរ្តិ៍ ដោយមកតាំងរាជធានីនៅយសោធរបុរៈ ដែលមានសិលាចារិកមួយបានចែងថា ព្រះអង្គបានរៀបចំទីក្រុងនេះឱ្យកាន់តែទំនើប និងឱ្យកាន់តែប្រសើរឡើង ដោយទ្រង់បានសាងសង់ប្រាសាទមាសមួយដ៏ភ្លឺចិញ្ចាចបីដូចជាប្រាសាទរបស់ព្រះមហិន្ទ្រៈនៅលើផែនដី។[14]

នៅក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី១ បរិក្ខារក្រុង (អង្គរទី១) ត្រូវរងការខូចខាតអស់ជាច្រើន ដោយសារសង្គ្រាមស៊ីវិល ម្ល៉ោះហើយព្រះអង្គបានបញ្ជាឱ្យគេរៀបចំស្ថាបនាជួសជុល ប៉ុន្តែលុះក្រោយបន្តិចមកព្រះអង្គក៏មានព្រះតម្រិះក្នុងការបង្កើតក្រុងថ្មីមួយទៀត ដើម្បីសម្រួលដល់ដំណើរជីវភាពរបស់ប្រជារាស្ត្រផង និងដើម្បីលើកកិត្តិយសព្រះរាជសន្តិវង្សរបស់ព្រះអង្គផង។ ហេតុនេះព្រះអង្គបានចាត់ឱ្យអ្នករៀបចំក្រុង រៀបប្លង់អង្គរទី២ ដែលគម្រោងប្លង់

---

[12] សៀវភៅ ប្រវត្តិនគរូបនីយកម្មនៅកម្ពុជា , បណ្ឌិត អ៊ូ វិឌី បោះពុម្ពឆ្នាំ២០១២ ទំព័រទី ១០

[13] ជនជាតិខ្មែរ ភាគទី ១ ស.វ.ទី១ - ស.វ.ទី១៥ , Paul Bruno និងលោក ស៊ុនហេង ម៉េងឈាង

[14] សៀវភៅ ប្រវត្តិនគរូបនីយកម្មនៅកម្ពុជា , បណ្ឌិត អ៊ូ វិឌី បោះពុម្ពឆ្នាំ២០១២ ទំព័រទី ១១

នេះ ត្រូវបានសម្រេចដោយស្នាព្រះហស្ថរបស់ក្សត្រព្រះនាមឧទ័យទិត្យវរ្ម័នទី២ ព្រះរាជាទាំងពីរអង្គនេះបាន ចាត់ចែងឱ្យគេស្ថាបនាបារាយណ៍មួយនៅខាងលិចទីក្រុងថ្មី គឺបារាយណ៍ខាងលិចដែលមានទំហំ ៨ ០០០ម៉ែត្រ គុណនឹង ២២០ម៉ែត្រ សម្រាប់យកទឹកប្រើប្រាស់ និងផ្គត់ផ្គង់កសិកម្ម ក្នុងបំណងចិញ្ចឹមប្រជាជន ដែលរស់នៅក្នុងទីក្រុងថ្មីរបស់ព្រះអង្គនាបច្ចុប្បន្ន និងទៅអនាគត។

មកដល់រាជ្យព្រះបាទសូរ្យវរ្ម័នទី២ បានបន្តការរៀបចំក្រុងអង្គរនេះ តទៅទៀត ដោយទ្រង់បានកសាងប្រាសាទមួយដ៏ធំអស្ចារ្យ គឺប្រាសាទអង្គរវត្ត ដែលនាំឱ្យទីក្រុងថ្មីនេះ មានសម្រស់កាន់តែឆើតឆាយថែមទៀត។ លុះដល់រាជ្យព្រះបាទជ័យវរ្ម័នទី៧ ព្រះអង្គបានស្ថាបនា និងរៀបចំក្រុងអង្គរទី៣ សព្វថ្ងៃយើងហៅថា អង្គរធំ។ ទីក្រុងថ្មី មួយនេះ សាងសង់នៅលើទីទួល ជាទីកន្លែងរបស់ទីក្រុងអង្គរចាស់ (អង្គរទី២) ដែលត្រូវបានទទួលរងនូវការវិនាសអន្តរាយ ដោយកងទ័ពចាមចូលវាយលុកលុយ បំផ្លិចបំផ្លាញនៅឆ្នាំ១១៧៧។

ដូចនេះ យើងសង្កេតឃើញថា ទីក្រុងអង្គរគឺជាទីក្រុងមួយ ដែលស្ថាបនាឡើងដោយឈរលើទស្សនៈបែបព្រាហ្មណ៍និយមផង និងបែបព្រះពុទ្ធសាសនាមហាយានផង។ តាមរយៈសំណង់ស្ថាបត្យកម្មដែលបានបន្សល់ទុកបានបង្ហាញឱ្យមនុស្សខ្មែរ ក៏ដូចជាមនុស្សជាតិលើពិភពលោកវាយតម្លៃបានថា ព្រះរាជានៃអាណាចក្រខ្មែរច្រើនតែជាក្សត្រដែលមានទេពកោសល្យខាងនគរូបនីយកម្ម ហើយព្រះរាជាដែលមានស្នាដៃអស្ចារ្យជាងគេលើវិស័យនេះ គឺព្រះបាទជ័យវរ្ម័នទី៧។[15]

### ១.១.២.២. ការរៀបចំទីក្រុងខ្មែរនៅសម័យអង្គរ និងទំនាក់ទំនងជាមួយនឹងទស្សនៈព្រាហ្មណ៍សាសនា និងព្រះពុទ្ធសាសនា

តាមធម្មតាប្លង់ទីក្រុងបែកចេញពីប្លង់ប្រាសាទដែលស្ថិតនៅចំកណ្តាល ហើយប្រាសាទទាំងនេះត្រូវបានហ៊ុមព័ទ្ធដោយកំពែងមួយជាន់ ឬពីរជាន់ ឯនៅខាងក្រៅកំពែង មានគូទឹកហ៊ុមព័ទ្ធមួយជាន់ថែមទៀត។ ប្រាសាទកណ្តាលតំណាងឱ្យភ្នំព្រះសុមេរុ មានន័យថា នៅសម័យកាលនោះ អ្នករៀបចំស្ថាបនាទីក្រុងបានឈរលើស្មារតីដោយយកទីក្រុងជាតំណាងឱ្យពិភពលោកទាំងមូល ដែលមានកំពែងធ្វើអំពីថ្មបាយក្រៀម និងមានខ្លោងទ្វាររៀបលាយជាមួយថ្មភក់ ឬជាការប្រមើលគន់គួរគិត និងសន្និដ្ឋានថា ជាជួរភ្នំចក្រវាឡដែលព័ទ្ធជុំវិញពិភពលោក ចំណែកឯគូទឹកតំណាងឱ្យមហាសាគរ។ ភាគច្រើន ប្លង់ទីក្រុងទាំងនោះ តែងរៀបចំឡើងដោយមានគំនិតទាក់ទងទៅនឹងតារាវិទ្យា។ ជាទូទៅ កំពែងមានរាងបួនជ្រុងស្មើ ដោយមានកំពែងក្នុង និងកំពែងក្រៅ។ កំពែងក្នុងហៅថា "**កំពែងប្រាសាទ**" ឯកំពែងក្រៅហៅថា "**កំពែងវិស័យ**" ។ នៅចន្លោះកំពែងទាំងពីរ គឺជាទីប្រជុំជន ដែលទីប្រជុំជនភូមិ មានផ្ទះរបស់បណ្តារាស្ត្រប្រក់ស្លឹក ឬស្បូវ រួមមានវាលស្រែ និងចម្ការ ព្រមទាំងផ្លូវទឹកតូចធំ។ នៅចំកណ្តាលនៃជ្រុងកំពែងនីមួយៗ មានផ្លូវក្រាលថ្មពុះជ្រុងទាំងឡាយ ទៅប្រសព្វមុខគ្នានៅទីប្រាសាទភ្នំបាន

[15] សៀវភៅ ប្រវត្តិនគរូបនីយកម្មនៅកម្ពុជា , បណ្ឌិត អ៊ូ វ៉ឌី បោះពុម្ពឆ្នាំ២០១២ ទំព័រទី ១២

សេចក្តីថា មានបែងចែកផ្ទៃក្រឡាដីនៅក្នុងបរិវេណប្រាសាទជាបួនភាគស្មើគ្នា។ ជាទូទៅ ទៅមិនឆ្ងាយប៉ុន្មានពីប្រាសាទ ឬទីក្រុងមានការជីកបារាយណ៍ ជីកត្រពាំងតូច ឬត្រពាំងធំ សម្រាប់ផ្តល់ទឹកទៅឱ្យគូទឹកដែលស្ថិតនៅជុំវិញប្រាសាទ ឬផ្តល់ទឹកឱ្យទៅទីក្រុងទាំងនោះ និងឱ្យទៅប្រាសាទដទៃទៀត ដែលស្ថិតនៅក្នុងបរិវេណទីក្រុងដូចជាអង្គរធំ។ ការរៀបចំក្រុងធ្វើតាមរបៀបនេះ គឺដើម្បីឱ្យប្រជាពលរដ្ឋគ្រប់ៗគ្នា មានទឹកប្រើប្រាស់គ្រប់គ្រាន់សម្រាប់ធ្វើកសិកម្មផង និងមានទឹកសម្រាប់ប្រើប្រាស់ជាប្រយោជន៍សាធារណៈផង។ ចំណុចមួយដែលយើងគួរឱ្យកត់សម្គាល់ដែរនោះគឺ ការរៀបចំកំពែង និងគូទឹកព័ទ្ធជុំវិញទីក្រុងនេះ ក្រៅពីទំនាក់ទំនងជាមួយនឹងសាសនា និងបម្រើឱ្យតម្រូវការរបស់ប្រជារាស្ត្រ វាក៏មានតួនាទីក្នុងការការពារទីក្រុងពីការឈ្លានពានវាយលុកពីសត្រូវខាងក្រៅផងដែរ។

ដោយសារស្ថានភាពដីនៅក្រុងអង្គរ ទេរបន្តិចចុះពីជើងឆ្ពោះមកត្បូង អ្នករៀបចំក្រុងសម័យអង្គរបានរកឃើញមធ្យោបាយដើម្បីបង្ហូរទឹកកខ្វក់ ឬទឹកសម្អុយ ចេញពីបរិវេណក្រុងតាមប្រឡាយជាច្រើន មកចាក់ចោលក្នុងត្រពាំងមួយហៅថា "បឹងធំ" ស្ថិតនៅជាប់កំពែងខាងត្បូងឆៀងខាងលិច។

ក្រុងអង្គរបានធ្វើឱ្យឈ្មួញបរទេសជំនាន់ លោក ជីវ តាក្វាន់ និងបេសកសង្ឃព័រទុយហ្គាល់ អេស្ប៉ាញជាច្រើននៅជំនាន់ក្រោយៗមកទៀត លាន់មាត់ស្ងើចសរសើរមិនមានដាច់។ ម៉្យាងទៀត អ្នកប្រាជ្ញសម័យបច្ចុប្បន្នជាច្រើន ដូចជាលោក ព្យែរគ្មូ (Pierre Gourou) ជនជាតិបារាំង បានកោតសរសើរពីទេពកោសល្យដ៏អស្ចារ្យនៃក្រុងអង្គរ ដែលចេះផ្សំជំនឿផ្នែកសាសនា ជាមួយទ្រឹស្តីនយោបាយ ជាមួយកសិកម្ម ឱ្យកើតចេញជារបៀបរៀបចំទឹកដីដ៏ប៉ិនប្រសប់ ទាំងនេះគឺជាគំនិតសំយោគមួយ ដែលពុំមានប្រជាជនណាលើលោកនេះអាចធ្វើបានដូច។[16]

### ១.១.៣. មូលហេតុនៃការរៀបចំក្រុង

ជាគោលការណ៍ ការរៀបចំទីក្រុងមួយឱ្យបានល្អប្រសើរ គឺទាមទារឱ្យមានការគិតគូរឱ្យបានសព្វជ្រុងជ្រោយពីកត្តាជាច្រើនដោយអ្នកជំនាញ ក៏ប៉ុន្តែជាញឹកញាប់ ពិសេសនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍ គេសង្កេតឃើញថាការវិវត្តទីក្រុងភាគច្រើនច្រើនកើតមានឡើងដោយឥតព្រាងទុក ពោលគឺចេះតែរីកទៅៗទៅតាមតម្រូវការដី និងបម្លាស់ទីរបស់មនុស្ស ដែលចេះតែរំកិលទៅៗ ដោយពុំមានការគិតគូរត្រឹមត្រូវ (Urban Sprawl) ហើយការអភិវឌ្ឍបែបនេះនាំឱ្យមានដង់ស៊ីតេប្រជាជនតិច ខាតនូវលទ្ធភាពនៃការប្រើប្រាស់ដី ការបំពេញមុខងារ និងតម្រូវការក្នុងទីក្រុងមិនបានត្រឹមត្រូវ ព្រមទាំងបង្កឱ្យមានបញ្ហាទីក្រុងជាច្រើនដូចជា ការកកស្ទះចរាចរណ៍ ការប៉ះពាល់ដល់បរិស្ថាន ពិសេសគឺប៉ះពាល់ដល់និរន្តរភាពទីក្រុង។

[16] សៀវភៅ ប្រវត្តិនគរូបនីយកម្មនៅកម្ពុជា , បណ្ឌិត អ៊ូ វ័ឌី បោះពុម្ពឆ្នាំ២០១២ ទំព័រទី ១៩

ដោយមូលហេតុខាងលើនេះហើយ ទើបគេអាចកំណត់ពីមូលហេតុចម្បងដែលជម្រុញឱ្យមានការរៀបចំទីក្រុងជា ៤ គឺ៖ កំណើនប្រជាជន ភាពក្រីក្រ គុណភាពនៃការរស់នៅ និងការដាក់សម្ពាធបរិស្ថាន។

**១.១.៣.១. កំណើនប្រជាជន**

ជាទូទៅសមាសភាពនៃកំណើនប្រជាជនក្នុងទីក្រុងមានចំនួន ៣ សំខាន់គឺ៖

- កំណើនប្រជាជនក្នុងក្រុងជាលក្ខណៈធម្មជាតិ
- កំណើនប្រជាជនដោយសារមានការចំណាកស្រុកពីជនបទ
- កំណើនដោយសារការបែងចែកប្រភេទសណ្ឋាននៃក្រុងថ្មី ដែលពីមុនមកតំបន់នេះជាទីជនបទ

កំណើនប្រជាជនក្នុងក្រុងជាលក្ខណៈធម្មជាតិ ជាធាតុចម្បងដែលនាំឱ្យមានការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនប្រជាជន ចំណែកឯកំណើនប្រជាជនដោយសារមានការចំណាកស្រុកពីជនបទ និងកំណើនដោយសារតែការបែងចែកប្រភេទសណ្ឋានដីនៃក្រុងថ្មីដែលពីមុនមកតំបន់នេះជាទីជនបទ គ្រាន់តែជាធាតុចូលបន្ទាប់បន្សំប៉ុណ្ណោះ។[17]

**១.១.៣.២. ភាពក្រីក្រ**

ការកំណត់អំពីស្ថានភាពក្រីក្រមានការលំបាកនៅក្នុងការកំណត់ណាស់ ប៉ុន្តែជាទូទៅ ភាពក្រីក្រសំដៅដល់ការដែលតម្រូវការរបស់មនុស្សមិនត្រូវបានបំពេញ។ ជារួម ប្រទេសភាគច្រើនបានកំណត់ពីភាពក្រីក្រតាមរយៈប្រាក់ចំណូលទាប ដែលពួកគេមិនអាចចាយវាយគ្រប់គ្រាន់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេឡើយ។ តម្រូវការប្រចាំថ្ងៃរួមមាន តម្រូវការរូបកាយ ចំណីអាហារ លំនៅឋាន ការងារធនធានទឹក អគ្គិសនី អនាម័យ សុខុមាលភាពសង្គម នៅមានការខ្វះខាត។ លើសពីនេះ សិទ្ធិសេរីភាពផ្នែកស្មារតី សិទ្ធិប្រជាពលរដ្ឋ និងសិទ្ធិនយោបាយក៏នៅមានកម្រិតដែរ។

នៅត្រង់ចំណុចនេះ ភាគច្រើនតែងទទួលបាននូវការយកចិត្តទុកដាក់ ជាពិសេសពីសំណាក់អង្គការសហប្រជាជាតិ ក៏ដូចជាអង្គការនានា ទៅលើប្រជាជនក្រីក្រនៅតាមទីក្រុង ពីព្រោះពួកគាត់គឺជាក្រុមងាយរងគ្រោះនៅក្នុងទីក្រុង ហេតុនេះរាជរដ្ឋាភិបាល និងអង្គការពាក់ព័ន្ធចាំបាច់ត្រូវរៀបចំគោលនយោបាយទីក្រុង ក៏ដូចជាការរៀបចំហេដ្ឋារចនាសម្ព័ន្ធទីក្រុងយ៉ាងណា ដើម្បីធានាឱ្យបាននូវសមភាព និងសមធម៌ក្នុងការរស់នៅសម្រាប់ពួកគាត់នៅក្នុងទីក្រុង។

**១.១.៣.៣. គុណភាពនៃការរស់នៅ**

ភាពខុសគ្នានៃស្ថានភាពជីវភាព គឺជាកត្តាចម្បងដែលត្រូវបានគិតគូរនៅពេលមានការពិភាក្សាជុំវិញការជម្រុញឱ្យមានការរៀបចំក្រុង។ កម្រិតជីវភាព និងប្រាក់បៀវត្សរ៍ខ្ពស់នៅទីក្រុងជាកត្តាទាក់ទាញមនុស្សឱ្យមករស់

[17] សៀវភៅ នីតិនគរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២០ ទំព័រទី ៥

នៅទីក្រុង។ ដរាបណាភាពខុសគ្នារវាងទីក្រុង និងជនបទមានគម្លាតខ្ពស់ ប្រជាពលរដ្ឋនៅជនបទ នៅតែចង់ចូលមករស់នៅក្នុងក្រុង។ ជាទូទៅ កត្តាសេដ្ឋកិច្ច និងអត្រានិកម្មភាពខ្ពស់ ជាកត្តាជម្រុញឱ្យមានចំណាកស្រុក ដោយសារតែពេលខ្លះការងារនៅជនបទនៅមានកម្រិត ដូច្នេះបើទោះជាទទួលបានប្រាក់ខែទាបក៏ត្រូវតែបង្ខំចិត្តចំណាកស្រុកមកកាន់ទីក្រុងដែរ។ លើសពីនេះ នៅទីក្រុងមានការប្រមូលផ្តុំដោយកត្តាសង្គម នយោបាយល្អប្រសើរខណៈពេលសេវាសុខាភិបាល ព្រមទាំងសេវាអប់រំមានភាពសម្បូរបែបដែលកាន់តែធ្វើឱ្យអ្នករស់នៅមានអារម្មណ៍ថាមានសុវត្ថិភាពជាងកន្លែងណាៗទាំងអស់។

**១.១.៣.៤. ការដាក់សម្ពាធបរិស្ថាន**

សម្ពាធមួយដ៏ធំបំផុតរបស់ប្រជាពលរដ្ឋនៅជនបទពាក់ព័ន្ធនឹងវិស័យបរិស្ថានគឺ កង្វះដីបង្កបង្កើនផលដើម្បីធ្វើកសិកម្ម។ ករណីនេះកើតមានច្រើននៅពេលដែលដីពួកគេទទួលបានពីដូនតា ឪពុកម្តាយ របស់ខ្លួនត្រូវបានពួកគេចែកឱ្យកូនៗអស់។ ចំណែកផ្ទៃដីដែលនៅសល់មានទំហំតូចមិនសមល្មមសម្រាប់ធ្វើកសិកម្ម ឬបង្កបង្កើនផលដំណាំផ្សេងៗឡើយ ហើយពេលខ្លះស្ថានភាពដីនោះមានលក្ខណៈខ្សោះ និងគ្មានជីជាតិទៀត។ ប្រសិន បើក្រឡេកទៅមួយជ្រុងទៀត ចំពោះប្រជាពលរដ្ឋក្រីក្រនៅពេលដែលគាត់មានដីគ្រប់គ្រាន់ហើយ តែគាត់បែរជាខ្វះប្រព័ន្ធធារាសាស្ត្រស្រោចស្រព និងជីកសិកម្មសម្រាប់បង្កបង្កើនផលបានគ្រប់គ្រាន់វិញ។ ករណីនេះច្រើនកើតមាននៅក្នុងប្រទេសកំពុងអភិវឌ្ឍក្នុងតំបន់មេគង្គក្រោម។[18]

**១.១.៤. ការវិវត្តនៃរាជធានីភ្នំពេញ**

**១.១.៤.១. ការតាំងរាជធានីនៅភ្នំពេញ**

តាមឯកសារជនជាតិខ្មែរភាគទី១ និពន្ធដោយលោក Paul Brunon និងលោកស៊ុនហេង ម៉េងឈាង បានឱ្យដឹងថា ព្រះបាទពញាយ៉ាតបានលើករាជធានីពីអង្គរមកតាំងនៅទួលបាសាន (ស្រីសន្ធរ ខេត្តកំពង់ចាម) បន្ទាប់មកនៅចតុមុខក្នុង ឆ្នាំ១៤៣២ ដែលក្រុងចតុមុខនេះ គឺជារាជធានីភ្នំពេញសព្វថ្ងៃនេះឯង។ គេអាចដឹងថា ក្រោយពីទីក្រុងចតុមុខបានបង្កើតឡើងហើយ តមកការតាំងរាជធានីមិនជាប់លាប់ឡើយ ហើយអ្វីដែលគួរឱ្យកត់សម្គាល់គឺ មានការកសាងរាជធានីថ្មី ដូចជាក្រុងលង្វែក (ក្នុងរជ្ជកាលអង្គច័ន្ទទី១ ឆ្នាំ១៥២៧ ដល់ឆ្នាំ១៥២៩) និងជាបន្តមកទៀត មានការលើករាជធានីទៅក្រុងឧដុង្គ នៅក្នុងរជ្ជកាលព្រះជ័យជេដ្ឋាទី២ (១៦១៨–១៦២៨)។

ព្រះបាទពញាយ៉ាតគឺជាព្រះរាជាដំបូងគេដែលបានមកតាំងរាជធានីនៅទីក្រុងភ្នំពេញនេះ ព្រះអង្គបានបញ្ជាឱ្យគេកេណ្ឌកម្លាំង ដើម្បីកសាងព្រះរាជនិវេសន៍លើដីទួលនៅទិសអាគ្នេយ៍នៃភ្នំដូនពេញសម្រាប់ធ្វើកំពែងសង់ប្រាសាទ និងដំណាក់តូចធំក្នុងរយៈពេលដ៏ខ្លីបំផុត។ បន្ទាប់មកព្រះអង្គបានបញ្ជាឱ្យគេកេណ្ឌប្រជារាស្ត្រលើកដីចាក់បំពេញតំបន់ជុំវិញវត្តភ្នំ និងព្រះរាជវាំង ដែលធ្វើឱ្យតំបន់នេះ មានសណ្ឋានដីរាបស្មើល្អ រហូតដល់

[18] សៀវភៅ នីតិនគរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២០ ទំព័រទី ៧

មាត់ទន្លេ ដែលអ្នកផងហៅថា "កំពង់រាប" តាំងពីពេលនោះមក។ ឯកន្លែងដែលគេជីកយកអាចម៍ដីនោះក៏ក្លាយជាបឹងធំជ្រៅមួយ ទើបឱ្យឈ្មោះថា "បឹងតេជោ" ដែលបច្ចុប្បន្នតាំងនៅត្រង់ផ្សារធំថ្មីសព្វថ្ងៃ។

ព្រះអង្គបានបញ្ជាឱ្យជីកព្រែកបង្ហូរទឹកចូលក្នុងបារាយណ៍នៅស្រុកបាទី សម្រាប់យកទឹកមកប្រើប្រាស់។ តាមការស្រាវជ្រាវ ព្រែកនេះស្ថិតនៅតាមបណ្តោយសួនច្បារមុខស្ថានីយរាជាយស្ម័យយានរហូតមកដល់មាត់ទន្លេសាប ដែលពីដើមឡើយគេហៅថា ព្រែកឧកញ៉ាផ្លុង។ ដើម្បីជាកិច្ចការពារប្រជារាស្ត្រ ព្រះរាជាបានបញ្ជាឱ្យគេជីកគូទឹក និងលើកដីជាកំពែងតាមបណ្តោយព័ទ្ធជុំវិញរាជធានី នៅទិសខាងត្បូង គឺព្រែកតាកែវ ឯខាងលិចគឺព្រែកអូរគ ខាងជើងគឺ ព្រែកពោងពាយ ឬព្រែកចិនដំដែក ពីព្រោះនៅកន្លែងនោះប្រជាពលរដ្ឋភាគច្រើន មានរបររកស៊ីខាងជាងដំដែក។ ក្រៅពីមុខងារការពារទីក្រុង ព្រែក ឬគូទឹកទាំងនោះ នៅមានមុខងារម៉្យាងទៀត គឺផ្តល់ទឹកឱ្យប្រជារាស្ត្រធ្វើស្រែនៅទិសភាគខាងលិច ។[19]

ក្រោយពីព្រះបាទពញាយ៉ាតសោយទិវង្គតទៅ មានព្រះរាជាបីអង្គទៀតបានបន្តគង់នៅក្រុងភ្នំពេញ គឺព្រះនារាយណ៍រាជា ព្រះស្រីរាជា និងព្រះធម្មរាជា។ នៅសតវត្សរ៍ ទី១៧ មានស្តេចមួយអង្គទៀតបានមកតាំងទីនៅក្នុងរាជធានីភ្នំពេញបានមួយរយៈពេលខ្លី គឺព្រះពញាញោម។ នៅសតវត្សរ៍ទី១៩ ព្រះបាទឧទ័យរាជាអង្គច័ន្ទបានលើករាជធានីមកនៅភ្នំពេញវិញ ដោយបានកសាងវាំងថ្មីខាងត្បូងវត្តឧណ្ណាលោមហៅថា "រាជវាំងកំពែងកែវ" ដែលស្ថិតនៅរហូតមកដល់សព្វថ្ងៃ។ លុះក្រោយមកព្រះឧទ័យរាជាអង្គច័ន្ទបានប្តូររាជធានីទៅកាន់កោះស្លាកែតវិញរហូតមកដល់រជ្ជកាលព្រះបាទសម្តេចនរោត្តមឆ្នាំ ១៨៦៧។ មកដល់ឆ្នាំ១៩០៤ ទើបមានការប្តូររាជធានីមកនៅភ្នំពេញ ហើយការតាំងទីក្រុង ឬរាជធានីមិនមានការផ្លាស់ប្តូរទៀតឡើយ រហូតមកដល់សព្វថ្ងៃនេះ។[20]

### ១.១.៤.២. ការពង្រីកទីក្រុងភ្នំពេញ និងល្បឿននគរូបនីយកម្ម

ទីក្រុងភ្នំពេញ ឬទីក្រុងចតុមុខ ចាប់ពីសតវត្សរ៍ទី១៥ ដល់ជិតពាក់កណ្តាល សតវត្សរ៍ទី១៩ ពុំមានការពង្រីកក្រុងឱ្យធំទូលាយទេ ព្រោះមានវិបត្តិក្នុងប្រទេស និងសង្គ្រាមជាមួយប្រទេសជិតខាង ហើយកម្ពុជាត្រូវស្ថិតនៅក្រោមអាណាព្យាបាលរបស់បារាំង (ឆ្នាំ១៨៦៣)។ ជាបន្តបន្ទាប់ ទីក្រុងភ្នំពេញបានចាប់ពង្រីកខ្លួន និងរីកធំឡើងចាប់ពីពាក់កណ្តាលសតវត្សរ៍ទី១៩ ជាពិសេសនៅពេលដែលកម្ពុជាបានទទួលឯករាជ្យពីប្រទេសបារាំងនាឆ្នាំ១៩៥៣ រហូតមកដល់សតវត្សរ៍ទី២១ គឺបន្ទាប់ពីការតាំងទីក្រុងភ្នំពេញជាប់លាប់។

បើយើងងាកមកក្រោយវិញបន្តិច នៅក្នុងឆ្នាំ១៨៧៦ ទីក្រុងភ្នំពេញបានលាតសន្ធឹងតាមបណ្តោយត្រើយខាងលិចទន្លេសាប និងទន្លេបាសាក់ មានបណ្តោយប្រវែងប្រហែល ៣ គីឡូម៉ែត្រប៉ុណ្ណោះ និងទទឹងចូលពីមាត់ទន្លេទៅក្នុងជម្រៅដីគោក ប្រវែងយ៉ាងច្រើនពី ៣០០ម៉ែត្រទៅ ៣៥០ម៉ែត្រ ដែលប្រជាជនច្រើននៅប្រមូលផ្តុំ ឬរស់

[19] សៀវភៅ ប្រវត្តិនគរូបនីយកម្មនៅកម្ពុជា , បណ្ឌិត អ៊ូ វ័ឌី បោះពុម្ពឆ្នាំ២០១២ ទំព័រទី ២៩

[20] សៀវភៅ ប្រវត្តិនគរូបនីយកម្មនៅកម្ពុជា , បណ្ឌិត អ៊ូ វ័ឌី បោះពុម្ពឆ្នាំ២០១២ ទំព័រទី ៣០

នៅតាមមាត់ទន្លេ។ លុះមកដល់ ឆ្នាំ១៨៨៥ មានការចាប់ផ្តើមពង្រីកទីក្រុងទៅទិសខាងលិច តែទិសខាងជើង និងខាងត្បូងពុំសូវមានការប្រែប្រួលទេ។ ដើម្បីអភិវឌ្ឍក្រុងឱ្យកាន់តែមានសោភណភាព សកម្មភាពពង្រីកក្រុងបានប្រព្រឹត្តទៅជាបណ្តើរៗ ព្រោះស្ថានភាពទីតាំងក្រុងស្ថិតក្នុងតំបន់ទំនាបទាប និងសម្បូរដោយបឹងបួ អូរតូចៗ និងព្រែកជីកព័ទ្ធក្រុង ដូចនេះ នៅរដូវវស្សា ដីមួយផ្នែកដែលទាបត្រូវលិចទឹក ជួនកាលលិចដោយទឹកជំនោរផង និងទឹកភ្លៀងផង ដែលចាំបាច់ត្រូវមានការចាក់លុបបំពេញ និងជំនួសដោយ សួនឧទ្យាន អគាររដ្ឋបាល និងផ្លូវនានាជាក្រឡាចក្រត្រង្គ ដូចជាសួនច្បារនៅមុខស្ថានីយរាជាយស្ម័យយាន និងការចាក់បំពេញដីតំបន់ខាងមុខសណ្ឋាគារឡឺរ៉ូយ៉ាល់ (Hotel Le Royal) តំបន់បឹងកេងកង អូរឫស្សី ចំការមន បឹងទំពន់។ល។

ការចាក់ដីលុបបំពេញតំបន់ទាបៗនៅ ឆ្នាំ១៩១០ បានធ្វើឱ្យក្រុងភ្នំពេញមានទិដ្ឋភាពកាន់តែល្អ និងក្លាយជាទីក្រុងមួយពេញលេញ ការពង្រីកទីក្រុងទៅទិសខាងលិចកាន់តែរីកធំឡើងៗ ហើយរចនាសម្ព័ន្ធទីក្រុងមានការប្រែប្រួលជាបន្តបន្ទាប់។ ប្រការមួយដែលគួរឱ្យកត់សម្គាល់នោះគឺ ឈ្មោះមួយចំនួនដែលហៅនៅតាមសង្កាត់នានា រហូតមកដល់សព្វថ្ងៃមានភ្ជាប់ដោយឈ្មោះ បឹង អូរ ព្រែក ឬទួល ដែលករណីទាំងនេះអាចជាតឹកតាងបញ្ជាក់ប្រាប់ដល់មនុស្សជំនាន់ក្រោយឱ្យដឹងថា ទីក្រុងភ្នំពេញបានកសាងឡើងលើតំបន់ទំនាបទាបនៃទន្លេចតុមុខដែលជាតំបន់ងាយលិចទឹកបំផុត ជាពិសេសនៅរដូវជំឡើង (រដូវវស្សា) ឬនៅពេលមានទឹកជំនន់ទន្លេមេគង្គម្តងៗ ហើយឈ្មោះទាំងនោះមានដូចជាបឹងកេងកង បឹងត្របែក បឹងព្រលិត បឹងរាំង បឹងជើងឯក បឹងទំពន់ បឹងតេជោ និងបឹងមួយចំនួនដែលមាននៅសព្វថ្ងៃ ស្ថិតក្នុងតំបន់ត្រូវអភិវឌ្ឍ ដូចជាបឹងកក់ និងនៅមានបឹងពោងពាយ ឬអូរឫស្សី ព្រែកចិនដំដែក ព្រែកតាកែវ ព្រែកអូរគ និងព្រែកឧកញ៉ាផ្លុង (ជាព្រែកដែលត្រូវបានជីកដោយប្រជាពលរដ្ឋដើម្បីបង្ហូរទឹកសម្រាប់ធ្វើស្រែ) ។

នៅទសវត្សរ៍ទី៦០ រាជធានីភ្នំពេញមានការអភិវឌ្ឍទៅមុខយ៉ាងលឿន ដែលធ្វើឱ្យមុខមាត់ទីក្រុងមានឈ្មោះបោះសំឡេងថា ជាទីក្រុងមួយតូចស្អាតជាងគេ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ រហូតមកដល់ឆ្នាំ១៩៦២ ទីក្រុងភ្នំពេញមានផ្ទៃដី ៤៦ គីឡូម៉ែត្រការ៉េ។ នៅឆ្នាំ១៩៧៩ ពិសេសក្រោយថ្ងៃរំដោះ ៧ មករា និងនៅឆ្នាំ១៩៨១ ផ្ទៃក្រឡាទីក្រុងភ្នំពេញបានកើនឡើងដល់ ១៤៩ គីឡូម៉ែត្រការ៉េ ដែលការកើនឡើងនៃផ្ទៃដីទីក្រុងនេះពាក់ព័ន្ធទៅនឹងការកើនឡើងនៃចំនួនប្រជាជនដែលធ្វើចលនាចូលមករស់នៅក្នុងក្រុងភ្នំពេញ ។

បើធ្វើការប្រៀបធៀបពីផ្ទៃដីក្រុងភ្នំពេញ នៅចន្លោះសម័យសង្គមរាស្ត្រនិយម ឆ្នាំ១៩៦២ (ផ្ទៃដីមាន ៤៦ គីឡូម៉ែត្រការ៉េ) និងសម័យបច្ចុប្បន្ន ឆ្នាំ២០២១ (ផ្ទៃដី ៦៩២,៤៦ គីឡូម៉ែត្រការ៉េ) នោះគេឃើញថាក្នុងរយៈពេល ៥៩ឆ្នាំ ទីក្រុងភ្នំពេញមានផ្ទៃដីរីកធំឡើងដល់ទៅ ១៥ដង។

### ១.១.៤.៣. នគរូបនីយកម្មនៅក្រុងភ្នំពេញ

តាមរយៈប្លង់អភិវឌ្ឍទីក្រុងភ្នំពេញពី ឆ្នាំ១៨៧៦ ដល់ ឆ្នាំ១៩៥៨ និងប្លង់សុរិយោដី ឆ្នាំ១៩២២ បាន បង្ហាញពីទីក្រុងដែលបន្តរីកធំឡើងឆ្ពោះទៅទិសខាងលិច។ ប្លង់ក្រុងបានបង្ហាញពីការប្រើប្រាស់ដីគឺ ស្ថិតនៅត្រឹម មហាវិថីព្រះមុនីវង្សប៉ុណ្ណោះ ហើយការប្រើប្រាស់ដីនៅខាងលិចផ្លូវព្រះមុនីវង្ស ប្រជាពលរដ្ឋច្រើនធ្វើកសិកម្មមាន ដាំស្រូវជាដើម។ ផ្លូវទាំងឡាយដែលនៅជុំវិញផ្សារធំថ្មី មានទម្រង់ជាធរណីមាត្រ។ អ្នករៀបចំក្រុងបានយកផ្សារ ធំថ្មីជាចំណុចកណ្តាល និងមានផ្លូវប្រសព្វដល់ទៅប្រាំបី ដែលផ្លូវទាំងនេះត្រូវបានកសាងឡើងនៅឆ្នាំ ១៩៤៦។ តាមឯកសារលោក Emest Hebrard ជាជនជាតិបារាំង និងជាប្រធានផ្នែកខាងរៀបចំក្រុងប្រចាំនៅតំបន់ ឥណ្ឌូចិន បានបញ្ជាក់ឱ្យដឹងថា នគរូបនីយកម្មបានចាប់ផ្តើមកើតឡើងនៅឆ្នាំ១៩២៥។[21]

ក្រោយឆ្នាំ១៩៥៣ ពេលដែលព្រះរាជាណាចក្រកម្ពុជាបានទទួលឯករាជ្យពេញលេញពីសាធារណរដ្ឋ បារាំង នោះទីក្រុងភ្នំពេញចាប់ផ្តើមមានកំណើនប្រជាជន ដែលនេះបានបង្ហាញពីចលនាផ្លាស់ទីលំនៅចូលមក រស់នៅក្នុងទីក្រុង។ ទោះបីជានៅទសវត្សរ៍ឆ្នាំ៦០ រាជធានីភ្នំពេញមានទំហំតូចក៏ដោយ តែការអភិវឌ្ឍបានបោះ ជំហានទៅមុខយ៉ាងលឿន មុខមាត់ទីក្រុងមានការផ្លាស់ប្តូរ ធ្វើឱ្យទីក្រុងភ្នំពេញមានឈ្មោះបោះសំឡេងក្លាយជា **"ទីក្រុងគជ់"** និងជាប្រទេសដែលមានឈ្មោះថា **"កោះសន្តិភាពនៅក្នុងតំបន់អាស៊ីអាគ្នេយ៍"**។

ក្រោយពេលរំដោះពីរបបប៉ុលពត ជាបណ្តើរៗចំនួនប្រជាជនក្រុងភ្នំពេញមានការកើនឡើងជាបន្តបន្ទាប់ ចំនួនប្រជាជនក្រុងភ្នំពេញពី ឆ្នាំ១៩៨០ មាន ១១២ ៩៦៥ នាក់ មកដល់ឆ្នាំ១៩៩៨ មាន ៩៩៥ ៧០៤ នាក់ បើ ធ្វើការប្រៀបធៀបរវាងចន្លោះឆ្នាំទាំងពីរ ចំនួនប្រជាជនក្រុងភ្នំពេញបានកើនឡើងដល់ទៅជិត ៩ដង ដែលនេះគឺ ជាកំណើនមួយដ៏ឆាប់រហ័ស។

នគរូបនីយកម្មនៃទីក្រុងភ្នំពេញមានល្បឿនកាន់តែលឿនឡើង បន្ទាប់ពីទីក្រុងនេះមានលទ្ធភាពក្នុងការ អភិវឌ្ឍក្រោយពីការរស់រានមានជីវិតឡើងវិញជាលើកទី២។ ភ្នំពេញដែលកើតពីទីក្រុងខ្មោចនោះបានរស់ឡើង វិញ ដោយមានការខិតខំស្តារ និងកសាងឡើងវិញជាបន្តបន្ទាប់ធ្វើឱ្យទីក្រុងនេះនៅតែជាទីក្រុងសំខាន់មួយរបស់ ប្រទេស មានការទាក់ទាញសម្រាប់ភ្ញៀវទេសចរ និងបានក្លាយជាទីក្រុងដ៏អស្ចារ្យមួយនៅសតវត្សរ៍ទី ២១ ដោយ បានជាប់ចំណាត់ថ្នាក់លេខ១ លើពិភពលោកលើប្រធានបទ **"ការរៀបចំស្តារទីក្រុងឡើងវិញ"** នៅឆ្នាំ២០០៥។[22]

ការកើនឡើងនៃចំនួនប្រជាជន និងនគរូបនីយកម្មបានធ្វើឱ្យភ្នំពេញមានការអភិវឌ្ឍមិនឈប់ឈរ។ សំណង់ស្ថាបត្យកម្មរីកដុះដាល និងពង្រីកខ្លួនឆ្ពោះទៅតំបន់ក្រៅក្រុង។ នៅឆ្នាំ២០១០ ក្រុងភ្នំពេញមានផ្ទៃដីកើន ឡើងដល់ទៅ ៦៧៨,៧គីឡូម៉ែត្រការ៉េ និងបានស្រូបយកតំបន់ជុំវិញដែលស្ថិតនៅក្នុងខេត្តកណ្តាល ។

---

[21] សៀវភៅ ប្រវត្តិនគរូបនីយកម្មនៅកម្ពុជា , បណ្ឌិត អ៊ូ វ័ឌី បោះពុម្ពឆ្នាំ២០១២ ទំព័រទី ៤០

[22] សៀវភៅ ប្រវត្តិនគរូបនីយកម្មនៅកម្ពុជា , បណ្ឌិត អ៊ូ វ័ឌី បោះពុម្ពឆ្នាំ២០១២ ទំព័រទី ៤៤

### ១.១.៥. ស្ថានភាពនៃការរៀបចំក្រុងបច្ចុប្បន្ន

ស្របពេលដែលទីក្រុងភ្នំពេញកំពុងមានការអភិវឌ្ឍ និងការរីកចម្រើនគួរឱ្យកត់សម្គាល់ ការវិនិយោគទៅលើការរៀបចំទីក្រុង និងការរៀបចំហេដ្ឋារចនាសម្ព័ន្ធឱ្យបានគ្រប់គ្រាន់ពិតជាមានមានសារៈសំខាន់យ៉ាងខ្លាំង។ ផលវិបាកចំពោះការមិនវិនិយោគទៅលើវិស័យទាំងនេះនឹងនាំមកនូវបញ្ហាមួយចំនួនដូចជា ការប៉ះពាល់ដល់គុណភាពរស់នៅ ការបំពុលបរិស្ថាន និងបញ្ហាសុខភាពជាដើម។

អាជ្ញាធរមូលដ្ឋានត្រូវមានកាតព្វកិច្ចក្នុងការទទួលខុសត្រូវឱ្យបានច្បាស់លាស់ចំពោះតួនាទី ពិសេសគឺការទទួលខុសត្រូវរវាងក្រសួងពាក់ព័ន្ធនានា និងសាលារាជធានីភ្នំពេញ ដើម្បីយ៉ាងណាធានាឱ្យមានការធ្វើសមាហរណកម្ម ការរៀបចំផែនការទីក្រុង និងការផ្តល់សេវាព្រមគ្នាប្រកបដោយនិរន្តរភាព។

#### ១.១.៥.១. ការរៀបចំស្ថាប័ន

ការអភិវឌ្ឍ និងការពង្រីកទីក្រុងនៅកម្ពុជា ភាគច្រើន កើតឡើងដោយគ្មានផែនការ និងគ្មានការគ្រប់គ្រងឱ្យបានត្រឹមត្រូវនោះទេ។ បើទោះបីជាមានច្បាប់ ក្របខណ្ឌ និងផែនការ ពាក់ព័ន្ធនឹងការអភិវឌ្ឍក្រុង និងការគ្រប់គ្រងដី នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យ៉ាងណាក៏ដោយ ការអនុវត្តការងារស្ថិតនៅរាយប៉ាយតាមស្ថាប័នផ្សេងៗគ្នា ក៏ដូចជា សមត្ថភាពធ្វើនិយ័តកម្ម និងសមត្ថភាពបច្ចេកទេស នៅមានកម្រិត ជាកត្តាដែលរារាំងមិនឱ្យមានការអនុវត្តច្បាប់ ក្របខណ្ឌ និងផែនការទៅមុខបាន។

មានការសង្កេតឃើញថា ផែនការនៅមិនទាន់តាមទាន់នឹងល្បឿននៃការអភិវឌ្ឍជាក់ស្តែង ខណៈពេលដែលមានការដាក់ចេញនូវផែនការគោលឆ្នាំ២០៣៥ សម្រាប់រាជធានីភ្នំពេញ រួចក៏ដោយ ផែនការនេះ នៅតែជាឯកសារយុទ្ធសាស្ត្រទូលំទូលាយ ដោយពុំមានប្លង់ប្រើប្រាស់ដីធ្លី ឬផែនការអនុវត្តបែងចែកជាដំណាក់កាលៗលម្អិតនៅឡើយ។ ប្លង់គោលតាមវិស័យ និងការសិក្សាអំពីលទ្ធភាពជាច្រើន សម្រាប់ប្រព័ន្ធគមនាគមន៍ក្រុង ប្រព័ន្ធលូរំដោះទឹកភ្លៀង ការផ្គត់ផ្គង់ទឹក ប្រព័ន្ធលូទឹកស្អុយ និងការសម្អាតទឹកស្អុយ ត្រូវបានរៀបចំដោយ JICA, ADB និងអ្នកផ្តល់ជំនួយផ្សេងទៀត ក៏ប៉ុន្តែពុំមានស្ថាប័នណាត្រួតពិនិត្យលើការរៀបចំ និងការអភិវឌ្ឍក្រុងឱ្យបានសព្វគ្រប់ជ្រុងជ្រោយឡើយ។

តារាងនៅទំព័របន្ទាប់នេះនឹងបង្ហាញអំពីស្ថាប័ននានា ដែលធ្វើការងារពាក់ព័ន្ធនឹងការរៀបចំក្រុងនៅក្នុងប្រទេសកម្ពុជា នៅកម្រិតផ្សេងៗនៃរាជរដ្ឋាភិបាល។[23]

[23] ការអភិវឌ្ឍទីក្រុង រាជធានីភ្នំពេញ ប្រទេសកម្ពុជា , ក្រុមការងារធនាគារពិភពលោក ទំព័រទី ២៦

## ការរៀបចំ និងការគ្រប់គ្រងក្រុង នៅកម្ពុជា
## (ផ្អែកតាមលទ្ធផលរកឃើញរបស់ក្រុមការងារធនាគារពិភពលោក ឆ្នាំ២០១៧)



### ១.១.៥.២. ស្ថានភាពគតិយុត្តនៃការរៀបចំក្រុងនៅប្រទេសកម្ពុជា

គោលនយោបាយ និងច្បាប់ ពាក់ព័ន្ធជាមួយនឹងការគ្រប់គ្រងដីធ្លី និងនគរូបនីយកម្ម គឺនៅថ្មីនៅឡើយសម្រាប់ប្រទេសកម្ពុជា ពោលគឺ គោលនយោបាយ និងច្បាប់ពាក់ព័ន្ធទាំងនេះ ទើបតែត្រូវបានរៀបចំឡើងកាលពីឆ្នាំ២០០១ តែប៉ុណ្ណោះ។

បើទោះជា បន្ទាប់ពីការបោះឆ្នោតនីតិកាលទី១ នាឆ្នាំ១៩៩៣ ឯកសារដែលពាក់ព័ន្ធនឹងការរៀបចំដីធ្លីនៅព្រះរាជាណាចក្រកម្ពុជាត្រូវបានអនុម័ត និងប្រកាសឱ្យប្រើជាបន្តបន្ទាប់យ៉ាងណាក្តី លុះរហូតដល់ឆ្នាំ២០០១ ដែលមានការអនុម័តឱ្យប្រើច្បាប់ភូមិបាល ទើបគេសង្កេតឃើញថាស្ថានភាពភូមិបាល ពិសេសគឺបេបកម្មសិទ្ធិលើអចលនវត្ថុទាំងឡាយនៅព្រះរាជាណាចក្រកម្ពុជាមានលក្ខណៈល្អប្រសើរ។ លទ្ធកម្មនៃកម្មសិទ្ធិលើដីធ្លីត្រូវបានផ្តល់ជូនប្រជាពលរដ្ឋទៅតាមតំបន់វិនិច្ឆ័យនានា។ ឯកសារគតិយុត្តចម្បងៗដែលពាក់ព័ន្ធនឹងដីធ្លី និងការគ្រប់គ្រងនគរូបនីយវិទ្យាមាន ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ (ដែលត្រូវបានប្រកាសឱ្យប្រើនៅក្នុងឆ្នាំ១៩៩៤), ប្លង់គោល, និងប្លង់ប្រើប្រាស់ដីធ្លី និងសំណង់។[24] នៅមុនឆ្នាំ២០០១ ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ត្រូវបានសម្អាងលើកម្មសិទ្ធិដែលបានអនុលោមទៅតាមច្បាប់ភូមិបាលនាឆ្នាំ១៩៩២ ក៏ប៉ុន្តែ ច្បាប់ភូមិបាលឆ្នាំ១៩៩២ ត្រូវបានកែប្រែ ផ្លាស់ប្តូរដោយច្បាប់ភូមិបាលឆ្នាំ២០០១ ដូចនេះ ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ក៏ត្រូវបានកែច្នៃឱ្យស្របទៅតាមច្បាប់ភូមិបាលនាឆ្នាំ២០០១ ដែលយើងកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ននេះផងដែរ។[25] ឯកសារទាំងឡាយ ដែលទាក់ទងនឹងការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំតាមករណីនីមួយៗ ឱ្យសមស្របទៅតាមស្ថានភាព លក្ខណៈពិសេសនៃទឹកដី ខេត្ត ក្រុង តំបន់ក្នុងស្មារតីការពារដល់បេតិកភណ្ឌ ដល់បរិស្ថានការពារធនធានធម្មជាតិ ព្រមទាំងធានាដល់ការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច។[26]

បើយើងក្រឡេកមកមើល ការទទួលខុសត្រូវពាក់ព័ន្ធនឹងការរៀបចំក្រុងរបស់អាជ្ញាធរ នាពេលបច្ចុប្បន្នកម្រិតរដ្ឋបាលផ្សេងៗគ្នារបស់រដ្ឋាភិបាល (ថ្នាក់ជាតិ ខេត្ត ក្រុង និងឃុំ) មានការទទួលខុសត្រូវផ្សេងៗគ្នា ពាក់ព័ន្ធនឹងការរៀបចំក្រុង ការរៀបចំភូមិសាស្ត្រ និងការរៀបចំផែនការប្រើប្រាស់ដីធ្លីនេះ។

តារាងខាងក្រោមគឺជាការបង្ហាញដោយសង្ខេបនូវតួនាទីផ្សេងៗ កម្រិតលម្អិតនៃការរៀបចំផែនការ វដ្តនៃការរៀបចំផែនការ និងដំណើរការផ្តល់ការអនុម័តនៅតាមកម្រិតរដ្ឋបាលទាំងនេះ។

---

[24] សៀវភៅ នីតិនគរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២០ ទំព័រទី ១១៨

[25] ច្បាប់ ស្តីពី ការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ១៩៩៤, មាត្រា ២

[26] ច្បាប់ ស្តីពី ការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ១៩៩៤, មាត្រា ៤

**ការពិពណ៌នាអំពីការរៀបចំក្រុង ប្រព័ន្ធរៀបចំភូមិសាស្ត្រ និងប្រព័ន្ធរៀបចំផែនការយុទ្ធសាស្ត្រដីធ្លី នៅកម្រិតរដ្ឋបាលនានា**[27]

| កម្រិត | ពិពណ៌នាអំពីផែនការ |
|---|---|
| ថ្នាក់ជាតិ/ភូមិភាគ | រៀបចំដោយគណៈកម្មាធិការជាតិគ្រប់គ្រងដែនដី និងនគរូបនីយកម្ម ដែលត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យក្រោមការដឹកនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងត្រូវអនុម័តដោយព្រះរាជក្រឹត្យ។ ផែនការនេះនឹងត្រូវមានចក្ខុវិស័យយ៉ាងហោចណាស់រយៈពេល ២០ ឆ្នាំ ហើយនឹងត្រូវកែសម្រួល ១០ ឆ្នាំក្រោយ (ឬអាចឆាប់ជាងនេះ) តាមរយៈការស្នើសុំរបស់រាជរដ្ឋាភិបាល។ |
| ថ្នាក់រាជធានី/ខេត្ត | រៀបចំដោយគណៈកម្មាធិការគ្រប់គ្រងដែនដី និងនគរូបនីយកម្ម ថ្នាក់រាជធានីខេត្តដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ ក្រោមការសម្របសម្រួលពីក្រុមប្រឹក្សារាជធានីខេត្ត និងមានការឯកភាពពីគណៈកម្មាធិការជាតិគ្រប់គ្រងដែនដី និងនគរូបនីយកម្ម។ ផែនការនេះត្រូវមានចក្ខុវិស័យ សម្រាប់រយៈពេលយ៉ាងហោចណាស់ ២០ ឆ្នាំ និងអាចកែសម្រួល រៀងរាល់ ៥ ឆ្នាំម្តង។ |
| ថ្នាក់ក្រុង/ស្រុក/ខណ្ឌ | រៀបចំដោយគណៈកម្មាធិការគ្រប់គ្រងដែនដី និងនគរូបនីយកម្ម ថ្នាក់ក្រុង/ស្រុក/ខណ្ឌ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ ដែលផែនការនេះត្រូវមានការយល់ព្រមពីក្រុមប្រឹក្សារាជធានីខេត្ត និងអនុម័តដោយប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងដែនដី និងនគរូបនីយកម្ម។ ផែនការនេះត្រូវមានចក្ខុវិស័យ សម្រាប់រយៈពេលយ៉ាងហោចណាស់ ១៥ ឆ្នាំ និង អាចកែសម្រួលរៀងរាល់ ៥ ឆ្នាំម្តង។ |
| ថ្នាក់ឃុំ/សង្កាត់ | រៀបចំដោយក្រុមប្រឹក្សាឃុំ/សង្កាត់ ដោយមានការសម្របសម្រួល និងការគាំទ្របច្ចេកទេសពីគណៈកម្មាធិការគ្រប់គ្រងដែនដីនិងនគរូបនីយកម្មថ្នាក់ក្រុង/ស្រុក/ខណ្ឌ។ ផែនការនេះត្រូវអនុម័តដោយក្រុមប្រឹក្សារាជធានីខេត្ត តាមរយៈគណៈកម្មាធិការគ្រប់គ្រងដែនដី និងនគរូបនីយកម្ម ថ្នាក់រាជធានីខេត្ត។ ផែនការនេះត្រូវមានចក្ខុវិស័យរយៈពេល ១០ ទៅ ១៥ ឆ្នាំ និងអាចកែសម្រួលរៀងរាល់ ៥ ឆ្នាំម្តង ឬទៅតាមតម្រូវការនៃការអភិវឌ្ឍមូលដ្ឋាន និងកម្មវិធីវិនិយោគឃុំ-សង្កាត់។ |

[27] របាយការណ៍ ស្តីពី ការអភិវឌ្ឍទីក្រុង រាជធានីភ្នំពេញ ប្រទេសកម្ពុជា , ក្រុមការងារធនាគារពិភពលោក ទំព័រទី ២៧

យ៉ាងណាមិញ បើទោះបីជាមានក្របខណ្ឌសម្រាប់ដំណើរការរៀបចំផែនការក៏ដោយ កង្វះសមត្ថភាព (ថវិកា និងជំនាញបច្ចេកទេស) បង្កជាការរាំងស្ទះដល់ការរៀបចំក្រុង ការរៀបចំភូមិសាស្ត្រ និងការរៀបចំផែនការប្រើប្រាស់ដីធ្លី ជាពិសេស នៅថ្នាក់ខណ្ឌ និងសង្កាត់។ ដោយសារមូលហេតុនេះហើយទើបជារឿយៗ ប្លង់គោលតាមវិស័យសម្រាប់ក្រុងត្រូវបានរៀបចំដោយអ្នកផ្តល់ជំនួយ។[28]

គួរឱ្យកត់សម្គាល់ផងដែរថា នៅប្រទេសកម្ពុជា ប្លង់គោលលេចឡើងតាមរយៈ ២ រូបភាពគឺ៖

- ប្លង់គោលសម្រាប់ខេត្ត/ក្រុង៖ ត្រូវរៀបចំដោយគណៈកម្មាធិការរៀបចំដែនដីនគរូបនីយកម្ម និងសំណង់រាជធានីភ្នំពេញ ឬអនុគណៈកម្មាធិការរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ តាមបណ្តាខេត្ត/ក្រុង ហើយប្លង់គោលនេះត្រូវតែមានការយល់ព្រមពីគណៈកម្មាធិការរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ។
- ប្លង់គោលសម្រាប់តំបន់ពិសេស៖ ត្រូវបានបង្កើតឡើង ដើម្បីការពារនូវបេតិកភណ្ឌ បរិស្ថាន និងដើម្បីបានធានានូវការអភិវឌ្ឍសេដ្ឋកិច្ច។ ចំពោះតំបន់ពិសេសណាមួយដែលគណៈរដ្ឋមន្ត្រីបានកំណត់ នោះគណៈកម្មាធិការរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ មានភារកិច្ចរៀបចំប្លង់គោលនេះសម្រាប់ដាក់ជូនគណៈរដ្ឋមន្ត្រីអនុម័ត។[29]

ចំណែកឯប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ ត្រូវរៀបចំឡើងសម្រាប់រាជធានី ខេត្ត ក្រុង និងត្រូវបានបង្កើតឡើងដោយផ្អែកទៅលើប្លង់គោល ដោយប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ ដើម្បីជាកត្តាជម្រុញភាពខ្វះចន្លោះនៃការអនុវត្តប្លង់គោល។[30] ហេតុនេះហើយ ការរៀបចំឱ្យមានជាប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ លុះត្រាតែមានប្លង់គោលជាមុនសិន ព្រោះប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ គឺត្រូវអនុលោមទៅតាមប្លង់គោល ដោយសំដៅច្រៀកបន្ថែមតំបន់នីមួយៗដែលបានកំណត់នៅក្នុងប្លង់គោល ដោយមានបញ្ជាក់ច្បាស់លាស់អំពីតំបន់ដែលត្រូវប្រើប្រាស់សម្រាប់ការពារជាតិ សម្រាប់កសិកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម សិប្បកម្ម វប្បធម៌ ទេសចរណ៍ សាសនា រួមទាំងសំណង់នៃរដ្ឋបាល និងបរិក្ខារសាធារណៈ ព្រមទាំងកំណត់ផងដែរនូវលទ្ធភាពសម្រាប់សាងសង់។[31] ប្លង់នេះត្រូវមានការគោរពពីសំណាក់ឯកជន ក៏ដូចជាអាជ្ញាធរសាធារណៈក្នុងកិច្ចការសាងសង់របស់ខ្លួន។

នៅថ្នាក់ជាតិនាពេលបច្ចុប្បន្ន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ពុំមានគោលនយោបាយអភិវឌ្ឍន៍ក្រុងជាក់លាក់នោះទេ ប៉ុន្តែបញ្ហាគោលនយោបាយក្រុងសំខាន់ៗ ត្រូវបានដាក់បញ្ចូលទៅក្នុងឯកសារ

---

[28] ការអភិវឌ្ឍទីក្រុង រាជធានីភ្នំពេញ ប្រទេសកម្ពុជា , ក្រុមការងារធនាគារពិភពលោក ទំព័រទី ២៦

[29] ច្បាប់ ស្តីពី ការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ១៩៩៤, មាត្រា ៥

[30] ច្បាប់ ស្តីពី ការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ១៩៩៤, មាត្រា ៨

[31] ច្បាប់ ស្តីពី ការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ១៩៩៤, មាត្រា ៧

ផ្សេងៗ។ ជាការឆ្លើយតបបន្ទាន់ចំពោះបញ្ហាប្រឈមជុំវិញការអភិវឌ្ឍ និងការពង្រីកទីក្រុង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានរៀបចំក្របខណ្ឌយុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍក្រុង (សេចក្តីព្រាងនេះបាន ទទួលការអនុម័តកាលពី ខែធ្នូ ឆ្នាំ ២០១៥) ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ និងអនុវត្តស្រប តាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ការអនុម័តលើយុទ្ធសាស្ត្រនេះ គឺមានគោលបំណងជួយ និងផ្តល់ការ គាំទ្រដល់អ្នកធ្វើសេចក្តីសម្រេចចិត្ត អ្នកជំនាញ អ្នកពាក់ព័ន្ធផ្សេងទៀត ហើយសាធារណជនទូទៅ តាមរយៈការ ផ្តល់ការកែតម្រង់ទិស និងការគាំទ្រដល់ការអភិវឌ្ឍក្រុង និងដំណើរការនៃការអភិវឌ្ឍក្រុងថ្នាក់ជាតិ និងថ្នាក់ក្រោម ជាតិ ក្រោមបរិបទកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា។[32]

ចំពោះថ្នាក់ក្រោមជាតិ (កម្រិតក្រុង) អនុក្រឹត្យលេខ ១៨១ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ គាំទ្រដល់ "ការអនុវត្តប្លង់គោលប្រើប្រាស់ដីធ្លី ក្នុងរាជធានីភ្នំពេញ" សម្រាប់ឆ្នាំគោលដៅ ២០៣៥ ផែនការដែលត្រូវបាន ព្រាងឡើងជាមួយនឹងជំនួយពី ការិយាល័យកិច្ចការទីក្រុង របស់ប្រទេសបារាំង គឺជាឯកសារកម្រិតយុទ្ធសាស្ត្រ ទូលំទូលាយដែលមានការបង្កើតជាផែនទី ស្តីពីការប្រើប្រាស់ដីធ្លី ដែលមានលក្ខណៈទូលំទូលាយ។

### ១.១.៥.៣. ស្ថានភាពទីក្រុងនៅរាជធានីភ្នំពេញ

ភ្នំពេញ គឺជារាជធានីជាតិតាំងពីសម័យបារាំងដាក់អាណានិគមលើប្រទេសកម្ពុជា និងបានរីកចម្រើន ក្លាយជាមជ្ឈមណ្ឌលកណ្តាល នៃមជ្ឈមណ្ឌលនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច ទេសចរណ៍ វប្បធម៌ និងការទូត ដែលមានការអភិវឌ្ឍលើគ្រប់វិស័យ។ ស្ថិតនៅភាគខាងត្បូងនៃប្រទេសកម្ពុជា ត្រង់ទន្លេចតុមុខ ដែលជាចំណុច ប្រសព្វរវាងទន្លេមេគង្គលើ ទន្លេមេគង្គក្រោម ទន្លេសាប និងទន្លេបាសាក់ ភ្នំពេញ ជារាជធានី និងជាទីក្រុងធំជាង គេបំផុតនៃប្រទេសកម្ពុជា។

#### ក. ទីតាំងភូមិសាស្ត្រ

រាជធានីភ្នំពេញមានផ្ទៃដីសរុបចំនួន ៦៩២,៤៦ គីឡូម៉ែត្រការ៉េ ស្មើនឹង 0,៣៨% នៃផ្ទៃដីសរុបទូទាំង ប្រទេស ចែកចេញជា ១៤ខណ្ឌ ១០៥សង្កាត់ និង៩៥៣ភូមិ។[33]

#### ខ. អភិបាលកិច្ច

នាពេលបច្ចុប្បន្ន រាជធានីភ្នំពេញត្រូវបានគ្រប់គ្រងដោយគណៈអភិបាល ដែលក្នុងនោះរួមមានអភិបាល ១រូប និងអភិបាលរង ៦រូប ជាសេនាធិការ។ គណៈអភិបាលទទួលខុសត្រូវផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋ

[32] សេចក្តីព្រាងក្របខណ្ឌយុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍក្រុង , ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ២០១៥

[33] ផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំ២០២០-២០២៤, ក្រុមប្រឹក្សារាជធានីភ្នំពេញ ឆ្នាំ២០២០

ដើម្បីបំពេញតាមតម្រូវការរបស់ពួកគេ និងស្តារហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រភេទដើម្បីកែលម្អកម្រិតជីវភាពរបស់ប្រជាជននៅទីក្រុង។[34]

**គ. ប្រជាជន**

ប្រជាជនរាជធានីភ្នំពេញបានកើនឡើងច្រើនជាង ៣ដង គឺចាប់ពីប្រមាណ ០,៥៧ លាននាក់នៅក្នុងឆ្នាំ១៩៩៨ ដល់ប្រមាណ ១,៥ លាននាក់នៅឆ្នាំ២០១៥។[35] ការពង្រីកទីក្រុង និងការបង្កើតខណ្ឌបន្ថែមនៅក្នុងរយៈកាលកន្លងមក គឺដើម្បីសម្របតាមកំណើនចំនួនប្រជាជន។ បើយោងតាមការព្យាករកំណើនប្រជាជននៅក្នុងការសិក្សារបស់ JICA សម្រាប់រៀបចំផែនការមេប្រព័ន្ធដឹកជញ្ជូន គេប៉ាន់ស្មានថាកំណើនប្រជាជននៅតែបន្តកើនឡើងដល់ ២,៨៦លាននាក់ នៅឆ្នាំ ២០៣៥។

**ឃ. សេដ្ឋកិច្ច**

ក្នុងរយៈពេល ១ទសវត្សរ៍ ចុងក្រោយនេះ កំណើនសេដ្ឋកិច្ចប្រទេសកម្ពុជា ភាគច្រើន ប្រមូលផ្តុំនៅរាជធានីភ្នំពេញ ។ អត្រាកំណើនសេដ្ឋកិច្ចក្នុងរយៈកាលប៉ុន្មានឆ្នាំថ្មីៗនេះ បានបង្កើតនូវការរីកដុះដាលសេដ្ឋកិច្ចយ៉ាងឆាប់រហ័សនៅរាជធានីភ្នំពេញ ជាពិសេសការវិនិយោគនៅក្នុងវិស័យសំណង់ រួមទាំងសណ្ឋាគារ ភោជនីយដ្ឋាន ក្លឹបកម្សាន្ត អគារស្នាក់នៅ និងអគារពាណិជ្ជកម្មខ្ពស់ៗ។ អត្រាកំណើនខ្ពស់នៃវិស័យឧស្សាហកម្មផ្នែកកម្មន្តសាលក្នុងនោះវិស័យកាត់ដេរបានរួមចំណែក ៧៥% នៃទិន្នផលសរុបនៃវិស័យកម្មន្តសាលរបស់ជាតិនៅឆ្នាំ២០១០។[36] ក្នុងឆ្នាំ២០១៥ ទីក្រុងភ្នំពេញទទួលបានការវិនិយោគបរទេសប្រមាណជា ៧៥% ទៅលើវិស័យឧស្សាហកម្ម និងការមកដល់របស់ភ្ញៀវទេសចរប្រមាណជា ១លាន នាក់។ ការរីកលូតលាស់នៅក្នុងវិស័យសេវាកម្មត្រូវបានជម្រុញដោយកំណើនពាណិជ្ជកម្ម និងសេវាកម្មផ្សេងទៀត ភាគច្រើននៅរាជធានីភ្នំពេញដែលរួមបញ្ចូលជាមួយកំណើនដ៏ឆាប់រហ័សនៃវិស័យហិរញ្ញវត្ថុ (ក្នុងអត្រា ១៩,៤% ក្នុងឆ្នាំ ២០១៨)។[37]

**ង. កម្រិតភាពក្រីក្រ**

អត្រាភាពក្រីក្រនៅរាជធានីភ្នំពេញ មានកម្រិតទាបជាងតំបន់ផ្សេងទៀតក្នុងប្រទេសកម្ពុជា។ គ្រួសារនីមួយៗនៅរាជធានីភ្នំពេញ មានចំណូលកើនឡើងជិត ២ដង នៃកម្រិតជាមធ្យមថ្នាក់ជាតិ។ ទិន្នន័យដែលមានស្តីពី វិសមភាពនៃប្រាក់ចំណូល បង្ហាញនូវការធ្លាក់ចុះបន្តិចនៃកម្រិតវិសមភាព នៃប្រាក់ចំណូលនៅរាជធានីភ្នំពេញចន្លោះពី ឆ្នាំ ២០០៩ ដល់ ឆ្នាំ ២០១៤។ ក៏ប៉ុន្តែទោះបីជាមានការធ្លាក់ចុះនៃវិសមភាពក៏ដោយ អត្រាភាព

---

[34] ដកស្រង់ពីគេហទំព័រសាលារាជធានីភ្នំពេញ http://phnompenh.gov.kh/en/about-us/organization-chart/ ចូលមើលថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២១

[35] ព្រឹត្តិបត្រសាលារាជធានីភ្នំពេញ លេខ៣៥ ខែកញ្ញា ឆ្នាំ២០១៧

[36] Maintaining High Growth: Cambodia Econmic Update , World Bank Group បោះពុម្ពឆ្នាំ២០១៥

[37] របាយការណ៍ របស់ធនាគារជាតិនៃកម្ពុជា ឆ្នាំ២០១៨

ក្រីក្រនៅរាជធានីភ្នំពេញបានកើនឡើងក្នុងអំឡុង ឆ្នាំ ២០០៨ ដល់ ឆ្នាំ ២០១២ ដែលឆ្លុះបញ្ចាំងនូវការកើនឡើងនៃតម្លៃទំនិញ និងសេវាប្រើប្រាស់ជាមូលដ្ឋាន។ គ្រួសារនៅរាជធានីភ្នំពេញក៏បានជួបប្រទះអត្រាកំណើនប្រាក់ចំណូលយឺត ដែលមានអត្រាកំណើនមធ្យមប្រចាំឆ្នាំរវាងចន្លោះឆ្នាំ ២០០៩ និងឆ្នាំ ២០១៤ ប្រហែល ៦,៨% និងកំណើនសរុបប្រហែល ៤១%។[38, 39]

### ច. បញ្ហាប្រឈមនៃការអភិវឌ្ឍទីក្រុង និងការប្រែប្រួលអាកាសធាតុ

ដោយសារការរីកលូតលាស់យ៉ាងឆាប់រហ័សនៃវិស័យនគរូបនីយកម្ម រាជធានីភ្នំពេញកំពុងប្រឈមមុខនឹងបញ្ហាជាច្រើន រួមមានការសាងសង់សំណង់អគារដោយមិនមានការត្រួតពិនិត្យស្តង់ដារត្រឹមត្រូវ ការកកស្ទះចរាចរណ៍ ការគ្រប់គ្រងសំណល់ ការបំពុល និងទឹកជំនន់។ បញ្ហាប្រឈមទាំងនេះអាចមានសភាពកាន់តែធ្ងន់ធ្ងរបន្ថែមទៀតដោយការគំរាមកំហែងពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

ក្នុងចំណោមបណ្តាប្រទេសនៃទន្លេមេគង្គក្រោម ប្រទេសកម្ពុជា និងឡាវ ត្រូវបានកំណត់ថាជាប្រទេសងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុ ដោយសាររយៈកម្ពស់ទាបខ្លាំង ព្រមទាំងនៅជិតមហាសមុទ្រ និងទន្លេមេគង្គ ហើយសមត្ថភាព ក្នុងការសម្របទៅនឹងហានិភ័យពីការប្រែប្រួលអាកាសធាតុនៅមានកម្រិតនៅឡើយ។[40] ទឹកជំនន់ និងការប្រែប្រួលកម្រិតទឹកភ្លៀង ក៏ផ្តល់នូវផលអវិជ្ជមានលើបរិមាណ និងគុណភាពនៃការផ្គត់ផ្គង់ទឹកដល់ទីក្រុង និងបណ្តាលឱ្យមានផលប៉ះពាល់ដល់ប្រជាជនរាប់លាននាក់ទៀតផង។ ក្រៅពីនេះ គេក៏ឃើញមានការគំរាមកំហែងផ្សេងៗទៀត រួមមានផលប៉ះពាល់នៃខ្យល់ព្យុះត្រូពិចដែលបានកើតឡើងរួចមកហើយក្នុងរយៈកាល ២-៣ ទសវត្សរ៍ចុងក្រោយមកនេះ។ កម្រិតខ្យល់ព្យុះត្រូពិចត្រូវបានព្យាករថានឹងមានការកើនឡើងជាញឹកញាប់បន្តទៀត និងមានសន្ទុះខ្លាំងជាងមុន។ ការឡើងកម្ពស់ទឹកសមុទ្រ ក៏នឹងប៉ះពាល់ដល់ទឹកសាបរបស់រាជធានីភ្នំពេញផងដែរ ដោយបង្កើនការជន់លិចទឹកប្រៃនៅតំបន់ដែលមានរយៈកម្ពស់ទាប ហើយវាក៏រួមចំណែកធ្វើឱ្យមានសំណឹកច្រាំងសមុទ្រ។[41]

### ឆ. បរិស្ថាន និងការបំពុល

តាមរយៈទិន្នន័យតាមដានគុណភាពខ្យល់ក្នុងរយៈពេល ២៤ម៉ោង (Real Time Air Quality Monitoring) នៅក្រសួងបរិស្ថាន ឃើញថាកម្រិតភាគល្អិតនិចល នៅក្នុងខ្យល់ជាមធ្យម ១០,២៤ ug/m៣ [42] ធៀបទៅនឹង

---

[38] ការគណនាអត្រាភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជារួមបញ្ចូលបន្ទាត់ក្រីក្រផ្នែកស្បៀង ដោយគិត ២២០០ កាឡូរីក្នុងម្នាក់ក្នុងមួយថ្ងៃ និងធាតុផ្សំមិនមែនស្បៀងដែលត្រូវបានប៉ាន់ស្មានដាច់ដោយឡែកពីគ្នាសម្រាប់រាជធានីភ្នំពេញ ព្រមទាំងតំបន់ទីក្រុង និងតំបន់ជនបទផ្សេងទៀត។

[39] Cambodia: Country Poverty Analysis 2014 , ADB បោះពុម្ពឆ្នាំ២០១៤

[40] Climate change vulnerability mapping for Southeast Asia Report, Yusuf, A., និង Francisco, H. ឆ្នាំ២០០៩

[41] Climate change vulnerability mapping for Southeast Asia Report, Yusuf, A., និង Francisco, H. ឆ្នាំ២០០៩

[42] Micrograms per Cubic Meter of Air

កម្រិតស្តង់ដារ PM[43] ២,៥ គឺ ៥0 ug/m[៣] ក្នុងរយៈពេល ២៤ ម៉ោង គិតចាប់ពីថ្ងៃទី០៣ ដល់ ០៩ ខែមិថុនា ឆ្នាំ២០១៨។[44,45] ប្រសិនបើកម្រិតស្តង់ដារនេះតំណាងឱ្យការវាស់គុណភាពខ្យល់នៅទូទាំងរាជធានី នេះបញ្ជាក់ថាគុណភាពខ្យល់នៅរាជធានីភ្នំពេញមិនមានផលប៉ះពាល់អាក្រក់ដល់ការដកដង្ហើម និងសុខភាពរបស់អ្នករស់នៅក្នុងរាជធានីទេ។ បើទាក់ទងទៅនឹងបញ្ហាទឹកកខ្វក់វិញ ប្រព័ន្ធទន្លេ និងបឹងមួយចំនួននៅរាជធានីភ្នំពេញ នៅមានការបំពុលខ្លាំងដោយសារមិនមាននូវប្រព្រឹត្តកម្មទឹកសំណល់ មុននឹងទឹកសំណល់ទាំងនោះត្រូវបានបញ្ចេញទៅក្នុងទន្លេ ឬប្រឡាយសាធារណៈ។[46]

### ១.១.៥.៤. បញ្ហាប្រឈមសំខាន់ៗក្នុងទីក្រុង

### ក. ការដឹកជញ្ជូនក្នុងរាជធានីភ្នំពេញ

កំណើនយានយន្តដ៏ឆាប់រហ័ស កើតឡើងទន្ទឹមគ្នានឹងការអភិវឌ្ឍ និងការពង្រីកខ្លួនយ៉ាងឆាប់រហ័សរបស់រាជធានីភ្នំពេញ។ កំណើននេះនាំឱ្យមានការកើនឡើងនូវបញ្ហាកកស្ទះចរាចរណ៍ទូទាំងទីក្រុងទាំងមូល។

#### ១). ការគ្រប់គ្រងផ្លូវថ្នល់ និងចរាចរណ៍

បណ្តាញផ្លូវថ្នល់របស់រាជធានីភ្នំពេញមានផ្លូវធំៗជាច្រើន ចេញពីតំបន់កណ្តាលក្រុង [47] និងផ្លូវក្រវាត់ ដូចជា មហាវិថីសីហនុ មហាវិថីម៉ៅសេទុង ផ្លូវក្នុងក្រុង និងផ្លូវក្រវាត់ក្រុងជាដើម។ ផ្លូវធំៗទាំងនេះភ្ជាប់ទៅកាន់ផ្លូវជាតិលេខ១ លេខ២ លេខ៣ លេខ៤ លេខ៥ និងលេខ៦ នៅតំបន់ជាយក្រុង។ ផ្លូវក្រាលកៅស៊ូក្នុងខណ្ឌនៅកណ្តាលក្រុងទាំង៤[48] មាន ៩៥% ខណៈពេលដែលផ្លូវក្រាលកៅស៊ូនៅតំបន់ជាយក្រុងមានត្រឹមតែ ២៧% តែប៉ុណ្ណោះ។ នៅពេលដែលគម្រោងអភិវឌ្ឍន៍លំនៅឋានថ្មីៗនៅតំបន់ជាយក្រុងបញ្ចប់ គេរំពឹងថានឹងមានការកកស្ទះចរាចរណ៍បន្ថែមទៀត។ សមត្ថភាពរបស់ផ្លូវជាតិធំៗចូលមកក្នុងទីក្រុងនឹងមិនអាចបំពេញទៅតាមបរិមាណចរាចរណ៍ថ្មីពីផ្លូវដែលភ្ជាប់ទៅតំបន់តូចៗក្នុងទីក្រុងឡើយ។ លើសពីនេះ ផ្លូវតាមជាយក្រុងជាច្រើននៅមិនទាន់បានក្រាលកៅស៊ូ និងពុំមានប្រព័ន្ធលូបង្ហូរទឹកភ្លៀងឱ្យបានត្រឹមត្រូវ ហើយត្រូវការកែលម្អនៅពេលដែលបរិមាណចរាចរណ៍មានការកើនឡើង។ ចំនួនគ្រោះថ្នាក់ចរាចរណ៍ក៏មានការកើនឡើងព្រមគ្នាជាមួយនឹងកំណើនកម្មសិទ្ធិ

[43] Particulate Matter

[44] គម្រោង ស្តីពី ការតាមដានគុណភាពខ្យល់នៅកម្ពុជា ឆ្នាំ២០១៦, ដកស្រង់ពីគេហទំព័រ http://aqicn.org/country/cambodia ចូលមើលថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២១

[45] សេចក្តីជូនដំណឹងអំពីស្ថានភាពគុណភាពខ្យល់នៅក្នុងរាជធានីភ្នំពេញ, ដកស្រង់ពីគេហទំព័រ http://www.moe.gov.kh/index/6143 ចូលមើលថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២១

[46] របាយការណ៍ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព សម្រាប់រាជធានីភ្នំពេញ ២០១៨-២០៣០ , វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ឆ្នាំ២០១៨ ទំព័រទី ១៣

[47] មានដូចជា មហាវិថីមុនីវង្ស មហាវិថីនរោត្តម មហាវិថីសហព័ន្ធរុស្ស៊ី មហាវិថីឆាលដឺហ្គោល និងមហាវិថីមុនីរ៉េត

[48] ខណ្ឌកណ្តាលក្រុងទាំង៤ រួមមាន ខណ្ឌចំការមន ខណ្ឌដូនពេញ ខណ្ឌ ៧មករា និងខណ្ឌទួលគោក

យានយន្តផងដែរ។ ខណៈពេលដែលគ្រោះថ្នាក់ចរាចរណ៍ជាច្រើននៅទីក្រុងភ្នំពេញបង្កឡើងដោយកំហុសមនុស្ស និងឥរិយាបថបើកបរគ្មានសុវត្ថិភាព ដូចជាការបើកបរស្រវឹង និងលើសល្បឿនកំណត់ ការគ្រប់គ្រងចរាចរណ៍នៅមានកម្រិតខ្សោយ ការពង្រឹងការអនុវត្តច្បាប់ចរាចរណ៍នៅមានកម្រិតទាប និងកង្វះការអប់រំអ្នកបើកបរ ជាកត្តាដែលរួមចំណែកនាំឱ្យស្ថានភាពមិនល្អបែបនេះ។ គិតត្រឹមខែមករា ឆ្នាំ២០១៣ មានប្រសព្វផ្លូវចំនួន ៦៩ ដែលមានភ្លើងសញ្ញាចរាចរណ៍មានកំណត់ពេលវេលា។ ភ្លើងសញ្ញាចរាចរណ៍បន្ថែម និងប្រព័ន្ធគ្រប់គ្រងចរាចរណ៍បែបទំនើបត្រូវបានដំឡើង ក្រោមជំនួយរបស់ JICA និងប្រទេសចិន។[49]

**២). មធ្យោបាយធ្វើដំណើរសាធារណៈ**

ការផ្តល់មធ្យោបាយធ្វើដំណើរសាធារណៈជាជម្រើសនៅក្នុងទីក្រុងភ្នំពេញកន្លងមក ពុំមានប្រសិទ្ធភាពឡើយ។ ការអង្កេតលើការធ្វើដំណើរ ដែល JICA បានធ្វើកាលពីឆ្នាំ ២០១២ បង្ហាញថា មធ្យោបាយធ្វើដំណើរពេញនិយមជាងគេក្នុងទីក្រុងភ្នំពេញ គឺទោចក្រយានយន្ត ៥២% បន្ទាប់មកគឺថ្មើរជើង ២៤% មធ្យោបាយធ្វើដំណើរពិសេស (Paratransit) ១៤% និងរថយន្ត ១០%។ JICA ធ្លាប់បានចូលរួមពាក់ព័ន្ធស៊ីជម្រៅជាមួយនឹងវិស័យរថយន្តក្រុងសាធារណៈក្នុងទីក្រុងភ្នំពេញ។ ជាផ្នែកមួយនៃផែនការប្រព័ន្ធគមនាគមន៍គ្រប់ជ្រុងជ្រោយសម្រាប់ទីក្រុងភ្នំពេញ JICA បានអនុវត្តសាកល្បងសេវារថយន្តក្រុងសាធារណៈលើផ្លូវប្រវែង ៨,៥ គីឡូម៉ែត្រក្នុងឆ្នាំ២០០១ ជាការពិសោធធ្វើតេស្តលើភាពអាចប្រើប្រាស់បាន និងការទទួលយកសេវានេះ។ ក្នុងឆ្នាំ២០១៤ ក្រសួងសាធារណការ និងដឹកជញ្ជូន សាលារាជធានីភ្នំពេញ និងJICA បានសាកល្បងបណ្តាញរថយន្តក្រុងសាធារណៈតាមបណ្តោយផ្លូវចំនួន ៣ (ប្រវែងសរុប ៥៤ គីឡូម៉ែត្រ) ប៉ុន្តែបើទោះជាមានការចាប់អារម្មណ៍ខ្លាំងពីសាធារណជនក្នុងខែដំបូងក៏ដោយ ចំនួនអ្នកធ្វើដំណើរដែលនៅបន្តប្រើប្រាស់សេវានេះមានកម្រិតទាប ដោយសារតែស្ថានភាពចរាចរណ៍មិនល្អ កាលវិភាគរថយន្តមិនអាចទទួលយកបាន ហើយរថយន្តក្រុងដែលប្រើប្រាស់មានគុណភាពទាប។[50]

ផ្អែកតាមការសម្ភាសរបស់ក្រុមការងារធនាគារពិភពលោកជាមួយក្រុមអ្នកជំនាញ JICA នៅឆ្នាំ២០១៦ បានបង្ហាញថា អ្នកធ្វើដំណើរតាមរថយន្តក្រុងសាធារណៈនៅរាជធានីភ្នំពេញមានប្រមាណជា ៨ ០០០ នាក់ ក្នុងមួយថ្ងៃ ស្មើនឹង ០,៣% នៃតម្រូវការចរាចរណ៍សរុប។ ខណៈពេលដែល ថ្លៃសេវារថយន្តក្រុងត្រូវបានកំណត់ទាបត្រឹម ១ ៥០០ រៀល ក្នុងមួយជើងក៏ដោយ មានអ្នកជិះរថយន្តក្រុងប្រមាណជា ៤០% ប្រើប្រាស់សេវារថយន្តក្រុងដោយមិនគិតថ្លៃ ដូចជា សិស្ស ព្រះសង្ឃ ចាស់ជរា និងជនពិការជាដើម ដែលជាកត្តាដាក់កំហិតលើនិរន្តរភាពហិរញ្ញវត្ថុរបស់សេវានេះ។ គិតត្រឹមឆ្នាំ២០១៦ ចំនួនរថយន្តក្រុងសាធារណៈសរុបមានប្រមាណជា ១០០គ្រឿង

[49] របាយការណ៍ ស្តីពី ការអភិវឌ្ឍទីក្រុង រាជធានីភ្នំពេញ ប្រទេសកម្ពុជា , ក្រុមការងារធនាគារពិភពលោក ទំព័រទី ៣១

[50] របាយការណ៍ ស្តីពី ការអភិវឌ្ឍទីក្រុង រាជធានីភ្នំពេញ ប្រទេសកម្ពុជា , ក្រុមការងារធនាគារពិភពលោក ទំព័រទី ៣១

ប៉ុន្តែការប្រើប្រាស់រថយន្តទាំងនេះមានកម្រិតទាបត្រឹម ៨០% ដោយសារតែរថយន្តក្រុងដែលប្រើហើយទាំងនេះត្រូវការការជួសជុលថែទាំញឹកញាប់។ ចំនួនអ្នកជិះតិច ឧបត្ថម្ភធនពុំមាននិរន្តរភាព ការចំណាយលើបុគ្គលិកខ្ពស់ដោយសារតែបុគ្គលិកមានចំនួនច្រើនលើសពីតម្រូវការ ព្រមទាំងការផ្តល់ប្រាក់បៀវត្សរ៍ខ្ពស់ និងជំនាញធ្វើធុរកិច្ចខ្សោយ ធ្វើឱ្យសេវារថយន្តក្រុងសាធារណៈក្លាយជាបន្ទុកហិរញ្ញវត្ថុ និងប្រតិបត្តិការសម្រាប់ទីក្រុងវិញ ហើយជួបការខាតបង់ប្រមាណ ១,២ លានដុល្លារ ក្នុងឆ្នាំ២០១៥។[51]

### ៣). បញ្ហាពាក់ព័ន្ធនឹងការភ្ជាប់ពីចំណុចចេញដំណើរដំបូង ទៅគោលដៅចុងក្រោយ និងផ្លូវសម្រាប់អ្នកដំណើរថ្មើរជើង

ការពុំមានការភ្ជាប់ពីចំណុចចេញដំណើរដំបូងដល់គោលដៅចុងក្រោយ គឺជាកត្តាចម្បងមួយដែលរារាំងមិនឱ្យប្រជាជនប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈ ជាពិសេស បើធៀបជាមួយនឹងភាពងាយស្រួលការប្រើប្រាស់មធ្យោបាយធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ ដូចជាយានយន្តផ្ទាល់ខ្លួន ទោចក្រយានយន្ត និងជម្រើសផ្សេងទៀត ដូចជារ៉ឺម៉កកង់បី ជាដើម។ ខណៈពេលដែលកង្វះការពង្រឹងការអនុវត្តច្បាប់ចរាចរណ៍ និងបទបញ្ញាស្តីពីការចតយានយន្ត គឺជាកត្តាធំមួយដែលនាំឱ្យគេប្រើចិញ្ចើមថ្នល់ថ្មើរជើងសម្រាប់គោលបំណងផ្សេង ការខ្វះកន្លែងសម្រាប់ចតយានយន្ត រឹតតែបន្ថែមទម្ងន់ដល់បញ្ហានេះថែមទៀត។ ក្នុងតំបន់ពាណិជ្ជកម្មកណ្តាលក្រុងភ្នំពេញ បច្ចុប្បន្ននៅខ្វះកន្លែងចតយានយន្ត ១២ ០០០ កន្លែង សម្រាប់ទោចក្រយានយន្ត និង៦ ០០០ កន្លែងទៀតសម្រាប់រថយន្ត។ ចំពោះបញ្ហានេះ វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ក៏បានធ្វើការសិក្សាពីបញ្ហាចំណតយានយន្តក្នុងទីក្រុងភ្នំពេញ ដើម្បីបន្តកំណត់ពីស្ថានភាព និងបញ្ហាប្រឈមបច្ចុប្បន្នផងដែរ។[52]

### ខ. ប្រព័ន្ធលូរំដោះទឹកភ្លៀង និងការការពារទឹកជំនន់ ក្នុងទីក្រុងភ្នំពេញ

ដោយមានទីតាំងនៅតាមបណ្តោយទន្លេសាប ទន្លេមេគង្គ និងទន្លេបាសាក់ ទីក្រុងភ្នំពេញ និងតំបន់ជុំវិញ សម្បូរដោយវាលទំនាបដីល្បាប់។ នេះជាមូលហេតុដែលទីក្រុងភ្នំពេញងាយរងទឹកជំនន់ ទាំងជំនន់ទឹកភ្លៀងផង និងទឹកជំនន់តាមរដូវជាទ្រង់ទ្រាយធំផង ដូចតំបន់ផ្សេងទៀតក្នុងប្រទេសកម្ពុជាដែរ។

ការខ្វះប្រព័ន្ធគ្រប់គ្រងលូរំដោះទឹកភ្លៀងគ្រប់ជ្រុងជ្រោយ ធ្វើឱ្យផលប៉ះពាល់ដែលកើតឡើងដោយសារគ្រោះទឹកជំនន់ទាំងនេះកាន់តែមានសភាពធ្ងន់ធ្ងរ។ កាលពីឆ្នាំ២០១១ និងឆ្នាំ២០១៣ ទីក្រុងភ្នំពេញជួបប្រទះនូវគ្រោះទឹកជំនន់ធ្ងន់ធ្ងរ ដែលបង្កឡើងដោយសារភ្លៀងធ្លាក់រដូវមូសុងច្រើនខុសធម្មតា ការកើតព្យុះទីហ្វុងជាបន្តបន្ទាប់ និងការឡើងកម្ពស់ទឹកទន្លេមេគង្គបង្កផលប៉ះពាល់ដល់ប្រជាពលរដ្ឋ ១៧ ០០០គ្រួសារ ក្នុងគ្រោះទឹកជំនន់ឆ្នាំ២០១១ និងជាង ៣ ៥០០ គ្រួសារ ក្នុងគ្រោះទឹកជំនន់ឆ្នាំ២០១៣។

[51] របាយការណ៍ ស្តីពី ការអភិវឌ្ឍទីក្រុង រាជធានីភ្នំពេញ ប្រទេសកម្ពុជា , ក្រុមការងារធនាគារពិភពលោក ទំព័រទី ៣២

[52] របាយការណ៍ ស្តីពី ការអភិវឌ្ឍទីក្រុង រាជធានីភ្នំពេញ ប្រទេសកម្ពុជា , ក្រុមការងារធនាគារពិភពលោក ទំព័រទី ៣៣

ទីក្រុងភ្នំពេញ ប្រើប្រាស់បណ្តាញលូរំដោះទឹកភ្លៀងបញ្ចូលគ្នាជាមួយនឹងបណ្តាញលូទឹកស្អុយ ដែលពុំអាចបំពេញទៅនឹងតម្រូវការបច្ចុប្បន្នបានឡើយ។ ការចាក់ដីលុបបឹងធម្មជាតិទន្លេ និងស្ទឹង ដើម្បីបង្កើតកន្លែងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងធ្វើការអភិវឌ្ឍថ្មីៗ បានកាត់បន្ថយលទ្ធភាពពឹងផ្អែកលើប្រព័ន្ធធម្មជាតិ សម្រាប់ជួយរំដោះទឹកភ្លៀងចេញពីទីក្រុងនេះ។ ចាប់តាំងពីឆ្នាំ១៩៩៨ មក ជំនួយឥតសំណងរបស់ JICA (ដំណាក់កាលទី១ ទី២ និងទី៣) ក៏ដូចជាគម្រោង កម្ចីរបស់ADB (២០០០-២០០៣) បានជួយដោះស្រាយបញ្ហាទឹកជំនន់នៅតំបន់កណ្តាលក្រុងដែលមានមនុស្សរស់នៅកកកុញច្រើន។ មានការកែលម្អប្រព័ន្ធ និងបច្ចេកវិទ្យារំដោះទឹកភ្លៀងគួរឱ្យកត់សម្គាល់ សម្រាប់ខណ្ឌកណ្តាលក្រុងចំនួន ៤ (ដូចជា មានការបង្កើតបណ្តាញប្រឡាយលូរំដោះទឹកភ្លៀង កន្លែងបង្ហូរភក់ចេញ ស្ថានីយបូម និងបឹងផ្ទុកទឹកជាដើម) និងមានប្រព័ន្ធការពារទឹកជំនន់ តាមរយៈការសាងសង់ទំនប់ជាច្រើន។ ផ្ទុយទៅវិញ ខណ្ឌជាយក្រុង និងតំបន់ដែលនៅជិតនោះ នៅខ្វះប្រព័ន្ធលូរំដោះទឹកភ្លៀង និងប្រព័ន្ធការពារទឹកជំនន់គ្រប់ជ្រុងជ្រោយ ហើយនៅតែងាយរងទឹកជំនន់ដែលកើតឡើងកាន់តែញឹកញាប់ជាងមុន។ លើសពីនេះ ការអភិវឌ្ឍយ៉ាងឆាប់រហ័សនូវទីក្រុងរណបធំៗនៅតំបន់ជុំវិញក្រុង ក៏បង្កឱ្យមានបញ្ហាប្រឈមបន្ថែមទៀតផងដែរ។ គេពុំឃើញមានការរៀបចំផែនការ ឬសាងសង់ប្រព័ន្ធលូរំដោះទឹកភ្លៀងនៅតាមបណ្តាទីក្រុងរណបទាំងនេះឱ្យបានសមស្រប ទៅតាមស្តង់ដាររួមតែមួយនោះទេ។

បើទោះជាអនុក្រឹត្យលេខ ៨៦ ស្តីពីលិខិតអនុញ្ញាតសាងសង់ និងក្រមបរិស្ថាន និងធនធានធម្មជាតិរបស់ប្រទេសកម្ពុជា តម្រូវឱ្យអ្នកអភិវឌ្ឍន៍អចលនទ្រព្យខ្នាតធំទទួលខុសត្រូវលើប្រព័ន្ធរំដោះទឹកភ្លៀងក៏ដោយ ក៏គេនៅមិនទាន់ឃើញមានការពង្រឹងការអនុវត្ត និងការកំណត់ស្តង់ដារបច្ចេកទេសសម្រាប់ហេដ្ឋារចនាសម្ព័ន្ធការពារទឹកជំនន់នៅឡើយ។ លក្ខខណ្ឌតម្រូវទាំងនោះមានដូចជា តម្រូវឱ្យមាន ទ្វារទឹកសម្រាប់រំដោះទឹកចេញនៅនឹងកន្លែង តំបន់សម្រាប់ប្រមូលភក់ និងកម្ទេចកម្ទីលើដី (Bio-Swales) តំបន់បៃតង និងផ្ទៃអាចជ្រាបទឹកបានជាដើម)។[53]

### គ. ប្រព័ន្ធលូទឹកស្អុយ និងការសម្អាតទឹកស្អុយ ក្នុងទីក្រុងភ្នំពេញ

បច្ចុប្បន្ននេះ ពុំមានប្រព័ន្ធសម្អាតទឹកស្អុយផ្លូវការក្នុងទីក្រុងភ្នំពេញនៅឡើយទេ។ ទឹកស្អុយ និងទឹកសំណល់តាមផ្ទះ សហគ្រាសពាណិជ្ជកម្ម និងឧស្សាហកម្ម ហូរលាយឡំជាមួយនឹងទឹកភ្លៀងទៅក្នុងប្រឡាយលូដែលមានគម្រប និងប្រឡាយលូចំហ ហើយបន្ទាប់មកហូរធ្លាក់ទៅក្នុងទន្លេ បឹង និងតំបន់ដីសើមរបស់ទីក្រុង។[54] ហេដ្ឋារចនាសម្ព័ន្ធរំដោះទឹកភ្លៀង និងសម្អាតទឹកស្អុយដែលនៅមានភាពទន់ខ្សោយ ព្រមទាំងកង្វះលិខិតបទដ្ឋានគតិយុត្ត និងការពង្រឹងការអនុវត្តឱ្យបានសមស្រប ធ្វើឱ្យមានទឹកស្អុយដែលមិនបានសម្អាតក្នុងបរិមាណ

---

[53] ផែនការយុទ្ធសាស្ត្រទីក្រុងបៃតង សម្រាប់ទីក្រុងភ្នំពេញ ២០១៧-២០២៦ , វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល ឆ្នាំ២០១៦

[54] Phnom Penh: City of Water, សមាគមជាងត្នោត ឆ្នាំ២០១២

ដ៏ច្រើនត្រូវបានបង្ហូរទៅក្នុងប្រព័ន្ធទឹកធម្មជាតិ។ ស្ថានភាពបែបនេះ បង្កការគំរាមកំហែងដល់បរិស្ថានទីក្រុងជាពិសេស ដល់ប្រជាជនរស់នៅលើតំបន់ដែលមានចំណូលទាបជុំវិញប្រឡាយ និងបឹងបួនានា។ គម្រោងសិក្សាពីការកែលម្អប្រព័ន្ធលូរំដោះទឹកភ្លៀង និងលូទឹកស្អុយក្នុងរាជធានីភ្នំពេញរបស់ JICA បានចាត់ទុកការបង្កើតរោងចក្រសម្អាតទឹកសំណល់ និងទឹកស្អុយ និងការដំឡើងប្រព័ន្ធលូទឹកស្អុយ ថាជាអាទិភាពបន្ទាន់ ដោយបានធ្វើការសិក្សាពីជម្រើសផ្សេងៗ សម្រាប់សម្អាតទឹកស្អុយនៅនឹងកន្លែង ព្រមទាំងនៅកន្លែងផ្សេងៗផងដែរ។ ភាពបន្ទាន់នៃការសម្អាតទឹកស្អុយក្នុងទីក្រុងភ្នំពេញ ក៏ត្រូវបានលើកឡើងក្នុង **"ផែនការយុទ្ធសាស្ត្រទីក្រុងបៃតងសម្រាប់ទីក្រុងភ្នំពេញ ២០១៧-២០២៦"** របស់វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ផងដែរ។[55]

### ឃ. ការផ្គត់ផ្គង់ទឹក ក្នុងទីក្រុងភ្នំពេញ

ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ក្នុងទីក្រុងភ្នំពេញ គឺជាវិស័យមួយក្នុងចំណោមវិស័យមួយចំនួនតូចដែលបានទទួលជោគជ័យកន្លងមក។ រដ្ឋករទឹកស្វយ័តក្រុងភ្នំពេញ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៨៩៥ និងបានទទួលស្វ័យភាពក្នុងឆ្នាំ ១៩៩៧។ ជាមួយនឹងការផ្តល់ហិរញ្ញប្បទាន ៣ដំណាក់កាលពីអ្នកផ្តល់ជំនួយ ក្នុងនោះមាន JICA[56] និង AFD[57] ជាដើម រោងចក្រសម្អាតទឹកចំនួន ៤ ត្រូវបានបង្កើតឡើង ដូចជា រោងចក្រសម្អាតទឹកភូមិព្រៃក ជ្រោយចង្វារ ចំការមន និង និរោធន៍ក៏ដូចជាបណ្តាញចែកចាយធំទូលាយ សម្រាប់ផ្គត់ផ្គង់ទឹកដល់ទីក្រុងភ្នំពេញទាំងមូល។ ៨ ទៅ ១០% នៃថ្លៃសេវាដែលប្រមូលបាន ត្រូវកាត់ទៅឱ្យសាលារាជធានីភ្នំពេញ និងប្រើប្រាស់ជាថវិកាសម្រាប់ដំណើរការប្រព័ន្ធរំដោះទឹកភ្លៀង និងប្រព័ន្ធលូទឹកស្អុយ។ ខណៈពេលដែលការផ្គត់ផ្គង់ក្នុងទីក្រុងភ្នំពេញបានទទួលជោគជ័យ ចាំបាច់ត្រូវមានការពង្រីកបណ្តាញចែកចាយដើម្បីផ្គត់ផ្គង់ដល់តំបន់អភិវឌ្ឍន៍ថ្មីៗនៅជាយក្រុង ដែលនៅកំពុងជួបប្រទះនឹងការខ្វះការផ្គត់ផ្គង់ទឹកស្អាតនៅឡើយ។[58]

### ង. ការគ្រប់គ្រងសំណល់រឹង ក្នុងទីក្រុងភ្នំពេញ

#### ១). ការប្រមូលសំរាម

កាលពីមុន ការប្រមូលសំណល់រឹង ក្នុងទីក្រុងភ្នំពេញ គ្រប់គ្រងផ្តាច់មុខដោយក្រុមហ៊ុនឯកជនក្នុងស្រុកមួយឈ្មោះ CINTRI ដែលបានទទួលកិច្ចសន្យាផ្តល់សេវាផ្តាច់មុខរយៈពេល ៤៩ឆ្នាំ ជាមួយរដ្ឋាភិបាល។ ក៏ប៉ុន្តែកាលពីថ្មីៗនេះ រដ្ឋបាលរាជធានីភ្នំពេញបានចេញសេចក្តីជូនដំណឹងពីការផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូន

[55] របាយការណ៍ ស្តីពី ការអភិវឌ្ឍទីក្រុង រាជធានីភ្នំពេញ ប្រទេសកម្ពុជា , ក្រុមការងារធនាគារពិភពលោក ទំព័រទី ៣៥

[56] Japan International Cooperation Agency

[57] Agence Française de Développement

[58] របាយការណ៍ ស្តីពី ការអភិវឌ្ឍទីក្រុង រាជធានីភ្នំពេញ ប្រទេសកម្ពុជា , ក្រុមការងារធនាគារពិភពលោក ទំព័រទី ៣៦

សំរាម សំណល់រឹង នៅរាជធានីភ្នំពេញដោយប្រតិបត្តិករថ្មីដោយចែកទៅតាមតំបន់ចំនួន ៣។ ក្រុមហ៊ុនទាំង ៣ នោះមានៈ

- ក្រុមហ៊ុន 800 Super/GAEA ផ្តល់សេវានៅតំបន់ទី១ ដែលមាន ៥ខណ្ឌ គឺ ខណ្ឌទួលគោក ខណ្ឌឫស្សីកែវ ខណ្ឌសែនសុខ ខណ្ឌជ្រោយចង្វារ និងខណ្ឌព្រែកព្នៅ
- ក្រុមហ៊ុន Mizuda ផ្តល់សេវានៅតំបន់ទី២ ដែលមាន ៥ខណ្ឌ គឺ ខណ្ឌដូនពេញ ខណ្ឌ៧មករា ខណ្ឌដង្កោ ខណ្ឌពោធិ៍សែនជ័យ និងខណ្ឌកំបូល
- ក្រុមហ៊ុន CINTRI ផ្តល់សេវានៅតំបន់ទី២ ដែលមាន ៤ខណ្ឌ គឺ ខណ្ឌចំការមន ខណ្ឌបឹងកេងកង ខណ្ឌមានជ័យ និងខណ្ឌច្បារអំពៅ។[59]

មានការប៉ាន់ស្មានថា មានសំណល់រឹងពី ១០០ ដល់ ២០០តោន ត្រូវបានគេទុកចោលមិនប្រមូលជារៀងរាល់ថ្ងៃក្នុងទីក្រុងភ្នំពេញ។ នៅតាមតំបន់ដែលពុំមានការផ្តល់សេវាគ្រប់គ្រាន់ ឬពុំមានសេវាប្រមូលសំរាមទៅដល់តែម្តង ប្រជាពលរដ្ឋនាំគ្នាដុត ឬកប់សំរាមចោល ឬយកសំរាមទៅចោលតាមផ្លូវ ឬក្នុងប្រឡាយទឹក។ ការចោលសំរាមក្នុងប្រឡាយទឹក ធ្វើឱ្យបញ្ហាពាក់ព័ន្ធនឹងប្រព័ន្ធរំដោះទឹកភ្លៀង និងប្រព័ន្ធការពារទឹកជំនន់ កាន់តែធ្ងន់ធ្ងរមួយកម្រិតទៀត។[60]

### ២). ការធ្វើប្រព្រឹត្តកម្មសំរាម និងការចោលសំរាមចុងក្រោយ

ក្រៅពីបញ្ហាដូចលើកឡើងខាងលើ ទីក្រុងនេះក៏ខ្វះទីតាំងសម្រាប់ចោលសំរាមផងដែរ។ ក្នុងឆ្នាំ២០០៩ ទីលានចាក់សំរាមថ្មីទំហំ ៣១ ហិចតា ក្នុងទីក្រុងភ្នំពេញ បានបើកឱ្យដំណើរការជាមួយនឹងអាយុកាលប្រើប្រាស់ ២៥ ឆ្នាំ។ ប៉ុន្តែក្រោយពីបានដំណើរការរយៈពេល ៥ ឆ្នាំដំណាក់កាលទីមួយ ដែលមានផ្ទៃដី១៤ ហិចតា ត្រូវបានចាក់សំរាមពេញអស់។ ដំណាក់កាលទីពីរ ជាមួយនឹងផ្ទៃដី១៧ ហិចតា បានចាប់ផ្តើម តាំងពីឆ្នាំ ២០១៥ មកម្ល៉េះ ប៉ុន្តែការព្យាករក្នុងកំឡុងឆ្នាំ២០១៧ បង្ហាញថា កន្លែងចាក់សំរាមដែលនៅសល់នេះគឺគ្រប់គ្រាន់តែ រយៈពេល ៥ឆ្នាំទៀតប៉ុណ្ណោះ ពោលគឺបានតែពាក់កណ្តាលនៃអាយុកាលដែលបានគ្រោងទុកប៉ុណ្ណោះ។ ទីក្រុងនេះកំពុងជួបការលំបាកជាមួយនឹងបរិមាណ និងសមាសភាគចម្រុះ នៃសំរាមដែលមានជារៀងរាល់ថ្ងៃ ដែលបានកើនឡើងពីប្រមាណជា ៨០០ តោន ក្នុងមួយថ្ងៃក្នុងឆ្នាំ២០០៩ ដល់ ១ ៤៧៥ តោន ក្នុងមួយថ្ងៃក្នុងឆ្នាំ២០១៤។[61]

[59] សេចក្តីជូនដំណឹងរបស់រដ្ឋបាលរាជធានីភ្នំពេញ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ស្តីពី ការចាប់ផ្តើមអនុវត្តការផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង នៅរាជធានីភ្នំពេញដោយប្រតិបត្តិករថ្មី

[60] របាយការណ៍ ស្តីពី ការអភិវឌ្ឍទីក្រុង រាជធានីភ្នំពេញ ប្រទេសកម្ពុជា , ក្រុមការងារធនាគារពិភពលោក ទំព័រទី ៣៧

[61] ការកែទម្រង់ការគ្រប់គ្រងសំណល់រឹង នៅទីក្រុងភ្នំពេញ , មូលនិធិអាស៊ី វិទ្យាស្ថានអភិវឌ្ឍន៍ក្រៅប្រទេស ឆ្នាំ២០១៦

### ច. ការផ្គត់ផ្គង់លំនៅឋាន និងការអភិវឌ្ឍអចលនទ្រព្យ

ការអភិវឌ្ឍ និងការពង្រីកទីក្រុងយ៉ាងឆាប់រហ័ស និងការហូរចូលយ៉ាងគំហុកនូវការវិនិយោគដោយផ្ទាល់ពីបរទេស (FDI)[62] នាំឱ្យមានការអភិវឌ្ឍអចលនទ្រព្យក្នុងទីក្រុងភ្នំពេញ។ ក្នុងទីក្រុងភ្នំពេញ ក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យ និងក្រុមហ៊ុនម៉ៅការសាងសង់ ត្រូវការលិខិតអនុញ្ញាតសាងសង់ ពីស្ថាប័នពាក់ព័ន្ធទៅតាមទំហំនៃការអភិវឌ្ឍ និងកម្ពស់នៃអគារទើបអាចធ្វើការសាងសង់បាន [63] ដែលនេះជាផ្នែកមួយនៃនីតិវិធីផ្តល់ការអនុញ្ញាតដល់គម្រោងទាំងនេះ មានការពិនិត្យផ្ទៀងផ្ទាត់លើកម្មសិទ្ធិដីធ្លី និងបច្ចេកទេសសំណង់បន្តិចបន្តួច ប៉ុន្តែពុំមានការពិចារណាអំពីការប្រើប្រាស់ដីធ្លី ឬអនុលោមទៅតាមប្លង់គោលរបស់ទីក្រុងឡើយ។ ម្យ៉ាងទៀត ផលប៉ះពាល់ និងវិធានការកាត់បន្ថយផលប៉ះពាល់ដល់ការអភិវឌ្ឍថ្មីៗទាំងនេះមានមកលើហេដ្ឋារចនាសម្ព័ន្ធរបស់ទីក្រុង ដូចជាចរាចរណ៍ ផ្ទៃដីសម្រាប់សាធារណៈ ប្រព័ន្ធលូរំដោះទឹកភ្លៀង និងការសម្អាតទឹកស្អុយ មិនត្រូវបានគេយកមកគិតពិចារណាឡើយ។

ប្រទេសកម្ពុជាបានទទួលស្គាល់ កង្វះលំនៅឋានដែលមានតម្លៃសមរម្យថាជាបញ្ហា និងបានដាក់ចេញគោលនយោបាយជាតិស្តីពីលំនៅឋានកាលពីឆ្នាំ២០១៤ ដែលចែងថា ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិទទួលបានលំនៅឋានសមរម្យ និងផ្តល់នូវជម្រើសផ្សេងៗ សម្រាប់ធានាសិទ្ធិកាន់កាប់ និងកម្មសិទ្ធិដីធ្លី។ គោលនយោបាយនេះមានគោលបំណងផ្តល់លំនៅឋាន សមរម្យដល់គ្រួសារដែលមានចំណូលទាប និងមធ្យម និងដល់ក្រុមងាយរងគ្រោះ ប៉ុន្តែការអនុវត្តមានភាពយឺតយ៉ាវ ហើយប្រជាពលរដ្ឋក្រីក្រជាច្រើននាក់ និងប្រជាពលរដ្ឋដែលតាំងទីលំនៅនៅតំបន់មិនរៀបរយនៅតែប្រឈមនឹងភាពងាយរងគ្រោះ។[64]

## ១.២. ការរៀបចំរាជធានីភ្នំពេញឱ្យមានសណ្តាប់ធ្នាប់ និងសោភណភាព

ការរៀបចំក្រុងប្រកបដោយបច្ចេកទេស ត្រូវបានសង្កេតឃើញថាឈរលើគោលការណ៍សសរស្តម្ភចំនួន ៥ គឺ ផលិតភាព និរន្តរភាព ភាពដែលអាចរស់នៅបាន ភាពជាអ្នកដឹកនាំ និងការរចនាដ៏ល្អប្រសើរ ពោលគឺថាត្រូវធ្វើយ៉ាងណាបង្កើតកន្លែងមួយដែលមានផលិតភាព និរន្តរភាព និងភាពអាចរស់នៅបានតាមរយៈភាពជាអ្នកដឹកនាំ និងការរួមបញ្ចូលគ្នានៃការរចនាក្រុងមួយដ៏ល្អប្រសើរ។[65]

---

[62] Foreign Direct Investment

[63] អនុក្រឹត្យលេខ ២២៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពី លិខិតអនុញ្ញាតសាងសង់គ្រប់ប្រភេទ

[64] របាយការណ៍ ស្តីពី ការអភិវឌ្ឍទីក្រុង រាជធានីភ្នំពេញ ប្រទេសកម្ពុជា, ក្រុមការងារធនាគារពិភពលោក ទំព័រទី ៤០

[65] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២០ ទំព័រទី ១៣

### ១.២.១. ធាតុផ្សំនៃសណ្តាប់ធ្នាប់

នាពេលបច្ចុប្បន្ននេះ ការរៀបចំសណ្តាប់ធ្នាប់ក្នុងទីក្រុងត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំងពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច និងពីសំណាក់ប្រជាពលរដ្ឋផ្ទាល់ ដោយសារតែគុណភាពនៃការរស់នៅរបស់មនុស្សកាន់តែមានការរីកចម្រើនទៅមុខៗ។ ទីក្រុងមួយដែលមានការរៀបចំសណ្តាប់ធ្នាប់ល្អប្រសើរ រមែងធ្វើឱ្យអ្នករស់នៅក្នុងទីក្រុងនោះមានផាសុកភាព មានសេចក្តីសុខទាំងផ្លូវកាយ និងផ្លូវចិត្ត ហើយសណ្តាប់ធ្នាប់នេះទៀតសោត ក៏ជាចំណែកមួយដ៏ធំក្នុងការទាក់ទាញភ្ញៀវទេសចរ និងវិនិយោគិនផងដែរ។

សណ្តាប់ធ្នាប់នៅក្នុងទីក្រុងមានធាតុផ្សំ ៣ គឺ សន្តិសុខ ភាពស្ងប់ស្ងៀម និងអនាម័យ។

#### ១.២.១.១. សន្តិសុខ

**ក. សុវត្ថិភាពបុគ្គល**

ជាការពិតណាស់ មនុស្សគ្រប់ៗរូបតែងតែចង់បាននូវសុវត្ថិភាពផ្ទាល់ខ្លួន។ ដើម្បីធានា និងការពារដល់សន្តិសុខសុវត្ថិភាពជូនប្រជាពលរដ្ឋបាន អាជ្ញាធរពាក់ព័ន្ធត្រូវគិតគូររៀបចំចំពោះសុវត្ថិភាពក្នុងការដើរហើររបស់ប្រជាជនដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគោលនយោបាយ "ភូមិ-ឃុំ មានសុវត្ថិភាព" ដោយការពារកុំឱ្យមានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ, គ្មានក្មេងទំនើង, គ្មានការដាំដុះ ការផលិត ការចរាចរ ការជួញដូរ ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់, គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ, គ្មានការប្រើប្រាស់អាវុធខុសច្បាប់គ្រប់ប្រភេទ និងបទល្មើសគ្រប់ប្រភេទជាដើម។[66]

ជាងនេះទៅទៀត អាជ្ញាធរត្រូវយកចិត្តទុកដាក់ក្នុងការរក្សានូវសុវត្ថិភាពចរាចរណ៍របស់ប្រជាពលរដ្ឋតាមរយៈការអប់រំប្រជាពលរដ្ឋអនុវត្តតាមច្បាប់ចរាចរណ៍ផ្លូវគោកឱ្យបានខ្ជាប់ខ្ជួន និងដាក់វិធានការក្នុងការពិន័យប្រជាពលរដ្ឋដែលល្មើសច្បាប់ឱ្យបានតឹងរ៉ឹង។

**ខ. សម្ភារៈ**

ដូចគ្នានឹងសុវត្ថិភាពបុគ្គលដែរ សុវត្ថិភាពខាងផ្នែកសម្ភារៈក៏ជាផ្នែកមួយ ដែលត្រូវការអាជ្ញាធរពាក់ព័ន្ធយកចិត្តទុកដាក់ ព្រោះប្រសិនបើប្រជាពលរដ្ឋបាត់បង់សម្ភារៈ ទ្រព្យសម្បត្តិច្រើនវាអាចនឹងបង្កជាក្តីកង្វល់ដល់ពួកគាត់ ហើយអំពើនេះអាចបង្កអសន្តិសុខដល់សង្គមផងដែរ។ ដូចគ្នានឹងសុវត្ថិភាពបុគ្គល កត្តាដែលនាំឱ្យមានសុវត្ថិភាពខាងផ្នែកសម្ភារៈ លុះត្រាតែក្នុងមូលដ្ឋាននោះអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគោលនយោបាយ "ភូមិ-ឃុំ មានសុវត្ថិភាព"។

[66] ផែនការណែនាំ លេខ ០២២ ជក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១២ ស្តីពី ការចាត់តាំងអនុវត្តគោលនយោបាយ "ភូមិ-ឃុំមានសុវត្ថិភាព", ទំព័រទី ២

**គ. ចំណីអាហារ**

ការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារ គឺជាសមត្ថកិច្ចរបស់ អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) នៃក្រសួងពាណិជ្ជកម្មដែលមានសាខាកាំកុងត្រូលរាជធានី-ខេត្តជាសេនាធិការ។ ការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារ គឺដើម្បីធានាឱ្យបាននូវសុវត្ថិភាព និងសុខភាពរបស់អ្នកប្រើប្រាស់ និងអ្នកបរិភោគឱ្យតាមស្តង់ដារជាតិនូវរាល់ទំនិញដែលនាំចូលមកក្នុងប្រទេស និងរាល់ទំនិញដែលចរាចរនៅលើទីផ្សារ។[67]

បន្ថែមពីនេះ នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាងនៃក្រសួងសុខាភិបាលក៏បានអនុវត្តនូវវិធានការក្នុងការវាយតម្លៃគោលការណ៍អនុវត្តអនាម័យល្អ និងផ្តល់វិញ្ញាបនបត្រដល់ភោជនីយដ្ឋាន និងអាហារដ្ឋាន ដោយផ្អែកតាមគោលការណ៍ស្ម័គ្រចិត្ត។ វិធានការនេះមានគោលបំណងការពារសុខភាពមនុស្ស និងធានាអនាម័យ និងសុវត្ថិភាពចំណីអាហារនៅតាមភោជនីយដ្ឋាន និងអាហារដ្ឋាន ដោយអនុលោមតាមកម្រិតហានិភ័យ ដើម្បីជម្រុញឱ្យមានការប្រកួតប្រជែងនៅក្នុងអាជីវកម្មចំណីអាហារ។[68]

**១.២.១.២. ភាពស្ងប់ស្ងៀម**

ភាពស្ងប់ស្ងៀម សំដៅដល់ទីតាំងមួយដែលពុំមានការបំពុលដោយសំឡេង។ ដើម្បីទទួលបានការរៀបចំទីក្រុងមួយដែលគ្មានការបំពុលនេះ អាជ្ញាធរពាក់ព័ន្ធ មុននឹងរៀបចំប្លង់គោលនៃការអភិវឌ្ឍក្រុងត្រូវបែងចែកទីតាំងដែលអាចបង្កជាការរំខានដោយសំឡេងខ្លាំងៗ ដូចជា កន្លែងកម្សាន្ត ក្លឹប បារ ខារ៉ាអូខេ នានា ឱ្យនៅដាច់ពីតំបន់រស់នៅរបស់ប្រជាពលរដ្ឋ និងណែនាំដល់ម្ចាស់ទីតាំងទាំងនោះឱ្យរៀបចំប្រព័ន្ធកាត់បន្ថយសំឡេងឱ្យត្រូវតាមស្តង់ដារ និងបច្ចេកទេស។ ម្យ៉ាងវិញទៀត អាជ្ញាធរមូលដ្ឋានត្រូវតែចុះណែនាំដល់ប្រជាពលរដ្ឋដែលមានកម្មវិធីនានា ដូចជា ពិធីរៀបអាពាហ៍ពិពាហ៍ ខួបកំណើត ជប់លៀងជាដើម ដោយមិនត្រូវមានការច្រៀងរាំដល់យប់ជ្រៅពេកនោះទេ ព្រោះវាអាចបង្កជាការរំខានដល់ប្រជាពលរដ្ឋដែលនៅជិតតំបន់នោះផងដែរ។

**១.២.១.៣. អនាម័យ**

អនាម័យនៅទីនេះ សំដៅដល់ទីតាំងមួយដែលមិនមានការបំពុលទឹក ការបំពុលខ្យល់ ការបំពុលដី និងការបំពុលដោយសំណល់រឹងរាវ។ ក៏ប៉ុន្តែ នាពេលបច្ចុប្បន្ន បញ្ហាបរិស្ថាននៅតែចោទជាបញ្ហានៅឡើយដោយក្នុងនោះវាបានបង្កជាបញ្ហានានា ដែលបានផ្តល់ផលប៉ះពាល់ទៅដល់សុខភាពមនុស្ស សត្វ និងរុក្ខជាតិយ៉ាង

[67] ប្រកាសលេខ ២៣៣ ព.ណបល.ប្រក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់សាខាកាំកុងត្រូលរាជធានី-ខេត្ត , ប្រការ ១

[68] ប្រកាសលេខ១៣០៩ អបស/ឱអបស ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២ ស្តីពី បែបបទ និងលក្ខខណ្ឌសម្រាប់ផ្តល់វិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ នៅតាមភោជនីយដ្ឋាន និងអាហារដ្ឋាន

ធ្ងន់ធ្ងរដែលទាមទារឱ្យមានការបង្កើតការយកចិត្តទុកដាក់ និងរៀបចំវាឡើងវិញ ដើម្បីធ្វើយ៉ាងណាដោះស្រាយបញ្ហានេះឱ្យបានល្អប្រសើរ។

យ៉ាងណាមិញ គេក៏ឃើញមានចលនាប្រឡងប្រណាំងទីក្រុងស្អាតដែលត្រូវបានរៀបចំឡើងក្នុងគោលបំណងលើកកម្ពស់សោភណភាពបរិស្ថានអនាម័យ និងសណ្តាប់ធ្នាប់ទីក្រុង-ខណ្ឌ (២៧ទីក្រុង និង១៤ខណ្ឌនៃរាជធានីភ្នំពេញ) នៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសចូលរួមក្នុងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍នានារបស់រាជរដ្ឋាភិបាល។ ដើម្បីជាការលើកទឹកចិត្ត រាជរដ្ឋាភិបាលនឹងផ្តល់រង្វាន់ដល់ទីក្រុង-ខណ្ឌ ដែលបានខិតខំប្រឹងប្រែងក្នុងការរៀបចំ និងអភិវឌ្ឍន៍ទីក្រុងខ្លួន ពិសេសថែរក្សាការពារបរិស្ថាន និងបានជម្រុញឱ្យតួអង្គសំខាន់ៗក្នុងវិស័យទេសចរណ៍ ប្រជាពលរដ្ឋ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់បានចូលរួមចំណែកយ៉ាងសកម្មក្នុងការគ្រប់គ្រងបរិស្ថាននៅតាមបណ្តាទីក្រុង។[69]

### ១.២.២. សោភណភាព

#### ១.២.២.១. សោភណភាពពេលថ្ងៃ

សោភណភាពពេលថ្ងៃ សំដៅទៅលើការរៀបចំហេដ្ឋារចនាសម្ព័ន្ធ រួមមានសំណង់អគារតូចធំទាំងអស់ ការកសាងផ្លូវថ្នល់ ស្ពាន ប្រព័ន្ធលូ ផ្លូវក្រោមដី សួនច្បារសាធារណៈ ការរៀបចំចរាចរណ៍តាមដងផ្លូវ ដូចជាការរៀបចំភ្លើងសញ្ញា ស្លាកសញ្ញា និងគំនូសសញ្ញាចរាចរណ៍ ព្រមទាំងការរៀបចំផ្លូវឱ្យសមស្របសម្រាប់អ្នកប្រើប្រាស់ផ្លូវគ្រប់ប្រភេទ ជាពិសេសគឺផ្លូវសម្រាប់អ្នកថ្មើរជើង។

ដើម្បីធានាដល់សុវត្ថិភាពនៃការធ្វើចរាចរណ៍ ក៏ដូចជាការរៀបចំហេដ្ឋារចនាសម្ព័ន្ធសម្រាប់ផ្លូវល្បឿនលឿន ផ្លូវជាតិ និងផ្លូវខេត្ត ឱ្យមានសណ្តាប់ធ្នាប់ និងសោភណភាព ច្បាប់ស្តីពីផ្លូវថ្នល់ក៏បានកំណត់នូវចំណុចមួយចំនួនដូចខាងក្រោម៖

- ការសាងសង់សំណង់ដូចជា ស្ថានីយប្រេងឥន្ធនៈ ស្ថានីយហ្គាស កន្លែងលាងយានយន្ត យានដ្ឋាន ឬសំណង់ប្រហាក់ប្រហែលផ្សេងៗទៀត ដែលមានមនុស្សជួបជុំគ្នាមធ្យមត្រូវស្ថិតក្នុងចម្ងាយយ៉ាងតិច ១៥ ម៉ែត្រ ពីខ្សែបន្ទាត់ព្រំដីចំណីផ្លូវ
- ការកសាងសង់មជ្ឈមណ្ឌលពាណិជ្ជកម្ម ពហុកីឡដ្ឋាន ទីលានប្រកួត រោងមហោស្រព មន្ទីរពេទ្យ គ្រឹះស្ថានសិក្សា ការរៀបចំផ្សារ ផ្សារណាត់ ពិព័រណ៍ទំនិញ ឬកិច្ចការផ្សេងទៀតដែលមានមនុស្សជួបជុំគ្នាច្រើន ត្រូវស្ថិតក្នុងចម្ងាយយ៉ាងតិចបំផុត ៥០ម៉ែត្រ ពីខ្សែបន្ទាត់ព្រំដីចំណីផ្លូវថ្នល់។[70]

[69] ដកស្រង់ពីគេហទំព័រ គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត http://www.cambodiacleancity.gov.kh/kh ចូលមើលថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២០

[70] ច្បាប់ ស្តីពី ផ្លូវថ្នល់ លេខ នស/រកម/០៥១៤/008 ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៤ , មាត្រា ៣០

លើសពីនេះ ដើម្បីអាចរៀបចំហេដ្ឋារចនាសម្ព័ន្ធឱ្យកាន់តែមានសោភណភាព លុះត្រាតែក្រុងនោះគោរពតាមប្លង់គោល និងប្រើប្រាស់ដីធ្លីនៃក្រុងនីមួយៗ ដែលប្លង់គោលនេះមានសារៈសំខាន់ជាខ្លាំងចំពោះនយោបាយនគរូបនីយកម្ម ឬអាចនិយាយបានថាជាឯកសារដែលមិនអាចខ្វះបានក្នុងនយោបាយនគរូបនីយកម្ម ក៏ដូចជាការអភិវឌ្ឍប្រទេស។

**១.២.២.២. សោភណភាពពេលយប់**

សោភណភាពនាពេលយប់ជាកត្តាមួយដែលទាក់ទាញយ៉ាងសំខាន់ ដែលអាជ្ញាធរពាក់ព័ន្ធត្រូវយកចិត្តទុកដាក់។ ដើម្បីទាក់ទាញប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងភ្ញៀវទេសចរក្នុងទីក្រុងនាពេលរាត្រី អាជ្ញាធរត្រូវរៀបចំការតុបតែង លម្អ និងបំពាក់ភ្លើងបំភ្លឺនៅតាមទីតាំងមួយចំនួនខាងក្រោម៖

- សំណង់អគារតូចធំទាំងអស់របស់ស្ថាប័ន អង្គភាពសាធារណៈ និងគ្រឹះស្ថានរដ្ឋ និងឯកជន
- សួនច្បារសាធារណៈ និងនៅតាមកន្លែងកម្សាន្តនានា
- ផ្លូវក្រោមដី និងប្រព័ន្ធសុវត្ថិភាពចរាចរណ៍រួមមាន ភ្លើងសញ្ញា ស្លាកសញ្ញា និងគំនូសសញ្ញាចរាចរណ៍រួមទាំងតាមបណ្តាដងផ្លូវនៃយានយន្តគ្រប់ប្រភេទ ព្រមទាំងផ្លូវថ្មើរជើង។[71]

**១.២.៣. ផែនការយុទ្ធសាស្ត្រ ក្នុងការរៀបចំសណ្តាប់ធ្នាប់ និងសោភណភាពនៅក្នុងរាជធានីភ្នំពេញ**

**១.២.៣.១. ការប្រើប្រាស់ចិញ្ចើមផ្លូវសាធារណៈ**

ចិញ្ចើមផ្លូវអាចយកទៅប្រើប្រាស់សម្រាប់បម្រើសកម្មភាពក្នុងគោលបំណងដូចខាងក្រោម៖

- បម្រើដល់ការធ្វើចរាចរណ៍ដោយថ្មើរជើង
- បម្រើសកម្មភាពដូចជា សកម្មភាពវប្បធម៌ កីឡា ការតាំងពិព័រណ៍ និងពិធីបុណ្យផ្សេងៗនៅលើដងផ្លូវ ប៉ុន្តែត្រូវមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ទៅតាមកម្រិតនៃពិធី និងតាមភាពចាំបាច់
- បម្រើសកម្មភាពជីកកប់បណ្តាញក្រោមដី ដូចជាបណ្តាញទឹកស្អាត ប្រព័ន្ធលូ ខ្សែបញ្ជូនអគ្គិសនី បំពង់ទុយោខ្សែកាបអុបទិកគ្រប់ប្រភេទ និងបរិក្ខារក្រោមដីផ្សេងៗទៀត
- បម្រើសកម្មភាពសាងសង់ ក្នុងគម្រោងចាំបាច់មួយចំនួន ដូចជាបរិក្ខារបម្រើឱ្យវិស័យការពារជាតិ សន្តិសុខជាតិ បរិក្ខារបម្រើឱ្យការគ្រប់គ្រង ឬការសាងសង់ផ្លូវ និងបរិក្ខារសំណង់សេវាសាធារណៈផ្សេងៗទៀត តាមការចាំបាច់

[71] សៀវភៅ នីតិនគរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២០ ទំព័រទី ១

- ក្រៅអំពីសកម្មភាពខាងលើ ការប្រើប្រាស់ចិញ្ចើមផ្លូវជាប្រយោជន៍ឯកជន ទោះក្នុងគោលបំណងណាក៏ដោយ ត្រូវចាត់ទុកជាសកម្មភាពខុសច្បាប់ ប្រសិនបើពុំមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអាជ្ញាធរមានសមត្ថកិច្ច។

**១.២.៣.២. ការរៀបចំសណ្តាប់ធ្នាប់តាមបណ្តោយមហាវិថីអាទិភាព**

កន្លងមក រដ្ឋបាលរាជធានីភ្នំពេញ បានចេញសេចក្តីណែនាំ ស្តីពីការរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ និងការប្រើប្រាស់ចិញ្ចើមផ្លូវសាធារណៈ ព្រមទាំងសេចក្តីណែនាំស្តីពីការដោះស្រាយចរាចរណ៍ និងរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ដោយជ្រើសរើសផ្លូវចំនួន ១១ខ្សែ[72] ជាអាទិភាពគំរូសម្រាប់អនុវត្តវិធានការ។ វិធានការទាំងអស់នេះរួមមាន៖

**ក. វិធានការចំពោះប្រជាពលរដ្ឋ ម្ចាស់លំនៅឋាន ម្ចាស់អាជីវកម្ម ម្ចាស់ការដ្ឋាន មន្ទីរពេទ្យ សាលារៀនវិស័យឯកជន អគារសាធារណៈ និងអ្នកប្រើប្រាស់ផ្លូវថ្នល់**

ដើម្បីដោះស្រាយបញ្ហាចរាចរណ៍ និងរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវអាទិភាព រដ្ឋបាលរាជធានីភ្នំពេញ បានដាក់ចេញនូវសេចក្តីណែនាំដូចជា៖

- ចៀសវាងដាច់ខាតការឈប់ ឬចតយានជំនិះនៅកន្លែងហាមឃាត់ដូចជានៅលើទ្រូងផ្លូវ ចិញ្ចើមផ្លូវដែលបម្រុងទុកឱ្យអ្នកថ្មើរជើង និងនៅគ្រប់ទីកន្លែងដែលធ្វើឱ្យរាំងស្ទះដល់ច្រកចេញ-ចូលការចត ឬការឈប់នៃយានជំនិះដទៃទៀត ឬច្រកចេញចូលនៃអគារសាធារណៈ ឬកន្លែងឯកជនជិតផ្លូវប្រសព្វ ឬផ្លូវបត់
- ហាមការចតពីរជួរ ឬច្រើនជួរទន្ទឹមគ្នា និងនៅកន្លែងដែលមានសញ្ញាហាមឈប់ ឬហាមចត
- ហាមដាច់ខាត មិនឱ្យម្ចាស់ការដ្ឋានសំណង់គ្រប់ប្រភេទ ធ្វើការហ៊ុមព័ទ្ធការដ្ឋាននៅចិញ្ចើមផ្លូវលើសពី ១/៣ និង/ឬប្រើប្រាស់ទ្រូងផ្លូវ ដើម្បីទុកសម្ភារៈសំណង់របស់ខ្លួនដូចជា ដែក ខ្សាច់ គ្រួស ថ្ម ជាដើម
- រថយន្តដឹកទំនិញធំៗ រថយន្តកុងតឺន័រ រថយន្តបាញ់បេតុង រថយន្តក្រឡុកស៊ីម៉ង់ត៍ត្រូវចេញ-ចូលគោរពតាមការណែនាំរបស់រដ្ឋបាលរាជធានីភ្នំពេញ និងចៀសវាងការប្រើប្រាស់ទ្រូងផ្លូវក្នុងការលើកដាក់ផ្ទេរទំនិញ និងបាញ់បេតុង។ ក្នុងការចៀសវាងមិនបាន ត្រូវអនុវត្តការលើកដាក់ទំនិញ និងការបាញ់បេតុងចាប់ពីម៉ោង ២១:០០នាទី រហូតដល់ម៉ោង ៦:០០នាទី ព្រឹក។ ក្នុងករណីចាំបាច់បម្រើឱ្យការងារសំណង់ម្ចាស់ការដ្ឋាន ត្រូវណែនាំដល់អ្នកបើករថយន្តទាំងនោះ ត្រូវចតរថយន្តរបស់ខ្លួនឱ្យមានសណ្តាប់ធ្នាប់ដាក់ផ្លាកសញ្ញាការដ្ឋាន និងត្រូវរៀបចំកម្លាំងដើម្បីជួយសម្រួលចរាចរណ៍

[72] ផ្លូវអាទិភាពគំរូរួមមាន៖ ១. មហាវិថីសហព័ន្ធរុស្ស៊ី, ២. មហាវិថីព្រះមុនីវង្ស, ៣. មហាវិថីកម្ពុជាក្រោម, ៤. មហាវិថីម៉ៅសេទុង, ៥. មហាវិថីព្រះសីហនុ និងមហាវិថីនេរុហ៍, ៦. មហាវិថីព្រះនរោត្តម, ៧. មហាវិថីសម្តេចមុនីរ៉េត, ៨. ផ្លូវឧកញ៉ាទេពផន, ៩. មហាវិថីហ្សាលឌីហ្គោល, ១០. មហាវិថីយោធពលខេមរភូមិន្ទ (ផ្លូវ ២៧១) និងផ្លូវឧកញ៉ាឃ្លាំងមឿង (ផ្លូវលេខ ៧០) និង ១១. តីរវិថីព្រះស៊ីសុវត្ថិ។

- ការរៀបចំសម្ភារៈ ទំនិញ ម៉ូតូ និងរថយន្តដាក់តាំងលក់ អាចប្រើប្រាស់ចំណែកចិញ្ចើមផ្លូវត្រឹម ១/៣ ជាលក្ខណៈបណ្ដោះអាសន្នតែប៉ុណ្ណោះ ដោយទុក ២/៣ សម្រាប់ថ្មើរជើង និងបម្រើឱ្យការងារសណ្ដាប់ធ្នាប់ និងចរាចរណ៍
- រាល់ការប្រើប្រាស់ចិញ្ចើមផ្លូវជាទីតាំងផ្ញើកង់ម៉ូតូមិនត្រូវឱ្យលើសពី ១/៣ ឡើយ
- ហាមឃាត់ការធ្វើរោងបុណ្យ រោងអាពាហ៍ពិពាហ៍ និងកម្មវិធីផ្សេងៗ ចាប់ពីថ្ងៃ០១ ខែកក្កដា ឆ្នាំ២០១៩ ទៅ ដោយរដ្ឋបាលរាជធានីភ្នំពេញតម្រូវឱ្យប្រជាពលរដ្ឋ រកទីតាំងឯកជន ឬទីតាំងសមស្របណាមួយជំនួសការប្រើប្រាស់ចិញ្ចើមផ្លូវ ឬទ្រូងផ្លូវណាមួយដើម្បីធ្វើកម្មវិធីជាលក្ខណៈឯកជននៅលើចិញ្ចើមផ្លូវ ឬទ្រូងផ្លូវ។[73]

**ខ. តួនាទីគណៈបញ្ជាការឯកភាពខណ្ឌ**

យោងតាមសេចក្ដីណែនាំខាងលើនេះទៀតសោត គណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌមានតួនាទីត្រូវអនុវត្តនូវចំណុចខាងក្រោមៈ

- ត្រូវចុះធ្វើការណែនាំដល់ប្រជាពលរដ្ឋដែលបាន និងកំពុងប្រើប្រាស់ទ្រូងផ្លូវ ចិញ្ចើមផ្លូវដោយរំលោភបំពាន ដោយប្រើប្រាស់វិធីសាស្ត្រទន់ភ្លន់ តែម៉ឺងម៉ាត់ ឱ្យចូលរួមអនុវត្តតាមសេចក្ដីណែនាំ
- គ្រប់ករណីនៅតែមិនអនុវត្តតាមការណែនាំ មន្ត្រីអនុវត្តត្រូវធ្វើកំណត់ហេតុ និងចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន
- ត្រូវណែនាំដល់ម្ចាស់ទីតាំងភោជនីយដ្ឋាន និងម្ចាស់ទីតាំងអាជីវកម្មនានាឱ្យគោរពតាមសេចក្ដីណែនាំខាងលើ។ ក្នុងករណីពុំព្រមអនុវត្តតាម អាជ្ញាធរខណ្ឌត្រូវសហការជាមួយកម្លាំងមានសមត្ថកិច្ច និងជំនាញពាក់ព័ន្ធដើម្បីធ្វើការផាកពិន័យតាមច្បាប់ និងអាចឈានទៅដល់ការបិទទីតាំងអាជីវកម្ម
- ត្រូវធ្វើការណែនាំ និងធ្វើកំណត់ហេតុឱ្យបានត្រឹមត្រូវជាមួយម្ចាស់ការដ្ឋានដែលរំលោភបំពានទ្រូងផ្លូវ និងចិញ្ចើមផ្លូវ ក្នុងករណីមិនរាងចាលត្រូវផ្អាកការដ្ឋាននោះភ្លាម
- ត្រូវចុះល្បាត និងឃ្លាំមើលជាប្រចាំចំពោះរថយន្តដឹកទំនិញធំៗ រថយន្តកុងតឺន័រ រថយន្តបាញ់បេតុង និងរថយន្តក្រឡុកស៊ីម៉ង់ត៍ និងត្រូវមានវិធានការឱ្យបានម៉ឺងម៉ាត់ក្នុងករណីចេញ-ចូលរាជធានីភ្នំពេញ ខុសពីសេចក្ដីណែនាំរបស់រដ្ឋបាលរាជធានីភ្នំពេញ
- រៀបចំផែនការចុះរុះរើការសាងសង់សំណង់ឯកជន ការតសំយ៉ាបដំបូលផ្ទះ ការហ៊ុមព័ទ្ធចិញ្ចើមផ្លូវ និងបញ្ឈប់ការប្រើប្រាស់ចិញ្ចើមផ្លូវដែលរំលោភបំពាន

[73] សេចក្ដីណែនាំ លេខ ០១៣/១៨ សណន ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ ស្ដីពី ការរៀបចំសណ្ដាប់ធ្នាប់តាមដងផ្លូវ និងការប្រើប្រាស់ចិញ្ចើមផ្លូវសាធារណៈទាំងអស់នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ

- បង្កើតក្រុមការងាររៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ និងប្រើប្រាស់ចិញ្ចើមផ្លូវសាធារណៈទាំងអស់នៅក្នុងភូមិសាស្ត្រនៃខណ្ឌដោយមានអភិបាលនៃគណៈអភិបាលខណ្ឌជាប្រធាន។ ក្រុមការងារនេះមានតួនាទី និងភារកិច្ចទទួលខុសត្រូវក្នុងការរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ និងត្រូវធានាការប្រើប្រាស់ចិញ្ចើមផ្លូវឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងសមស្របទៅនឹងសកម្មភាពប្រើប្រាស់។[74]

**គ. តួនាទីស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ និងបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ**

ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ និងបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ ក៏មានតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមពង្រឹងចរាចរណ៍ និងរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវផងដែរ ដោយត្រូវ៖

- បន្ថែមកម្លាំងនគរបាលចរាចរណ៍ ដោះស្រាយបញ្ហាចរាចរណ៍តាមគោលដៅដែលមានការកកស្ទះនៅចន្លោះម៉ោងមមាញឹក គឺនៅម៉ោង ៧:៣០នាទី ដល់ម៉ោង ៨:៣០នាទី, ម៉ោង១១:៣០នាទី ដល់ម៉ោង ១២:៣០នាទី និងម៉ោង ១៧:០០នាទី ដល់ម៉ោង ១៨:៣០នាទី
- រៀបចំរថយន្តស្ទូច ដើម្បីសហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌ ដើម្បីអនុវត្តវិធានការច្បាប់។

ជាឧទាហរណ៍ជាក់ស្តែងនៃការអនុវត្តរបស់រដ្ឋបាលរាជធានីភ្នំពេញកន្លងមក ដើម្បីរក្សាបាននូវការរៀបចំសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ រដ្ឋបាលរាជធានីភ្នំពេញក៏បានសម្រេចតុបតែងលម្អសោភណភាពនៅតាមដងមហាវិថីព្រះនរោត្តម ដោយសារមហាវិថីនេះជាចំណុចស្នូលនៃខណ្ឌដូនពេញ ក៏ដូចជារាជធានីភ្នំពេញទាំងមូល។ រដ្ឋបាលខណ្ឌបានរៀបចំឱ្យមានផ្លូវសម្រាប់អ្នកថ្មើរជើង ផ្លូវសម្រាប់ជនពិការ ផ្លូវសម្រាប់អ្នកជិះកង់ ព្រមទាំងដាំដើមឈើតាមដងមហាវិថីផងដែរ។ យ៉ាងណាមិញ ការរៀបចំនេះនៅពុំទាន់មានភាពរលូននៅឡើយដោយសារការប្រើប្រាស់ចិញ្ចើមផ្លូវខុសច្បាប់ ហេតុនេះ រដ្ឋបាលខណ្ឌនៅតែបន្តចាត់វិធានការរឹតបន្តឹងលើម្ចាស់អាជីវកម្ម ស្ថាប័នរដ្ឋ ឯកជន ដែលបានកំពុងចតរថយន្ត ម៉ូតូ នៅលើចិញ្ចើមផ្លូវសម្រាប់អ្នកថ្មើរជើង និងសម្រាប់ជនពិការ។

ទន្ទឹមនឹងនេះ រដ្ឋបាលខណ្ឌដូនពេញក៏បានសម្រេចដាក់ចេញជាគោលការណ៍មួយចំនួន ដើម្បីធានានូវសោភណភាព និងសុវត្ថិភាពសម្រាប់ប្រជាពលរដ្ឋក្នុងការដំណើរឆ្លងកាត់ ព្រមទាំងបញ្ចៀសការកកស្ទះចរាចរណ៍ដូចខាងក្រោម៖

- មិនអនុញ្ញាតឱ្យមានការចតរថយន្ត ម៉ូតូ គ្រប់ប្រភេទនៅលើចិញ្ចើមផ្លូវសាធារណៈ និងផ្លូវសម្រាប់អ្នកថ្មើរជើង (ដែលក្នុងនោះចំណុចគំនូសពណ៌លឿងមកដល់ជញ្ជាំងផ្ទះប្រជាពលរដ្ឋ ឬរបងស្ថាប័នរដ្ឋ/ឯកជន

[74] សេចក្តីណែនាំ លេខ ០០៧/១៧ សណន.ច ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧ ស្តីពី ការដោះស្រាយចរាចរណ៍ និងរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ

គឺទុកសម្រាប់ជនពិការ ក៏ដូចជារទេះជនពិការធ្វើដំណើរឆ្លងកាត់ និងមួយផ្នែកទៀតពីគំនូសពណ៌លឿងមកដល់ចិញ្ចើមផ្លូវត្រូវរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើដំណើរឆ្លងកាត់)

- នៅខាងមុខនៃទីតាំងអាជីវកម្មនីមួយៗ ត្រូវមានចំណតផ្ទាល់ខ្លួន ដែលមិនត្រូវធ្វើឱ្យប៉ះពាល់ទៅដល់សណ្តាប់ធ្នាប់សាធារណៈ
- នៅខាងមុខទីតាំងអាជីវកម្មនីមួយៗ ក៏ដូចជាស្ថាប័នរដ្ឋ និងឯកជនត្រូវសម្អាតអនាម័យឱ្យបានស្អាតជានិច្ចដើម្បីរួមចំណែកការពារបរិស្ថានសម្រាប់រាជធានីភ្នំពេញ
- ម្ចាស់ទីតាំងស្ថាប័នរដ្ឋ និងឯកជនអាចសុំចតរថយន្ត និងម៉ូតូរបស់ខ្លួន តាមគំនូសទីតាំងដែលមន្ទីរសាធារណការរាជធានីភ្នំពេញបានកំណត់
- ក្នុងករណី ប្រជាពលរដ្ឋមិនអនុវត្តតាមសេចក្តីជូនដំណឹង ក៏ដូចជាការណែនាំរបស់អាជ្ញាធរនោះរដ្ឋបាលខណ្ឌនឹងចាត់វិធានការរដ្ឋបាលដោយស្វ័យយករថយន្ត និងម៉ូតូទៅរក្សាទុកនៅរដ្ឋបាលខណ្ឌរយៈពេល ១៥ ថ្ងៃ ទើបដោះស្រាយជូន។[75]

### ១.២.៤. ការប្រើប្រាស់ដីធ្លី និងសំណង់

#### ១.២.៤.១. បទប្បញ្ញត្តិនគរូបនីយកម្មនៃប្លង់ប្រើប្រាស់ដីធ្លី និងសំណង់

ប្លង់ត្រូវបែងចែក និងកំណត់តំបន់ ឱ្យសមស្របទៅនឹងសក្តានុពលសង្គម និងសេដ្ឋកិច្ចទូទៅតាមវិស័យអភិវឌ្ឍនីមួយៗ ដោយមានការកំណត់ជាក់លាក់។

**ក. ប្លង់កម្ពស់**

ប្លង់កម្ពស់ ជាផ្នែកបញ្ឈររបស់អគារដែលគិតចាប់ពីបាតអគារ មកត្រឹមចុងដំបូលនៃអគារ។ ប្លង់កម្ពស់មាន ៣ ប្រភេទគឺៈ

- កម្ពស់បញ្ឈរៈ ជាកម្ពស់បញ្ឈររបស់អគារដែលគិតពីបាតអគារមកត្រឹមពិដានដំបូល។
- កម្ពស់អតិបរមាៈ ជាកម្ពស់របស់អគារដែលគិតចាប់ពីបាតអគារមកត្រឹមចុងដំបូល។
- កម្ពស់តាមជាន់ៈ ជាកម្ពស់តាមជាន់នីមួយៗរបស់អគារដែលគិតពីកម្រាលជាន់មួយទៅកម្រាលជាន់មួយទៀត។

សម្រាប់អគារសុំសាងសង់ថ្មី ត្រូវយកកម្ពស់តាមជាន់នីមួយៗឱ្យស្មើនឹងអគារមានស្រាប់នៅជិតខាងខ្លួនដែលស្ថិតនៅជួរជាមួយគ្នា។ ក៏ប៉ុន្តែ ក្នុងករណីអគារមានស្រាប់ដែលនៅជិតខាងខ្លួននោះមានកម្ពស់តាម

[75] សេចក្តីជូនដំណឹង ចុះថ្ងៃទី១៨ កុម្ភៈ ២០១៩ ស្តីពី ការរៀបចំសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈតាមបណ្តោយមហាវិថីព្រះនរោត្តម

ជាន់នីមួយៗមិនស្មើគ្នាទេ នោះកម្ពស់តាមជាន់នៃអគារដែលនឹងត្រូវសាងសង់ថ្មី ត្រូវយកតាមអគារមានស្រាប់ភាគច្រើនដែលស្ថិតនៅជួរជាមួយគ្នានោះ។[76]

**ខ. ជួរតម្រង់**

ជួរតម្រង់ជាព្រំប្រទល់ខណ្ឌរវាងដីសាធារណៈ និងដីឯកជន។ ការកំណត់ជួរតម្រង់ត្រូវកំណត់ឱ្យមានសមស្រប និងសមរម្យនៅក្នុងតំបន់នីមួយៗ ដើម្បីជាភាពងាយស្រួលក្នុងការប្រើប្រាស់សម្រាប់សាធារណជន ក៏ដូចជាការសម្រួលផ្នែកចរាចរណ៍ ព្រមទាំងរក្សាទុកនូវដីចំណីផ្លូវ [77] សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នាពេលខាងមុខផងដែរ។ ជាឧទាហរណ៍ ដីឡូត៍នៅជាប់តាមបណ្ដោយផ្លូវជាតិ ត្រូវតែកំណត់នូវជួរតម្រង់សម្រាប់សំណង់នានាដូចជា របង ផ្ទះ អគារជាដើម។ ពោលគឺរាល់សំណង់ទាំងនោះ ត្រូវសង់ឱ្យឃ្លាតពីចិញ្ចើមផ្លូវឱ្យបានសមរម្យ ដើម្បីបញ្ចៀសនូវបញ្ហានាពេលខាងមុខ ការកកស្ទះ ឬគ្រោះថ្នាក់ផ្សេងៗ។[78] ចន្លោះដីដែលថយពីជួរតម្រង់នេះ មិនអាចត្រូវបានប្រើប្រាស់ជាលក្ខណៈឯកជនទោះបីក្នុងកាលៈទេសៈណាមួយក៏ដោយ ហើយជួរតម្រង់នេះត្រូវបានកំណត់ស្មើៗគ្នា ចំពោះគ្រប់សំណង់ទាំងអស់សម្រាប់តំបន់ណាមួយស្របទៅតាមប្លង់គោល។

**គ. ធ្លាគម្លាត**

ធ្លាគម្លាត ជាលំហរបស់សំណង់ឃ្លាតថយពីជួរតម្រង់ (របងមុខ)។ នៅលើធ្លាគម្លាតមិនត្រូវបានអនុញ្ញាតឱ្យសាងសង់អ្វីឡើយ ប៉ុន្តែអាចប្រើប្រាស់ជាសកម្មភាពនានាបាន ហើយធ្លាគម្លាតនេះ គឺអាស្រ័យទៅតាមទំហំនៃការសាងសង់។ ធ្លាគម្លាតត្រូវបានបែងចែកសម្រាប់ដីឡូត៍ ៣ ប្រភេទ៖

- ធ្លាគម្លាតសម្រាប់អគារនៅលើដីឡូត៍ធម្មតា៖ រាល់អគារដែលសាងសង់ក្នុងដីឡូត៍ប្រភេទនេះត្រូវរក្សាគម្លាតតូចបំផុតត្រឹម ៤ ម៉ែត្រ ពីរបង (ជួរតម្រង់)។
- ធ្លាគម្លាតសម្រាប់អគារនៅលើដីឡូត៍កាច់ជ្រុងផ្លូវកែង៖ រាល់អគារដែលសង់ក្នុងដីឡូត៍ប្រភេទនេះ ត្រូវរក្សាធ្លាគម្លាតតូចបំផុតត្រឹម ៤ ម៉ែត្រ ពីរបង។ រីឯរបងដីឡូត៍ត្រូវបិតជ្រុងតូចបំផុត ៤ ម៉ែត្រ ចំណែកតួអគារត្រូវបិតជ្រុងតូចបំផុត ២ ម៉ែត្រ។
- ធ្លាគម្លាតសម្រាប់អគារនៅលើដីឡូត៍ច្រមុះជ្រូក ឬផ្លូវត្រឡែងកែង៖ រាល់អគារសាងសង់ក្នុងដីឡូត៍ប្រភេទនេះត្រូវរក្សាគម្លាតតូចបំផុតត្រឹម ៨ ម៉ែត្រ ពីរបងផ្នែកកំណោង ហើយរបងដីឡូត៍ ត្រូវថយតូចបំផុត ៨ ម៉ែត្រ ពីគែមចិញ្ចើមផ្លូវផ្នែកកំណោង។

[76] សៀវភៅ នីតិនគរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២០ ទំព័រទី ១៦៤

[77] ដីចំណីផ្លូវសម្រាប់ផ្លូវជាតិដែលមានលេខ ០១ ខ្ទង់ ត្រូវមានទទឹង ៣០ ម៉ែត្រចេញពីអ័ក្សផ្លូវ ចំណែកឯដីចំណីផ្លូវសម្រាប់ផ្លូវជាតិដែលមានលេខ ០២ ខ្ទង់ ត្រូវមានទទឹង ២៥ ម៉ែត្រចេញពីអ័ក្សផ្លូវ។

[78] សៀវភៅ នីតិនគរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២០ ទំព័រទី ១៦៥

ដោយឡែក យោងតាមសេចក្តីណែនាំបន្ថែមរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បាន កំណត់ធ្លាគម្លាតនគរូបនីយកម្មចំពោះសំណង់ដែលមានកម្ពស់ខ្ពស់ ស្ថិតនៅតាមបណ្តោយមហាវិថីនៃរាជធានី ក្រុង និងទីប្រជុំជនដូចខាងក្រោម៖

- ប្រភេទទី ១៖ អគារមានកម្ពស់ចាប់ពីជាន់ទី ៣១ ឡើងទៅ ត្រូវរក្សាធ្លាខាងមុខយ៉ាងតិច ១០ ម៉ែត្រ និង ធ្លាគម្លាតខាងក្រោយ និងចំហៀងសងខាងយ៉ាងតិច ៤ ម៉ែត្រ។
- ប្រភេទទី ២៖ អគារមានកម្ពស់ចាប់ពីជាន់ទី ២១ ដល់ជាន់ទី ៣០ ត្រូវរក្សាធ្លាគម្លាតខាងមុខយ៉ាងតិច ៨ ម៉ែត្រ និងធ្លាគម្លាតខាងក្រោយ និងចំហៀងសងខាងយ៉ាងតិច ៣,៥ ម៉ែត្រ។
- ប្រភេទទី ៣៖ អគារមានកម្ពស់ចាប់ពីជាន់ទី ១២ ដល់ជាន់ទី ២០ ត្រូវរក្សាធ្លាគម្លាតខាងមុខយ៉ាងតិច ៦ ម៉ែត្រ និងធ្លាគម្លាតខាងក្រោយ និងចំហៀងសងខាងយ៉ាងតិច ៣ ម៉ែត្រ។[79]

**ឃ. ផលធៀបក្រឡាផ្ទៃបាត**

ផលធៀបក្រឡាផ្ទៃបាត គឺជាផលធៀបរវាង ក្រឡាផ្ទៃបាតសំណង់ និងក្រឡាផ្ទៃដីឡូត៍ដែលសំណង់ នោះតាំងនៅ។

ឧទាហរណ៍៖ អគារមួយមានក្រឡាផ្ទៃបាត ២ ០០០ ម៉ែត្រការ៉េ ស្ថិតនៅលើដីឡូត៍មួយកន្លែងមានក្រឡា ផ្ទៃ ៨ ០០០ ម៉ែត្រការ៉េ។ ដូច្នេះ ផលធៀបក្រឡាផ្ទៃបាតគឺ ២ ០០០ ៖ ៨ ០០០ = ០.២៥។

**ង. សន្ទស្សន៍ប្រើប្រាស់ដី**

សន្ទស្សន៍ប្រើប្រាស់ដី គឺជាផលធៀបរវាង ផ្ទៃក្រឡាកម្រាលសំណង់សរុបគ្រប់ជាន់ជាផ្លូវការ ធៀបនឹង ក្រឡាផ្ទៃដីឡូត៍ដែលសំណង់នោះតាំងនៅ។[80]

ឧទាហរណ៍៖ អគារមួយមានកម្ពស់ ១០ ជាន់ ដោយគិតទាំងជាន់ផ្ទាល់ដី ស្ថិតនៅលើដីឡូត៍មួយកន្លែង មានក្រឡាផ្ទៃ ៨ ០០០ ម៉ែត្រការ៉េ។ ជាន់នីមួយៗនៃអគារនោះមានក្រឡាផ្ទៃ ២ ០០០ ម៉ែត្រការ៉ េនោះគេបានផ្ទៃក្រឡា កម្រាលសំណង់សរុបស្មើ ២ ០០០ × ១០ = ២០ ០០០ ម៉ែត្រការ៉េ។ ដូច្នេះ សន្ទស្សន៍ប្រើប្រាស់ដីនៃអគារនោះគឺ ២០ ០០០ ៖ ៨ ០០០ = ២.៥។

[79] លិខិតជម្រាបលេខ ១៤៤៥ ដនស ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៧ ស្តីពី ការកំណត់ធ្លាគម្លាតនគរូបនីយកម្មចំពោះសំណង់មានកម្ពស់ខ្ពស់

[80] អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពី នគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន, មាត្រា ២២

**១.២.៤.២. លក្ខណៈស្ថាបត្យកម្ម**

ជាទូទៅ ដើម្បីបញ្ជាក់ថា សំណង់ណាមួយមានលក្ខណៈសមស្រប ឬមិនសមស្របទៅតាមលក្ខណៈស្ថាបត្យកម្ម គេត្រូវពិនិត្យទៅលើលក្ខណៈមួយចំនួនដូចជា ប្លង់រួម ប្លង់បាតគ្រប់ជាន់ មុខភាព ឬសោភណភាពផ្នែកខាងក្រៅ និងបរិស្ថានជុំវិញសំណង់នោះ។[81]

**ក. ប្លង់រួម**

- ចំពោះផ្ទះ ឬអគារល្វែង ការកំណត់ប្លង់រួមត្រូវកំណត់អំពីចំណុចខាងក្រោមដូចតទៅ៖
  - ផលធៀបផ្ទៃបាតមិនលើសពី ៧៥%
  - កម្ពស់ត្រូវអនុវត្តទៅតាមប្លង់កម្ពស់នៃប្លង់ប្រើប្រាស់ដីធ្លីរួម
  - ជួរតម្រង់៖ គម្លាតថយអាចស្មើ ០% ឬធំជាង ឬស្មើនឹង ៤ម៉ែត្រ តាមការកំណត់នៃប្លង់ប្រើប្រាស់ដីធ្លី
  - គម្លាតជាមួយអ្នកជិតខាង អាចជាប់ព្រំ ឬគម្លាតធំជាង ឬស្មើនឹង ២ម៉ែត្រ។[82]
- ចំពោះភូមិគ្រឹះ អគារសាធារណៈ ការិយាល័យ សណ្ឋាគារ ឃ្លាំង រោងចក្រ ការកំណត់ប្លង់រួមត្រូវកំណត់អំពីចំណុចខាងក្រោមដូចតទៅ៖
  - ផលធៀបផ្ទៃបាតមិនលើសពី ៥០% ហើយផ្ទៃក្រឡាដែលនៅសល់ត្រូវរៀបចំ ជាសួនបៃតង និងដីជ្រាបទឹកយ៉ាងហោចណាស់ឱ្យបានពាក់កណ្ដាលនៃផ្ទៃក្រឡាដែលនៅសល់នោះ[83]
  - កម្ពស់ជាក់ស្ដែងទៅតាមស្ថានភាពតំបន់ ដែលបានកំណត់ដោយប្លង់កម្ពស់ក្នុងប្លង់ប្រើប្រាស់ដីធ្លី
  - ជួរតម្រង់មុខ៖ គម្លាតថយគួរឱ្យលើសពី ៤ ម៉ែត្រ ពីព្រំរបងមុខ
  - គម្លាតជាមួយអ្នកជិតខាង ត្រូវថយពីរបងឱ្យធំជាង ឬស្មើ ២ ម៉ែត្រ
  - ដើម្បីបំពេញនូវតម្រូវការនៃការប្រើប្រាស់ក្នុងអគារ ចំណតរថយន្តត្រូវរៀបចំឱ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការនៃប្រភេទអគារនីមួយៗ ហើយទីតាំងនៃចំណត ត្រូវស្ថិតនៅក្រៅពីទីតាំងសាធារណៈ និងផ្លូវសាធារណៈ។

ជាក់ស្ដែង ចំនួនចំណតរថយន្តអប្បបរមាសម្រាប់អគារក្នុងដីឡូត៍ ត្រូវបានកំណត់ដូចខាងក្រោម៖

**១). អគារលំនៅឋានរួមមាន៖**

- លំនៅឋានដាច់ (ភូមិគ្រឹះ និងពាក់កណ្ដាលភូមិគ្រឹះ) ផ្ទៃក្រឡាកម្រាល ១០០ម$^២$ ត្រូវមានចំណតរថយន្តតូច ១កន្លែង

[81] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២០ ទំព័រទី ១៦៦

[82] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២០ ទំព័រទី ១៦៧

[83] អនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពី លិខិតអនុញ្ញាតសាងសង់, មាត្រា ៣៥

- លំនៅឋានជាប់ (ផ្ទះល្វែង និងផ្ទះជាប់គ្នា) ផ្ទៃក្រឡាប្រមាណ ១២០ម² ត្រូវមានចំណតរថយន្តតូច ១
- អគារស្នាក់នៅរួមប្រភេទប្រណីត ផ្ទៃក្រឡាប្រមាណ ១០០ម² ត្រូវមានចំណតរថយន្តតូច ១
- អគារស្នាក់នៅរួមប្រភេទមធ្យម ផ្ទៃក្រឡាប្រមាណ ១២០ម² ត្រូវមានចំណតរថយន្តតូច ១
- អគារស្នាក់នៅរួមប្រភេទធម្មតា ផ្ទៃក្រឡាប្រមាណ ១៥០ម² ត្រូវមានចំណតរថយន្តតូច ១

**២). អគារពាណិជ្ជកម្ម រួមមាន៖**

- ភោជនីយដ្ឋាន ភេសជ្ជដ្ឋាន និងក្លឹបកម្សាន្ត ផ្ទៃក្រឡាប្រមាណ ២០ម² ត្រូវមានចំណតរថយន្តតូច ១ និងផ្ទៃក្រឡាកន្លែងរាំ ១ម² ត្រូវមានចំណតរថយន្តតូច ១
- ផ្សារទំនើប ផ្ទៃក្រឡាប្រមាណ ៥០ម² ត្រូវមានចំណតរថយន្តតូច ១ ត្រូវមានចំណតរថយន្តតូច ១
- ផ្សារ ឬកន្លែងលក់ដូរ ៥០ម² ត្រូវមានចំណតរថយន្តតូច ១ ត្រូវមានចំណតរថយន្តតូច ១
- អគារពាណិជ្ជកម្មផ្សេងៗ ៥០ម² ត្រូវមានចំណតរថយន្តតូច ១ ត្រូវមានចំណតរថយន្តតូច ១

**៣). អគារឧស្សាហកម្ម រួមមាន៖**

- អគាររោងចក្រ ផ្ទៃក្រឡាប្រមាណ ២៥០ម² ត្រូវមានចំណតរថយន្តតូច ១ និងផ្ទៃក្រឡា ១ ២៥០ម² ត្រូវមានចំណតរថយន្តធំ ១
- អគារឃ្លាំងផ្ទុកទំនិញផ្ទាល់ខ្លួន ផ្ទៃក្រឡាប្រមាណ ៤០០ម² ត្រូវមានចំណតរថយន្តតូច ១ និងផ្ទៃក្រឡា ២ ០០០ម² ត្រូវមានចំណតរថយន្តធំ ១

**៤). អគារសិក្សាធិការ អប់រំ និងកីឡា រួមមាន៖**

- អគារគ្រឹះស្ថានឧត្តមសិក្សា ផ្ទៃក្រឡាប្រមាណ ១០០ម² ត្រូវមានចំណតរថយន្តតូច ១
- អគារគ្រឹះស្ថានមធ្យមសិក្សា ផ្ទៃក្រឡាប្រមាណ ២០០ម² ត្រូវមានចំណតរថយន្តតូច ១
- អគារគ្រឹះស្ថានបឋមសិក្សា ផ្ទៃក្រឡាប្រមាណ ៣០០ម² ត្រូវមានចំណតរថយន្តតូច ១
- មជ្ឈមណ្ឌលកីឡា ផ្ទៃក្រឡាប្រមាណ ១០០ម² ត្រូវមានចំណតរថយន្តតូច ១

**៥). អគារសុខភាព រួមមាន៖**

- អគារមន្ទីរពេទ្យ ផ្ទៃក្រឡាប្រមាណ ១០០ម² ត្រូវមានចំណតរថយន្តតូច ១
- ក្លឹបហាត់ប្រាណ និងសុខភាព ផ្ទៃក្រឡាប្រមាណ ១២០ម² ត្រូវមានចំណតរថយន្តតូច ១

**៦). អគារសាលមហោស្រព សាលប្រជុំ ពិធី និងរោងភាពយន្ត៖** ផ្ទៃក្រឡាប្រមាណ ៣០ម² ត្រូវមានចំណតរថយន្តតូច ១ និងផ្ទៃក្រឡា ៣០០ម² ត្រូវមានចំណតរថយន្តធំ ១

**៧). អគារសណ្ឋាគារ និងផ្ទះសំណាក់ រួមមាន៖**

- អគារសណ្ឋាគារ ចំនួនបន្ទប់ ៥បន្ទប់ ត្រូវមានចំណតរថយន្តតូច ១ និងចំនួនបន្ទប់ ៣០បន្ទប់ ត្រូវមានចំណតរថយន្តធំ ១
- អគារផ្ទះសំណាក់ ចំនួនបន្ទប់ ១០បន្ទប់ ត្រូវមានចំណតរថយន្តតូច ១ និងចំនួនបន្ទប់ ៣០បន្ទប់ ត្រូវមានចំណតរថយន្តធំ ១

**៨). អគារការិយាល័យសាធារណៈ និងការិយាល័យឯកជន៖** ផ្ទៃក្រឡាកម្រាល ១០០ម² ត្រូវមានចំណតរថយន្តតូច ១

**៩). ស្ថានីយប្រេងឥន្ធនៈ៖** ផ្ទៃក្រឡាកម្រាល ១០ម² ត្រូវមានចំណតរថយន្តតូច ១ និងផ្ទៃក្រឡា ១០០ម² ត្រូវមានចំណតរថយន្តធំ ១

**១០). អគារការិយាល័យដឹកជញ្ជូន៖** ផ្ទៃក្រឡាកម្រាល ១០០ម² ត្រូវមានចំណតរថយន្តតូច ១ និងផ្ទៃក្រឡា ៥០០ម² ត្រូវមានចំណតរថយន្តធំ ១

**១១). អគារផ្សេងៗ៖** ផ្ទៃក្រឡាកម្រាល ១៥០ម² ត្រូវមានចំណតរថយន្តតូច ១ និងផ្ទៃក្រឡា ៥០០ម² ត្រូវមានចំណតរថយន្តធំ ១

**១២). អគារបម្រើមុខងារចម្រុះ (Mixed Use Building)៖** ការគណនាចំនួនចំណតរថយន្ត ត្រូវគណនាតាមប្រភេទមុខងារនីមួយៗ ហើយបូកសរុបបញ្ចូលគ្នា ទើបទទួលបានចំនួនចំណតសរុបសម្រាប់អគារទាំងមូល។

បន្ថែមពីនេះ ការរៀបចំចំណតយានយន្តនៅទីសាធារណៈ និងឯកជនត្រូវមានចំណតសម្រាប់ជនពិការ និងជនងាយរងគ្រោះ។[84]

**ខ. ប្លង់បាតគ្រប់ជាន់**

- គួរមានយ៉ រានហាល
- បន្ទប់គេង បន្ទប់ធ្វើការ បន្ទប់ទទួលភ្ញៀវ ត្រូវមានពន្លឺគ្រប់គ្រាន់ និងមានខ្យល់ចេញចូលបានល្អ (ក្នុងបន្ទប់មួយយ៉ាងតិច មានបង្អួច ១.៥ ម៉ែត្រ)
- គួរមានរបាំងថ្ងៃ និងរបាំងភ្លៀង។

**គ. មុខភាព ឬសោភណភាពខាងក្រៅ (Façade)**

ដោយលក្ខណៈប្រពៃណី វប្បធម៌ និងអត្តសញ្ញាណជាខ្មែរ ជាគោលដៅក្នុងទិសដៅរៀបចំ ទីក្រុងភ្នំពេញ ដើម្បីប្រកួតប្រជែងជាមួយអន្តរជាតិ ដូច្នេះសោភណភាពខាងក្រៅនៃអគារគួរតម្រង់ទិសដៅដូចតទៅ៖

[84] អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពី នគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន, មាត្រា ៣៤

- ដំបូលគួរឱ្យមានរចនាបថជាខ្មែរ ដូចជាដំបូលផ្ទះខ្មែរ ដំបូលរោងដោល រោងឌៀង កន្តាំង ប៉ិត ឬការសំយោគនៃដំបូលទាំងនោះ
- ជញ្ជាំងគួរធ្វើឱ្យមានសមាមាត្រ សមស្របជាមួយដំបូល និងតួអគារ
- ចង្វាក់នៃការចោះបង្អួច គួរផ្សាភ្ជាប់រវាងសោភណភាព និងសុខភាពរបស់មនុស្ស ព្រមទាំងមុខងារនៃអគារផងដែរ តួយ៉ាង ចំពោះការរៀបចំ ទ្វារ បង្អួច ចម្រឹង របាំងថ្ងៃ របាំងទឹកភ្លៀង ស្លាបព្រិល ប្រហោងខ្យល់ ជាដើម។ល។
- គួរមានសីហៈឈរនៅមុខភាពខាងមុខ និងគួរមាន រានហាល[85] យ៉[86] សម្រាប់ជាកន្លែងលំហែ និងបន្ថែមរុក្ខជាតិបៃតងឱ្យចំលក្ខណៈ និងតម្រូវការរបស់អគារ។[87]

**ឃ. បរិស្ថាន (បរិភាពជុំវិញ)**

ដោយបរិស្ថានទីក្រុងជាទិសដៅសំខាន់មួយ វាអាចធ្វើឱ្យទីក្រុងភ្នំពេញប្រកួតប្រជែងជាមួយទីក្រុងដទៃទៀតបាន។ ដូចនេះ គ្រប់សំណង់គួរតែយកចិត្តទុកដាក់ចំពោះបរិស្ថានជុំវិញ ព្រោះវាផ្តល់ផលប្រយោជន៍ដល់សុខភាពផង និងងាយស្រួលក្នុងការសង្គ្រោះអគ្គិភ័យផង។ ម៉្យាងទៀត៖

- របងគួរមានលក្ខណៈសមស្របទៅតាមតំបន់ អាចជាជញ្ជាំងរឹងមាំ ឬរុក្ខជាតិសមស្រប
- ដីដែលនៅសល់ពីសំណង់គួររៀបចំជាផ្ទៃបៃតងប្រកបដោយអនាម័យ
- ប្រព័ន្ធទឹកកខ្វក់ លូ ឬអាងស្តុកលាមក គួររៀបចំគ្របឱ្យបានស្អាត កុំឱ្យប៉ះពាល់ដល់អ្នកជិតខាង។ មិនតែប៉ុណ្ណោះ រាល់សំណង់ ឬអគារនីមួយៗត្រូវ៖
- គួរមានផ្ទៃក្រឡាបៃតងឱ្យបានច្រើន ក្នុងគោលបំណងបរិស្ថាន
- ចំណតរថយន្ត និងកន្លែងដាក់កង់ គួរឱ្យមានគ្រប់គ្រាន់ជាពិសេសសម្រាប់ផ្សារ
- គួរមានអាងចម្រោះទឹកស្អុយ
- ស្ថាបត្យកម្មអគារគួរមានការសិក្សាជាលក្ខណៈខ្មែរ។[88]

### ១.២.៤.៣. ការរៀបចំផែនការប្រើប្រាស់ដីធ្លីទីក្រុង

ការរៀបចំផែនការប្រើប្រាស់ដីធ្លីនៅតាមតំបន់នីមួយៗនៃខេត្ត-ក្រុង មានសារៈសំខាន់ជាចាំបាច់ដែលត្រូវមាន ដើម្បីសណ្តាប់សាធារណៈ សោភណភាព និងរក្សាបាននូវការការពារសុខភាពមនុស្ស ការអភិរក្សជីវៈចម្រុះ

[85] រានហាល (នាម) គ្រែវាល ឬមានដំបូល មានសសរដាំក្នុងដីសម្រាប់អង្គុយលំហើយ ឬសម្រាប់ដាក់អីវ៉ាន់លក់ ជាដើម

[86] យ៉ (នាម) ផ្ទះតូច ឬរានហាលកំបុតមានសណ្ឋានជាកើយធ្វើភ្ជាប់នឹងគ្រឹហា, ប្រាសាទ, វិហារ

[87] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្តដា បោះពុម្ពឆ្នាំ២០២០ ទំព័រទី ១៦៧

[88] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្តដា បោះពុម្ពឆ្នាំ២០២០ ទំព័រទី ១៦៨

និយាយជាទូទៅ គឺលើកកម្ពស់គុណភាពបរិស្ថាន។ ម៉្យាងទៀត ការប្រើប្រាស់ដីដែលមានទំហំកម្រិតកំណត់ទៅតាមស្តង់ដារបច្ចេកទេសឱ្យបានត្រឹមត្រូវនោះ ក៏ជាការចូលរួមចំណែកមួយនៃការប្រើប្រាស់ធនធានធម្មជាតិ និងដីធ្លី ប្រកបដោយនិរន្តរភាព ក៏ដូចជាការធានាឱ្យការអភិវឌ្ឍប្រទេសប្រកបដោយនិរន្តរភាពផងដែរ។

ការកើនឡើងនូវតម្រូវការប្រើប្រាស់ដីធ្លី សម្រាប់គោលដៅក្នុងវិស័យនានា ដូចជាការត្រូវការដីសម្រាប់ពង្រីកតំបន់ឧស្សាហកម្ម តំបន់កសិកម្ម និងពាណិជ្ជកម្ម និងសម្រាប់លំនៅឋានដើម្បីឆ្លើយតបទៅនឹងកំណើនប្រជាជន និងកំណើនសេដ្ឋកិច្ចជាលំដាប់នោះ រឹតតែធ្វើឱ្យមានផែនការរៀបចំប្រើប្រាស់ដីធ្លីនេះត្រូវតែមានដោយខានពុំបាន។ នេះមានន័យថាខេត្ត-ក្រុងនីមួយៗត្រូវមានផែនការ ឬប្លង់ប្រើប្រាស់ដីធ្លីរបស់ខ្លួនឱ្យបានច្បាស់លាស់ និងត្រឹមត្រូវស្របតាមលក្ខណៈពិសេសនៃស្ថានភាពតំបន់នីមួយៗ ដោយធ្វើការបែងចែកឱ្យដាច់ពីគ្នាជាតំបន់សម្រាប់គោលដៅផ្សេងៗគ្នាដូចជា៖

- តំបន់ដែលត្រូវប្រើប្រាស់ ឬបម្រុងសម្រាប់វិស័យកសិកម្ម
- តំបន់ដែលសម្រាប់សកម្មភាពពាណិជ្ជកម្ម
- តំបន់សម្រាប់កសាង ឬសកម្មភាពរោងចក្រឧស្សាហកម្ម
- តំបន់សម្រាប់សិប្បកម្ម
- តំបន់សម្រាប់វប្បធម៌ទេសចរណ៍
- តំបន់សម្រាប់អគាររដ្ឋបាល ឬគ្រឹះស្ថានសាធារណៈរបស់រដ្ឋដូចជាក្រសួងមន្ទីរនានារបស់រដ្ឋ
- តំបន់សម្រាប់ហ្វឹកហាត់យោធា ឬតំបន់សម្រាប់បម្រើវិស័យការពារជាតិ ដូចជាឃ្លាំងអាវុធយុទ្ធភណ្ឌនានា
- តំបន់សម្រាប់ប្រតិបត្តិការជំនួញខាងផ្នែកខាងផ្នែកហិរញ្ញវត្ថុ ដូចជាធនាគារ ធានារ៉ាប់រង។ល។
- តំបន់សម្រាប់តែប្រើប្រាស់កសាងលំនៅឋានរបស់ប្រជាជនដែលចេះតែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ
- តំបន់សម្រាប់ការពារធនធានធម្មជាតិ និងអភិរក្សរមណីយដ្ឋានបុរាណវិទ្យាប្រវត្តិសាស្ត្រ។

ក្រៅពីការរៀបចំផែនការ ប្លង់ប្រើប្រាស់ដីធ្លីជាលក្ខណៈតំបន់ដាច់ដោយឡែកពីគ្នាដូចខាងលើ អ្នកធ្វើផែនការ ក៏ត្រូវគិតគូរផងដែរ ការបម្រុងដីទុកសម្រាប់ការអភិវឌ្ឍ និងការពង្រីកដីប្រើប្រាស់នៅថ្ងៃខាងមុខ ឬពេលអនាគត ការគិតគូរបម្រុងពួកដីទាំងនោះរួមមានដូចខាងក្រោម៖

- ដីធ្លីត្រូវរក្សា ឬបម្រុងទុកសម្រាប់វិស័យឧស្សាហកម្ម ពាណិជ្ជកម្មត្រូវតែមានតុល្យភាពទៅនឹងការបម្រុងដីទុក សម្រាប់សង់លំនៅឋាន សម្រាប់កន្លែងកម្សាន្តនានា
- ដីធ្លីដែលត្រូវបម្រុងទុកសម្រាប់ការពង្រីក ឬអភិវឌ្ឍលើវិស័យនានានោះ ក៏ត្រូវធ្វើការបម្រុងទុកដីផងដែរសម្រាប់កិច្ចការពារគុណភាពបរិស្ថាន ដូចជាទុកឱ្យមានទីធ្លាសាធារណៈឱ្យធំទូលាយសមរម្យ សួនច្បារ

ការដាំដើមឈើក្នុងទីក្រុង-ខេត្ត ជាដើម។ល។ ដើម្បីរក្សាបាននូវខ្យល់អាកាសបរិសុទ្ធ ចៀសវាងការបំពុលបរិយាកាស

- ដីធ្លីក៏ត្រូវបម្រុងទុកសម្រាប់ការពង្រីកនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានា ដូចជាបម្រុងទុកសម្រាប់ពង្រីកផ្លូវ កំពង់ផែ ស្ពាន អាកាសយានដ្ឋាន បណ្តាញទឹកស្អាតសាធារណៈ បណ្តាញលូសាធារណៈ និងកន្លែងសម្រាប់បំផ្លាញកាកសំណល់នានា ដូចជាសំរាម សំណល់ឧស្សាហកម្ម ទឹកកខ្វក់ ជាដើម។

ជាឧទាហរណ៍នៅប្រទេសសិង្ហបុរី ផែនការរៀបចំប្រើប្រាស់ដីធ្លី (Concept Plan) បានកំណត់ទុកផ្ទៃដីប្រហែល ២៥% នៃផ្ទៃដីប្រទេសទាំងមូល ឬប្រហែល ១៣ ២០០ ហិកតា សម្រាប់វិស័យឧស្សាហកម្មនៅក្នុងរយៈពេលវែង (Long Term) និងដីបម្រុងសម្រាប់ការពារធម្មជាតិមានប្រហែល ៣ 000 ហិកតា សម្រាប់ការពារព្រៃឈើ ធនធានធម្មជាតិ និងសត្វនានា។ ក្រៅពីនេះ ផ្ទៃដីប្រទេសសិង្ហបុរីត្រូវបម្រុងទុកសម្រាប់ការពង្រីកនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានា ដូចជា អាកាសយានដ្ឋាន កំពង់ផែ និងការពង្រីកដី សម្រាប់លំនៅឋាន។

រួមសេចក្តីមក ដើម្បីធ្វើឱ្យប្រទេសជាតិមួយមានការអភិវឌ្ឍប្រកបដោយនិរន្តរភាពនោះ ការរៀបចំផែនការប្រើប្រាស់ដីធ្លីនេះមានសារៈសំខាន់ជាទីបំផុតដែលត្រូវមានសម្រាប់ពេលបច្ចុប្បន្ន ក៏ដូចជាសម្រាប់ពេលអនាគតហើយការធ្វើផែនការរៀបចំប្រើប្រាស់ដីធ្លីខេត្ត-ក្រុងនីមួយៗនេះទៀតសោត ត្រូវយកបញ្ហានៃការការពារ និងលើកកម្ពស់គុណភាពបរិស្ថានទៅដាក់បញ្ចូលទៅក្នុងផែនការនោះ ទើបទីក្រុង-ខេត្តរបស់យើង នៅមានភាពស្អាតសោភណភាព សណ្តាប់ធ្នាប់សាធារណៈល្អ និងលើកកម្ពស់សុខភាពមនុស្ស។ ប្រសិនបើមិនបានយកចិត្តទុកដាក់ដល់កិច្ចការពារគុណភាពបរិស្ថានទេនោះ ការអភិវឌ្ឍ ឬការរៀបចំដែនដីមួយរបស់ប្រទេសនោះក៏ពុំមាននិរន្តរភាពបានដែរ។[89]

[89] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២០ ទំព័រទី ១៧៣

# ជំពូកទី២

# ការអភិវឌ្ឍរាជធានីភ្នំពេញប្រកប

# ដោយនិរន្តរភាព

# ជំពូកទី២
# ការអភិវឌ្ឍរាជធានីភ្នំពេញប្រកបដោយនិរន្តរភាព

ក្រៅពីការរៀបចំទីក្រុងមួយឱ្យមានសណ្តាប់ធ្នាប់ ផែនការអភិវឌ្ឍក្រុងឱ្យមាននិរន្តរភាពក៏ជាភាពចាំបាច់ផងដែរដើម្បីឱ្យទីក្រុងលូតលាស់ និងអភិវឌ្ឍបានល្អ។ យើងឃើញថារដ្ឋ និងអង្គការអន្តរជាតិជាច្រើននៅលើពិភពលោកចូលរួមជាមួយគ្នាដើម្បីបង្កើតនូវផែនការសកម្មភាព និងរបៀបវារៈមួយចំនួនដែលជម្រុញការអភិវឌ្ឍទីក្រុងដោយនិរន្តរភាព ដោយនៅក្នុងផែនការទាំងនោះ មានរបៀបវារៈទីក្រុងថ្មីមួយបានបង្កើតឡើងសម្រាប់ប្រទេសកម្ពុជា។ រួមជាមួយផែនការមេមួយចំនួននៃរាជធានីភ្នំពេញ ផែនការសកម្មភាព និងរបៀបវារៈក្រុងថ្មីទាំងនេះបានកំណត់នូវស្តង់ដារនៃការរៀបចំក្រុងភ្នំពេញឱ្យមាននូវនិរន្តរភាព។ ដូច្នេះ នៅក្នុងជំពូកទី២នេះ យើងនឹងសិក្សាអំពីរបៀបវារៈទីក្រុងថ្មី រួមជាមួយនឹងគោលដៅ និងវិធីសាស្ត្រនៃការអភិវឌ្ឍដោយនិរន្តរភាពរបស់ឯកសារនេះ នៅក្នុងប្រទេសកម្ពុជា ដោយខ្លឹមសារទាំងនោះនឹងត្រូវបានពន្យល់នៅក្នុងចំណុច ២.១។ បន្ទាប់មក នៅក្នុងចំណុច ២.២ យើងនឹងពិភាក្សាអំពីផែនការអភិវឌ្ឍន៍ និងផែនការមេផ្សេងៗដែលជម្រុញឱ្យទីក្រុងភ្នំពេញលូតលាស់ប្រកបដោយនិរន្តរភាព។

ជាចុងក្រោយ យើងក៏ផ្តោតទៅលើលើឧបសគ្គនានានៃការអភិវឌ្ឍឱ្យមាននិរន្តរភាពនៅក្នុងវិស័យផ្សេងៗនៅក្នុងរាជធានីភ្នំពេញផងដែរ។

## ២.១. របៀបវារៈទីក្រុងថ្មី (New Urban Agenda)

### ២.១.១. វិស័យសំខាន់នៃរបៀបវារៈទីក្រុងថ្មី

យើងបានដឹងរួចមកហើយថា អ្វីទៅជារបៀបវារៈទីក្រុងថ្មីនៅក្នុងជំពូកទី១ ដូច្នេះ នៅចំណុចនេះ យើងនឹងសិក្សាទៅលើវិស័យសំខាន់ៗនៃរបៀបវារៈទីក្រុងថ្មី។

របៀបវារៈទីក្រុងថ្មីរួមមានចំណុចនិរន្តរភាពចំនួន ៤ នៅក្នុងគ្រប់វិស័យដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍទីក្រុង។ ចំណុចនិរន្តរភាពទាំងនេះរួមគ្នាធានាថាផែនការទីក្រុង និងការអភិវឌ្ឍនាពេលអនាគតនឹងពោរពេញទៅដោយនិរន្តរភាពនៅក្នុងវិស័យផ្សេងៗ។ នៅចំណុចខាងក្រោមនេះ យើងនឹងធ្វើការសិក្សាទៅលើនិយមន័យ និងសារៈសំខាន់នៃនិរន្តរភាពទាំង ៤ ដែលរួមមាន៖ និរន្តរភាពសង្គម, និរន្តរភាពសេដ្ឋកិច្ច, និរន្តរភាពបរិស្ថាន, និងនិរន្តរភាពនៃលំហទីក្រុង។[90]

[90] សៀវភៅ New Urban Agenda Illustrated , អង្គការ UN-Habitat បោះពុម្ពឆ្នាំ២០២០

**២.១.១.១. និរន្តរភាពសង្គម** ( Social Sustainability )

របៀបវារៈទីក្រុងថ្មី សង្កត់ធ្ងន់ទៅលើសិទ្ធិ និងអត្ថប្រយោជន៍ស្មើគ្នារវាងប្រជាជនទាំងអស់នៅក្នុងទីក្រុងមួយ។ ដើម្បីបំពេញគោលដៅនេះ របៀបវារៈទីក្រុងថ្មីផ្តោតសំខាន់លើទីក្រុងដែលមានបរិយាប័ន្ន លើកកម្ពស់ការចូលរួមរបស់ពលរដ្ឋ លើកកម្ពស់ទំនាក់ទំនងសង្គម និងវប្បធម៌ ការបង្ហាញវប្បធម៌ និងការចូលរួមនយោបាយ និងជាកន្លែងដែលតម្រូវការរបស់ប្រជាជនទាំងអស់ត្រូវបានបំពេញ។ មិនត្រឹមតែប៉ុណ្ណោះ របៀបវារៈទីក្រុងថ្មី ក៏បានយកចិត្តទុកដាក់ ចំពោះការប្រយុទ្ធប្រឆាំងនឹងការរើសអើងទៅលើក្រុមដែលងាយរងគ្រោះដូចជា ជនពិការ ជនចាស់ជរា និងជនជាតិដើមភាគតិចជាដើម ជាពិសេសតាមរយៈការរៀបចំផែនការ និងកម្មវិធីសង្គមផ្សេងៗ ដើម្បីឆ្លើយតបនឹងតម្រូវការ និងផ្តល់លទ្ធភាពដល់ក្រុមដែលងាយរងគ្រោះទាំងនោះ។

ឆ្ពោះទៅកាន់និរន្តរភាពសង្គមដែលបានចែងខាងលើ របៀបវារៈទីក្រុងថ្មីបានដាក់ចេញនូវគោលដៅចំនួន ៤ ដែលត្រូវសម្រេច ដែលមានដូចខាងក្រោម៖

**ក. ការផ្តល់សិទ្ធិអំណាចដល់ក្រុមដែលបាត់បង់ឱកាស**

គោលដៅនេះសំដៅដល់ការគាំទ្រ និងរួមបញ្ចូលក្រុមដែលបាត់បង់ឱកាសដូចជា កុមារ មនុស្សចាស់ ស្ត្រី ជនពិការ ជនអនាថា ជនគ្មានទីលំនៅផ្លូវការ ជនជាតិភាគតិច ជនចំណាកស្រុក និងជនភៀសខ្លួន។ ដើម្បីសម្រេចគោលដៅនេះ គេតម្រូវឱ្យមានសកម្មភាពមួយចំនួនក្នុងផែនការអភិវឌ្ឍន៍ដូចជា៖

- បង្កើតការការពារនៅកន្លែងការងារសម្រាប់ក្រុមដែលបាត់បង់ឱកាស ដើម្បីប្រឆាំងនឹងអំពើហិង្សា ឬការកេងប្រវ័ញ្ច ភាពឯកោ និងការរើសអើងនៅកន្លែងធ្វើការ
- ជម្រុញឱ្យក្រុមដែលបាត់បង់ឱកាសចូលរួមក្នុងការងាររដ្ឋាភិបាលថ្នាក់មូលដ្ឋាន ដូចជាការធ្វើផែនការ ឬគោលនយោបាយជាដើម
- បង្កើតគណៈកម្មាធិការប្រឹក្សាយោបល់ ដើម្បីលើកកម្ពស់គណនេយ្យភាពចំពោះក្រុមដែលបាត់បង់ឱកាស
- អភិវឌ្ឍកម្រិតវប្បធម៌របស់មន្ត្រីក្រុង ដើម្បីលើកស្ទួយការផ្តល់សេវាត្រឹមត្រូវដល់ក្រុមទាំងនោះ
- ប្រមូល និងរក្សាទិន្នន័យប្រជាសាស្ត្រថ្មីៗដែលជាចាំបាច់ទៅដល់ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់សេវាដែលមានគុណភាពល្អជាពិសេសសម្រាប់ជនដែលបាត់បង់ឱកាស។[91]

**ខ. សមភាពយេនឌ័រ**

របៀបវារៈទីក្រុងថ្មីក៏គាំទ្រទៅលើការប្រឆាំងនឹងការរើសអើង និងអំពើហិង្សាចំពោះភេទស្រីផងដែរ ដោយធានាឱ្យមានការចូលរួមពេញលេញរបស់ស្ត្រីក្នុងសង្គម សិទ្ធិស្មើគ្នាក្នុងការទទួលបានសេវាមូលដ្ឋាន ការរៀបចំទីក្រុងមួយដោយយកចិត្តទុកដាក់ទៅលើភាពបៃតង គុណភាព និងសុវត្ថិភាពចំពោះភេទស្រី ហើយជាចុងក្រោយ

[91] សៀវភៅ New Urban Agenda Illustrated , អង្គការ UN-Habitat បោះពុម្ពឆ្នាំ២០២០ ទំព័រទី ៣

គាំទ្រដល់ការលើកកម្ពស់សមត្ថភាពរបស់ភេទស្រីតាមរយៈបច្ចេកវិទ្យា និងព័ត៌មាន។ ដើម្បីសម្រេចបានគោលដៅនេះ ផែនការអភិវឌ្ឍក្រុងត្រូវតែមាន៖

- នៅពេលរៀបចំផ្លូវ និងមហាវិថីក្នុងក្រុង ត្រូវយកចិត្តទុកដាក់ពិសេសទៅលើទីតាំងដែលស្ត្រីត្រូវការធ្វើដំណើរទៅ ដូចជាកន្លែងដែលផ្តល់សេវាសុខាភិបាល ឬការអប់រំជាដើម ជាពិសេសនៅតំបន់ជាយក្រុង
- ជម្រុញឱ្យស្ត្រីចូលរួមក្នុងកិច្ចការងារសង្គម និងរដ្ឋាភិបាលមូលដ្ឋាន ដើម្បីភាពប្រសើរឡើងនៅក្នុងសហគមន៍របស់ពួកគេ
- គាំទ្រកម្មវិធី និងគោលនយោបាយណាដែលជម្រុញឱ្យស្ត្រីបង្កើតទំនាក់ទំនង និងបណ្តាញសហគមន៍ជាមួយស្ត្រីផ្សេងៗទៀត ដែលកម្មវិធីទាំងនេះមានសារៈសំខាន់ណាស់សម្រាប់ជនដែលទើបធ្វើចំណាកស្រុក និងបុគ្គលដែលរស់នៅក្នុងផ្ទះក្រៅផ្លូវការ (លំនៅឋានខុសច្បាប់)។[92]

**គ. ផែនការសម្រាប់ជនចំណាកស្រុក ជនជាតិភាគតិច និងជនពិការ**

ក្រៅពីជនដែលបាត់បង់ឱកាស របៀបវារៈទីក្រុងថ្មីក៏យកចិត្តទុកដាក់ទៅការរៀបចំផែនការសម្រាប់ក្រុមមនុស្សផ្សេងៗដែលមានភាពលំបាកដែរ ដូចជាជនចំណាកស្រុក ជនជាតិភាគតិច និងជនពិការ។ យើងអាចឃើញថា ផែនការរៀបចំ និងកសាងហេដ្ឋារចនាសម្ព័ន្ធ និងកម្មវិធីផ្តល់សេវាកម្មទីក្រុងឱ្យស្របទៅតាមតម្រូវការរបស់ជនខាងលើ មិនសូវមានការខាតបង់ផ្នែកហិរញ្ញវត្ថុច្រើនឡើយ។ ដូច្នេះ ផែនការរៀបចំក្រុងត្រូវរួមបញ្ចូលសកម្មភាពដូចខាងក្រោម៖

- ពង្រឹងការអប់រំវិជ្ជាជីវៈដល់ជនចំណាកស្រុក និងជនភៀសខ្លួន ដើម្បីឱ្យជនទាំងនោះទទួលបាននូវជំនាញដែលនាំឱ្យពួកគេអាចរកការងារធ្វើនៅក្នុងទីក្រុងបាន
- ធ្វើឱ្យប្រសើរឡើងនូវការការពារផ្នែកពលកម្ម ពីព្រោះជនចំណាកស្រុកភាគច្រើនងាយរងគ្រោះនឹងការកេងប្រវ័ញ្ចក្នុងការងារខ្លួន ដោយសារពួកគេខ្វះខាតការអប់រំជាផ្លូវការ ឬជំនាញភាសា
- រៀបចំទីក្រុងមួយដោយផ្អែកលើគុណតម្លៃនៃការរួមបញ្ចូល និងការលើកកម្ពស់នៃភាពចម្រុះជាតិសាសន៍រវាងប្រជាជន ជនចំណាកស្រុក ជនភៀសខ្លួន និងជនជាតិភាគតិច
- គាំទ្រការចូលរួមសកម្មភាពសង្គម និងរដ្ឋាភិបាលរបស់ជនដែលទើបចូលប្រទេសកម្ពុជា ហើយពង្រីកការគាំពារសង្គមផ្នែកហិរញ្ញប្បទាន សម្រាប់ជនទាំងនោះ
- រៀបចំផែនការមធ្យោបាយធ្វើដំណើរសម្រាប់ក្រុមដែលងាយរងគ្រោះ ជាពិសេសជនពិការ ដើម្បីឱ្យពួកគេមានភាពងាយស្រួលក្នុងការធ្វើដំណើរឆ្លងកាត់ទីក្រុង

---

[92] សៀវភៅ New Urban Agenda Illustrated , អង្គការ UN-Habitat បោះពុម្ពឆ្នាំ២០២០ ទំព័រទី ៦

- ពង្រឹងស្តង់ដារ បទប្បញ្ញត្តិ និងមធ្យោបាយអនុវត្តសម្រាប់បង្កើតអគារឱ្យមាននិរន្តរភាព និងបរិយាប័ន្ន សម្រាប់ប្រជាជនទាំងអស់។[93]

**ឃ. ផែនការឆ្លើយតបតាមអាយុ**

របៀបវារៈទីក្រុងថ្មី ទទួលស្គាល់សារៈសំខាន់នៃការធ្វើផែនការឆ្លើយតបតាមអាយុ សម្រាប់យុវជន និង មនុស្សចាស់ ដោយសារវាជាធាតុផ្សំនៃការផ្តល់នូវលទ្ធភាព និងជម្រុញការចូលរួមទៅក្នុងគ្រប់វិស័យនៃការ អភិវឌ្ឍទីក្រុង។ គោលដៅនេះអាចសម្រេចបានតាមរយៈការលើកកម្ពស់សេវាមូលដ្ឋាន ពង្រីកហេដ្ឋារចនាសម្ព័ន្ធ ផ្សេងៗក្នុងក្រុង បង្កើនលទ្ធភាពទទួលបានការអប់រំសម្រាប់យុវជន ហើយនឹងជម្រុញកម្មវិធីណាដែលអភិវឌ្ឍ ជំនាញការងារ និងធនធានមនុស្ស។ ដូច្នេះ ផែនការរៀបចំក្រុងត្រូវរួមបញ្ចូល៖

- បង្កើតសូចនាករដើម្បីវាស់ស្ទង់ពីផលប៉ះពាល់នៃអាយុលើសង្គម និងសេវាកម្មមូលដ្ឋានផ្សេងៗ ដូចជា សេវាសុខាភិបាល ឱកាសការងារ និងឱកាសលំនៅឋានជាដើម
- លើកកម្ពស់ឱកាសរៀនសូត្រសម្រាប់ប្រជាជនទាំងអស់ ជាពិសេសសម្រាប់មនុស្សចាស់
- ផ្តល់ឱកាសទទួលបានគេហដ្ឋានសមរម្យសម្រាប់មនុស្សចាស់ និងការបណ្តុះបណ្តាលការងារ ត្រឹមត្រូវ សម្រាប់យុវជន
- បង្កើតមណ្ឌលព័ត៌មាន និងបណ្តាញដើម្បីភ្ជាប់និយោជកទៅនឹងយុវជន ដើម្បីឱ្យពួកគេងាយស្វែងរកការ បណ្តុះបណ្តាលសមរម្យ និងចូលរួមក្នុងទីផ្សារការងារ។[94]

**២.១.១.២. និរន្តរភាពសេដ្ឋកិច្ច** ( Economic Sustainability )

ក្រៅពីនិរន្តរភាពសង្គម របៀបវារៈទីក្រុងថ្មីក៏ទទួលស្គាល់ថាកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព និង ឱកាសការងារសមរម្យជាធាតុសំខាន់នៃការអភិវឌ្ឍទីក្រុងប្រកបដោយនិរន្តរភាព។ ហេតុនេះ របៀបវារៈទីក្រុងថ្មី ចាត់ទុកទីក្រុងជាទីកន្លែងផ្តល់ឱកាសឱ្យប្រជាពលរដ្ឋរស់នៅប្រកបដោយផលិតភាព និងភាពរុងរឿង តាមរយៈ ការបង្កើនផលិតភាពសេដ្ឋកិច្ច ពង្រីកនូវឱកាសការងារ ចំណេះដឹងជំនាញ និងគ្រឹះស្ថានអប់រំ ដែលទាំងនេះនឹង ចូលរួមឱ្យមានភាពប្រសើរឡើងនៃការប្រកួតប្រជែងសេដ្ឋកិច្ចរបស់ទីក្រុង។ របៀបវារៈនេះក៏ផ្តោតសំខាន់ទៅលើ ការផ្លាស់ប្តូរកម្លាំងពលកម្មមិនស្របច្បាប់ ទៅកម្លាំងពលកម្មស្របច្បាប់ដែរ។ ដូច្នេះ និរន្តរភាពសេដ្ឋកិច្ចសង្កត់ ធ្ងន់ទៅលើគោលដៅសំខាន់ ២ ដូចខាងក្រោម៖

[93] សៀវភៅ New Urban Agenda Illustrated , អង្គការ UN-Habitat បោះពុម្ពឆ្នាំ២០២០ ទំព័រទី ១១

[94] សៀវភៅ New Urban Agenda Illustrated , អង្គការ UN-Habitat បោះពុម្ពឆ្នាំ២០២០ ទំព័រទី ១៤

**ក. ការបង្កើតការងារ និងជីវភាពល្អ**

នគរូបនីយកម្មនៃទីក្រុង មានសារៈសំខាន់ណាស់ក្នុងការបង្កើតឱកាសការងារ និងជីវភាពរស់នៅល្អសម្រាប់ប្រជាជន។ ហេតុនេះ ទើបរបៀបវារៈទីក្រុងថ្មីទទួលស្គាល់ទំនាក់ទំនងរវាងនគរូបនីយកម្មល្អ ជាមួយនឹងឱកាសការងារ និងការរីកចម្រើននៃជីវភាពរស់នៅ។ ដើម្បីសម្រេចនូវគោលដៅនេះ ផែនការអភិវឌ្ឍក្រុងត្រូវមានសកម្មភាព៖

- អភិវឌ្ឍធនធានមនុស្ស
- បង្កើតឱកាសហិរញ្ញប្បទានសម្រាប់ម្ចាស់អាជីវកម្ម និងសហគ្រិនដើម្បីជម្រុញការអភិវឌ្ឍទីផ្សារ
- កសាងហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដើម្បីផ្តល់សេវាកម្ម និងពាណិជ្ជកម្ម
- ជម្រុញឧស្សាហកម្មស្វ័យប្រវត្តិកម្ម ដើម្បីបង្កើតការងារថ្មីៗដែលមានប្រាក់ខែខ្ពស់ជាងមុន ដូចជាការងារណាដែលភ្ជាប់ជាមួយវិស័យហេដ្ឋារចនាសម្ព័ន្ធ ថាមពលកកើតឡើងវិញ និងការអប់រំជាដើម។[95]

**ខ. ផលិតភាព និងការប្រកួតប្រជែង**

របៀបវារៈទីក្រុងថ្មីសង្កត់ធ្ងន់ទៅលើការបង្កើនផលិតភាពសេដ្ឋកិច្ច តាមរយៈការផ្តល់កម្លាំងពលកម្មនូវឱកាសការងារ ចំណេះដឹង ជំនាញ និងការអប់រំ ដើម្បីឱ្យសេដ្ឋកិច្ចក្រុងមានភាពច្នៃប្រឌិត និងមានការប្រកួតប្រជែងខ្ពស់។ យើងអាចឃើញថានគរូបនីយកម្មមានឥទ្ធិពលទៅលើផលិតភាពតាមរយៈទំនាក់ទំនង "**សេដ្ឋកិច្ចដែលមានលក្ខណៈជាក្រុម** (Integrated Urban Management)" ដែលជាប្រភេទសេដ្ឋកិច្ចដែលប្រមូលផ្តុំសេវាកម្ម គ្រួសារ និងធនធានឱ្យនៅជិតគ្នា ដើម្បីអនុញ្ញាតឱ្យពលកររស់នៅជិតកន្លែងការងារ ហើយមានឱកាសសិក្សា។ អាជីវកម្មក៏មានភាពងាយស្រួលក្នុងការទាក់ទងក្រុមហ៊ុនផ្សេងៗក្នុងទីផ្សារ អតិថិជន និងកម្លាំងពលកម្ម ដែលនាំឱ្យផលិតភាពកាន់តែលូតលាស់។

ដើម្បីបំពេញគោលដៅនេះ អាជ្ញាធរមានសមត្ថកិច្ចត្រូវរៀបចំសកម្មភាពមួយចំនួនដូចតទៅ៖

- រៀបចំបទប្បញ្ញត្តិដែលតម្រង់ទិសដៅឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ច ដើម្បីជម្រុញការអភិវឌ្ឍ និងការចូលរួមរបស់ឧស្សាហកម្មនានា
- រៀបចំហេដ្ឋារចនាសម្ព័ន្ធទីក្រុង ដើម្បីងាយស្រួលផ្តល់សេវាមូលដ្ឋានប្រកបដោយសមភាព
- រដ្ឋាភិបាលអាចជួយអភិវឌ្ឍឧស្សាហកម្មនានា តាមរយៈការធ្វើការជាមួយអាជីវកម្ម ក្រុមឧស្សាហកម្ម និងអង្គការមិនរកប្រាក់ចំណេញជាដើម។[96]

---

[95] សៀវភៅ New Urban Agenda Illustrated , អង្គការ UN-Habitat បោះពុម្ពឆ្នាំ២០២០ ទំព័រទី ២០

[96] សៀវភៅ New Urban Agenda Illustrated , អង្គការ UN-Habitat បោះពុម្ពឆ្នាំ២០២០ ទំព័រទី ២៣

### ២.១.១.៣. និរន្តរភាពបរិស្ថាន (Environmental Sustainability)

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាចសម្រេចបាននូវនិរន្តរភាពបរិស្ថានតាមរយៈការប្រើប្រាស់ថាមពលបៃតង រួមជាមួយនឹងមធ្យោបាយប្រើប្រាស់ដែនដី និងធនធានធម្មជាតិប្រកបដោយនិរន្តរភាពនៅពេលអភិវឌ្ឍទីក្រុង។ មិនតែប៉ុណ្ណោះ និរន្តរភាពបរិស្ថានក៏តម្រូវឱ្យមាននូវការការពារប្រព័ន្ធបរិស្ថាន និងជីវៈចម្រុះ ការលើកកម្ពស់ការប្រើប្រាស់ និងផលិតកម្មមាននិរន្តរភាព ការកសាងទីក្រុងធន់រឹងមាំ ការកាត់បន្ថយហានិភ័យនៃគ្រោះធម្មជាតិ ហើយនឹងការកាត់បន្ថយការផ្លាស់ប្តូរអាកាសធាតុ។ ដើម្បីសម្រេចបាននូវនិរន្តរភាពបរិស្ថាន របៀបវារៈទីក្រុងថ្មីបានកំណត់គោលដៅចំនួន ៣ រួមមាន៖

**ក. ការអភិរក្សជីវៈចម្រុះ និងប្រព័ន្ធបរិស្ថាន**

ជីវៈចម្រុះ និងប្រព័ន្ធបរិស្ថាននៃប្រទេស ឬទីក្រុងមួយគឺត្រូវអភិរក្សជានិច្ច ពីព្រោះកាលណាមានការអន់ថយនៃប្រព័ន្ធបរិស្ថានធម្មជាតិ នោះវានឹងនាំឱ្យមានអស្ថិរភាពសេដ្ឋកិច្ច និងហានិភ័យផ្នែកបរិស្ថាន ជាពិសេសសម្រាប់គ្រួសារដែលកំពុងរស់នៅក្នុងភាពក្រីក្រ និងអ្នកដែលរស់នៅក្នុងជាយទីក្រុង។ ដូច្នេះដើម្បីសម្រេចបាននូវការអភិរក្សបរិស្ថាន រដ្ឋាភិបាលត្រូវធ្វើសកម្មភាពមួយចំនួនដូចជា៖

- រៀបចំផែនការអភិវឌ្ឍទីក្រុងដោយរួមបញ្ចូលផ្នែកធម្មជាតិទៅក្នុងផែនការនោះ
- ប្រមូលទិន្នន័យ និងព័ត៌មានដើម្បីរៀបចំផែនការទាក់ទងទៅនឹងប្រព័ន្ធធម្មជាតិ
- ពិនិត្យមើលទៅលើបញ្ហានៃការអន់ថយរបស់បរិស្ថាននៅតាមជាយទីក្រុង
- ដោះស្រាយបញ្ហានៃការចេញប័ណ្ណកម្មសិទ្ធិដីធ្លី និងការអភិវឌ្ឍដីធ្លីក្រៅផ្លូវការ
- លើកទឹកចិត្តឱ្យមានការគោរពទៅដល់គោលការណ៍អភិរក្សជីវៈចម្រុះ និងប្រព័ន្ធបរិស្ថាន
- វាយតម្លៃទៅលើយុទ្ធសាស្ត្រទាក់ទងនឹងបរិស្ថាននៅក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងគម្រោងអភិវឌ្ឍន៍ទីក្រុងទាំងឡាយ។[97]

**ខ. ភាពធន់រឹងមាំ និងការបន្សាំទៅនឹងការផ្លាស់ប្តូរអាកាសធាតុ**

ចំពោះគោលដៅនេះ ការបន្សាំ សំដៅទៅដល់ការផ្លាស់ប្តូរការអភិវឌ្ឍបច្ចុប្បន្ន ដើម្បីសម្របខ្លួនទៅនឹងបរិស្ថានដែលកំពុងផ្លាស់ប្តូរ។ រីឯភាពធន់រឹងមាំ សំដៅដល់ស្ថានភាពសង្គម សេដ្ឋកិច្ច និងបរិស្ថានដែលនាំឱ្យសហគមន៍មួយអាចទប់ទល់នឹងឥទ្ធិពលនៃការផ្លាស់ប្តូរអាកាសធាតុបាន។

ដូច្នេះ ដើម្បីសម្រេចគោលដៅនេះ ផែនការអភិវឌ្ឍក្រុងត្រូវ៖

- បង្កើតយុទ្ធសាស្ត្រដែលអនុញ្ញាតឱ្យទីក្រុង ពិនិត្យនូវសមត្ថភាពរបស់ខ្លួន ក្នុងការដោះស្រាយបញ្ហាប្រឈមចំពោះការផ្លាស់ប្តូរអាកាសធាតុ ហើយផ្តល់នូវវេទិកាសម្រាប់ប្រមូលផ្តុំធនធានសមស្រប

[97] សៀវភៅ New Urban Agenda Illustrated, អង្គការ UN-Habitat បោះពុម្ពឆ្នាំ២០២០ ទំព័រទី ២៩

- រៀបចំគោលនយោបាយប្រើប្រាស់ដីធ្លីសម្រាប់ភាពធន់នឹងការផ្លាស់ប្តូរអាកាសធាតុ ដូចជាការបន្ថយកម្រិតអភិវឌ្ឍនៅតំបន់ដែលមានហានិភ័យខ្ពស់
- បង្កើតគោលនយោបាយជាក់លាក់ សម្រាប់ប្រភេទនីមួយៗនៃហានិភ័យគ្រោះធម្មជាតិ ដូចជាទឹកជំនន់ គ្រោះរាំងស្ងួត និងបញ្ហាការគ្រប់គ្រងធនធានផ្សេងៗ
- រៀបចំថវិកាសម្រាប់វិធានការបន្សាំនៅថ្នាក់មូលដ្ឋានតាមរយៈប្រភពហិរញ្ញវត្ថុផ្សេងៗ ហើយរៀបចំថវិកាសម្រាប់ស្តារឡើងវិញនូវស្ថានភាពសហគមន៍ មុនការកើតឡើងនៃគ្រោះមហន្តរាយ
- បង្កើតប្រព័ន្ធព័ត៌មានដែលអាចព្រមានពីគ្រោះមហន្តរាយទៅដល់សមាជិកសាធារណៈ
- រៀបចំហេដ្ឋារចនាសម្ព័ន្ធ ស្ថាប័ន និងអគារដែលមានស្រាប់ឱ្យធន់នឹងគ្រោះមហន្តរាយ។[98]

**គ. ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ**

យើងអាចឃើញថានាពេលបច្ចុប្បន្ន ទីក្រុងកំពុងអភិវឌ្ឍយ៉ាងឆាប់រហ័ស។ ហេតុនេះហើយ ដើម្បីឱ្យការអភិវឌ្ឍនោះមិនមានការខាតបង់ ឬប៉ះពាល់ដល់បរិស្ថាន របៀបវារៈទីក្រុងថ្មីបានជម្រុញឱ្យទីក្រុងនីមួយៗរៀបចំគោលនយោបាយ និងមធ្យោបាយផ្សេងៗដើម្បីបន្ថយឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ពិសេសដោយលើកកម្ពស់សកម្មភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឱ្យអនុវត្តការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ ដើម្បីឈានដល់គោលដៅនេះ ផែនការអភិវឌ្ឍទីក្រុងត្រូវមាន៖

- រៀបចំផែនការប្រើប្រាស់ដីរួមគ្នា និងរៀបចំទីក្រុងឱ្យមានដង់ស៊ីតេមធ្យម ដើម្បីជម្រុញការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនសាធារណៈ និងកាត់បន្ថយការបញ្ចេញឧស្ម័នពុលតាមរយៈការធ្វើដំណើរ
- បង្កើតប្រព័ន្ធអគ្គិសនីនៅតាមសហគមន៍ ដែលប្រើប្រាស់ថាមពលកកើតឡើងវិញ
- អភិវឌ្ឍប្រភពហិរញ្ញប្បទានសម្រាប់ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងបង្កើតយន្តការ សម្រាប់ឱ្យម្ចាស់ផ្ទះ និងម្ចាស់អាជីវកម្មងាយស្រួលរៀបចំអគារសម្រាប់ការកាត់បន្ថយហានិភ័យ
- វិនិយោគលើការកែលម្អហេដ្ឋារចនាសម្ព័ន្ធដែលបានសាងសង់រួចឱ្យមានភាពត្រជាក់
- អភិវឌ្ឍគោលនយោបាយគ្រប់គ្រងអគារដែលមានការបំភាយឧស្ម័នផ្ទះកញ្ចក់ខ្ពស់
- ធានាថាថវិកាវិស័យសាធារណៈនឹងត្រូវវិនិយោគទៅលើបច្ចេកវិទ្យាដែលបំភាយឧស្ម័នផ្ទះកញ្ចក់ទាប

[98] សៀវភៅ New Urban Agenda Illustrated , អង្គការ UN-Habitat បោះពុម្ពឆ្នាំ២០២០ ទំព័រទី ៣៣

- រួមបញ្ចូលគោលការណ៍សេដ្ឋកិច្ចរាងជារង្វង់ (Circular Economy)[99] គោលការណ៍គ្រប់គ្រងសំណល់និរន្តរភាព និងគោលការណ៍ប្រើប្រាស់វត្ថុធាតុដើមឡើងវិញ ដើម្បីឱ្យការអភិវឌ្ឍទីក្រុងមាននិរន្តរភាព។[100]

**២.១.១.៤. និរន្តរភាពនៃលំហទីក្រុង** ( Spatial Sustainability )

របៀបវារៈទីក្រុងថ្មីបានបញ្ជាក់ថា លក្ខណៈលំហនៃទីក្រុងមួយអាចពង្រឹងលទ្ធភាព បង្កើតតម្លៃសង្គម តម្លៃសេដ្ឋកិច្ច តម្លៃបរិស្ថាន និងសុខុមាលភាពសម្រាប់ប្រជាជន។ ដូច្នេះ រដ្ឋាភិបាលត្រូវតែសម្រេចឱ្យបាននូវនិរន្តរភាពនៃលំហទីក្រុងតាមរយៈការរចនាទម្រង់រូបវន្តនៃបរិស្ថានទីក្រុង ដើម្បីបង្កើនឱកាសការងារ ការទទួលបានលំនៅឋាន និងគុណភាពសហគមន៍ប្រកបដោយសមភាព។ ទម្រង់រូបវន្តនៃទីក្រុងមួយមានសារៈសំខាន់ណាស់សម្រាប់សុខុមាលភាពសង្គម សេដ្ឋកិច្ច និងគុណភាពនៃបរិស្ថានក្នុងទីក្រុង។ និរន្តរភាពនៃលំហទីក្រុងនេះកំណត់គោលដៅ ២ ដែលមានៈ

**ក. និរន្តរភាពលំហទីក្រុង និងសមភាព**

ការអភិវឌ្ឍឆាប់រហ័សពេករបស់ទីក្រុងមួយ អាចធ្វើឱ្យប្រជាជនក្រីក្រ មិនមានលទ្ធភាពទទួលសេវាសាធារណៈចាំបាច់។ ម្យ៉ាងទៀត ទីក្រុងដែលមានដង់ស៊ីតេប្រជាជនខ្ពស់ពេក ដោយមិនគិតពីបញ្ហានៃលទ្ធភាពសេវា កន្លែងបើកចំហ និងបរិស្ថានធម្មជាតិអាចនាំឱ្យមានការកកស្ទះ ភាពមិនអាចគ្រប់គ្រងបាន ភាពមិនអាចទទួលបានសេវាសាធារណៈ និងបញ្ហាសុខភាពមួយចំនួន។ ដូចនេះ ការអនុវត្តគោលដៅនេះពឹងផ្អែកទៅលើការអនុវត្តនៃគោលការណ៍ និងសកម្មភាពនៃគោលដៅបន្ទាប់របស់និរន្តរភាពលំហនេះ។[101]

**ខ. និរន្តរភាពលំហទីក្រុង និងដង់ស៊ីតេប្រជាជនក្នុងទីក្រុង**

ដង់ស៊ីតេប្រជាជន សំដៅទៅដល់ចំនួនប្រជាជនធៀបទៅនឹងផ្ទៃដីទាំងមូលនៃទីក្រុង។ ជាទូទៅ បញ្ហាសំខាន់នៃនិរន្តរភាព គឺកើតឡើងដោយសារដង់ស៊ីតេប្រជាជនខ្ពស់ពេក ជាមួយនឹងការប្រមូលផ្តុំលើសលប់នៃស្ថាប័ន ទំនិញ និងសេវាកម្ម។ ប៉ុន្តែ ទោះបីការអភិវឌ្ឍទីក្រុងមានសារៈសំខាន់ខ្លាំង និងល្បឿនលឿនក៏ដោយក៏អាជ្ញាធរមានសមត្ថកិច្ច ត្រូវតែរក្សានូវតុល្យភាពរវាងការរីកចម្រើននៃផ្ទៃដីទីក្រុង ជាមួយនឹងដង់ស៊ីតេប្រជាជន ហើយក៏ត្រូវពិនិត្យមើលកម្រិតអភិវឌ្ឍនៃហេដ្ឋារចនាសម្ព័ន្ធចាំបាច់ សេវាកម្មសាធារណៈ និងលំនៅឋាន។

[99] នៅក្នុងសេដ្ឋកិច្ចធម្មតា វត្ថុធាតុដើមត្រូវបានផលិតក្លាយជាផលិតផល ត្រូវបានប្រើប្រាស់ ហើយបន្ទាប់មកក្លាយជាកាកសំណល់។ ប៉ុន្តែសេដ្ឋកិច្ចរាងជារង្វង់ (Circular Economy) សំដៅទៅលើប្រភេទសេដ្ឋកិច្ចមួយដែលពន្យារអាយុកាលនៃផលិតផល ដោយនាំកាកសំណល់ ឬផលិតផលចុងក្រោយមកប្រើប្រាស់ក្នុងដំណើរការផលិតម្តងទៀត។

[100] សៀវភៅ New Urban Agenda Illustrated , អង្គការ UN-Habitat បោះពុម្ពឆ្នាំ២០២០ ទំព័រទី ៤១

[101] សៀវភៅ New Urban Agenda Illustrated , អង្គការ UN-Habitat បោះពុម្ពឆ្នាំ២០២០ ទំព័រទី ៤៧

ផែនការអភិវឌ្ឍក្រុងត្រូវមាន៖

- ការអភិវឌ្ឍទីក្រុងត្រូវមានការកំណត់ល្បឿននៃការអភិវឌ្ឍ ដោយល្បឿននោះអាចបត់បែនបាន ដើម្បីងាយស្រួលវាយតម្លៃទៅតាមកាលៈទេសៈនៃស្ថានភាពអភិវឌ្ឍន៍នៃទីក្រុង
- រៀបចំក្រុងឱ្យមានមជ្ឈមណ្ឌលការងារ និងពាណិជ្ជកម្មច្រើន ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការប្រមូលផ្តុំលើសលប់នៃប្រជាជន និងក្រុមហ៊ុនអាជីវកម្មនៅទីកន្លែងមួយ
- អាជ្ញាធរមានសមត្ថកិច្ចនានា អាចផ្តោតសំខាន់ទៅលើតំបន់ដែលមានដង់ស៊ីតេប្រជាជនទាប ដើម្បីងាយស្រួលអនុវត្តផែនការធ្វើឱ្យអាជីវកម្មនៅតំបន់នោះមានភាពប្រសើរឡើងវិញ ជាមួយនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅតំបន់នោះ។[102]

## ២.១.២. រៀបចំវារៈទីក្រុងថ្មីនៅក្នុងបរិបទប្រទេសកម្ពុជា

នៅក្នុងស្ថានភាពបច្ចុប្បន្ន ប្រទេសកម្ពុជាបានទទួលនូវសន្តិភាព សុវត្ថិភាព និងស្ថិរភាពនយោបាយ ប៉ុន្តែយើងអាចឃើញថានៅមានបញ្ហាប្រឈមដ៏សំខាន់ ពោលគឺថាចំនួនប្រជាជននៅក្នុងទីក្រុងមានការកើនឡើងលឿនជាងប្រជាជននៅតាមជនបទ ដែលនាំឱ្យមានបញ្ហានៃការបង្កើតការងារ ការទទួលបានសេវាកម្មសាធារណៈ និងបញ្ហាផ្សេងទៀតក្នុងការរៀបចំទីក្រុង ដែលជាហេតុនាំឱ្យស្ថានភាពរស់នៅក្នុងទីក្រុងមិនសូវមាននិរន្តរភាព។

នៅក្នុងចំណុចនេះ យើងនឹងពិនិត្យមើលលើបញ្ហាប្រឈមក្នុងការរៀបចំទីក្រុងភ្នំពេញ ជាមួយនឹងដំណោះស្រាយពីរបៀបវារៈទីក្រុងថ្មីដែលអាចប្រើប្រាស់បាន។

### ២.១.២.១. បញ្ហានគរូបនីយកម្ម

ការគ្រប់គ្រងផ្នែកនគរូបនីយកម្មនៃរាជធានីភ្នំពេញ កំពុងស្ថិតក្នុងដំណាក់កាលក្មេងខ្ចីនៅឡើយបើធៀបទៅនឹងទីក្រុងអភិវឌ្ឍន៍ផ្សេងៗទៀត។ តែទោះជាយ៉ាងណាក៏ដោយ ក៏យើងឃើញថាយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងថ្នាក់ជាតិត្រូវបានបង្កើតនៅចុងឆ្នាំ២០១៥ ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ជាមួយនឹងធនាគារអភិវឌ្ឍន៍អាស៊ី និងមូលនិធិជប៉ុន។ យុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងថ្នាក់ជាតិ មានគោលបំណងដោះស្រាយបញ្ហាផ្សេងៗនៅក្នុងទីក្រុងភ្នំពេញ តាមរយៈការសង្កត់ធ្ងន់ទៅលើការអភិវឌ្ឍនៃតំបន់នៅក្នុងក្រុងដែលមិនទាន់មានការអភិវឌ្ឍនៅឡើយ ពីព្រោះទីក្រុងភ្នំពេញកំពុងអភិវឌ្ឍយ៉ាងលឿន ដែលនាំឱ្យមានភាពចាំបាច់ក្នុងការគ្រប់គ្រងកម្រិតនៃការអភិវឌ្ឍនេះឱ្យបានត្រឹមត្រូវ ដើម្បីនាំមកនូវនិរន្តរភាព និងសមភាពនៃការអភិវឌ្ឍរវាងទីក្រុងតំបន់ជាយក្រុង និងតំបន់ជនបទ។ ប៉ុន្តែ ទោះបីអាជ្ញាធរមានសមត្ថកិច្ចមានយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងទាំងនេះក៏ដោយ ក៏នៅតែមានបញ្ហាប្រឈមមួយចំនួនដែរ ដែលយើងនឹងពិភាក្សាខាងក្រោម។

[102] សៀវភៅ New Urban Agenda Illustrated , អង្គការ UN-Habitat បោះពុម្ពឆ្នាំ២០២០ ទំព័រទី ៤៨

**ក. បញ្ហាប្រឈមផ្នែកប្រជាសាស្ត្រនៅទីក្រុង**

នគរូបនីយកម្ម និងការអភិវឌ្ឍដ៏ឆាប់រហ័សនៃទីក្រុងភ្នំពេញ នាំឱ្យមានសម្ពាធលើហេដ្ឋារចនាសម្ព័ន្ធ ហើយនាំឱ្យមានផលប៉ះពាល់ និងការលំបាកដល់ក្រុមងាយរងគ្រោះ ក្នុងការទទួលសេវាសាធារណៈ។ ក្រុមមួយដែលងាយរងគ្រោះខ្លាំងនោះគឺ ក្រុមយុវជន។ នេះគឺដោយសារឱកាសការងារក្នុងវិស័យធំៗ ដូចជាវិស័យសាងសង់ វិស័យឧស្សាហកម្ម និងវិស័យកាត់ដេរ ពុំលូតលាស់គ្រប់គ្រាន់ដើម្បីផ្តល់ការងារឱ្យយុវជនទាំងនោះឡើយ។ ម៉្យាងវិញទៀត កង្វះនៃការអប់រំជំនាញរឹង និងជំនាញទន់នឹងនាំឱ្យមានការងារដែលមានគុណភាពទាប ដែលនឹងជះឥទ្ធិពលអវិជ្ជមានដល់សេដ្ឋកិច្ចនៃប្រទេសទាំងមូល។ ទោះជាយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគោលនយោបាយសម្រាប់យុវជនក្នុងឆ្នាំ ២០១១ ជាពិសេសដោយផ្តោតលើការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ (TVET) តាមរយៈកិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលផ្សេងៗ។

រីឯក្រុមមនុស្សចាស់ជរា ក៏មានបញ្ហាប្រឈមដែរ ពីព្រោះសព្វថ្ងៃនេះមិនមានស្ថាប័នណាមួយផ្តោតសំខាន់លើការរៀបចំ និងគ្រប់គ្រងផែនការគេហដ្ឋានសម្រាប់ជនចាស់ជរាឡើយ។ គោលនយោបាយនគរូបនីយកម្មនៃទីក្រុងភ្នំពេញបច្ចុប្បន្នមិនបានពិចារណាទៅលើបញ្ហានៃកំណើនចំនួនមនុស្សចាស់ជរានោះទេ បើទោះបីកម្រិតនៃកំណើននេះកាន់តែលឿនទៅៗ ជាពិសេសនៅក្នុងតំបន់អនាធិបតេយ្យ។ បញ្ហានេះអាចបង្កឱ្យក្រុមមនុស្សចាស់ជរាមានភាពឯកោក្នុងសង្គម គ្មានអនាម័យនៅក្នុងសហគមន៍ និងមិនទទួលបានសេវាសុខាភិបាលត្រឹមត្រូវ។

ចុងក្រោយ ពលរដ្ឋភេទស្រី ក៏ប្រឈមនឹងបញ្ហាខ្លះដែរ ជាពិសេសទាក់ទងទៅនឹងសមភាពផ្លូវភេទ និងការទទួលបានសេវាមូលដ្ឋាននៅក្នុងទីក្រុង។ ម៉្យាងវិញទៀត មានការខ្វះខាតនៃសមាជិកស្ត្រីនៅក្នុងតំណែងជាអ្នកដឹកនាំ ហើយមិនមានច្បាប់ ឬគោលការណ៍អភិវឌ្ឍធនធានមនុស្សភេទស្រីឡើយ ដើម្បីឱ្យពួកគេក្លាយជាអ្នកដឹកនាំ។ លើសពីនេះទៅទៀត នៅក្នុងសហគមន៍ដែលមានគ្រួសារក្រីក្រ យើងអាចឃើញថាគ្រួសារទាំងនោះច្រើនត្រូវបានដឹកនាំដោយមេផ្ទះភេទស្រី ដែលជាសម្ពាធបន្ថែមទៅលើពួកគេ។[103]

**ខ. ផែនការដីធ្លី និងទីប្រជុំជន**

ដូចដែលបានបកស្រាយនៅចំណុចខាងលើ ប្រទេសកម្ពុជាមានការលូតលាស់យ៉ាងឆាប់រហ័សចំពោះផ្នែកនគរូបនីយកម្ម ជាពិសេសសម្រាប់ទីក្រុងភ្នំពេញ។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅមានបញ្ហាប្រឈមទាក់ទងទៅនឹងការអភិវឌ្ឍដោយនិរន្តរភាព ការគ្រប់គ្រងដីធ្លី សមត្ថភាពបច្ចេកទេស និងការដោះស្រាយបញ្ហាចល័តនៅតាមទីក្រុង។ បញ្ហាប្រឈមទាំងនេះ គឺកើតឡើងដោយសារការខ្វះខាតនូវតម្លាភាព និងចំណេះដឹង

---

[103] សៀវភៅ Cambodia National Report For Habitat III Preparation , អគ្គនាយកដ្ឋានលំនៅឋាន បោះពុម្ពឆ្នាំ២០១៦ ទំព័រទី ១៥

បច្ចេកទេសទៅលើការរៀបចំផែនការមេនៃទីក្រុងភ្នំពេញ ដែលនាំឱ្យមាននូវការអភិវឌ្ឍក្នុងក្រុងដោយគ្មានផែនការជាក់លាក់។

ម្យ៉ាងវិញទៀត សព្វថ្ងៃនេះទីក្រុងភ្នំពេញមានផែនការមេសម្រាប់ការរៀបចំចរាចរណ៍នៅក្នុងទីក្រុងភ្នំពេញ ប៉ុន្តែដោយសារមានការខ្វះខាតនូវមធ្យោបាយដឹកជញ្ជូនសាធារណៈនៅតាមទីក្រុង នោះនាំឱ្យមានការកើនឡើងនៃការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនឯកជន ដែលធ្វើឱ្យមានការបំពុលបរិយាកាស និងបញ្ហាសុខភាពផ្សេងៗ ហើយការខ្វះខាតនៃចំនួនមធ្យោបាយដឹកជញ្ជូនសាធារណៈនេះ ក៏មានឥទ្ធិពលអវិជ្ជមានទៅលើក្រុមដែលងាយរងគ្រោះផងដែរ ដោយសារពួកគេច្រើនរស់នៅតាមជាយក្រុង។[104]

**គ. បរិស្ថាន និងនគរូបនីយកម្ម**

ទោះបីមានការខិតខំប្រឹងប្រែងពីរាជរដ្ឋាភិបាលក៏ដោយ ក៏យើងអាចសង្កេតឃើញថាយុទ្ធសាស្ត្រដើម្បីកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយនៅក្នុងទីក្រុងភ្នំពេញនៅមានភាពខ្វះខាតនៅឡើយទេ។ ការខ្វះខាតនេះគឺដោយសារមិនមានក្របខណ្ឌ ឬគោលនយោបាយច្បាស់លាស់តាមថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ដើម្បីកាត់បន្ថយនូវហានិភ័យនៃគ្រោះមហន្តរាយ។ បន្ថែមពីនេះទៅទៀត ក៏មិនសូវមានសមាហរណកម្មសម្រាប់ការកាត់បន្ថយហានិភ័យនៃការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយទៅក្នុងផែនការអភិវឌ្ឍន៍ទីក្រុងភ្នំពេញឡើយ។

បញ្ហាប្រឈមមួយទៀត គឺអសមត្ថភាពនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ពីព្រោះមានការខ្វះខាតនូវធនធាន និងសមត្ថភាពដើម្បីបំពេញភារកិច្ច រួមជាមួយនឹងភាពមានកម្រិតនៃបច្ចេកវិទ្យារបស់គណៈកម្មាធិការនោះ ជាពិសេសទាក់ទងទៅនឹងការផ្សព្វផ្សាយព័ត៌មាននៃគ្រោះមហន្តរាយដល់ប្រជាពលរដ្ឋ។ លើសពីនេះទៅទៀត ការបែងចែកតួនាទី និងការទទួលខុសត្រូវដែលទាក់ទងទៅនឹងការត្រួតពិនិត្យ និងវាយតម្លៃនៃគម្រោងអភិវឌ្ឍពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិមិនសូវមានភាពច្បាស់លាស់ទេ ដែលធ្វើឱ្យមានភាពលំបាកក្នុងការបង្កើតផែនការសមស្របដើម្បីគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយ។[105]

**ឃ. បទប្បញ្ញត្តិ និងការគ្រប់គ្រងទីក្រុង**

បើធៀបទៅនឹងកម្រិតនៃការលូតលាស់យ៉ាងលឿនរបស់ទីក្រុងភ្នំពេញ ការលូតលាស់នៃបទប្បញ្ញត្តិ និងគោលនយោបាយនគរូបនីយកម្មនៅមានភាពយឺតយ៉ាវនៅឡើយ។ លើសពីនេះ ការអនុវត្តនៃបទប្បញ្ញត្តិ និងគោលនយោបាយដែលបានបង្កើតរួចនៅតែមានបញ្ហាប្រឈមមួយចំនួន ជាពិសេសនៅថ្នាក់ក្រោមជាតិដោយសារតែការខ្វះខាតនៃសមត្ថភាព និងធនធានមនុស្ស និងបច្ចេកទេស។ មិនតែប៉ុណ្ណោះ មានចំនួនគ្រួសារជាច្រើនដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រ ដោយមិនសូវមានការផ្តោតសំខាន់ទៅលើការកាត់បន្ថយភាពក្រីក្រក្នុង

[104] សៀវភៅ Cambodia National Report For Habitat III Preparation , អគ្គនាយកដ្ឋានលំនៅឋាន បោះពុម្ពឆ្នាំ២០១៦ ទំព័រទី ២៣

[105] សៀវភៅ Cambodia National Report For Habitat III Preparation , អគ្គនាយកដ្ឋានលំនៅឋាន បោះពុម្ពឆ្នាំ២០១៦ ទំព័រទី ៣០

យុទ្ធសាស្ត្រអភិវឌ្ឍទីក្រុងឡើយ។ ទោះបីមានកម្មវិធី "IDPoor" [106] ដើម្បីផ្តល់ជំនួយដល់គ្រួសារក្រីក្រក៏ដោយ (តាមរយៈការកំណត់ថាគ្រួសារណាកំពុងរស់នៅក្រោមបន្ទាត់ភាពក្រីក្រ) ក៏កម្មវិធីនេះមិនទាន់មានភាពគ្រប់គ្រាន់ឡើយ ជាពិសេសសម្រាប់គ្រួសារនៅតំបន់ជាយក្រុង។

ក្រៅពីនេះទៅទៀត ប្រជាពលរដ្ឋនៃទីក្រុងភ្នំពេញនៅតែប្រឈមមុខនឹងបញ្ហាសន្តិសុខ និងសុវត្ថិភាព ពោលគឺនៅមានឧក្រិដ្ឋកម្ម គ្រោះមហន្តរាយ និងគ្រោះថ្នាក់ចរាចរណ៍ ហើយកង្វះនៃការអនុវត្តបទប្បញ្ញត្តិពេញលេញជាមួយនឹងតម្លាភាពមិនគ្រប់គ្រាន់ក៏នាំឱ្យមានការកើនឡើងនៃអំពើពុករលួយដែរ។[107]

**ង. សេដ្ឋកិច្ចទីក្រុង**

សព្វថ្ងៃនេះ កម្រិតនៃការលូតលាស់សេដ្ឋកិច្ចទីក្រុងភ្នំពេញ ខ្វះនូវសមភាពតាមតំបន់ ដោយសារការលូតលាស់នៃសេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធច្រើនកើតមាននៅតំបន់កណ្តាលនៃទីក្រុងភ្នំពេញ ដោយមិនសូវមានការអភិវឌ្ឍលឿនលឿននៅតាមជាយក្រុងឡើយ។ រីឯសេវាតាមឃុំ-សង្កាត់ក៏ប្រឈមមុខនឹងបញ្ហាដែរ ដោយសារមានកម្រិតនៃធនធានហិរញ្ញវត្ថុ ជាមួយនឹងដំណើរការរដ្ឋបាលស្មុគស្មាញ ដែលបណ្តាលឱ្យមានកង្វះប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ ហើយក៏មានកង្វះនៃទិន្នន័យទៅលើការចំណាយ និងការវិនិយោគសាធារណៈដែរ ដែលជាកត្តាមួយដ៏សំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៃទីក្រុងមួយឱ្យមាននិរន្តរភាព។

កង្វះនៃទិន្នន័យនេះក៏មានផលប៉ះពាល់ទៅដល់ការរៀបចំផែនការអភិវឌ្ឍលំនៅឋានផងដែរ ជាពិសេសទាក់ទងនឹងចំនួន តម្រូវការ និងតម្លៃរបស់វា។ ហើយបញ្ហានេះក៏បង្កឱ្យមានការខ្វះខាតនៃហិរញ្ញប្បទានសម្រាប់ការសាងសង់ និងការទិញលំនៅឋានសម្រាប់គ្រួសារក្រីក្រក្នុងទីក្រុងភ្នំពេញផងដែរ។

មួយវិញទៀត ស្ថានភាពកន្លែងធ្វើការងារ តាមក្រុមហ៊ុន និងរោងចក្រមិនសូវមានស្តង់ដារដូចគ្នាឡើយ ដោយក្រុមហ៊ុន ឬរោងចក្រនីមួយៗផ្តល់ប្រាក់ឈ្នួលអប្បបរមាខុសៗគ្នា រួមជាមួយនឹងការអភិវឌ្ឍធនធានមនុស្សដែលមិនមានភាពស្មើគ្នាដែរ។ ម៉្យាងទៀត ទីក្រុងភ្នំពេញក៏កំពុងប្រឈមមុខនឹងបញ្ហានៃកង្វះចំនួនពលករជំនាញ និងកម្មវិធីអប់រំបច្ចេកទេស និងវិជ្ជាជីវៈដែលទាន់សម័យ ហើយបច្ចុប្បន្ន មន្ត្រីអធិការកិច្ចការងារភាគច្រើនមិនមានជំនាញគ្រប់គ្រាន់ឡើយ ដើម្បីគ្រប់គ្រងស្ថានភាពនៃកន្លែងធ្វើការងារប្រកបដោយប្រសិទ្ធភាព ជាពិសេសក្នុងអាជីវកម្មឯកជន។[108]

[106] សំដៅដល់កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដែលជាឧបករណ៍ដែលមានលក្ខណៈស្តង់ដាររួមមួយ ដើម្បីកំណត់កក្រុមគោលដៅ សម្រាប់អនុវត្តវិធានការជួយដល់ប្រជាជនក្រីក្រ

[107] សៀវភៅ Cambodia National Report For Habitat III Preparation , អគ្គនាយកដ្ឋានលំនៅឋាន បោះពុម្ពឆ្នាំ២០១៦ ទំព័រទី ៤០

[108] សៀវភៅ Cambodia National Report For Habitat III Preparation , អគ្គនាយកដ្ឋានលំនៅឋាន បោះពុម្ពឆ្នាំ២០១៦ ទំព័រទី ៥០

### ច. លំនៅឋាន និងសេវាកម្មមូលដ្ឋាន

ការសិក្សាស្រាវជ្រាវមួយដែលបានធ្វើឡើងនៅឆ្នាំ ២០១២ បានប៉ាន់ស្មានថាយ៉ាងហោចណាស់មានប្រជាជនចំនួន ២៥០ ០០០នាក់ រស់នៅក្នុងលំនៅឋានដែលមានស្ថានភាពមិនល្អ។[109] ទោះបីជាមានការបង្កើតនូវគោលនយោបាយគាំទ្រគ្រួសារក្រីក្រក៏ដោយ ក៏គេឃើញនៅភាពមានខ្វះខាតទាក់ទងទៅនឹងគោលនយោបាយដើម្បីដោះស្រាយបញ្ហាលំនៅឋានអនាធិបតេយ្យនៅក្នុងទីក្រុងភ្នំពេញ និងតំបន់ជាយក្រុង។ គោលនយោបាយលំនៅឋានបច្ចុប្បន្នគួរផ្តោតសំខាន់ទៅលើការអភិវឌ្ឍ និងកែលម្អនៃលំនៅឋានអនាធិបតេយ្យ ដោយមានការចូលរួមផ្តល់ពីសហគមន៍ ឬគ្រួសារដែលរស់នៅតំបន់នោះ ជាពិសេសតាមរយៈការសហការជាមួយ UPDF[110] និង CDF[111] ។ ក៏ប៉ុន្តែ ការអនុវត្តនេះនៅតែមានបញ្ហាប្រឈមមួយចំនួន ដោយសារតែកង្វះនៃទិន្នន័យ ធនធាន និងការដឹកនាំផ្នែកនយោបាយសមស្រប។

ម្យ៉ាងវិញទៀត ការផ្គត់ផ្គង់ទឹក និងរក្សានូវអនាម័យនៃទីក្រុងភ្នំពេញមានការរីកចម្រើនជាច្រើន ប៉ុន្តែវិស័យទាំងនេះនៅជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួន។ ជាពិសេស ប្រព័ន្ធផ្គត់ផ្គង់ទឹកតូចៗនៅតាមជាយក្រុងមិនសូវមានប្រសិទ្ធភាពពេញលេញឡើយបើធៀបនឹងប្រព័ន្ធផ្គត់ផ្គង់ទឹកតាមទីប្រជុំជន។ ប្រព័ន្ធផ្គត់ផ្គង់ទឹកតាមជាយក្រុងទាំងនេះច្រើនខ្វះការថែទាំដែលនាំឱ្យតំបន់ទាំងនោះពឹងផ្អែកភាគច្រើនទៅលើការជំនួយពីដៃគូអភិវឌ្ឍន៍។

ចំណែកឯការផ្គត់ផ្គង់អគ្គិសនីវិញ យើងអាចឃើញថាក្នុងចំណោមទីក្រុងអាស៊ីផ្សេងៗ ទីក្រុងភ្នំពេញមានតម្លៃអគ្គិសនីដ៏ខ្ពស់។ មិនតែប៉ុណ្ណោះ កម្រិតនៃការប្រើប្រាស់ថាមពលក៏មានលក្ខណៈខ្ពស់ដែរ ដែលបានប៉ាន់ស្មានថានឹងកើនយ៉ាងខ្លាំងនាពេលអនាគត ភាគច្រើនដោយសារមធ្យោបាយដឹកជញ្ជូនឯកជន។ ការអនុវត្តថាមពលវារីអគ្គិសនី និងថាមពលពន្លឺព្រះអាទិត្យបច្ចុប្បន្ននេះមិនទាន់មានប្រសិទ្ធភាពឡើយ ដោយមានបញ្ហាប្រឈមជាច្រើន ជាពិសេសទាក់ទងទៅនឹងហិរញ្ញប្បទាន និងការវិនិយោគពីវិស័យឯកជន។ លើសពីនេះទៀត ប្រទេសកម្ពុជាមិនទាន់មានបច្ចេកវិទ្យា និងការគាំទ្រផ្នែកហិរញ្ញវត្ថុចាំបាច់ ដើម្បីឱ្យប្រទេសកម្ពុជាអាចចូលដំណើរការទៅក្នុងទីផ្សារកាបូនឡើយ។[112]

109 របាយការណ៍ The Phnom Penh Urban Poor Assessment , រដ្ឋបាលរាជធានីភ្នំពេញ បោះពុម្ពឆ្នាំ២០១២ ទំព័រទី ៥

110 Urban Poor Development Fund (មូលនិធិអភិវឌ្ឍន៍ជនក្រីក្រក្នុងទីក្រុង)

111 Community Development Fund (មូលនិធិអភិវឌ្ឍន៍សហគមន៍កម្ពុជា)

112 ទីផ្សារកាបូន (Carbon Market) សំដៅទៅដល់ប្រព័ន្ធទីផ្សារមួយ ដែលមានគោលបំណងកម្រិតការបំភាយនៃឧស្ម័នផ្ទះកញ្ចក់ តាមរយៈការធ្វើពាណិជ្ជកម្មទៅលើ "សិទ្ធិបំភាយឧស្ម័នផ្ទះកញ្ចក់" ដូចជាពន្ធដារកាបូន ឬឥណទាន

### ២.១.២.២. ដំណោះស្រាយនៃរបៀបវារៈទីក្រុងថ្មីដែលអាចអនុវត្ត នៅក្នុងបរិបទនៃប្រទេសកម្ពុជា

ទោះបីរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំងនឹងបញ្ហាប្រឈមដែលបានរៀបរាប់ខាងលើក៏ដោយ ក៏នៅមានបញ្ហាជាច្រើនដែលត្រូវការការយកចិត្តទុកដាក់ពីបណ្តារាជរដ្ឋាភិបាលដែលយើងបានរៀបរាប់នៅចំណុចខាងលើ។ ជាពិសេស ផែនការអភិវឌ្ឍនៃទីក្រុងភ្នំពេញត្រូវមានការរួមបញ្ចូលនូវវិធានការនិរន្តរភាពមួយចំនួនដែលទាក់ទងទៅនឹងមធ្យោបាយដឹកជញ្ជូន ស្ថានភាពរស់នៅរបស់ប្រជាជនដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រ ផលិតកម្មនៃថាមពលស្អាត និងកំណើនសេដ្ឋកិច្ចដោយនិរន្តរភាព។

ក្នុងចំណុចនេះ យើងនឹងលើកឡើងនូវដំណោះស្រាយមួយចំនួនចំពោះបញ្ហាខាងលើ ដែលសមស្របទៅនឹងគោលការណ៍ និងការណែនាំរបស់របៀបវារៈទីក្រុងថ្មី។

#### ក. បញ្ហាប្រឈមផ្នែកប្រជាសាស្ត្រទីក្រុង

ជាដំបូង គោលការណ៍ដ៏សំខាន់ដែលអាចជួយក្នុងដំណើរការបង្កើតគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍទីក្រុងភ្នំពេញនោះ គឺការប្រមូលផ្តុំទិន្នន័យទីក្រុងភ្នំពេញឱ្យបានគ្រប់គ្រាន់តាមរយៈបច្ចេកវិទ្យា និងស្ថាប័នសមស្រប។ ដើម្បីអនុវត្តគោលការណ៍នេះបានសម្រេច រាជរដ្ឋាភិបាលមានគោលបំណងបង្កើតវិទ្យាស្ថានជាតិរៀបចំផែនការទីក្រុង ដើម្បីផ្តល់ជំនួយក្នុងការបង្កើត និងគ្រប់គ្រងគោលនយោបាយនគរូបនីយកម្ម តាមរយៈការប្រមូលផ្តុំ និងផ្តល់នូវទិន្នន័យ សូចនាករ និងស្ថិតិផ្សេងៗរបស់ទីក្រុងភ្នំពេញ។ លើសពីនេះទៀត ដំណើរការប្រមូលទិន្នន័យទាំងនេះ ដូចជាការរៀបចំផែនទីនៃលំនៅឋានអនាធិបតេយ្យជាដើម ត្រូវមានការផ្តោតសំខាន់បន្ថែមនៅក្នុងផែនការអភិវឌ្ឍទីក្រុងភ្នំពេញ។

ម៉្យាងវិញទៀត ដើម្បីដោះស្រាយបញ្ហានៃតម្រូវការដ៏ចម្រុះ និងផ្សេងៗគ្នារបស់ប្រជាពលរដ្ឋទាំងអស់នៅក្នុងទីក្រុង ដែលបណ្តាលមកពីនគរូបនីយកម្មយ៉ាងឆាប់រហ័សនោះ អាជ្ញាធរមានសមត្ថកិច្ចត្រូវរៀបចំក្រុងដោយមានការរួមបញ្ចូលវិស័យទាំងអស់ (Integrated Urban Development) ពោលគឺរៀបចំទីក្រុងភ្នំពេញដោយយកចិត្តទុកដាក់ទៅលើគ្រប់វិស័យនៅពេលតែមួយ ដោយមិនមានការផ្តោតទៅលើវិស័យណាមួយជាងវិស័យផ្សេងៗឡើយ។ ហើយប្រភេទនៃការរៀបចំទីក្រុងនេះគួរតែធ្វើឡើងដោយមានវិមជ្ឈការ និងមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋនៃទីក្រុង រដ្ឋាភិបាល សហគមន៍រស់នៅក្រោមបន្ទាត់ភាពក្រីក្រ និងស្ថាប័នឯកជនផ្សេងៗ ដើម្បីឈានទៅរកអភិបាលកិច្ចល្អសមរម្យ។ យុទ្ធសាស្ត្រនៃការរៀបចំទីក្រុងបែបនេះមានគោលបំណងធ្វើឱ្យទីក្រុងមានការលូតលាស់ផ្នែកសង្គម សេដ្ឋកិច្ច និងបរិស្ថានដោយមាននូវនិរន្តរភាព ដែលនឹងនាំឱ្យមានការគ្រប់គ្រងល្អប្រសើរជាងមុនចំពោះបញ្ហាកំណើនប្រជាជន ការប្រែប្រួលអាកាសធាតុ និងបញ្ហាផ្នែកប្រជាសាស្ត្រ។

បន្ថែមពីនេះទៅទៀត អាជ្ញាធរមានសមត្ថកិច្ចគួរតែផ្តោតលើការរៀបចំទីក្រុងមួយដែលអាចរស់នៅបានសម្រាប់យុវជន មនុស្សចាស់ និងស្ត្រី តាមរយៈការផ្តល់សេវាសាធារណៈដែលងាយទទួលយកបាន និងមានតម្លៃសមរម្យ ដូចជាមធ្យោបាយដឹកជញ្ជូនសាធារណៈនៅតាមទីក្រុងជាដើម។ មិនតែប៉ុណ្ណោះ ដើម្បីឈានទៅដល់តុល្យភាពនៃការលូតលាស់សេដ្ឋកិច្ចប្រកបដោយនិរន្តរភាពក្នុងទីក្រុង និងតាមតំបន់ជាយក្រុង របៀបវារៈទីក្រុងថ្មីបានជម្រុញឱ្យមានបទប្បញ្ញត្តិសម្រាប់ការសាងសង់ដែលតឹងរឹងជាងមុន ជាមួយនឹងការអភិរក្សបរិស្ថានប្រឆាំងការរំលោភបំពានធនធានធម្មជាតិ និងការគ្រប់គ្រងត្រឹមត្រូវនៃសំណល់រឹង និងសំណល់ផ្សេងៗទៀត ហើយក៏ត្រូវមានការអភិវឌ្ឍទីក្រុងរណបដែរ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការតភ្ជាប់រវាងទីក្រុងភ្នំពេញ និងតំបន់ជាយក្រុងដែលនឹងនាំឱ្យមានភាពងាយស្រួលដល់ការធ្វើដំណើរចំពោះប្រជាជន ដែលមកធ្វើការនៅទីក្រុង។[113]

**ខ. ផែនការដីធ្លី និងទីប្រជុំជន**

ចំពោះបញ្ហាប្រឈមនៃផែនការដីធ្លី និងនគរូបនីយកម្មនៅក្នុងទីក្រុងភ្នំពេញ របៀបវារៈទីក្រុងថ្មីបានជម្រុញនូវគោលការណ៍មួយចំនួនដើម្បីដោះស្រាយបញ្ហាទាំងនោះ។ ដើម្បីគ្រប់គ្រងបញ្ហាប្រឈមនៃនគរូបនីយកម្មឱ្យបានត្រឹមត្រូវ ជាដំបូងអាជ្ញាធរមានសមត្ថកិច្ចត្រូវបន្តការអភិវឌ្ឍធនធាន និងសមត្ថភាពរបស់ថ្នាក់ដឹកនាំជាពិសេសទាក់ទងទៅនឹងអភិបាលកិច្ចល្អ បច្ចេកវិទ្យា និងការបង្កើតផែនការមេ ព្រមទាំងត្រូវមានការលើកទឹកចិត្តចំពោះការចែករំលែកចំណេះដឹងអំពីការរៀបចំផែនការមេនៃទីក្រុងរវាងមន្ត្រីថ្នាក់ខ្ពស់ និងថ្នាក់ក្រោម រួមជាមួយនឹងការជម្រុញឱ្យមានមតិចូលរួមពីបណ្តាសាធារណជន ដោយសារពួកគេដើរតួដ៏សំខាន់ក្នុងការរៀបចំផែនការមេទីក្រុងភ្នំពេញ និងអភិវឌ្ឍសហគមន៍របស់ខ្លួន។

មិនតែប៉ុណ្ណោះ របៀបវារៈទីក្រុងថ្មីក៏គាំទ្រឱ្យរាជរដ្ឋាភិបាលធ្វើការវិនិយោគ និងបង្កើតគោលនយោបាយសម្រាប់គាំទ្រផលិតកម្មស្បៀងអាហារនៅតាមទីក្រុង និងតំបន់ជាយក្រុង ដើម្បីធានាថាមានបរិមាណស្បៀងគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ប្រជាជននៅទីក្រុងដែលមានចំនួនកើនឡើងជារៀងរាល់ឆ្នាំ។ គោលនយោបាយបែបនេះក៏អាចជួយកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងលើកកម្ពស់ជីវភាពរស់នៅរបស់ក្រុមងាយរងគ្រោះផងដែរ។

លើសពីនេះទៅទៀត គេក៏ឃើញមានការជម្រុញឱ្យគាំទ្រដល់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនសាធារណៈដែលមានលក្ខណៈរួមបញ្ចូលគ្នា (Integrated) ពោលគឺផែនការ និងយុទ្ធសាស្ត្រសាងសង់នេះត្រូវមានការសហការរវាងរដ្ឋាភិបាល និងក្រុមហ៊ុនដឹកជញ្ជូនឯកជន។ ក្រៅពីនេះ ក៏ត្រូវអភិវឌ្ឍនូវប្រព័ន្ធផ្លូវសម្រាប់ឡានក្រុងសាធារណៈ ផ្លូវដែក ផ្លូវជិះកង់ និងបង្កើនទំហំនៃទីធ្លាសម្រាប់អ្នកដើរថ្មើរជើងដែរ ដើម្បីឱ្យមធ្យោបាយ

[113] សៀវភៅ Cambodia National Report For Habitat III Preparation , អគ្គនាយកដ្ឋានលំនៅឋាន បោះពុម្ពឆ្នាំ២០១៦ ទំព័រទី ១៦

ដឹកជញ្ជូនមានតម្លៃសមស្របសម្រាប់ប្រជាជនក្នុងក្រុង និងតាមជាយក្រុង។ ក្រៅពីនេះ អាជ្ញាធរមានសមត្ថកិច្ចក៏ត្រូវពិនិត្យ និងកែទម្រង់ទៅលើដំណើរការចុះបញ្ជី និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីឱ្យមានប្រសិទ្ធភាព ពីព្រោះវានឹងជួយកាត់បន្ថយជម្លោះដីធ្លី និងផ្តល់នូវការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន។[114]

**គ. បរិស្ថាន និងនគរូបនីយកម្ម**

ចំពោះបញ្ហាប្រឈមបរិស្ថាន របៀបវារៈទីក្រុងថ្មីគាំទ្រយុទ្ធសាស្ត្រកាត់បន្ថយការប្រែប្រួលអាកាសធាតុតាមរយៈការបង្កើតនូវគោលនយោបាយកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដោយការប្រមូលទិន្នន័យ និងបច្ចេកវិទ្យា។ ហើយថ្នាក់ដឹកនាំថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិគួរតែសិក្សាពីភាពងាយរងគ្រោះរបស់ទីក្រុង ជាមួយនឹងការផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងការប្រែប្រួលអាកាសធាតុដល់សាធារណជនផងដែរ។ យុទ្ធសាស្ត្រទាំងអស់នេះគួរតែទទួលហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ក្រុមហ៊ុនឯកជន និងរាជរដ្ឋាភិបាល។

ទន្ទឹមនឹងនេះ រដ្ឋាភិបាលក៏ត្រូវបង្កើតក្របខណ្ឌច្បាប់ ដើម្បីកាត់បន្ថយការបំពុលបរិយាកាស ដូចជាបទប្បញ្ញត្តិគ្រប់គ្រងថាមពលឥន្ធនៈបៃតង និងស្តង់ដារសម្រាប់យានយន្តថ្មីជាដើម។ បន្ថែមពីនេះទៅទៀត អាជ្ញាធរមានសមត្ថកិច្ចគួរតែដំឡើងបច្ចេកវិទ្យាដែលអាចបង្ការការបំពុលបរិយាកាស ដូចជាមធ្យោបាយដឹកជញ្ជូនសារធារណៈ ការលើកកម្ពស់ការប្រើប្រាស់ថាមពលកកើតឡើងវិញ ព្រមទាំងលើកទឹកចិត្តដល់ការអភិវឌ្ឍទីកន្លែងសាធារណៈ ដោយសារវាដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយការបំពុលបរិយាកាស។[115]

**ឃ. បទប្បញ្ញត្តិ និងការគ្រប់គ្រងទីក្រុង**

បទប្បញ្ញត្តិសម្រាប់ការគ្រប់គ្រងនគរូបនីយកម្មនៃទីក្រុងភ្នំពេញ ត្រូវមានប្រសិទ្ធភាព ពិសេសសម្រាប់ **"យុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍ទីក្រុង"** ដែលត្រូវបានព្រាងទុកក្នុងឆ្នាំ ២០១៥ ដោយយុទ្ធសាស្ត្រនេះចាំបាច់ត្រូវទទួលការកែតម្រូវបន្ថែម តាមរយៈជំនួយផ្នែកធនធានមនុស្ស និងហិរញ្ញវត្ថុពីរដ្ឋាភិបាល ដើម្បីមានការគ្រប់គ្រងសមរម្យចំពោះនគរូបនីយកម្មយ៉ាងឆាប់រហ័សនាពេលបច្ចុប្បន្ន។ ដូច្នេះ ដើម្បីឱ្យអភិបាលកិច្ចក្រុងភ្នំពេញមានប្រសិទ្ធភាពអភិបាលកិច្ចនោះត្រូវមានវិមជ្ឈការ ដើម្បីងាយស្រួលយកចិត្តទុកដាក់ទៅលើបញ្ហា និងតម្រូវការរបស់ប្រជាជន។ យុទ្ធសាស្ត្របែបនេះ គឺស្របទៅតាមគោលការណ៍របស់របៀបវារៈទីក្រុងថ្មី ដែលជម្រុញឱ្យមានការចូលរួមពីសាធារណជនក្នុងការរៀបចំទីក្រុងភ្នំពេញ ដើម្បីឈានទៅដល់ទីក្រុងមួយដែលមានសមធម៌ និងសម្រាប់ប្រជាជនគ្រប់រូប។[116]

---

[114] សៀវភៅ Cambodia National Report For Habitat III Preparation , អគ្គនាយកដ្ឋានលំនៅឋាន បោះពុម្ពឆ្នាំ២០១៦ ទំព័រទី ២៤

[115] សៀវភៅ Cambodia National Report For Habitat III Preparation , អគ្គនាយកដ្ឋានលំនៅឋាន បោះពុម្ពឆ្នាំ២០១៦ ទំព័រទី ៣០

[116] សៀវភៅ Cambodia National Report For Habitat III Preparation , អគ្គនាយកដ្ឋានលំនៅឋាន បោះពុម្ពឆ្នាំ២០១៦ ទំព័រទី ៤២

**ង. សេដ្ឋកិច្ចទីក្រុង**

ដោយសារតែ ដំណើរការនគរូបនីយកម្មនឹងអាស្រ័យទៅលើការលូតលាស់សេដ្ឋកិច្ចរបស់ទីក្រុងភ្នំពេញ រាល់ផែនការសកម្មភាព និងហេដ្ឋារចនាសម្ព័ន្ធដែលត្រូវបានជម្រុញដោយរបៀបវារៈទីក្រុងថ្មីគួរតែទទួលបាននូវហិរញ្ញប្បទានពីក្រុមហ៊ុនវិស័យឯកជន រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ផ្សេងៗ។ លើសពីនេះទៀត ហិរញ្ញប្បទានសម្រាប់ការសាងសង់លំនៅឋាន គួរតែមានភាពងាយស្រួលក្នុងការទទួលយកបានសម្រាប់គ្រួសារដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រ (ឧទាហរណ៍៖ ឱ្យប្រាក់កម្ចីដែលមានការប្រាក់ទាប) ដែលគោលការណ៍នេះអាចសម្រេចបានតាមរយៈការបង្កើតគោលនយោបាយ និងហេដ្ឋារចនាសម្ព័ន្ធសមស្រប ជាមួយនឹងការគាំទ្រនូវ "**មូលនិធិអភិវឌ្ឍន៍ជនក្រីក្រក្នុងទីក្រុង**" និង "**មូលនិធិអភិវឌ្ឍន៍សហគមន៍កម្ពុជា**"។

ទន្ទឹមនឹងនេះ ដើម្បីនាំឱ្យមានការលូតលាស់សេដ្ឋកិច្ចបន្ថែម គួរតែមានកម្មវិធីដើម្បីលើកកម្ពស់ការចែករំលែកចំណេះដឹងការងារ ព្រមទាំងជម្រុញឱ្យមានការរីកចម្រើននៃស្ថានភាពកន្លែងការងារ។ ការបណ្តុះបណ្តាលចំណេះដឹងបច្ចេកទេស និងវិជ្ជាជីវៈក៏ត្រូវទទួលការកែលម្អ ដើម្បីអភិវឌ្ឍធនធានមនុស្សនៃទីក្រុងភ្នំពេញឱ្យទៅដល់កម្រិតសមរម្យ។ បទប្បញ្ញត្តិ និងគោលនយោបាយសម្រាប់គាំទ្រសហគ្រាសធុនតូច និងមធ្យមចាំបាច់ត្រូវបង្កើតឡើង ដើម្បីធានាថាសេដ្ឋកិច្ចទីក្រុងភ្នំពេញនឹងលូតលាស់ដោយនិរន្តរភាព។[117]

**ច. លំនៅឋាន និងសេវាកម្មមូលដ្ឋាន**

ចំពោះបញ្ហាលំនៅឋាន និងសេវាកម្មមូលដ្ឋាន របៀបវារៈទីក្រុងថ្មីបានជម្រុញឱ្យប្រសើរឡើងនូវតំបន់អនាធិបតេយ្យនៅក្នុងរាជធានីភ្នំពេញ ដោយផែនការនេះត្រូវមានការចូលរួមពីគ្រួសារដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រ។ ហើយផែនការនេះគួរតែបញ្ចូលទៅក្នុងក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិដែលមានស្រាប់ដូចជាសារាចរលេខ ០៣[118] ច្បាប់ភូមិបាល និងគោលនយោបាយជាតិស្តីពីលំនៅឋាន។[119] លើសពីនេះទៀត គេក៏គួរតែមានគោលនយោបាយអភិវឌ្ឍន៍មួយ ដើម្បីជួយសម្រួលដល់ការផ្តល់លំនៅឋាន និងការលើកកម្ពស់ជីវភាព សម្រាប់សហគមន៍ក្រីក្រនៅក្នុងទីក្រុងភ្នំពេញ។ ដូច្នេះ គោលនយោបាយដែលធ្វើឱ្យមានការលំបាកដល់សហគមន៍ក្រីក្រដូចជាការបណ្តេញចេញដោយបង្ខំ គួរតែចៀសវាងប្រើប្រាស់ ដោយសារវាជះឥទ្ធិពលអវិជ្ជមានទៅដល់ជីវភាពរស់នៅរបស់គ្រួសារក្រីក្រនោះ។

---

[117] សៀវភៅ Cambodia National Report For Habitat III Preparation, អគ្គនាយកដ្ឋានលំនៅឋាន បោះពុម្ពឆ្នាំ២០១៦ ទំព័រទី ៥២

[118] សារាចរណែនាំលេខ ០៣ សរ ស្តីពី ការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាមរាជធានី ទីក្រុង និងទីប្រជុំជន

[119] គោលនយោបាយជាតិស្តីពីលំនៅឋាន , ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានទទួលឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០១៤

ទន្ទឹមនឹងនេះ គួរតែមានការអភិវឌ្ឍនៃហេដ្ឋារចនាសម្ព័ន្ធនៅក្នុងទីក្រុងភ្នំពេញ ជាពិសេសទៅលើការផ្គត់ផ្គង់ទឹក និងអនាម័យជាដើម។ ក្រៅពីនេះ ក៏ត្រូវមានអភិវឌ្ឍនៃហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ថាមពលអគ្គិសនីដែរ ជាពិសេសនៅតាមតំបន់ជាយក្រុង។ មិនតែប៉ុណ្ណោះ ក៏ត្រូវមានបទប្បញ្ញត្តិសម្រាប់គ្រប់គ្រង និងកំណត់ស្តង់ដារចំពោះការផលិតថាមពលផងដែរ ដោយសារវាអាចនាំឱ្យមានការកែលម្អ និងជម្រុញការប្រើប្រាស់ថាមពលកកើតឡើងវិញ ដូចជាថាមពលព្រះអាទិត្យ ឬឧស្ម័នធម្មជាតិជាដើម។[120]

## ២.២. ការអភិវឌ្ឍរាជធានីភ្នំពេញប្រកបដោយនិរន្តរភាព

ក្រោយពីយើងបានសិក្សាដ៏ជ្រាលជ្រៅទៅលើគោលការណ៍ និងសកម្មភាពដែលត្រូវបានណែនាំដោយរបៀបវារៈទីក្រុងថ្មី ទាក់ទងទៅនឹងការអភិវឌ្ឍទីក្រុងដោយនិរន្តរភាព យើងក៏បានសិក្សាអំពីរបៀបនៃការអនុវត្តគោលការណ៍ទាំងនោះនៅក្នុងបរិបទប្រទេសកម្ពុជាដែរ។ ដូច្នេះ នៅក្នុងចំណុចនេះ យើងនឹងវិភាគទៅលើការអភិវឌ្ឍរាជធានីភ្នំពេញប្រកបដោយនិរន្តរភាព ដោយយោងតាមផែនការអភិវឌ្ឍន៍រាជធានីភ្នំពេញ ព្រមទាំងឯកសារគតិយុត្តផ្សេងៗទៀតដែលទាក់ទងទៅនឹងនគរូបនីយកម្មនៃរាជធានីរបស់ព្រះរាជាណាចក្រកម្ពុជា។

ជាពិសេស យើងនឹងធ្វើការសិក្សាទៅលើចក្ខុវិស័យ គោលបំណង និងគោលដៅនៃការអភិវឌ្ឍរាជធានីភ្នំពេញ រួចបកស្រាយគោលការណ៍នគរូបនីយកម្មផ្សេងៗដែលមាននៅក្នុងប្លង់គោលនៃរាជធានីភ្នំពេញ។ បន្ទាប់មក យើងនឹងមើលទៅលើវិស័យអាទិភាពទាំង៨ សម្រាប់អភិវឌ្ឍទីក្រុងឱ្យមាននិរន្តរភាព ជាមួយនឹងការរៀបចំរចនាសម្ព័ន្ធស្ថាប័នអនុវត្តទីក្រុងនិរន្តរភាព និងយន្តការគាំទ្រផ្សេងៗ។ ជាចុងក្រោយ ពួកយើងនឹងលើកឡើងឧបសគ្គក្នុងការអភិវឌ្ឍរាជធានីភ្នំពេញ។

### ២.២.១. ចក្ខុវិស័យ គោលបំណង និងគោលដៅក្នុងការអភិវឌ្ឍរាជធានីភ្នំពេញ

ការអភិវឌ្ឍទីក្រុង គឺមានសារៈសំខាន់ណាស់ក្នុងការលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ និងដោះស្រាយបញ្ហាផ្សេងៗដែលមាននៅទីក្រុងនោះ ដូចជាបញ្ហាទាក់ទងទៅនឹងនិរន្តរភាពជាដើម។ ហេតុនេះ ដើម្បីចាប់ផ្តើមការវិភាគទៅលើយុទ្ធសាស្ត្រអភិវឌ្ឍន៍នៃរាជធានីភ្នំពេញប្រកបដោយនិរន្តរភាព យើងត្រូវតែធ្វើការសិក្សាទៅលើចំណុចសំខាន់ ៣ ធំៗ គឺទៅលើ ចក្ខុវិស័យ គោលដៅ និងគោលបំណងនៃការអភិវឌ្ឍ និងការរៀបចំនគរូបនីយកម្មនៃរាជធានីភ្នំពេញ។

#### ២.២.១.១. ចក្ខុវិស័យ

ជាដំបូងឡើយ យើងត្រូវយល់ដឹងអំពីចក្ខុវិស័យនៃការអភិវឌ្ឍរាជធានីភ្នំពេញ ជាពិសេសទាក់ទងទៅនឹងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ ដូច្នេះ ចំពោះកិច្ចសិក្សានេះ យើងនឹងធ្វើការវិភាគទៅលើផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ដែលនៅក្នុងឯកសារនេះបានបញ្ជាក់អំពីចក្ខុវិស័យនៃការអភិវឌ្ឍរាជធានី

[120] សៀវភៅ Cambodia National Report For Habitat III Preparation, អគ្គនាយកដ្ឋានលំនៅឋាន បោះពុម្ពឆ្នាំ២០១៦ ទំព័រទី ៦២

ភ្នំពេញឱ្យមាននិរន្តរភាពដូចតទៅ៖ **"នៅឆ្នាំ២០៣០ រាជធានីភ្នំពេញនឹងក្លាយជាទីក្រុងស្អាត បៃតង និងប្រកបដោយការប្រកួតប្រជែង ដែលផ្តល់នូវរបៀបរស់នៅមានសុវត្ថិភាព និងគុណភាពដល់ប្រជាជន"។**[121]

បើយោងទៅតាមប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ឆ្នាំ២០៣៥ យើងឃើញថាអាជ្ញាធរថ្នាក់ជាតិមានគោលជំហរក្នុងការរក្សា និងអភិរក្ស អគារចាស់បុរាណមួយចំនួនធំនៅក្នុងខណ្ឌដូនពេញ។ បន្ថែមពីនេះទៀត អាជ្ញាធរមានការយកចិត្តទុកដាក់លើគុណភាពនៃការរស់នៅរបស់ប្រជាជន ដោយធ្វើការរក្សាតំបន់បៃតងរួមដែលមានស្រាប់ដូចជា សួនច្បារវត្តបុទុម សួនវិមានឯករាជ្យ វត្តភ្នំ និងធ្វើការអភិវឌ្ឍបន្ថែមលើសួននៅតាមបណ្តោយមាត់ទន្លេ។ លើសពីនេះទៀតសោត អាជ្ញាធរក៏យកចិត្តទុកដាក់ទៅលើការរៀបចំសណ្តាប់ធ្នាប់ និងសោភណភាពនៅតាមបណ្តោយដងផ្លូវ ពិសេសគឺមហាវិថីព្រះនរោត្តម ដោយរៀបចំឱ្យមានផ្លូវប្រកបដោយបរិយាប័ន្ន ពោលគឺផ្លូវសម្រាប់អ្នកថ្មើរជើងគ្រប់ប្រភេទ រួមទាំងជនពិការ ព្រមទាំងរៀបចំឱ្យមានការដាំដើមឈើជាជួរតាមបណ្តោយមហាវិថីផងដែរ។

### ២.២.១.២. គោលដៅ

បន្ទាប់ពីបានយល់ដឹងពីចក្ខុវិស័យនៃការអភិវឌ្ឍរាជធានីភ្នំពេញហើយ យើងនឹងធ្វើការបកស្រាយបន្តទៅលើគោលដៅនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍នៃរាជធានីភ្នំពេញឱ្យក្លាយទៅជាទីក្រុងដែលមាននិរន្តរភាព។ ក្រុមការងារបច្ចេកទេស បានបង្កើតឡើងនូវគោលដៅជាក់លាក់មួយចំនួនទាក់ទងនឹងការអភិវឌ្ឍទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ដែលមានដូចខាងក្រោម៖

- ការធ្វើឱ្យមានកំណើនសេដ្ឋកិច្ចដោយមិនប៉ះពាល់លើបរិស្ថាន
- ពង្រឹងបរិយាប័ន្នសង្គម កាត់បន្ថយភាពក្រីក្រ និងបង្កើនសុខុមាលភាពទីក្រុង
- ផ្តល់ដល់ប្រជាពលរដ្ឋទាំងអស់នៅក្នុងទីក្រុង នូវការរស់នៅដែលមានភាពបន្សាំទៅនឹងហានិភ័យគ្រោះធម្មជាតិ ការប្រែប្រួលអាកាសធាតុ និងហានិភ័យផ្សេងៗទៀត
- បង្កើនភាពប្រកួតប្រជែង និងភាពទាក់ទាញសម្រាប់កិច្ចការជំនួញ និងវិនិយោគ។[122]

### ២.២.១.៣. គោលបំណង

ដោយសារយើងបានលើកឡើង និងសិក្សាទៅលើគោលដៅនៃការអភិវឌ្ឍឱ្យរាជធានីភ្នំពេញមាននិរន្តរភាព ហើយចំពោះចំណុចចុងក្រោយនេះ យើងនឹងលើកឡើងគោលបំណងនៃផែនការអភិវឌ្ឍនេះដោយយោងទៅតាមវិស័យអាទិភាពសំខាន់ៗនៃការអភិវឌ្ឍទីក្រុងនិរន្តរភាព ដែលមានដូចខាងក្រោម៖

---

[121] របាយការណ៍ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ២០១៨-២០៣០ , វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ឆ្នាំ២០១៨ ទំព័រទី ៣

[122] របាយការណ៍ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ២០១៨-២០៣០ , វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ឆ្នាំ២០១៨ ទំព័រទី ៤

**ក. គោលបំណងនៅក្នុងវិស័យរៀបចំផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព**

- អនុវត្តឱ្យបាននូវផែនការមេរាជធានីភ្នំពេញ ស្តីពីការប្រើប្រាស់ដីធ្លី ឆ្នាំ២០៣៥ ស្របទៅតាមទិសដៅដែលបានគ្រោងទុក
- រៀបចំផែនទីលម្អិតស្តីពីការប្រើប្រាស់ដីធ្លី និងការបែងចែកតំបន់ប្រើប្រាស់ដីធ្លី
- ធ្វើឱ្យមាននិរន្តរភាពនៃការអនុវត្តគម្រោងអភិវឌ្ឍន៍ទីក្រុងរណបទាំង៧ ដែលបានគ្រោងនឹងបញ្ចប់នៅឆ្នាំ ២០៣០ ដោយគម្រោងនីមួយៗមានប្រព័ន្ធគ្រប់គ្រងសំណល់រឹង និងរាវ ជាមួយការអនុវត្តស្របតាមបទដ្ឋានសាងសង់បៃតង។

**ខ. គោលបំណងនៅក្នុងវិស័យភាពងាយរងគ្រោះរបស់ទីក្រុង**

- ការពារប្រជាជនក្នុងរាជធានីភ្នំពេញពីទឹកជំនន់ធ្ងន់ធ្ងរ
- កែលម្អបឹងធម្មជាតិ និងតំបន់ដីសើមនៅទីក្រុងដែលអាចប្រើប្រាស់ជាប្រព័ន្ធគ្រប់គ្រងទឹកជំនន់ធម្មជាតិ និងទឹកកខ្វក់
- បង្កើត ឬស្តារឡើងវិញនូវរបៀងបៃតងនៅក្នុងទីក្រុងទាំងមូល
- ប្រព្រឹត្តកម្មសំណល់រាវទំហំតូចៗតាមតំបន់ ដែលនឹងត្រូវបង្កើតឡើងនៅក្នុងតំបន់ទីក្រុង
- គ្រួសារនៅតំបន់ជុំវិញទីក្រុងប្រើប្រាស់ប្រព័ន្ធអនាម័យដែលមានការកែលម្អ និងមានសុវត្ថិភាពដែលនឹងការពារការរាលដាលនៃការបំពុលនៅក្នុងករណីមានភ្លៀង និងមានការជន់លិចខ្លាំង។

**គ. គោលបំណងក្នុងវិស័យថាមពល**

- បង្កើនបរិមាណប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យនៅក្នុងការផ្គត់ផ្គង់អគ្គិសនី
- កាត់បន្ថយការប្រើប្រាស់អគ្គិសនីនៅក្នុងគ្រួសារ និង ក្រុមហ៊ុនអាជីវកម្ម ឬសេវាកម្មទាំងឡាយតាមរយៈវិធានការប្រសិទ្ធភាពថាមពល
- បំពាក់ផ្ទាំងកញ្ចក់ស្រូបថាមពលព្រះអាទិត្យតាមអគាររដ្ឋបាលក្រុង និងរដ្ឋបាលផ្សេងទៀតដែលមានដំបូលសមស្រប។

**ឃ. គោលបំណងនៅក្នុងវិស័យដឹកជញ្ជូន**

- កាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់នៅក្នុងវិស័យដឹកជញ្ជូន
- ប្រព័ន្ធមធ្យោបាយដឹកជញ្ជូនសាធារណៈរថយន្តក្រុង ត្រូវបានបង្កើតឡើងដោយគ្របដណ្តប់លើច្រកដឹកជញ្ជូនសំខាន់ៗនៅក្នុងទីក្រុង
- កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍
- កាត់បន្ថយការកកស្ទះចរាចរណ៍តាមដងផ្លូវ។

**ង. គោលបំណងនៅក្នុងវិស័យបរិស្ថានសំណង់ (សំណង់អគារ)**

- អនុម័តបទដ្ឋានសាងសង់បៃតង (Green Building) សម្រាប់អគារដែលត្រូវសាងសង់ចាប់ពីឆ្នាំ២០២០ តទៅ
- កាត់បន្ថយការប្រើប្រាស់ថាមពលនៅក្នុងអគារបច្ចុប្បន្ន
- លំនៅឋានសម្រាប់គ្រួសារមានចំណូលទាបត្រូវបានបង្កើតឡើង ឬបំពាក់បរិក្ខារឡើងវិញដើម្បីឱ្យធន់នឹងគ្រោះធម្មជាតិ។

**ច. គោលបំណងក្នុងវិស័យកម្មន្តសាល**

- បង្កើតតំបន់ឧស្សាហកម្មដែលមានហេដ្ឋារចនាសម្ព័ន្ធគាំទ្របៃតង
- កាត់បន្ថយការបំពុលទឹកនៅក្នុងវិស័យកម្មន្តសាល
- បង្កើនប្រសិទ្ធភាពថាមពលនៅក្នុងឧស្សាហកម្មកម្មន្តសាល
- ធ្វើសវនកម្មប្រសិទ្ធភាពថាមពល និងបង្កើតផែនការគ្រប់គ្រងទៅលើប្រសិទ្ធភាពថាមពលសម្រាប់រោងចក្រកម្មន្តសាលធំៗ
- ក្រុមហ៊ុនកម្មន្តសាលធំៗបានអនុវត្តសវនកម្មលើការប្រើប្រាស់ទឹក និងបានបង្កើតផែនការគ្រប់គ្រងការប្រើប្រាស់ទឹក។

**ឆ. គោលបំណងនៅក្នុងវិស័យគ្រប់គ្រងសំណល់រឹង**

- ពង្រីកសេវាប្រមូល និងគ្រប់គ្រងសំណល់រឹងប្រកបដោយគុណភាព
- កាត់បន្ថយសំណល់សរីរាង្គដែលយកទៅចោលនៅកន្លែងចាក់សំរាម ឬកន្លែងដុតសំរាម
- ញែកសំណល់រឹងដើម្បីអាចធ្វើការកែច្នៃឡើងវិញនៅតាមផ្ទះប្រជាពលរដ្ឋ តាមទីផ្សារ និងតាមសហគ្រាសពាណិជ្ជកម្ម
- អនុវត្តគោលការណ៍ ៤Rs រួមមាន៖ កាត់បន្ថយ (Reduce) ប្រើប្រាស់ឡើងវិញ (Reuse) ជួសជុល (Repair) កែច្នៃឡើងវិញ (Recycle)។

**ជ. គោលបំណងនៅក្នុងវិស័យទីធ្លាសាធារណៈ និងបេតិកភណ្ឌវប្បធម៌**

- បង្កើនវិសាលភាពគម្របបៃតងទីក្រុង
- បង្កើនទីធ្លាសាធារណៈបៃតងនៅក្នុងទីក្រុង
- បង្កើតផែនការយុទ្ធសាស្ត្រដើម្បីអភិរក្សបេតិកភណ្ឌវប្បធម៌ទីក្រុង

- កំណើនភ្ញៀវទេសចរជាលទ្ធផលនៃការកែលម្អការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌។[123]

### ២.២.២. ផែនការមេក្នុងការអភិវឌ្ឍរាជធានីភ្នំពេញ

ផែនការអភិវឌ្ឍទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ បានតម្រង់ទិសដៅនៃការអភិវឌ្ឍរបស់រាជធានីភ្នំពេញឱ្យមាននិរន្តរភាពផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងបរិស្ថាន។ មិនតែប៉ុណ្ណោះ ក៏មានឯកសារគតិយុត្តផ្សេងៗទៀតដែលជួយតម្រង់យុទ្ធសាស្ត្រអភិវឌ្ឍទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ។ ដូច្នេះ នៅក្នុងចំណុចនេះ យើងនឹងធ្វើការសិក្សាទៅលើឯកសារផ្សេងៗទៀតដែលជួយក្នុងការអភិវឌ្ឍរាជធានីភ្នំពេញ ដូចជា ផែនការមេសម្រាប់ការប្រើប្រាស់ដីធ្លី ផែនការមេរៀបចំប្រព័ន្ធដឹកជញ្ជូនទីក្រុង និងក្របខណ្ឌគោលនយោបាយសម្រាប់អភិវឌ្ឍទីក្រុងនិរន្តរភាពនៅកម្ពុជា។

#### ២.២.២.១. ផែនការប្រើប្រាស់ដីធ្លីក្នុងរាជធានីភ្នំពេញក្នុងឆ្នាំ ២០៣៥

ផែនការមេរាជធានីភ្នំពេញស្តីពីការប្រើប្រាស់ដីធ្លី ឆ្នាំ២០៣៥ ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីនៃរាជធានីភ្នំពេញ ក្នុងគោលបំណងដោះស្រាយបញ្ហាកំណើនប្រជាជន និងការរីកដុះដាលយ៉ាងរហ័សនៃវិស័យសំណង់។ ផែនការមេនេះ ត្រូវបានបង្កើតឡើងដោយយោងតាមផែនការចក្ខុវិស័យ ដែលបានកំណត់ចំពោះរាជធានីភ្នំពេញនៅឆ្នាំ២០៣៥គឺៈ **"ក្លាយជាមជ្ឈមណ្ឌលមួយដែលមានការប្រកួតប្រជែង ផ្នែកនយោបាយ សេដ្ឋកិច្ច ជំនួញ និងវប្បធម៌ នៃប្រទេសកម្ពុជា ដែលមានការអភិវឌ្ឍប្រកបដោយចីរភាព និងសមធម៌"។**

ផែនការមេស្តីពីការប្រើប្រាស់ដីធ្លីឆ្នាំ២០៣៥ សង្កត់ធ្ងន់លើ ៣ ផ្នែកធំៗដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យដែលបានចែងដូចខាងក្រោមៈ

១). ដាក់ចេញសេចក្តីណែនាំស្តីពីការប្រើប្រាស់ដីធ្លី ដើម្បីធានាបាននូវសក្តានុពល ប្រសិទ្ធភាព និរន្តរភាព និងសមធម៌ ដែលនឹងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម សន្តិសុខស្បៀង និងបរិស្ថានស្អាតនៃប្រទេសកម្ពុជា

២). ដាក់ចេញសេចក្តីណែនាំស្តីពីការអភិវឌ្ឍនៅរាជធានីភ្នំពេញ ដោយថ្លឹងថ្លែងជាមួយការអភិវឌ្ឍនៃទីក្រុងតូចៗ និងទីរួមខេត្តផ្សេងទៀត

៣). ផ្តល់អំណាចដល់អត្តសញ្ញាណរបស់ទីក្រុង និងអភិវឌ្ឍភាពប្រកួតប្រជែងជាមួយទីក្រុងផ្សេងទៀតនៅក្នុងតំបន់ដែលនឹងផ្តល់ឱ្យរាជធានីភ្នំពេញនូវលទ្ធភាពទទួលបានបច្ចេកទេស និងហិរញ្ញវត្ថុបន្ថែមទៀត។

ដើម្បីសម្រេចគោលដៅខាងលើ ផែនការមេនេះបានស្នើឡើងផងដែរនូវយុទ្ធសាស្ត្រចម្បងចំនួន ៥ គឺៈ

- យុទ្ធសាស្ត្រទី១ៈ រាជធានីភ្នំពេញត្រូវក្លាយជាមជ្ឈមណ្ឌលស្នូលសម្រាប់ការអភិវឌ្ឍ
- យុទ្ធសាស្ត្រទី២ៈ រៀបចំរាជធានីភ្នំពេញឱ្យក្លាយជាទីក្រុងដែលមានស្តង់ដារអន្តរជាតិ
- យុទ្ធសាស្ត្រទី៣ៈ បង្កើតធនបម្រុងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តមេចាំបាច់

[123] របាយការណ៍ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ២០១៨-២០៣០ , វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ឆ្នាំ២០១៨ ទំព័រទី ៥-៦

- យុទ្ធសាស្ត្រទី៤៖ រៀបចំការអភិវឌ្ឍនគរូបនីយកម្មក្នុងកម្រិតទីក្រុងធំ (ស៊ីវីល័យ)
- យុទ្ធសាស្ត្រទី៥៖ ការបង្កើតតំបន់ពិសេសសម្រាប់បេតិកភណ្ឌវប្បធម៌ និងទេសភាពទីក្រុង។[124]

### ២.២.២.២. ផែនការមេរៀបចំប្រព័ន្ធដឹកជញ្ជូនទីក្រុង

ដោយមានជំនួយពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) សាលារាជធានីភ្នំពេញក៏បានបង្កើតផែនការមេរៀបចំប្រព័ន្ធដឹកជញ្ជូនទីក្រុងនៅរាជធានីភ្នំពេញ ឆ្នាំ២០៣៥ ដើម្បីដោះស្រាយបញ្ហាចរាចរណ៍ពេលបច្ចុប្បន្ន និងគាំទ្រដល់ចក្ខុវិស័យ ដែលបានកំណត់នៅក្នុងផែនការមេស្តីពីការប្រើប្រាស់ដីធ្លីឆ្នាំ២០៣៥។ ផែនការមេរៀបចំប្រព័ន្ធដឹកជញ្ជូនទីក្រុងមានគោលដៅការពារ និងរៀបចំវិស័យដឹកជញ្ជូនតំបន់ទីក្រុងដែលអំណោយផលដល់ប្រជាជន បរិស្ថាន និងផ្តល់ភាពរស់រវើកដល់សកម្មភាពទីក្រុងនៅរាជធានីភ្នំពេញ។

បេសកកម្មនៃផែនការមេរៀបចំប្រព័ន្ធដឹកជញ្ជូនទីក្រុង ឆ្នាំ២០៣៥ មាន ២ផ្នែក៖

- ផ្នែកទី១៖ ផ្លាស់ប្តូរពីប្រព័ន្ធដឹកជញ្ជូនក្នុងទីក្រុងដែលមានការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនឯកជនច្រើនលើសលប់ ទៅជាប្រព័ន្ធដឹកជញ្ជូនសាធារណៈ និងឯកជនដែលមានតុល្យភាពគ្នា តាមរយៈការគ្រប់គ្រងជាប្រព័ន្ធទៅលើបណ្តាញផ្លូវថ្នល់ មធ្យោបាយដឹកជញ្ជូនសាធារណៈ និងការគ្រប់គ្រងចរាចរណ៍ ដើម្បីកែលម្អការធ្វើដំណើររបស់ពលរដ្ឋ
- ផ្នែកទី២៖ សម្រេចសក្តានុពលអភិវឌ្ឍន៍របស់រាជធានីភ្នំពេញ។

ដើម្បីសម្រេចបេសកកម្មនេះ ផែនការមេមធ្យោបាយដឹកជញ្ជូនទីក្រុងឆ្នាំ២០៣៥ ស្នើឡើងនូវយុទ្ធសាស្ត្រចំនួន ៥ ដូចខាងក្រោម៖

- យុទ្ធសាស្ត្រទី១៖ ការបង្កើតប្រព័ន្ធដឹកជញ្ជូនទីក្រុងដែលអំណោយផលដល់ប្រជាជន និងបរិស្ថាន ដែលនឹងធ្វើឱ្យប្រជាពលរដ្ឋ មានលទ្ធភាពធ្វើដំណើរស្រួល
- យុទ្ធសាស្ត្រទី២៖ ការបង្កើតក្របខណ្ឌរូបវន្តទីក្រុង និងការបង្កើតការតភ្ជាប់រលូនរវាងទីក្រុងធំៗនៅក្នុងអនុតំបន់មេគង្គ
- យុទ្ធសាស្ត្រទី៣៖ ការប្រើប្រាស់ឱ្យបានជាអតិបរមានូវទីធ្លាដែលមានស្រាប់ សម្រាប់អភិវឌ្ឍន៍វិស័យដឹកជញ្ជូនបច្ចុប្បន្នក្នុងនោះ រួមមានតំបន់ក្រោមដី និងខ្ពង់រាបដែលមាននៅកណ្តាលទីក្រុង
- យុទ្ធសាស្ត្រទី៤៖ ប្រសិទ្ធភាពនៃលំហូរចរាចរណ៍ដឹកជញ្ជូនទំនិញ
- យុទ្ធសាស្ត្រទី៥៖ ការពិចារណាទៅលើបរិស្ថាន/សង្គម និងការរៀបចំស្ថាប័នគ្រប់គ្រងវិស័យដឹកជញ្ជូនគឺជាទស្សនទានមូលដ្ឋាននៃការធ្វើផែនការមេនេះ។[125]

---

[124] របាយការណ៍ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ២០១៨-២០៣០ , វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ឆ្នាំ២០១៨ ទំព័រទី ៧

[125] របាយការណ៍ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ២០១៨-២០៣០ , វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ឆ្នាំ២០១៨ ទំព័រទី ៩

### ២.២.២.៣. ក្របខណ្ឌគោលនយោបាយសម្រាប់អភិវឌ្ឍទីក្រុងនិរន្តរភាពនៅកម្ពុជា

គោលនយោបាយស្ដីពីការអភិវឌ្ឍបៃតងរបស់ប្រទេសកម្ពុជា ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីនៅឆ្នាំ២០១៣ ដោយមានទស្សនៈវិស័យ "រក្សាការពារឱ្យបាននូវតុល្យភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចជាមួយនឹងបរិស្ថាន សង្គម វប្បធម៌ និង ការប្រើប្រាស់ប្រកបដោយនិរន្តរភាពនូវធនធានជាតិតាមរយៈសមាហរណកម្ម ការបន្ស៊ី និង ការសម្របសម្រួល ព្រមទាំងសុខដុមនីយកម្មរវាងគោលការណ៍អភិវឌ្ឍន៍បៃតង និងគោលនយោបាយជាតិ"។

គោលនយោបាយនេះមានគោលដៅធ្វើឱ្យប្រសើរឡើងដល់ សុខុមាលភាព និងមុខរបរចិញ្ចឹមជីវិតរបស់ប្រជាជនទាំងអស់ដោយធ្វើឱ្យមានសុខដុមនីយកម្មជាមួយប្រព័ន្ធអេកូឡូស៊ីតាមរយៈការអភិវឌ្ឍបៃតង ការផ្ដោតលើសេដ្ឋកិច្ចបៃតង និងខៀវ កិច្ចការការពារបរិស្ថាន ប្រព័ន្ធសុវត្ថិភាពសង្គម និងរក្សាអត្តសញ្ញាណវប្បធម៌ជាតិ។ ផែនការយុទ្ធសាស្ត្រជាតិស្ដីពីការអភិវឌ្ឍបៃតងផ្ដោតសំខាន់លើសេចក្ដីណែនាំយុទ្ធសាស្ត្រពាក់ព័ន្ធចំនួន ៩ គឺ៖

- ការវិនិយោគបៃតង និងការបង្កើតការងារបៃតង
- ការគ្រប់គ្រងសេដ្ឋកិច្ចបៃតងដែលមានតុល្យភាពជាមួយបរិស្ថាន
- ការអភិវឌ្ឍសេដ្ឋកិច្ចខៀវប្រកបដោយនិរន្តរភាព
- ការគ្រប់គ្រងបរិស្ថានបៃតង និងធនធានធម្មជាតិ
- ការអភិវឌ្ឍធនធានមនុស្ស និងការអប់រំបៃតង
- ការគ្រប់គ្រងបច្ចេកវិទ្យាបៃតងប្រកបដោយប្រសិទ្ធភាព
- ការលើកកម្ពស់ប្រព័ន្ធសុវត្ថិភាពសង្គមបៃតងការរក្សា និងការការពារបេតិកភណ្ឌវប្បធម៌បៃតង និង អត្តសញ្ញាណជាតិ
- អភិបាលកិច្ចល្អនៃការអភិវឌ្ឍបៃតង។

"ការអភិវឌ្ឍទីក្រុងនិរន្តរភាព" ត្រូវបានកំណត់ថាជាវិស័យអាទិភាពមួយសម្រាប់ការរៀបចំផែនការ និងអនុវត្តការអភិវឌ្ឍបៃតងដោយរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច)។ ការអភិវឌ្ឍទីក្រុងនិរន្តរភាព មានគោលដៅផ្ដល់វិធីសាស្ត្រពេញលេញនៃការរៀបចំក្រុង ផ្ដល់អាទិភាពដល់ការវិនិយោគ និងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងបរិបទទីក្រុង ហើយនឹងដោះស្រាយការប្រែប្រួលអាកាសធាតុ ជាមួយនឹងការអនុវត្តនូវប្រសិទ្ធភាព ធនធាន និរន្តរភាពបរិស្ថាន សមាហរណកម្មក្នុងសង្គម និងការកាត់បន្ថយភាពក្រីក្រ។[126]

### ២.២.៣. វិស័យអាទិភាពទាំង៨ សម្រាប់ការអភិវឌ្ឍទីក្រុងនិរន្តរភាព

យោងតាមវិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតងរបស់ប្រទេសកម្ពុជា មានវិស័យគន្លឹះចំនួន ៨ ដែលមានសារៈសំខាន់ក្នុងការអភិវឌ្ឍនិរន្តរភាពនៅក្នុងទីក្រុង ដោយវិស័យទាំងនោះរួមមាន ការរៀបចំផែនការ

[126] របាយការណ៍ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ២០១៨-២០៣០ , វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ឆ្នាំ២០១៨ ទំព័រទី ១១

អភិវឌ្ឍន៍ទីក្រុងនិរន្តរភាព, ភាពងាយរងគ្រោះរបស់ទីក្រុង, វិស័យថាមពល, វិស័យដឹកជញ្ជូន, បរិស្ថានសំណង់, កម្មន្តសាល, ការគ្រប់គ្រងសំណល់រឹង, និងទីធ្លាសាធារណៈ និងបេតិកភណ្ឌវប្បធម៌។

### ២.២.៣.១. បញ្ហាប្រឈមសំខាន់ៗក្នុងវិស័យអាទិភាព

ការសិក្សាទៅលើវិស័យអាទិភាពទាំង៨ នេះគឺ ដើម្បីកំណត់ពីបញ្ហាប្រឈម និងឱកាសនៃការអភិវឌ្ឍនិរន្តរភាពនៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ ប្រសិទ្ធភាពធនធាន និរន្តរភាពបរិស្ថាន កំណើនសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ និងបរិយាប័ន្នសង្គម ដែលយើងនឹងវិភាគបន្ថែមនៅក្នុងចំណុចក្រោមៗនេះ។

**ក. ការរៀបចំផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព**

នៅមុនការអនុម័តផែនការមេប្រើប្រាស់ដីធ្លីរាជធានីភ្នំពេញ ឆ្នាំ២០៣៥ ទីក្រុងភ្នំពេញមានគម្រោងកម្មវិធីអភិវឌ្ឍន៍ពីវិស័យឯកជនជាច្រើន ប៉ុន្តែមានបទប្បញ្ញត្តិតិចតួចចែងអំពីការការពាររចនាសម្ព័ន្ធទីក្រុង ការបែងចែកតំបន់បេតិកភណ្ឌ តំបន់ធនធានធម្មជាតិ និងតំបន់សម្រាប់ប្រជាជនក្រីក្រ។ គេបានធ្វើការប៉ាន់ស្មានថា ចាប់តាំងពីឆ្នាំ១៩៩៩ មក ប្រជាជនប្រហែល ១៥០ ០០០នាក់ បានត្រូវបានផ្លាស់ទីលំនៅចេញពីទីតាំងកណ្តាលនៃរាជធានីភ្នំពេញដើម្បីសម្របតាមការអភិវឌ្ឍទីក្រុង (Redevelopment)។ ការបន្តការអភិវឌ្ឍជាឯកជននៅតែជាហានិភ័យសម្រាប់ប្រជាជនក្រីក្រក្នុងទីក្រុងដដែល។

ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ទីក្រុងភ្នំពេញមានការរីកចម្រើនយ៉ាងឆាប់រហ័សនូវសំណង់អគារថ្មីៗ អគារខុនដូខ្ពស់ៗ ផ្សារទំនើប កាស៊ីណូ សហគមន៍ និងភូមិគ្រឹះទំនើបស្កឹមស្កៃសម្រាប់គ្រួសារដែលមានប្រាក់ចំណូលខ្ពស់។ គម្រោងអភិវឌ្ឍន៍ទីក្រុងរណបចំនួន ៧ ត្រូវគ្រោងបញ្ចប់នៅក្នុងរយៈពេល ១០ ទៅ ១៥ឆ្នាំបន្ទាប់ដែលនឹងគ្របដណ្តប់លើផ្ទៃដីចំនួន ៨ ០០០ហិចតា ឬស្មើ ១២% នៃផ្ទៃដីសរុបរបស់ទីក្រុង។ ការសាងសង់សំណង់ដោយមិនអនុលោមតាមច្បាប់សាងសង់ អាចមានផលប៉ះពាល់អវិជ្ជមានដល់ការបំពេញមុខងាររបស់ទីក្រុងទាំងមូល។ កង្វះការគ្រប់គ្រងទៅលើការវិនិយោគឯកជនអាចធ្វើឱ្យមានការរាំងស្ទះដល់ការអនុវត្តផែនការមេប្រើប្រាស់ដីធ្លីឆ្នាំ២០៣៥។[127]

**ខ. ភាពងាយរងគ្រោះរបស់ទីក្រុង**

ការជន់លិចក្លាយជាបញ្ហាកាន់តែធ្ងន់ធ្ងរឡើងៗនៅរាជធានីភ្នំពេញ។ ក្នុងរយៈពេល ៥០ឆ្នាំចុងក្រោយនេះ ការជន់លិចដែលមានសភាពធ្ងន់ធ្ងរ បានកើតឡើងប្រហែលជារៀងរាល់ ៥ឆ្នាំម្តង។[128] ការជន់លិចកាន់តែធ្ងន់ធ្ងរនេះគឺ ដោយសារការអភិវឌ្ឍពាណិជ្ជកម្មរបស់វិស័យឯកជន នៅក្នុងតំបន់ដែលពីមុនមកគឺជាលំហបៃតង

---

[127] របាយការណ៍ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ២០១៨-២០៣០ , វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ឆ្នាំ២០១៨ ទំព័រទី ១៦

[128] របាយការណ៍ ស្តីពី ហានិភ័យគ្រោះមហន្តរាយនៃនគរូបនីយកម្ម ភាពងាយរងគ្រោះនៃតំបនក្រីក្រក្នុងក្រុងពីការលិចទឹកក្នុងទីក្រុង និងផលប៉ះពាល់ផ្សេងទៀត , អង្គការ People In Need (PIN) បោះពុម្ពឆ្នាំ២០១៥

សាធារណៈ បឹងធម្មជាតិ ឬតំបន់ដីសើម និងដែលកន្លងមកវាជាប្រព័ន្ធគ្រប់គ្រងទឹក ជំនន់ធម្មជាតិ និងប្រព័ន្ធគ្រប់គ្រងទឹកកខ្វក់។ ក្នុងអំឡុងឆ្នាំ២០០៣-២០១៥ គេបានប៉ាន់ស្មានថា តំបន់វាលភក់ បឹង និងតំបន់ដីសើមនៅរាជធានីភ្នំពេញបានថយចុះ ៥០%។[129]

បញ្ហាប្រឈមបន្ថែមទៀតនៃភាពងាយរងគ្រោះនៅទីក្រុងគឺ កង្វះហេដ្ឋារចនាសម្ព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។ នៅតំបន់ទីប្រជុំជនក្រុងសំខាន់ៗ ទឹកកខ្វក់ចេញពីផ្ទះ និងអគារពាណិជ្ជកម្មភាគច្រើនបង្ហូរចូលទៅក្នុងលូ/អាងស្តុកទឹកកខ្វក់ (Septic Tanks) នៅទីតាំងផ្ទាល់ដែលតភ្ជាប់ ទៅប្រព័ន្ធបណ្តាញលូក្រុងដែលរួមមានលូក្រោមដី និងប្រឡាយចំហ។ ការអង្កេតបានសន្និដ្ឋានថា គ្រួសារប្រហែល ៧០% មានលូ/អាងស្តុក ទឹកកខ្វក់ដែលតភ្ជាប់ទៅប្រព័ន្ធបណ្តាញលូ ខណៈដែលប្រហែល ២០% មានលូ/អាងស្តុកទឹកកខ្វក់ដែរ តែមិនមានការតភ្ជាប់។[130]

រាជធានីភ្នំពេញ ក៏ពុំមានហេដ្ឋារចនាសម្ព័ន្ធសម្រាប់សំណល់ភក់ដែលបង្កពីអាងទឹកកខ្វក់ដែរ។ កាលពីមុន សំណល់ទឹកកខ្វក់ ពីអគារពាណិជ្ជកម្ម និងតាមផ្ទះសម្បែងប្រជាពលរដ្ឋ ត្រូវបានយកចេញដោយរថយន្តស៊ីទែនបូមភក់ បន្ទាប់មកយកទៅចាក់ចោលនៅកន្លែងចាក់សំណល់រឹង។ នៅពេលរណ្តៅពេញណែនដោយភក់ ប្រតិបត្តិករកន្លែងចាក់សំរាមបានផ្អាកការចាក់គរភក់។ ដោយសារមិនមានទីតាំងដើម្បីចាក់ចោលភក់ ប្រតិបត្តិករបូមភក់ភាគច្រើនពេលនេះ កំពុងចាក់គរភក់ដោយខុសច្បាប់នៅប្រឡាយ និងនៅតំបន់ដីសើមដែលមានរយៈកម្ពស់ទាប។

នៅតំបន់ជុំវិញទីក្រុង និងតំបន់រស់នៅរបស់ប្រជាជនដែលមានប្រាក់ចំណូលទាប ហេដ្ឋារចនាសម្ព័ន្ធលើការរក្សាអនាម័យនៅតែមានកម្រិតខ្សោយ។ គ្រួសារមួយចំនួនដែលមានបង្គន់អនាម័យចាក់ទឹក គឺបង្ហូរទឹកសំណល់ផ្ទាល់ទៅក្នុងបណ្តាញលូ និងខ្សែទឹកក្នុងមូលដ្ឋាន។ ប្រហែល ១/៣ នៃគ្រួសារនៅតំបន់ក្រីក្របំផុតកប់សំណល់លាមក ឬបន្ទោរបង់ពាសវាលពាសកាល ហើយមានការរាយការណ៍ថាមាន អត្រាកើតមានជំងឺខ្ពស់ដូចជាជំងឺរាគរូស រលាកថ្លើមប្រភេទA ជំងឺព្រូន និងជំងឺសត្វតេនញ្ញា ដែលបណ្តាលមកពីការឆ្លងចេញពីលាមកដែលទាក់ទងទៅនឹងលក្ខខណ្ឌនៃការរស់នៅគ្មានអនាម័យ និងបន្សាំទៅនឹងកន្លែងបញ្ចេញទឹកសំណល់។

ភាពអសន្តិសុខនៃការកាន់កាប់ដី ក៏ជាបញ្ហាប្រឈមមួយទៀតចំពោះភាពងាយរងគ្រោះរបស់ទីក្រុងផងដែរ។ ការបណ្តេញចេញដោយបង្ខំទៅលើប្រជាជនមានប្រាក់ចំណូលទាប ដែលបង្កដោយគម្រោងអភិវឌ្ឍន៍ខ្នាតធំ បានបណ្តាលឱ្យគ្រួសារជាច្រើនកាន់តែងាយរងគ្រោះចំពោះផលប៉ះពាល់ដ៏ធ្ងន់ធ្ងរនៃការជន់លិច និង

[129] របាយការណ៍ វឌ្ឍនភាពពីការសិក្សាគម្រោងធ្វើឱ្យប្រសើរឡើងនៃប្រព័ន្ធលូទឹកកខ្វក់ និងទឹកភ្លៀងក្នុងតំបន់ទីប្រជុំជនរាជធានីភ្នំពេញ , JICA បោះពុម្ពខែវិច្ឆិកា ឆ្នាំ២០១៥

[130] របាយការណ៍ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ២០១៨–២០៣០ , វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ឆ្នាំ២០១៨ ទំព័រទី ១៩

ភាពក្រីក្រជាបន្ត ព្រោះពួកគេត្រូវបានប្ដូរទីលំនៅជាញឹកញាប់ទៅកាន់តំបន់ជាយទីក្រុង និងប្រឈមមុខទៅនឹងហានិភ័យខ្ពស់។[131]

**គ. វិស័យថាមពល**

ការខាតបង់តាមប្រព័ន្ធបណ្ដាញចែកចាយអគ្គិសនីនៅរាជធានីភ្នំពេញមានចន្លោះពី ៨,២% ដល់ ៩,៦% រវាងឆ្នាំ២០០៩ និងឆ្នាំ ២០១៤។[132] វិស័យថាមពលក៏កំពុងជួបការលំបាកផងដែរដោយសារប្រសិទ្ធភាពផ្នែករដ្ឋបាល ការបញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធផលិតថាមពល មិនទាន់មានលក្ខណៈល្អប្រសើរ។ គុណភាពនៃការផ្គត់ផ្គង់នៅមានកម្រិតទាប ការកាត់ផ្ដាច់ចរន្តអគ្គិសនី និងការឡើងចុះតង់ស្យុងកើតឡើងជាទូទៅ។ នៅឆ្នាំ២០១៥ ចំនួនជាមធ្យមនៃការដាច់ភ្លើងអគ្គិសនីនៅរាជធានីភ្នំពេញ ដែលអាចប៉ាន់ប្រមាណបានគឺ ២៤ដង ហើយរយៈពេលដាច់ជាមធ្យមគឺ ៧២០នាទី (អត្រាខ្ពស់បំផុតក្នុងចំណោមបណ្ដាប្រទេសសមាជិកអាស៊ាន) ហើយសហគ្រាសក្នុងស្រុក និងបរទេសភាគច្រើនយល់ឃើញថា តម្លៃខ្ពស់ និងកង្វះការផ្គត់ផ្គង់អគ្គិសនីគឺជាកត្តារាំងស្ទះចម្បងមួយនៅក្នុងការធ្វើអាជីវកម្ម នៅប្រទេសកម្ពុជា។[133]

ប្រទេសកម្ពុជាមានសក្ដានុពលថាមពលកកើតឡើងវិញយ៉ាងច្រើនដូចជាថាមពលព្រះអាទិត្យ ជីវម៉ាស និងការកែច្នៃសំណល់ទៅជាថាមពល។ ទោះជាយ៉ាងនេះក្ដី ការប្រើប្រាស់ប្រភពថាមពលទាំងនេះនៅមានកម្រិតទាប។ សំណល់រឹង និងទឹកកខ្វក់ក្នុងទីក្រុងអាចប្រើជាប្រភពជីវថាមពលដែលជាសក្ដានុពលផ្សេងបន្ថែមទៀត។ ការផលិតជីវឧស្ម័នសម្រាប់គោលបំណងបង្កើតកំដៅ និងការផលិតអគ្គិសនីមានសក្ដានុពលសំខាន់នៅរាជធានីភ្នំពេញ សម្រាប់អាងប្រព្រឹត្តកម្មទឹកកខ្វក់ និងរោងចក្រកម្មន្តសាលនៅក្នុងទីក្រុង។

ការលើកកម្ពស់ថាមពលកកើតឡើងវិញមានបញ្ហាប្រឈមជាច្រើនដូចជា អត្រាការប្រាក់ខ្ពស់សម្រាប់កម្ចីតូចៗ ដែលធ្វើឱ្យមានការពិបាកក្នុងការបង់ថ្លៃចំណាយជាមុន ភាពស្ទាក់ស្ទើររបស់ឧស្សាហកម្មក្នុងការបណ្ដាក់ទុនវិនិយោគ កង្វះការគាំទ្រផ្នែកច្បាប់ គោលនយោបាយ ឧទាហរណ៍លើការលក់អគ្គិសនីដែលបានពីប្រភពថាមពលកកើតឡើងវិញទៅក្នុងបណ្ដាញអគ្គិសនីជាតិ (Net-Metering) ឬថ្លៃអនុគ្រោះលើបច្ចេកវិទ្យាថាមពលកើតឡើងវិញ (Feed-In Tariff) កង្វះការយល់ដឹងពីប្រព័ន្ធអគ្គិសនីនេះ ក្នុងចំណោមអតិថិជនជាសក្ដានុពល និងកង្វះអ្នកផ្ដល់សេវាថែទាំ។

[131] របាយការណ៍ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ២០១៨-២០៣០ , វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ឆ្នាំ២០១៨ ទំព័រទី ១៩

[132] របាយការណ៍ប្រចាំឆ្នាំរបស់អគ្គិសនីកម្ពុជា ឆ្នាំ២០១៤

[133] របាយការណ៍ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ២០១៨-២០៣០ , វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ឆ្នាំ២០១៨ ទំព័រទី ២៣

ឧបសគ្គផ្សេងទៀតចំពោះការបង្កើនប្រសិទ្ធភាពថាមពលនៅប្រទេសកម្ពុជារួមមាន៖

- កង្វះការយល់ដឹងអំពីកាលានុវត្តភាពនៃប្រសិទ្ធភាពប្រើប្រាស់ថាមពល ទោះបីជាថ្លៃថាមពលមានតម្លៃខ្ពស់ក៏ដោយ
- កង្វះការយល់ដឹងអំពីការវិនិយោគដែលមានប្រសិទ្ធភាពថាមពល ក្នុងចំណោមអ្នកផ្តល់កម្ចីពាណិជ្ជដែលនាំឱ្យមានភាពស្ទាក់ស្ទើរក្នុងការផ្តល់ហិរញ្ញប្បទានដល់គម្រោងអាជីវកម្មដែលមានប្រសិទ្ធភាពថាមពល
- កង្វះនូវមូលនិធិសម្រាប់កម្មវិធី ប្រកបដោយការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីប្រសិទ្ធភាពថាមពល
- កង្វះស្ថាប័នដែលអាចធ្វើសវនកម្មថាមពល និងអនុវត្តវិធានការប្រសិទ្ធភាពថាមពល (ដូចជាក្រុមហ៊ុនសេវាថាមពល)។

### ឃ. វិស័យដឹកជញ្ជូន

ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន មិនអាចតាមទាន់ការកើនឡើងយ៉ាងឆាប់រហ័សនូវបរិមាណចរាចរណ៍ឡើយ។ ដោយធៀបនឹងទីក្រុងផ្សេងទៀតនៅក្នុងតំបន់ រាជធានីភ្នំពេញមានដង់ស៊ីតេផ្លូវថ្នល់ទាបជាពិសេសនៅខាងក្រៅតំបន់កណ្តាលទីក្រុង (ខណ្ឌកណ្តាលក្រុងមាន ផ្លូវថ្នល់ ៩៤%)។ គម្រោងលំនៅឋានមួយចំនួនកំពុងត្រូវបានបន្តធ្វើនៅតំបន់ជាយក្រុង ដោយមិនបានធ្វើការពិចារណាដល់លទ្ធភាព ប្រើប្រាស់បណ្តាញផ្លូវថ្នល់ និងការរីកសាយចរាចរណ៍។ ស្រដៀងគ្នានេះដែរ កង្វះខាតការធ្វើផែនការសម្រាប់យានយន្តធុនធ្ងន់ដែលបម្រើដល់រោងចក្រ និងដេប៉ូគ្រឿងសំណង់បាននាំឱ្យមានការចុះទ្រុឌទ្រោមផ្លូវថ្នល់នៅតំបន់មួយចំនួន។

មានបញ្ហាប្រឈមជាច្រើនដែលត្រូវបានកំណត់នៅក្នុងការគ្រប់គ្រងចរាចរណ៍នៅរាជធានីភ្នំពេញ ដូចជាផ្លូវបំបែកដែលចោទជាបញ្ហា ប្រព័ន្ធដាក់សញ្ញាធ្វើដំណើរមិនគ្រប់គ្រាន់ កង្វះការដាក់សញ្ញាសម្គាល់ផ្លូវថ្នល់ និងចំណតមិនមានការត្រួតពិនិត្យ។ កន្លែងចតមិនគ្រប់គ្រាន់នៅតំបន់កណ្តាលទីក្រុងកំពុងក្លាយជាបញ្ហាចោទខ្លាំងដែលនាំឱ្យអ្នកបើកបរចតនៅលើផ្លូវថ្នល់ ឬនៅលើចិញ្ចើមផ្លូវ ដែលធ្វើឱ្យរាំងស្ទះផ្លូវថ្មើរជើង។ លើសពីនេះទៅទៀតចិញ្ចើមផ្លូវសម្រាប់ថ្មើរជើងនៅរាជធានីភ្នំពេញ ត្រូវបានបាត់បង់មួយចំនួនដោយសារការពង្រីកផ្លូវសម្រាប់រថយន្ត។ ការអនុវត្តបទប្បញ្ញត្តិស្តីពីការចតយានយន្ត គឺជាបញ្ហាប្រឈមចម្បង។ ការដឹកជញ្ជូនទំនិញក៏កំពុងប្រឈមមុខនឹងបញ្ហា ដូចជាការខូចខាតផ្លូវថ្នល់ និងកង្វះលំហក្រៅផ្លូវសាធារណៈសម្រាប់ការរើទំនិញចុះ។[134]

### ង. បរិស្ថានសំណង់

ទោះបីមានកិច្ចខិតខំប្រឹងប្រែងនៅក្នុងក្របខណ្ឌគោលនយោបាយ ដើម្បីការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យក៏ដោយ ក៏ការផ្គត់ផ្គង់លំនៅឋានប្រភេទនេះនៅតែមានចំនួនមិនគ្រប់គ្រាន់នៅឡើយ។ គម្រោងអភិវឌ្ឍលំនៅឋាន

[134] របាយការណ៍ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ២០១៨–២០៣០ , វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ឆ្នាំ២០១៨ ទំព័រទី ២៧

ថ្មីៗស្ទើរតែទាំងអស់នៅក្នុងរាជធានីភ្នំពេញ គឺបានផ្តោតទៅលើអ្នកដែលមានប្រាក់ចំណូលខ្ពស់ និងជនបរទេស ដែលវាជាកត្តាប្រឈមធ្វើឱ្យការផ្គត់ផ្គង់លំនៅឋានតម្លៃសមរម្យនៅមានកម្រិត។ ដំណោះស្រាយគឺត្រូវធ្វើយ៉ាងណាឱ្យគម្រោងវិនិយោគសាងសង់លំនៅឋានមានតម្លៃសមរម្យ និងមានលក្ខណៈបៃតង ក្លាយជាអាទិភាពមួយរបស់រាជរដ្ឋាភិបាល ដើម្បីឱ្យមានភាពទាក់ទាញចំពោះវិនិយោគិនឯកជន។ ផ្ទះបើកអាជីវកម្មបច្ចុប្បន្នដែលមានតម្លៃសមរម្យ គឺមិនបានរចនាសាងសង់ឱ្យស្របទៅនឹងបទដ្ឋានពាក់ព័ន្ធនឹងប្រសិទ្ធភាពថាមពល និងការតម្រូវឱ្យមានខ្យល់ចេញចូលធម្មជាតិឡើយ។ អ្នកធ្វើការដែលមានប្រាក់ចំណូលទាបមាននិន្នាការជួលបន្ទប់នៅក្នុងផ្ទះដែលមានមនុស្សច្រើនកុះករ និងបញ្ហាហប់ខ្យល់ដែលអាចបង្កឱ្យមានគ្រោះថ្នាក់ដល់អ្នកស្នាក់នៅ។ លើសពីនេះទៀត ផ្ទះបើកអាជីវកម្មភាគច្រើនត្រូវបានសាងសង់នៅជាប់នឹងចិញ្ចើមផ្លូវ ដោយមិនទុកលំហសម្រាប់តំបន់បៃតង ឬដើមឈើឡើយ។

ខណៈពេលដែលការរីកដុះដាលយ៉ាងរហ័សនៃវិស័យសំណង់ មានឯកសារតិចតួចបំផុតដែលត្រូវបានចងក្រងស្តីអំពីទស្សនទាននៃការរចនាសំណង់អគារបៃតង ហើយបញ្ចូលទៅក្នុងផែនការជាតិស្តីពីស្ថាបត្យកម្ម និងការគ្រប់គ្រងសំណង់អគារ។ ដោយមានការធ្វើបច្ចុប្បន្នភាពក្រមស្តីពីសំណង់អគារ គឺយើងមានឱកាសក្នុងការដាក់បញ្ចូលទស្សនទានស្តីពីអគារបៃតងទៅក្នុងក្រម។[135]

**ច. កម្មន្តសាល**

សម្រាប់វិស័យកម្មន្តសាលរបស់ប្រទេសកម្ពុជា បញ្ហាប្រឈមដែលត្រូវដោះស្រាយដើម្បីឱ្យមាននិរន្តរភាពក្នុងវិស័យនេះរួមមាន ការកាត់បន្ថយការបំពុល ការកាត់បន្ថយការប្រើប្រាស់ថាមពលតាមរយៈវិធានការប្រសិទ្ធភាពថាមពល និងការសន្សំសំចៃថាមពល ការថែរក្សាសុខភាព និងពង្រឹងសុវត្ថិភាពការងារ ព្រមទាំងការកែលម្អលក្ខខណ្ឌការងារផងដែរ។ ការតាមដាន និងការអនុវត្តបទដ្ឋាន គ្រប់គ្រងការបំពុលតម្រូវឱ្យមានការពង្រឹងបន្ថែមទៀត។

បញ្ហាបរិស្ថានសំខាន់ចំពោះវិស័យកាត់ដេររួមមាន ការបំពុលខ្យល់ ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (Green House Gas - GHG) ពីឡកំដៅ និងសំណល់រាវដែលអាចមានជាតិពុលចេញពីដំណើរការលាយពណ៌ និងដាក់ថ្នាំឱ្យមានពណ៌ស។ ឧស្សាហកម្មទាំងនេះក៏ប្រើប្រាស់ថាមពលច្រើនដែរ និងជាទូទៅធ្វើប្រតិបត្តិការដោយប្រើប្រាស់បរិក្ខារចាស់ៗ និងគ្មានប្រសិទ្ធភាព។ លើសពីនេះទៀត ការផ្តល់នូវការបញ្ចេញបញ្ចូលខ្យល់នៅកន្លែងធ្វើការគ្រប់គ្រាន់ និងការបញ្ចៀសការប្រឈមរបស់កម្មករទៅនឹងសារធាតុគីមីពុលមានការចាំបាច់ ដើម្បីកែលម្អបរិយាកាសធ្វើការ។

[135] របាយការណ៍ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ២០១៨-២០៣០ , វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ឆ្នាំ២០១៨ ទំព័រទី ២៩

បញ្ហាមួយផ្សេងទៀត គឺការបោះទីតាំងរោងចក្រកម្មន្តសាលនៅក្នុងតំបន់ទីក្រុងពហុបំណង ដូចជានៅជាប់នឹងការប្រើប្រាស់ដី លំនៅឋាន និងកសិកម្ម។ ក្នុងកាលៈទេសៈទាំងនេះ ការបញ្ចេញសារធាតុបំពុលពីរោងចក្រអាចបណ្តាលឱ្យមានបញ្ហាច្រើនចំពោះប្រជាជនដែលរស់នៅ និងធ្វើការនៅក្បែរនោះ ដែលនេះគឺជាប្រភពសំខាន់នៃបណ្តឹងទៅអាជ្ញាធរទីក្រុង។ ស្រដៀងគ្នានេះដែរ ការបោះទីតាំងរោងចក្រ កម្មន្តសាលនៅតំបន់ដែលមិនមានបណ្តាញផ្លូវដឹកជញ្ជូនសមស្រប អាចបង្កបញ្ហាកកស្ទះចរាចរណ៍សម្រាប់តំបន់ជុំវិញទីនោះ។[136]

**ឆ. ការគ្រប់គ្រងសំណល់រឹង**

ប្រព័ន្ធនៃការគ្រប់គ្រងសំរាម សំណល់រឹងទីក្រុងនៅរាជធានីភ្នំពេញ គួរតែត្រូវធ្វើការកែលម្អពីដំណាក់កាលដំបូងនៃការកកើតសំរាមរហូតដល់ដំណាក់កាលចុងក្រោយ។ នៅដំណាក់កាលដំបូង សំរាមកើតចេញពីការប្រើប្រាស់នៅតាមផ្ទះ និងកន្លែងធ្វើអាជីវកម្ម/ពាណិជ្ជកម្មនានា សំរាមទាំងនោះគួរត្រូវបានធ្វើការបែងចែកទៅតាមប្រភេទសំរាមដើម្បីបង្កភាពងាយស្រួលក្នុងការប្រមូល និងធ្វើការកែច្នៃឡើងវិញ ការយកមកធ្វើជាកំប៉ុស្ត៍ ឬបំប្លែងទៅជាថាមពលប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព។ លើសពីនេះទៀត សំរាមនៅតំបន់ជាយក្រុងមួយចំនួនមិនត្រូវបានប្រមូលទេ ព្រោះក្រុមហ៊ុនប្រមូលសំរាមមិនអាចចូលទៅដល់កន្លែងទាំងនោះបាន និងមិនមានសម្ភារៈបរិក្ខារសម្រួលដល់តំបន់ទាំងនោះក្នុងការទុកដាក់សំរាម។

បញ្ហាប្រឈមផ្សេងទៀត គឺតម្រូវការនូវទីលានចាក់សំរាមដែលមានលក្ខណៈសមស្របផ្នែកបច្ចេកទេស ពោលគឺទីលានចាក់សំរាម ដែលមានសក្តានុពលក្នុងការបង្កើត និងប្រតិបត្តិការស្ថានីយធ្វើជីកំប៉ុស្ត៍ពីសំរាម ឬរោងចក្រដែលអាចបំប្លែងសំរាមទៅជាថាមពល ជាដើម។ ទីលានចាក់សំរាមចាស់នៅស្ទឹងមានជ័យដែលមានប្រតិបត្តិការតាំងពីឆ្នាំ១៩៦៥ គឺមិនមានលក្ខណៈសមស្របតាមបច្ចេកទេស ហើយក៏ធ្លាប់ជួបប្រទះការឆេះសំរាមផងដែរ។ ទីលានចាក់សំរាមនេះស្តុកសំរាមលើសចំណុះ ដូច្នេះត្រូវបានធ្វើការបិទបញ្ចប់ និងដាក់ឱ្យឈប់ដំណើរការចាប់តាំងពីឆ្នាំ២០០៩ មក។

ចាប់តាំងពីខែកក្កដា ឆ្នាំ២០០៩ មក ទីលានចាក់សំរាមថ្មីមួយត្រូវបានបើកឱ្យដំណើរការនៅខណ្ឌដង្កោ ដោយមានរណ្តៅផ្ទុកសំរាម ចំនួន៤ (A B C និងD)។ ទីលានចាក់សំរាមនេះស្ថិតនៅចម្ងាយ ១៥គីឡូម៉ែត្រ ពីកណ្តាលរាជធានីភ្នំពេញ និងគ្របដណ្តប់លើផ្ទៃដីប្រមាណជាង ៣១ ហិចតា។ រណ្តៅចំនួនពីរ (A និងB) បានពេញចំណុះ ហើយរណ្តៅ C និងD ត្រូវបានបើកឱ្យដំណើរការនៅខែមេសា ឆ្នាំ២០១៦។ ទីលានចាក់សំរាមបានពេញយ៉ាងលឿន ហើយមានការសង្កេតឃើញថា ទីលានចាក់សំរាមនេះមានដំណើរការមិនទាន់សមស្របតាម

[136] របាយការណ៍ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ២០១៨-២០៣០ , វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ឆ្នាំ២០១៨ ទំព័រទី ៣២

ផ្នែកបច្ចេកទេស និងមិនអំណោយផលទៅដល់បរិស្ថាន។ ជាឧទាហរណ៍ បច្ចេកទេសក្នុងការបង្រួមសំរាមមិនត្រូវបានអនុវត្តនោះទេ ដែលនាំឱ្យមានការប្រើប្រាស់ទីលានចាក់សំរាមមិនសូវមានប្រសិទ្ធភាព។[137]

**ជ. ទីធ្លាសាធារណៈ និងបេតិកភណ្ឌវប្បធម៌**

ទីធ្លាសាធារណៈដែលសំខាន់មួយផងដែរនោះ គឺចិញ្ចើមផ្លូវក្នុងទីក្រុងសម្រាប់អ្នកថ្មើរជើង ត្រូវបានទន្ទ្រានយកដោយការចតរថយន្ត ម៉ូតូ និងអ្នកលក់ដូរក្រៅប្រព័ន្ធដែលធ្វើឱ្យការធ្វើដំណើរដោយថ្មើរជើងនៅរាជធានីភ្នំពេញមានការពិបាកយ៉ាងខ្លាំង ហើយពេលខ្លះមានគ្រោះថ្នាក់ផងដែរ។ ជាងនេះទៅទៀត ទីធ្លាសាធារណៈជាច្រើនដែលបានបង្កើតឡើង មិនទទួលបាននូវការរចនាល្អពាក់ព័ន្ធនឹងការគ្រប់គ្រងទឹក និងការធ្វើឱ្យមានភាពត្រជាក់ដោយធម្មជាតិ។ ឧទ្យាន និងសួនច្បារនៅខណ្ឌក្នុងក្រុងជាច្រើន ត្រូវបានក្រាលយ៉ាងពេញលេញដោយសម្ភារៈក្រាស់ដែលការពារទឹកមិនឱ្យជ្រាបចូលក្នុងដី។

លើសពីនេះទៀត ដើមឈើ និងចុល្លព្រឹក្សលម្អនៅក្នុងសួនច្បារទាំងនេះដែលសមត្ថភាពនៅមានកម្រិតសម្រាប់ការផ្តល់ម្លប់ និងសម្រាប់ការរក្សាទុកទឹក។ អគារ និងតំបន់បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ ជាច្រើនត្រូវបានបំផ្លាញចោល ដើម្បីផ្តល់ឱកាសដល់គម្រោងអភិវឌ្ឍន៍ទីក្រុងថ្មីៗ ឬត្រូវបានអនុញ្ញាតឱ្យបំផ្លាញចោល។ អគារទាំងនេះ គឺជាឧទាហរណ៍នៃស្ថាបត្យកម្មពីសម័យអាណានិគមបារាំង ព្រមទាំងពីចលនាស្ថាបត្យកម្មខ្មែរថ្មី (New Khmer Architecture) នៃទសវត្សរ៍ ឆ្នាំ១៩៥០ និង១៩៦០។ អគារប្រវត្តិសាស្ត្រដែលរងការគំរាមកំហែងក្នុងនោះមាន ពហុកីឡដ្ឋានជាតិ ប៉ុស្តិ៍នគរបាលរាជធានីភ្នំពេញចាស់ និងសណ្ឋាគាររណសិរ្សប្រវត្តិសាស្ត្រ។ ប្រសិនបើត្រូវបានស្តារឡើងវិញ អគារទាំងនេះមិនត្រឹមតែផ្តល់អត្តសញ្ញាណវប្បធម៌ដល់ទីក្រុងប៉ុណ្ណោះទេ ប៉ុន្តែអគារទាំងនេះក៏មានសក្តានុពលសម្រាប់ការទាក់ទាញភ្ញៀវទេសចរផងដែរ។[138]

**២.២.៣.២. សកម្មភាពអាទិភាពក្នុងការអភិវឌ្ឍទីក្រុងនិរន្តរភាព**

ដើម្បីឈានទៅដល់ការបំពេញចក្ខុវិស័យ គោលបំណង និងគោលដៅនៃការអភិវឌ្ឍទីក្រុងបៃតង និងនិរន្តរភាព ផែនការអភិវឌ្ឍន៍ទីក្រុងភ្នំពេញដោយនិរន្តរភាព បានដាក់នូវផែនការសកម្មភាពមួយចំនួនសម្រាប់ដោះស្រាយបញ្ហាប្រឈមដែលមាននៅក្នុងវិស័យអាទិភាពទាំង ៨ រួមមាន៖

**ក. ការរៀបចំផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព**

- ផ្សព្វផ្សាយផែនការមេ (ប្លង់គោល) ស្តីពីការប្រើប្រាស់ដីធ្លីឆ្នាំ២០៣៥ ដើម្បីបង្ហាញពីហេដ្ឋារចនាសម្ព័ន្ធ/តំបន់សម្រាប់ពេលអនាគតនៃទីប្រជុំជនក្នុងទីក្រុង ទីតាំង និងមុខងារនៃការកំណត់តំបន់ ដង់ស៊ីតេ

[137] របាយការណ៍ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ២០១៨-២០៣០ , វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ឆ្នាំ២០១៨ ទំព័រទី ៣៦

[138] របាយការណ៍ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ២០១៨-២០៣០ , វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ឆ្នាំ២០១៨ ទំព័រទី ៣៨

បរិស្ថាន អគារសំណង់ដែលនឹងត្រូវបានបង្កើត ទិសដៅនៃការរីកលូតលាស់ និងការបែងចែកតំបន់ជុំវិញរាជធានី

- កំណត់តំបន់អភិរក្ស (ធនធានធម្មជាតិ ទីធ្លាសាធារណៈ បេតិកភណ្ឌវប្បធម៌ និងបូជនីយដ្ឋានដែលត្រូវបានការពារអភិរក្ស) ដែលមិនអនុញ្ញាតឱ្យមានសកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ឬអគារណាមួយអាចធ្វើឡើងបានឡើយ
- កំណត់ទិសដៅនៃការពង្រីកទីប្រជុំជនក្រុង បញ្ចៀសទិសដៅដែលមានហានិភ័យធម្មជាតិ និងអាកាសធាតុដូចជាការជន់លិច ឬការសឹកច្រាំងទន្លេ រៀបចំផែនការសម្រាប់អភិវឌ្ឍន៍ទីក្រុងដែលបញ្ចេញកាបូនទាបដែលនឹងបង្កើនដង់ស៊ីតេទីប្រជុំជនខ្ពស់ និងសម្រាប់ការប្រើប្រាស់ជាអតិបរមានូវហេដ្ឋារចនាសម្ព័ន្ធទីក្រុង
- ចៀសវាងការប្រើតែមធ្យោបាយដឹកជញ្ជូនដែលមានការចំណាយច្រើន គ្មានប្រសិទ្ធភាពថាមពល និងមានការបំពុលបរិយាកាស ផ្តល់ដីដល់តំបន់លំនៅឋានសម្រាប់គ្រួសារមានប្រាក់ចំណូលទាប និងកំណត់តំបន់ប្រមូលផ្តុំរោងចក្រឱ្យនៅឆ្ងាយពីលំនៅឋាន
- កែលម្អការប្រមូល និងការគ្រប់គ្រង ទិន្នន័យមូលដ្ឋាន សម្រាប់ការធ្វើគោលនយោបាយអភិវឌ្ឍន៍ទីក្រុងប្រកបដោយភាពជាក់លាក់ និងមានការវិភាគត្រឹមត្រូវ
- ពង្រឹងកិច្ចសហប្រតិបត្តិការ ការសម្របសម្រួល និងតម្លាភាពនៃដំណើរការរៀបចំផែនការ ដោយមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ និងសាធារណជន (ជាពិសេសអ្នកដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ពីសេចក្តីសម្រេចចិត្ត)
- អនុវត្តយុទ្ធនាការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ តាមរយៈអាជ្ញាធរមូលដ្ឋានអំពីដំណើរការរៀបចំផែនការអភិវឌ្ឍន៍ទីក្រុង កែលម្អអភិបាលកិច្ចមូលដ្ឋាន និងការអនុវត្តបទប្បញ្ញត្តិនានាទាក់ទងទៅនឹងសណ្តាប់ធ្នាប់ និងការរក្សាអនាម័យទីក្រុង ពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។[139]

**ខ. ភាពងាយរងគ្រោះរបស់ទីក្រុង**

- ការពារបឹងធម្មជាតិ ស្ទឹង ប្រឡាយ និងតំបន់ដីសើមក្នុងទីក្រុង និងមិនត្រូវអនុញ្ញាតឱ្យមានការធ្វើពាណិជ្ជកម្មបន្ថែមទៀតឡើយ
- ស្តារឡើងវិញច្រករបៀងបៃតង ឬបង្កើតច្រករបៀងទាំងនោះនៅក្នុងទីក្រុងឱ្យមានការប្រើប្រាស់សម្រាប់ការវិនិយោគ

[139] របាយការណ៍ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ២០១៨-២០៣០ , វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ឆ្នាំ២០១៨ ទំព័រទី ៣៩

- បង្កើនទ្វេដងនូវទីធ្លាបៃតង ធៀបទៅនឹងពេលបច្ចុប្បន្ន ដោយក្នុងមនុស្សម្នាក់មាន ១,១ ម៉ែត្រ ដើម្បីជាប្រព័ន្ធផ្ទុក (ស្រូប) ជំនន់ទឹកភ្លៀង កាត់បន្ថយការជន់លិច និងបង្កើនជីវៈចម្រុះ
- ស្ដារឡើងវិញនូវប្រព័ន្ធជលវិទ្យាធម្មជាតិ ដើម្បីប្រើប្រាស់បានច្រើនមុខងារ (នេសាទ វារីវប្បកម្ម កម្សាន្ត និងការកែលម្អជីវៈចម្រុះ)
- ធ្វើឱ្យកាន់តែរឹងមាំនូវប្រព័ន្ធបណ្ដាញលូនៅតំបន់ងាយជន់លិច ដោយប្រើប្រាស់ប្រព័ន្ធទប់ស្កាត់ទឹកភ្លៀង ប្រមូលទឹកភ្លៀង ការស្ដារ ប្រព័ន្ធជលវិទ្យាធម្មជាតិ តំបន់បៃតង និងវិធានការវិស្វកម្ម
- ធ្វើជីវវិស្វកម្មដោយប្រើប្រាស់ប្រភេទរុក្ខជាតិដើមក្នុងស្រុកដើម្បីការពារការសឹក ការពារទឹកជំនន់ និងផ្ទុក (ស្រូប) ទឹកភ្លៀង
- ចម្រោះទឹកកខ្វក់ដែលកើតមាននៅក្នុងតំបន់ប្រជុំជនក្រុង ដោយប្រើប្រាស់យ៉ាងហោចណាស់ប្រព័ន្ធប្រព្រឹត្តកម្មបន្ទាប់បន្សំ
- បង្កើតប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់វិមជ្ឈការ (ខ្នាតតូចតាមតំបន់) និងពង្រឹងការអនុវត្តនៅក្នុងសហគមន៍ក្រីក្រដែលនៅជាយរាជធានី
- កាត់បន្ថយការខូចខាតផ្នែកទ្រព្យសម្បត្តិ ការបាត់បង់អាយុជីវិត និងការខូចខាតសេដ្ឋកិច្ចដែលបណ្ដាលមកពីការជន់លិចនៅក្នុងទីក្រុង
- ជម្លៀសប្រជាជនដែលរស់នៅក្នុងតំបន់លិចទឹក ទៅតំបន់ទីតាំងលំនៅឋានដែលមានសុវត្ថិភាព និងសន្តិសុខជាងនៅក្នុងទីក្រុង
- ជម្រុញ និងលើកទឹកចិត្តគ្រួសារទាំងអស់ដែលរស់នៅតំបន់ជុំវិញទីក្រុងប្រើប្រាស់ប្រព័ន្ធអនាម័យដែលមានការកែលម្អ និងមានសុវត្ថិភាព។[140]

**គ. វិស័យថាមពល**

- បង្កើនសកម្មភាពក្នុងវិស័យថាមពល គាំទ្រដល់ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់
- អនុវត្តសវនកម្មប្រសិទ្ធភាពថាមពលនៅគ្រប់ស្ថាប័នក្រុងទាំងអស់ ហើយកំណត់ និងអនុវត្តផែនការគ្រប់គ្រងថាមពល និងប្រសិទ្ធភាពថាមពលដែលសមស្រប
- គ្រឿងអគ្គិសនី និងចង្គ្រានអគ្គិសនីទាំងអស់ដែលត្រូវបានធ្វើតេស្ត និងបិទស្លាកសញ្ញាស្របតាមបទដ្ឋានជាតិ ស្លាកពិពណ៌នាប្រសិទ្ធភាពថាមពលសរសេរជាភាសាខ្មែរ

[140] របាយការណ៍ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ២០១៨-២០៣០ , វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ឆ្នាំ២០១៨ ទំព័រទី ៣៩

- បង្កើតទីផ្សារសម្រាប់សេវាប្រសិទ្ធភាពថាមពល និងហិរញ្ញវត្ថុដើម្បីបម្រើសេវាដល់វិស័យពាណិជ្ជកម្ម និងវិស័យឧស្សាហកម្ម បំពាក់បរិក្ខារដែលគាំទ្រទៅដល់ថាមពលកកើតឡើងវិញ នៅលើដំបូលអគារ និង/ឬស្ថាប័ន រាជរដ្ឋាភិបាល អគារពាណិជ្ជកម្ម និងឧស្សាហកម្មថ្មីទាំងអស់។[141]

**ឃ. វិស័យដឹកជញ្ជូន**

- បង្កើតប្រព័ន្ធគ្រប់គ្រងចរាចរណ៍ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ មានប្រសិទ្ធភាពធនធាន និងមានបុគ្គលិកគ្រប់គ្រាន់សម្រាប់ការអនុវត្ត
- អនុវត្តបទប្បញ្ញត្តិនានាទាក់ទងនឹងការគ្រប់គ្រងចំណត
- កំណត់កម្រិតចំណុះសារធាតុស៊ុលហ្វួរសម្រាប់ឥន្ធនៈមធ្យោបាយដឹកជញ្ជូន ស្របតាមបទដ្ឋានតំបន់
- បង្កើតប្រព័ន្ធតាមដានគុណភាពខ្យល់ប្រចាំថ្ងៃ (កើនឡើងពីស្ថានីយតាមដានដែលមានក្នុងពេលបច្ចុប្បន្ន ចំនួន ៣) នៅទូទាំងរាជធានី ដែលតាមដានសារធាតុបំពុលខ្យល់សំខាន់ៗ
- កាត់បន្ថយការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនដែលប្រើម៉ាស៊ីន បង្កើតផែនការលើកទឹកចិត្តការប្រើប្រាស់ទោចក្រយាន (កង់) ឬថ្មើរជើង ដោយរួមបញ្ចូលទាំងការរៀបចំគន្លងផ្លូវសម្រាប់អ្នកជិះកង់ និងអ្នកថ្មើរជើង ដើម្បីបង្កភាពងាយស្រួលសម្រាប់ពួកគាត់
- លើកទឹកចិត្តការប្រើប្រាស់យានយន្ត ដែលមានការបំភាយឧស្ម័នទាប (ដូចជាយានយន្តដែលមានស្តង់ដារសមត្ថភាពបំភាយល្អ យានយន្តដែលមានប្រព័ន្ធហាយប្រ៊ីដ ឬយានយន្តដើរដោយអគ្គិសនី)។[142]

**ង. បរិស្ថានសំណង់**

- បង្កើតលំនៅឋានដែលមានតម្លៃសមរម្យ និងមានភាពធន់នឹងគ្រោះធម្មជាតិនៅក្នុងទីក្រុង
- ជម្រុញសំណង់លំនៅឋានទីក្រុងដែលរួមបញ្ចូលពីរចនាបទស្ថាបត្យកម្មទំនើប និងបុរាណលាយគ្នា ដើម្បីថែរក្សាអត្តសញ្ញាណវប្បធម៌របស់ក្រុង
- ណែនាំតាមគ្រួសារ និងសហគ្រាសពាណិជ្ជកម្មនានាអំពីវិធានការការពារទឹកជំនន់
- ណែនាំអំពីការសាងសង់ ឬការបំពាក់បរិក្ខារឡើងវិញនូវលំនៅឋាន និងអគារដែលមានប្រសិទ្ធភាពថាមពល
- គម្រោងសាងសង់ធំថ្មីៗត្រូវបែងចែកទីធ្លាគ្រប់គ្រាន់សម្រាប់របៀងបៃតង និងប្រកាន់ខ្ជាប់នូវបទដ្ឋានសំណង់អគារបៃតង

[141] របាយការណ៍ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ២០១៨-២០៣០ , វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ឆ្នាំ២០១៨ ទំព័រទី ៤០

[142] របាយការណ៍ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ២០១៨-២០៣០ , វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ឆ្នាំ២០១៨ ទំព័រទី ៤០

- អនុវត្តច្បាប់ថ្មីស្តីពីនគរូបនីយកម្ម ពាក់ព័ន្ធនឹងការបែងចែកទីធ្លាគ្រប់គ្រាន់នៅលើដីឡូត៍សាងសង់សម្រាប់ផ្ទៃបៃតង។[143]

**ច. កម្មន្តសាល**

- តាមដាន និងអនុវត្តបទប្បញ្ញត្តិស្តីពីប្រសិទ្ធភាពថាមពល ការប្រើប្រាស់ទឹក និងការបំភាយសារធាតុពុលក្នុងវិស័យកម្មន្តសាល
- បង្កើតយន្តការហិរញ្ញប្បទានសម្រាប់ផ្តល់ឱ្យគម្រោងវិនិយោគប្រើប្រាស់ប្រសិទ្ធភាពថាមពល និងគ្រប់គ្រងការបំពុលនៅក្នុងវិស័យកម្មន្តសាល
- បង្កើតក្រុមហ៊ុនសេវាប្រើប្រាស់ថាមពល នៅក្នុងទីក្រុងដើម្បីជម្រុញឱ្យមានប្រសិទ្ធភាពនៃការប្រើប្រាស់ថាមពល និងធនធាននៅតាមសហគ្រាសកម្មន្តសាល
- តម្រូវឱ្យរោងចក្រ ឬសហគ្រាសដែលមានការបញ្ចេញទឹកកខ្វក់ទាំងអស់ត្រូវមានអាងប្រព្រឹត្តកម្មទឹកកខ្វក់នៅនឹងកន្លែង
- ការវាយតម្លៃលើការប្រើប្រាស់ធនធាន ត្រូវបានធ្វើឡើងសម្រាប់វិស័យឧស្សាហកម្មធំៗនៅក្នុងទីក្រុងដោយក្រឡេកមើល ជាពិសេសទៅលើលំហូរសម្ភារៈ និងកាលានុវត្តភាពសម្រាប់ការប្រើប្រាស់សំណល់ពីរោងចក្រមួយចំនួនជាវត្ថុធាតុដើមចូលទៅក្នុងឧស្សាហកម្មផ្សេងទៀត
- បង្កើនការងារបៃតងនៅក្នុងវិស័យកម្មន្តសាល រួមបញ្ចូលទាំងនៅក្នុងវិស័យសិប្បកម្ម។[144]

**ឆ. ការគ្រប់គ្រងសំណល់រឹង**

- បង្កើនធនធាន និងសមត្ថភាពសម្រាប់ខណ្ឌនីមួយៗក្នុងការគ្រប់គ្រងការប្រមូលសំរាម
- បង្កើតការប្រកួតប្រជែង ដើម្បីឱ្យខណ្ឌទាំងអស់ជ្រើសរើសក្រុមហ៊ុនប្រមូលសំរាមដែលសមស្របបំផុតចំពោះតម្រូវការគ្រប់គ្រងសំរាមរបស់ខ្លួន
- បង្កើតឱ្យមានសហគ្រិនភាពដើម្បីប្រមូលសំរាមនៅខណ្ឌមួយចំនួន ប្រសិនបើមិនទាន់មានក្រុមហ៊ុនប្រមូលសំរាមទៅដល់ទីនោះ
- បង្កើតយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈដើម្បីណែនាំគ្រួសារ សហគ្រាស ពាណិជ្ជកម្ម និងអាជីវករតាមផ្សារអំពីវិធីសាស្ត្រញែកសំរាម និងអត្ថប្រយោជន៍
- ជម្រុញការញែកសំរាមតាមទីតាំងឧស្សាហកម្ម

[143] របាយការណ៍ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ២០១៨-២០៣០ , វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ឆ្នាំ២០១៨ ទំព័រទី ៤១

[144] របាយការណ៍ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ២០១៨-២០៣០ , វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ឆ្នាំ២០១៨ ទំព័រទី ៤១

- យុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈ ដើម្បីផ្តល់ព័ត៌មានដល់ពលរដ្ឋអំពីជម្រើសផ្សេងៗជំនួសឱ្យការប្រើប្រាស់ថង់ផ្លាស្ទិច និងផលវិបាកទៅលើបរិស្ថានពីការបន្តប្រើប្រាស់ថង់ផ្លាស្ទិចទាំងនោះ
- ហាមឃាត់ការប្រើប្រាស់ថង់ផ្លាស្ទិច និងជំនួសដោយថង់អាចប្រើឡើងវិញបាន (ថង់មេត្រីភាពបរិស្ថាន - Eco Bags)។[145]

**ជ. ទីធ្លាសាធារណៈ និងបេតិកភណ្ឌវប្បធម៌**

- ពង្រីកបន្ថែមឧទ្យាន សួនច្បារ និងរបៀងបៃតងសាធារណៈនៅទូទាំងទីក្រុង
- សាងសង់ ឬចនាឡើងវិញនូវតំបន់សាធារណៈដែលមានស្រាប់មួយចំនួន ដើម្បីបញ្ចូលដើមឈើដែលផ្តល់ម្លប់ ជីវៈចម្រុះ ផ្ទៃជ្រាបទឹក និងបន្លែដែលអាចស្រូបយកទឹកភ្លៀងបន្ថែមទៀតដើម្បីគ្រប់គ្រងការហូរទឹកភ្លៀង
- បង្កើតតំបន់បៃតងបន្ថែមទៀតដើម្បីកាត់បន្ថយឥទ្ធិពលនៃតំបន់ក្តៅក្នុងទីក្រុង
- អភិវឌ្ឍតំបន់កម្សាន្តពហុមុខងារបន្ថែមទៀត ដើម្បីគាំទ្រដល់ការហាត់ប្រាណ សកម្មភាពកីឡា និងការរាប់អានគ្នាក្នុងសង្គម
- អភិរក្ស ជួសជុល និងកែលម្អ តំបន់ អគារបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រនៅរាជធានីភ្នំពេញ
- អនុម័ត និងអនុវត្ត បទបញ្ជា ដើម្បីការពារ និងជួសជុលកែលម្អអគារ និងតំបន់បេតិកភណ្ឌវប្បធម៌
- បង្កើតថវិកាទីក្រុង ឬជាតិតាមរយៈការបង់ថ្លៃរបស់ភ្ញៀវទេសចរ ឬថ្លៃអ្នកប្រើប្រាស់ផ្សេងទៀត ដើម្បីអភិរក្សអគារ និងតំបន់បេតិកភណ្ឌវប្បធម៌
- យុទ្ធនាការវិស័យទេសចរណ៍ដើម្បីបង្កើនការយល់ដឹងអំពីបេតិកភណ្ឌវប្បធម៌។[146]

**២.២.៣.៣. និរន្តរភាព និងវិសមភាព**

បើទោះបីត្បិតតែមានការយល់ដឹងដ៏ស៊ីជម្រៅចំពោះបញ្ហាប្រឈមនៃការអភិវឌ្ឍនិរន្តរភាព រួមទាំងផែនការដំណោះស្រាយបញ្ហាទាំងនោះចំពោះវិស័យអាទិភាពទាំង ៨ នោះក៏ដោយ ក៏នៅមានឧបសគ្គមួយចំនួនក្នុងការអនុវត្តផែនការនោះផងដែរ ចំពោះទំនាក់ទំនងរវាងនឹងនិរន្តរភាព និងវិសមភាព ជាពិសេសចំពោះគ្រួសារដែលរស់នៅក្នុងតំបន់មិនសូវអភិវឌ្ឍ និងងាយរងគ្រោះ។ ដើម្បីធានាយ៉ាងណាឱ្យការអភិវឌ្ឍ និងការពង្រីកទីក្រុងធ្វើឡើងប្រកបដោយបរិយាប័ន្ន និងមិនទុកអ្នកជួបការលំបាកចោល ចាំបាច់ត្រូវតែមានការខិតខំប្រឹងប្រែងកំណត់ និងផ្តល់ការគាំទ្រឱ្យចំប្រជាពលរដ្ឋ ដែលមានជីវភាពក្រីក្រជាងគេ និងងាយរងគ្រោះជាងគេ។

[145] របាយការណ៍ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ២០១៨-២០៣០ , វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ឆ្នាំ២០១៨ ទំព័រទី ៤១

[146] របាយការណ៍ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ២០១៨-២០៣០ , វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ឆ្នាំ២០១៨ ទំព័រទី ៤២

ក្នុងទីក្រុងភ្នំពេញ មានការកំណត់ចំណាត់ថ្នាក់សំខាន់ៗសម្រាប់កំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងងាយរងគ្រោះចំនួន២ គឺ៖ កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងប្រជាពលរដ្ឋក្រីក្រក្នុងទីក្រុង។

**"អត្តសញ្ញាណកម្មគ្រួសារក្រីក្រ"** គឺជាវិធីសាស្ត្រវាយតម្លៃភាពក្រីក្រថ្នាក់ជាតិ ដែលប្រើប្រាស់សម្រាប់កំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ក្នុងគោលបំណងអនុវត្តកម្មវិធីផ្តល់ជំនួយឱ្យចំអ្នកដែលត្រូវការជាងគេ។ ចំណែកពាក្យថា **"ប្រជាពលរដ្ឋក្រីក្រក្នុងទីក្រុង" "សហគមន៍ក្រីក្រក្នុងទីក្រុង"** និង **"តំបន់ទីលំនៅរបស់ប្រជាជនក្រីក្រក្នុងទីក្រុង"** មានន័យដូចគ្នា ដើម្បីសំដៅលើសហគមន៍ដែលរស់នៅទីតាំងមិនរៀបរយ ឬផ្លាស់ប្តូរទីលំនៅពីទីតាំងមិនរៀបរយមក។ សាលារាជធានីភ្នំពេញ ប្រើប្រាស់កូដសម្គាល់ ១១ ខុសៗគ្នា សម្រាប់កំណត់អត្តសញ្ញាណសហគមន៍ក្រីក្រក្នុងទីក្រុង ពោលគឺសហគមន៍ដែលរស់នៅលើដីសាធារណៈរបស់រដ្ឋ (ផ្លូវរថភ្លើង ចំណីផ្លូវ លូទឹកស្អុយ បឹង មាត់ទន្លេ ដំបូលអគារចាស់ៗ វត្តអារាម ចេតិយ) ដីឯកជនរបស់រដ្ឋ ដីសហគមន៍ ដីឯកជនទីតាំងដែលរដ្ឋាភិបាលផ្លាស់ប្តូរពួកគេទៅ និងដីឯកជនដែលជួលដោយរដ្ឋាភិបាល ឬដោយសហគមន៍។[147]

ការសិក្សាឆ្នាំ២០១៣ បានរកឃើញថា ៧២% នៃសហគមន៍ក្រីក្រក្នុងខណ្ឌជាយក្រុង ពុំបានទទួលសេវាប្រមូលសំរាមឡើយ ខណៈពេលដែលខណ្ឌកណ្តាលក្រុងដល់ទៅ ៨២% បានទទួលសេវាប្រមូលសំរាម។ ម្យ៉ាងក៏មានការរកឃើញផងដែរថា ៥៨% នៃខណ្ឌជាយក្រុងពុំមានប្រព័ន្ធលូរំដោះទឹកភ្លៀងឡើយ ហើយមានសហគមន៍ក្នុងខណ្ឌកណ្តាលក្រុងតែ ៦%ប៉ុណ្ណោះ ដែលពុំមានប្រព័ន្ធលូរំដោះទឹកភ្លៀង។

បញ្ហាប្រឈមធំមួយទៀតរបស់គ្រួសារដែលរស់នៅតាមសហគមន៍ក្រីក្រក្នុងទីក្រុង គឺលក្ខណៈមិនរៀបរយនៃឱកាសរកចំណូលជាច្រើនរបស់ពួកគេ។ បើតាមការអង្កេតឆ្នាំ២០១២ របស់សាលារាជធានីភ្នំពេញ ជិតពាក់កណ្តាលនៃការងារ ដែលធ្វើឡើងដោយសមាជិកគ្រួសារតាមសហគមន៍ក្រីក្រក្នុងទីក្រុង ៤៣,៦% គឺជាការងារសំណង់ (ភាគច្រើន សម្រាប់បុរស) ឬការងាររោងចក្រ (ភាគច្រើន សម្រាប់ស្ត្រី)។ បើទោះបីជាការងារទាំងនេះផ្តល់ចំណូលជាប្រចាំក៏ដោយ ជាធម្មតា ប្រាក់ឈ្នួលមានកម្រិតទាប ហើយភាពជាប់លាប់នៃការងារក៏មានកម្រិតទាបផងដែរ ដោយសារតែនិយោជក អាចត្រូវការបុគ្គលិកក្នុងចំនួនផ្សេងៗគ្នានៅថ្ងៃផ្សេងៗគ្នា។ ការងារដែលមានស្ថិរភាព ដូចជា ការងារនៅតាមស្ថាប័នរដ្ឋ និងឯកជនជាដើម គឺនៅមានកម្រិតទាប ពោលគឺត្រឹមតែ ១៤,៥% ប៉ុណ្ណោះ។

កិច្ចខិតខំប្រឹងប្រែងរបស់សាលារាជធានីភ្នំពេញ ដើម្បីឆ្លើយតបចំពោះសេចក្តីត្រូវការរបស់សហគមន៍ក្រីក្រក្នុងទីក្រុង បានទទួលការគាំទ្រពីអង្គការអន្តរជាតិជាច្រើន ដែលកំពុងផ្តល់ការគាំទ្រផ្សេងៗ ដូចជាឥណទាន ការបណ្តុះបណ្តាលជំនាញធ្វើការងារ ការអប់រំ និងការកែលម្អសេវាសុខភាព ជាដើម។[148]

[147] របាយការណ៍ ស្តីពី ការវាយតម្លៃតម្រូវការសហគមន៍ក្រីក្រ ក្នុងទីក្រុងភ្នំពេញ ខែធ្នូ ឆ្នាំ២០១២ , សាលារាជធានីភ្នំពេញ

[148] របាយការណ៍ ស្តីពី ការអភិវឌ្ឍទីក្រុង រាជធានីភ្នំពេញ ប្រទេសកម្ពុជា , ក្រុមការងារធនាគារពិភពលោក ទំព័រទី ៤០-៤៤

### ២.២.៤. សំណើនៃការរៀបចំរចនាសម្ព័ន្ធស្ថាប័នអនុវត្តទីក្រុងនិរន្តរភាព និងយន្តការគាំទ្រ

គណៈកម្មការប្រឹក្សាយោបល់ចំនួន ១ក្រុម និងក្រុមការងារបច្ចេកទេសចំនួន ៤ក្រុម នឹងត្រូវបានស្នើឱ្យបង្កើតឡើងដើម្បីជាយន្តការគាំទ្រដល់សាលារាជធានីភ្នំពេញ ក្នុងការអនុវត្តនូវផែនការអភិវឌ្ឍទីក្រុងនិរន្តរភាពនេះឱ្យមានប្រសិទ្ធភាព។ នៅផ្នែកខាងក្រោមនេះនឹងផ្តល់នូវការ ពិពណ៌នាលម្អិតអំពី តួនាទី និងទំនួលខុសត្រូវរបស់ក្រុមគណៈកម្មការប្រឹក្សាយោបល់ និងក្រុមការងារបច្ចេកទេស។[149]




**ការរៀបចំស្ថាប័នគាំទ្រសម្រាប់អនុវត្តផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពនៅរាជធានីភ្នំពេញដែលស្នើឡើង**

#### ២.២.៤.១. គណៈកម្មការប្រឹក្សាយោបល់

តួនាទីចម្បងរបស់គណៈកម្មការប្រឹក្សាយោបល់ គឺការផ្តល់យោបល់ជាយុទ្ធសាស្ត្រ និងធ្វើការត្រួតពិនិត្យលើការអនុវត្តផែនការយុទ្ធសាស្ត្រ។ គណៈកម្មការនេះមានគោលដៅធានាថា ចក្ខុវិស័យដែលបានចែងនឹងត្រូវសម្រេចបានគោលដៅ ហើយផែនការយុទ្ធសាស្ត្រជាទូទៅត្រូវបានអនុវត្តយ៉ាងជោគជ័យក្នុងក្របខណ្ឌពេលវេលាដែលបានកំណត់។ គណៈកម្មការប្រឹក្សាយោបល់នឹងមានការទទួលខុសត្រូវដូចខាងក្រោម៖

- ផ្តល់ការត្រួតពិនិត្យ និងសេចក្តីណែនាំជាយុទ្ធសាស្ត្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រ និងធានាថាចក្ខុវិស័យនៃផែនការត្រូវបានសម្រេច គោលដៅត្រូវបានបំពេញតាម ហើយផែនការយុទ្ធសាស្ត្រនឹងត្រូវបានអនុវត្តយ៉ាងជោគជ័យទៅតាមកាលកំណត់

[149] របាយការណ៍ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ២០១៨-២០៣០ , វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ឆ្នាំ២០១៨ ទំព័រទី ៤៨

- តែងតាំងមន្ត្រីមកពីក្រសួងពាក់ព័ន្ធឱ្យក្លាយជាសមាជិកនៃក្រុមការងារបច្ចេកទេសមួយ ឬច្រើនទៅតាមវិស័យពាក់ព័ន្ធ
- ឯកភាព និងគាំទ្រការប្រគល់សកម្មភាពរបស់រដ្ឋបាលរាជធានីភ្នំពេញ
- ធ្វើការប្រជុំជាទៀងទាត់ដើម្បីពិនិត្យឡើងវិញ និងតាមដានវឌ្ឍនភាពនៃការអនុវត្ត និងការសម្រេចបាន។

គណៈកម្មការប្រឹក្សាយោបល់រួមមានតំណាងជាន់ខ្ពស់មកពីក្រសួង រដ្ឋបាលរាជធានីភ្នំពេញ និងស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ គណៈកម្មការនេះនឹងមានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) ជាប្រធាន ដោយសារថាក្រុមប្រឹក្សានេះមានបទពិសោធន៍ ច្រើនផ្នែកសម្របសម្រួលក្នុងចំណោមក្រសួងពាក់ព័ន្ធ (ខ្សែបណ្តោយ) និងតួនាទីរបស់ក្រុមប្រឹក្សានេះនៅក្នុងការអភិវឌ្ឍទីក្រុងនិរន្តរភាពនៅប្រទេសកម្ពុជា ហើយអនុប្រធាន គឺក្រសួងមហាផ្ទៃ ដោយសារថាការទទួលខុសត្រូវរបស់ក្រសួងនេះក្នុងការរៀបចំផែនការ និងតាមដានការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ។[150]

### ២.២.៤.២. ក្រុមការងារបច្ចេកទេស

គោលបំណងចម្បងរបស់ក្រុមការងារបច្ចេកទេស គឺការគាំទ្រដល់រដ្ឋបាលរាជធានីភ្នំពេញនៅក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ ដោយផ្តល់យោបល់ និងការគាំទ្រផ្នែកបច្ចេកទេស ដើម្បីឈានទៅសម្រេចគោលដៅដែលបានកំណត់នៅក្នុងផែនការ។ តួនាទី និងទំនួលខុសត្រូវរបស់ក្រុមការងារបច្ចេកទេសមានដូចខាងក្រោម៖

- ផ្តល់ធាតុចូលបច្ចេកទេសសម្រាប់ការអនុវត្ត
- រៀបចំផែនការសកម្មភាពរយៈពេលខ្លី និងមធ្យមសម្រាប់វិស័យនីមួយៗ
- ប្រើប្រាស់ធនធានសម្រាប់ការអនុវត្តគម្រោងទីក្រុងនិរន្តរភាពជាអាទិភាព
- តាមដានការរីកចម្រើនឈានទៅកាន់គោលដៅទីក្រុងនិរន្តរភាពនៅក្នុងវិស័យនីមួយៗ
- រៀបចំរបាយការណ៍អំពីវឌ្ឍនភាពប្រចាំឆ្នាំ
- រាយការណ៍ជូនរដ្ឋបាលរាជធានីភ្នំពេញជាទៀងទាត់

រដ្ឋបាលរាជធានីភ្នំពេញនឹងធ្វើការរាយការណ៍ទៅគណៈកម្មការប្រឹក្សាយោបល់អំពីដំណើរការ និងវឌ្ឍនភាពនៃការអនុវត្តរបស់ក្រុមការងារបច្ចេកទេស។ ក្រុមការងារបច្ចេកទេសទាំង៤ ដូចរៀបរាប់ខាងក្រោមត្រូវបានបង្កើតឡើងដើម្បីដឹកនាំការអនុវត្តតាមវិស័យចំនួន៨ ដែលត្រូវបានលើកឡើងនៅក្នុងផែនការទីក្រុងនិរន្តរភាព។

- **ក្រុមការងារបច្ចេកទេសទី១ ការរៀបចំក្រុង និងដឹកជញ្ជូន៖** ក្រុមការងារបច្ចេកទេសនេះនឹងធ្វើការងារលើប្រធានបទដូចជា ការធ្វើផែនការប្រើប្រាស់ដី ការបែងចែកតំបន់ ការធ្វើផែនការតំបន់ឧស្សាហកម្មថ្មី

[150] របាយការណ៍ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ២០១៨–២០៣០ , វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ឆ្នាំ២០១៨ ទំព័រទី ៤៩

ការបង្កើតដែនបម្រុងដីទីក្រុងសម្រាប់លំនៅឋានរបស់អ្នកដែលមានប្រាក់ចំណូលទាប ការដឹកជញ្ជូនសាធារណៈ ការគ្រប់គ្រងចរាចរណ៍ ការត្រួតពិនិត្យយានយន្ត ការបំពុលខ្យល់ ចំណត។ល។

- **ក្រុមការងារបច្ចេកទេសទី២ កម្មន្តសាល និងថាមពល៖** ប្រធានបទដែលត្រូវបានគ្របដណ្តប់រួមមានថាមពលកកើតឡើងវិញ ប្រសិទ្ធភាពថាមពល ដំណើរការផលិតកម្មបៃតង ការប្រើប្រាស់ទឹកនៅក្នុងសហគ្រាសខ្នាតតូច និងមធ្យម និងក្នុងតំបន់សេដ្ឋកិច្ចពិសេស។ល។
- **ក្រុមការងារបច្ចេកទេសទី៣ ក្រុមការងារលើកិច្ចការគ្រប់គ្រងសំណល់ និងភាពងាយរងគ្រោះរបស់ទីក្រុង៖** ក្រុមការងារបច្ចេកទេសនេះ ទទួលខុសត្រូវដឹកនាំការងារបច្ចេកទេស ទៅលើការគ្រប់គ្រងសំណល់រឹង និងរាវ អនាម័យតាមផ្ទះ អាងប្រព្រឹត្តកម្មទឹកកខ្វក់ខ្នាតតូច ការបង្ការទឹកជំនន់ បណ្តាញលូ។ល។
- **ក្រុមការងារបច្ចេកទេសទី៤ លើកិច្ចការទីធ្លាសាធារណៈ បេតិកភណ្ឌវប្បធម៌ និងបរិស្ថានសំណង់៖** ប្រធានបទដែលត្រូវពិភាក្សា នៅក្នុងក្រុមការងារបច្ចេកទេសនេះអាចរួមមានបេតិកភណ្ឌវប្បធម៌ ការអភិរក្ស និងការស្តារឧទ្យានកម្សាន្តពហុមុខងារ ជាដើម។

រដ្ឋបាលរាជធានីភ្នំពេញ ដោយមានការជួយគាំទ្រពីក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត ត្រូវធ្វើការដឹកនាំ និងសម្របសម្រួលក្នុងចំណោមក្រុមការងារបច្ចេកទេសទាំងបួន។ រដ្ឋបាលរាជធានីភ្នំពេញ ក៏អាចប្រើប្រាស់នូវរចនាសម្ព័ន្ធដែលមានស្រាប់ជាយន្តការអនុវត្ត និងសម្របសម្រួលការអនុវត្តផែនការនេះ។

សមាជិកនៃក្រុមការងារបច្ចេកទេសនីមួយៗ ត្រូវមានតំណាងបច្ចេកទេសមកពីមន្ទីរពាក់ព័ន្ធនៃរដ្ឋបាលរាជធានីភ្នំពេញ តំណាងខណ្ឌទាំង១៤ នៃរដ្ឋបាលរាជធានីភ្នំពេញ នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងនីមួយៗ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល វិស័យឯកជន និងស្ថាប័នសិក្សាស្រាវជ្រាវដែលធ្វើការងារនៅក្នុងវិស័យពាក់ព័ន្ធ។ ក្រុមការងារបច្ចេកទេសនីមួយៗ ត្រូវមានប្រធាន ១នាក់ និងសហប្រធាន ១នាក់ ដែលនឹងរាយការណ៍អំពីវឌ្ឍនភាពការងារទៅដល់រដ្ឋបាលរាជធានីភ្នំពេញ។[151]

### ២.២.៥. ឧបសគ្គក្នុងការអភិវឌ្ឍរាជធានីភ្នំពេញ

ការផ្លាស់ប្តូរមុខមាត់ទីក្រុង ពីទីក្រុងដែលរងគ្រោះពីការបំផ្លិចបំផ្លាញដោយសារជម្លោះ អស្ថិរភាព ទៅជាទីក្រុងដែលមានការពង្រីកខ្លួន និងការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស គឺជាសមិទ្ធផលមួយដែលគួរឱ្យកត់សម្គាល់។ ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ដូចគ្នានឹងទីក្រុងដែលមានការរីកចម្រើនឆាប់រហ័សផ្សេងៗទៀតនៅអាស៊ី ការរីកចម្រើន និងការអភិវឌ្ឍនេះកើតឡើងដោយគ្មានផែនការច្បាស់លាស់ និងកំពុងដាក់សម្ពាធកាន់តែ

[151] របាយការណ៍ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ២០១៨-២០៣០ , វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (GGGI) ឆ្នាំ២០១៨ ទំព័រទី ៤៩

ខ្លាំងឡើងៗមកលើហេដ្ឋារចនាសម្ព័ន្ធរបស់ទីក្រុង។ ការហូរចូលនូវប្រជាជនក្នុងចំនួនដ៏ច្រើន តែក្នុងរយៈពេលមួយដ៏ខ្លី និងសមត្ថភាពរៀបចំទីក្រុង និងការអនុវត្តនៅទាប គួបផ្សំនឹងការវិនិយោគ និងការអភិវឌ្ឍអចលនទ្រព្យផងកំពុងចោទជាបញ្ហាដល់ការអភិវឌ្ឍសម្រាប់ទីក្រុង។ កត្តាមួយចំនួនដែលបង្កជាឧបសគ្គ ចំពោះការអភិវឌ្ឍទីក្រុងដែលត្រូវបានលើកយកមកពិភាក្សាក្នុងចំណុចខាងក្រោមរួមមាន៖ កង្វះភាពច្បាស់លាស់ក្នុងការអនុវត្តការបែងចែកតួនាទី និងការទទួលខុសត្រូវ, ការអនុវត្តផែនការនៅមានកម្រិតទាប និងសមត្ថភាពស្ថាប័ននៅមានកម្រិត, និងការផ្តល់ហិរញ្ញប្បទានពុំមាននិរន្តរភាព។

### ២.២.៥.១. កង្វះភាពច្បាស់លាស់ក្នុងបែងចែកតួនាទី និងការទទួលខុសត្រូវ

សម្រាប់ទីក្រុងភ្នំពេញការសម្របសម្រួលការងារអភិវឌ្ឍន៍ទីក្រុងនៅតែជាបញ្ហាប្រឈមនៅឡើយ ពោលគឺការសម្របសម្រួលតាមក្រសួងមន្ទីរជំនាញ និងសាលារាជធានីភ្នំពេញផង និងការសម្រួលរវាងក្រសួងស្ថាប័នមួយនោះ និងស្ថាប័នផ្សេងទៀតនៅពុំទាន់មានភាពច្បាស់លាស់នៅឡើយ។

ប្រទេសកម្ពុជាប្រើប្រាស់ប្រព័ន្ធរៀបចំផែនការ ២ ដាច់ពីគ្នា មួយជាប្រព័ន្ធរៀបចំផែនការអភិវឌ្ឍសង្គមសេដ្ឋកិច្ច ក្រោមការគ្រប់គ្រងរបស់ក្រសួងផែនការ និងមួយទៀតសម្រាប់រៀបចំភូមិសាស្ត្រ ក្រោមការគ្រប់គ្រងរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ការរៀបចំផែនការអភិវឌ្ឍសង្គមសេដ្ឋកិច្ចត្រូវបានធ្វើឡើងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាទូទៅដំណើរការនេះត្រូវបានគេចាត់ទុកថាជាដំណើរការដែលមានភាពរឹងមាំ។ ចំណែកការរៀបចំភូមិសាស្ត្រវិញហាក់បីដូចជានៅមានភាពយឺតយ៉ាវនៅឡើយ។

ការរៀបចំផែនការចាំបាច់ត្រូវមានការសម្របសម្រួលតាមវិស័យ ដើម្បីធានាឱ្យមានការរៀបចំផែនការទីក្រុងទៅតាមតម្រូវការ ត្រូវមានការលៃទុកដីដើម្បីបំពេញតម្រូវការជាច្រើនដូចជា សម្រាប់ឧស្សាហកម្ម ពាណិជ្ជកម្ម លំនៅឋាន ហេដ្ឋារចនាសម្ព័ន្ធធំៗជាច្រើន ដូចជាអាកាសយានដ្ឋាន និងផ្លូវថ្នល់ជាដើមសម្រាប់ការរៀបចំការប្រើប្រាស់ដីធ្លី។ ជារួម ក្រសួងជំនាញជាអ្នកកំណត់ពីតម្រូវការសម្រាប់ការប្រើប្រាស់ដីធ្លី ហេដ្ឋារចនាសម្ព័ន្ធចាំបាច់ និងសេវានានា ដោយប្រើប្រាស់ដំណើរការរៀបចំផែនការបែបពិគ្រោះយោបល់ ដើម្បីធានាយ៉ាងណាឱ្យផែនការស្តីពីការប្រើប្រាស់ដីដែលរៀបចំចេញមកបានធ្វើការពិចារណាពីតម្រូវការផ្សេងៗ ដែលពេលខ្លះតម្រូវការទាំងនោះមានភាពប្រទាំងប្រទើសជាមួយគ្នា។

កម្រិតនៃការអនុវត្តខ្វះការសម្របសម្រួលរវាងមន្ទីរ និងស្ថាប័ននានា ធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធមិនអាចតាមទាន់ល្បឿននៃការអភិវឌ្ឍបាន។ ការផ្តល់សេវាក្នុងទីក្រុងភ្នំពេញ ត្រូវជួបនឹងឧបសគ្គ ដោយសារពុំមានការថែទាំហេដ្ឋារចនាសម្ព័ន្ធនានាឱ្យបានត្រឹមត្រូវ ឬពុំមានហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗដូចជា ផ្លូវថ្នល់ និងប្រព័ន្ធរំដោះទឹកភ្លៀងជាដើម។ ដោយសារតែមានការបន្ធូរបន្ថយបទបញ្ញាកំណត់កម្ពស់អគារ ដើម្បីលើកទឹកចិត្តឱ្យមានការ

សាងសង់អគារដែលប្រជាពលរដ្ឋអាចរស់នៅបានច្រើន និងមានប្រសិទ្ធភាព ប៉ុន្តែការអភិវឌ្ឍទីក្រុងតាមលំនាំបែបនេះកើតឡើងដោយពុំមានការបង្កើនសមត្ថភាពរបស់ហេដ្ឋារចនាសម្ព័ន្ធឡើយ។[152]

**២.២.៥.២. សមត្ថភាពស្ថាប័ន និងការអនុវត្តផែនការនៅមានកម្រិត**

ប្រព័ន្ធរៀបចំផែនការក្នុងប្រទេសកម្ពុជាហាក់ដូចជានៅខ្វះក្របខណ្ឌ និងការណែនាំអំពីរបៀបយកផែនការមួយទៅធ្វើជាគោលសម្រាប់រៀបចំផែនការផ្សេងទៀតនៅកម្រិតរដ្ឋបាលផ្សេងៗគ្នា។ ក៏ប៉ុន្តែ យ៉ាងណាមិញ ការអនុវត្តជាប្រព័ន្ធ និងការអភិវឌ្ឍកម្រិតខ្ពស់ បែរជាមិនសូវមានរចនាសម្ព័ន្ធ និងការសម្របសម្រួលទៅវិញ ហើយដែលជាលទ្ធផលធ្វើឱ្យការរៀបចំផែនការ និងការអភិវឌ្ឍកើតឡើងមិនរៀបរយក្នុងកម្រិតមួយចាំបាច់។ម្យ៉ាងទៀត គេក៏តម្រូវឱ្យមានការរៀបចំក្រុងឱ្យកាន់តែគ្រប់ជ្រុងជ្រោយ និងពង្រឹងការអនុវត្តកំណែទម្រង់លិខិតបទដ្ឋានគតិយុត្តសម្រាប់ទីក្រុងដើម្បីធានាយ៉ាងណាឱ្យការអភិវឌ្ឍ និងការពង្រីកទីក្រុង អាចដំណើរការទៅបានឱ្យកាន់តែមាននិរន្តរភាព។

លើសពីនេះសមត្ថភាពអនុវត្តផែនការ និងពង្រឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្តនៅថ្នាក់មូលដ្ឋាននៅមានកម្រិតខ្សោយនៅឡើយ។ ក្រសួងដែលធ្វើការងារពាក់ព័ន្ធនឹងការអភិវឌ្ឍទីក្រុងពុំទាន់មានសមត្ថភាពដើម្បីអនុវត្តកិច្ចការសម្របសម្រួលកម្មវិធីនៅថ្នាក់ជាតិ និងដាក់ចេញនូវវិធានការ និងលិខិតបទដ្ឋានគតិយុត្តនានាដែលសមត្ថភាពនៅថ្នាក់មូលដ្ឋាននៅមានកម្រិតទាបនៅឡើយ។ មន្ទីរថ្នាក់ខេត្ត/រាជធានីនៅស្ថិតក្រោមចំណុះក្រសួងជំនាញទូទៅពុំមានបុគ្គលិក និងបរិក្ខារគ្រប់គ្រាន់។ ពាក់ព័ន្ធនឹងការងាររៀបចំទីក្រុងវិញ មូលហេតុសំខាន់មួយដែលត្រូវបានលើកឡើងថាជាមូលហេតុដែលនាំឱ្យខ្វះផែនការប្រើប្រាស់ដីធ្លីលម្អិត គឺខ្វះបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលបច្ចេកទេសដើម្បីរៀបចំផែនការនេះ។[153]

**២.២.៥.៣. ការផ្តល់ហិរញ្ញប្បទានពុំមាននិរន្តរភាព**

ជាធម្មតា ការអភិវឌ្ឍក្រុងទទួលបានហិរញ្ញប្បទានតាមបែបវិធី ២យ៉ាងដូចតទៅ៖ ការវិនិយោគសាធារណៈលើសេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសំខាន់ៗ (ដូចជា ផ្លូវថ្នល់ រោងចក្រសម្អាតទឹកស្អុយ និងបណ្តាញលូ) ឬការវិនិយោគឯកជនលើការអភិវឌ្ឍ និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធ។ សម្រាប់ករណីទីក្រុងភ្នំពេញដោយសារតែការរួមចំណែករបស់ចំណូលផ្ទេរក្នុងទៅក្នុងថវិកាក្រុងនៅមានកម្រិតទាប ហេដ្ឋារចនាសម្ព័ន្ធសាធារណៈមួយផ្នែកធំទទួលបានហិរញ្ញប្បទានពីជំនួយបរទេស និងការវិនិយោគឯកជន។

សម្រាប់សេវាទីក្រុងមួយចំនួនដូចជា ការជួសជុលថែទាំផ្លូវជាដើម ការទទួលខុសត្រូវលើការផ្តល់សេវានេះ និងថវិកាសម្រាប់ធ្វើការងារនេះនៅដាច់ទំនាក់ទំនងពីគ្នានៅឡើយ។ ផ្លូវជាតិស្ថិតក្រោមការទទួលខុសត្រូវ

---

[152] របាយការណ៍ ស្តីពី ការអភិវឌ្ឍទីក្រុង រាជធានីភ្នំពេញ ប្រទេសកម្ពុជា , ក្រុមការងារធនាគារពិភពលោក ទំព័រទី ៤៥

[153] របាយការណ៍ ស្តីពី ការអភិវឌ្ឍទីក្រុង រាជធានីភ្នំពេញ ប្រទេសកម្ពុជា , ក្រុមការងារធនាគារពិភពលោក ទំព័រទី ៤៩

របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ខណៈពេលដែលសាលារាជធានីភ្នំពេញទទួលខុសត្រូវផ្តល់ថវិកាសម្រាប់ជួសជុលថែទាំបណ្តាញផ្លូវក្នុងក្រុងដែលបន្តមានការកើនឡើងយ៉ាងច្រើនជាបន្តបន្ទាប់។ ការស្នើឱ្យមានការផ្លាស់ប្តូររបបពន្ធអចលនទ្រព្យ កាលពីឆ្នាំ២០១៨ នឹងផ្តល់លទ្ធភាពឱ្យសង្កាត់ ដែលជាកម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិទាបជាងគេ អាចរក្សាទុក ៣០% នៃចំណូលដែលរកបានក្នុងមូលដ្ឋានសម្រាប់វិនិយោគលើវិស័យអាទិភាពនៅថ្នាក់ឃុំ។ ខណៈពេលដែលការធ្វើបែបនេះអាចបង្កើនភាពឆ្លើយតបរបស់រដ្ឋបាលថ្នាក់មូលដ្ឋានចំពោះតម្រូវការវិនិយោគខ្នាតតូច និងតម្រូវការជួសជុលថែទាំ វានៅតែមានភាពចាំបាច់ឱ្យមានការបញ្ជាក់ឱ្យបានកាន់តែច្បាស់លាស់បន្ថែមពីតួនាទី និងការទទួលខុសត្រូវ ក្នុងការផ្តល់ហិរញ្ញប្បទានដល់តម្រូវការវិនិយោគ ខ្នាតមធ្យម និងខ្នាតធំ។

ឧបសគ្គធំមួយនៃការសិក្សាពីបញ្ហាហិរញ្ញប្បទានទីក្រុងនេះ គឺភាពខ្វះខាតនៃការទទួលបានទិន្នន័យអំពីការផ្តល់ហិរញ្ញប្បទានសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាក្នុងទីក្រុង។ ព័ត៌មាននេះ មិនអាចរកបានឡើយដែលអាចធ្វើឱ្យគេមិនអាចធ្វើសេចក្តីសម្រេច និងរៀបចំគោលនយោបាយ ផ្អែកតាមព័ត៌មានត្រឹមត្រូវបាន។[154]

[154] របាយការណ៍ ស្តីពី ការអភិវឌ្ឍទីក្រុង រាជធានីភ្នំពេញ ប្រទេសកម្ពុជា , ក្រុមការងារធនាគារពិភពលោក ទំព័រទី ៥៣

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក យើងអាចសង្កេតឃើញថា ទីក្រុងភ្នំពេញកំពុងមានសន្ទុះនៃការអភិវឌ្ឍគួរឱ្យកត់សម្គាល់ ជាពិសេសទាក់ទងទៅនឹងចំនួនប្រជាជន សេដ្ឋកិច្ច និងនគរូបនីយកម្ម។ លើសពីនេះទៅទៀត អាជ្ញាធរមានសមត្ថកិច្ចក៏បានបង្កើតនូវគោលនយោបាយ និងផែនការអភិវឌ្ឍន៍មួយចំនួនផងដែរសម្រាប់ជម្រុញទីក្រុងភ្នំពេញឱ្យក្លាយទៅជាទីក្រុងដែលមានសណ្តាប់ធ្នាប់ សោភណភាព និងនិរន្តរភាព។ ក៏ប៉ុន្តែ ទោះបីមានកម្រិតនៃការលូតលាស់យ៉ាងលឿនក៏ដោយ ក៏យើងអាចកត់សម្គាល់ថាទិសដៅនៃការអភិវឌ្ឍទីក្រុងភ្នំពេញដែលត្រូវបានកំណត់ដោយស្ថាប័នពាក់ព័ន្ធទាំងនោះ គឺមិនសូវមាននិរន្តរភាព និងមិនឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់ទីក្រុងឡើយ ពោលគឺមានន័យថាផែនការអភិវឌ្ឍន៍របស់ទីក្រុងភ្នំពេញភាគច្រើនដែលត្រូវបានអនុវត្តនោះ គឺត្រូវបានធ្វើឡើងដើម្បីដោះស្រាយបញ្ហាជាបណ្តោះអាសន្ន ហើយច្រើនតែអនុវត្តនៅពេលចាំបាច់ (Ad-Hoc)។ ដូច្នេះ ផែនការអភិវឌ្ឍន៍ដែលបានបង្កើតឡើង និងអនុវត្តដោយអាជ្ញាធរនោះ ពុំសូវមានភាពស្អិតរមួតជាមួយគ្នាឡើយ ដែលនាំឱ្យទិសដៅនៃការអភិវឌ្ឍទីក្រុង មានភាពអាក់រអួល និងគ្មានភាពប្រទាក់ប្រឡា ឬបំពេញឱ្យគ្នានោះឡើយ ពោលគឺសមិទ្ធផលនៃការអភិវឌ្ឍស្ថិតនៅដាច់ពីគ្នា។

បន្ថែមពីនេះទៅទៀត របៀបនៃការអភិវឌ្ឍទីក្រុងបែបនេះ បានបណ្តាលឱ្យទីក្រុងភ្នំពេញមានការលូតលាស់យ៉ាងឆាប់រហ័ស ដែលស្ទើរតែមិនអាចគ្រប់គ្រងបាន (Urban Sprawl)។ ហើយបញ្ហានេះក៏នាំឱ្យមានការខ្វះខាតនៃហេដ្ឋារចនាសម្ព័ន្ធសមស្របផងដែរ ពោលគឺ បើទោះបីទីក្រុងភ្នំពេញមានហេដ្ឋារចនាសម្ព័ន្ធផ្សេងៗក៏ដោយ ក៏ហេដ្ឋារចនាសម្ព័ន្ធទាំងនោះច្រើនទទួលបាននូវការអភិវឌ្ឍតិចតួច ដែលបង្កការលំបាកដល់ប្រជាពលរដ្ឋជាច្រើន ហើយនឹងក្លាយជាឧបសគ្គមួយទៅដល់ការអភិវឌ្ឍនៃទីក្រុងភ្នំពេញ។ ម្យ៉ាងវិញទៀត អភិបាលរាជធានីភ្នំពេញក៏បានរៀបចំកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្សជាច្រើនផងដែរ ប៉ុន្តែកម្មវិធីទាំងនេះភាគច្រើនទទួលបានការអភិវឌ្ឍតិចតួច មិនបំពេញតម្រូវការ ឬភាពប៉ិនប្រសប់របស់អ្នកដែលចូលរួមក្នុងកម្មវិធីនោះ ហើយក៏មិនឆ្លើយតបទៅនឹងតម្រូវការទីផ្សាររបស់ពិភពលោកឡើយ។ ហេតុដូចនេះ យើងសង្កេតឃើញថាមានកិច្ចការជាច្រើនដែលស្ថាប័នពាក់ព័ន្ធនឹងការរៀបចំរាជធានីភ្នំពេញ ត្រូវបំពេញ ដើម្បីតម្រង់ទិសដៅនៃការអភិវឌ្ឍរបស់ទីក្រុងភ្នំពេញឱ្យឆ្ពោះក្លាយទៅជាទីក្រុងមួយដែលមានសណ្តាប់ធ្នាប់ សោភណភាព និងប្រកបដោយនិរន្តរភាព។

# អនុសាសន៍

# អនុសាសន៍

យោងតាមការសិក្សាប្រធានបទស្រាវជ្រាវខាងលើនេះមក យើងយល់ឃើញថា ការអភិវឌ្ឍទីក្រុងគួរតែផ្តោតលើមនុស្សជាចម្បង (Human-Centered Design) ដោយយកចិត្តទុកដាក់ទៅលើតម្រូវការរបស់មនុស្ស ហើយសិក្សាឱ្យបានស៊ីជម្រៅពីឫសគល់នៃបញ្ហា មុននឹងឈានដល់ការស្វែងរកដំណោះស្រាយ ការរៀបចំនូវផែនការអភិវឌ្ឍន៍ ការរៀបចំសណ្តាប់ធ្នាប់ និងការរចនាសោភណភាព។ ទន្ទឹមនឹងនេះ យើងខ្ញុំមានអនុសាសន៍មួយចំនួនទាក់ទងទៅនឹងការអភិវឌ្ឍរាជធានីភ្នំពេញនាពេលបច្ចុប្បន្នទៅលើចំណុចមួយដូចតទៅៈ

- **សម្រាប់មធ្យោបាយសាធារណៈ**
  - ឧបសគ្គចម្បងមួយដែលធ្វើឱ្យមនុស្សមិនជ្រើសរើសយកមធ្យោបាយធ្វើដំណើរសាធារណៈ គឺចម្ងាយធ្វើដំណើររវាងចំណតរថយន្តក្រុង ទៅទិសដៅដែលគាត់ចង់ទៅ ឬទិសដៅដែលគាត់កំពុងស្ថិតនៅទៅចំណតមានចម្ងាយឆ្ងាយ ហេតុនេះដើម្បីជួយសម្រួលដល់ការផ្សាភ្ជាប់ការធ្វើដំណើររវាងចំណតរថយន្តក្រុងសាធារណៈ ទៅកន្លែងនានាដែលគ្មានចំណតរថយន្តក្រុងទៅដល់ រាជរដ្ឋាភិបាលគួរតែរៀបចំឱ្យមានកន្លែងដាក់កង់ នៅជិតចំណតរថយន្តក្រុងសាធារណៈ និងលើកទឹកចិត្តឱ្យមានការប្រើប្រាស់ប្រភេទកង់ស្កូតធ័រ (Scooter) ដែលមនុស្សអាចធ្វើដំណើរបានក្នុងរយៈចម្ងាយខ្លីដើម្បីទៅចំណតរថយន្តក្រុងសម្រាប់អ្នកមិនអាចដើរឆ្ងាយបាន។ ការធ្វើបែបនេះបាន លុះត្រាតែអាជ្ញាធររៀបចំផ្លូវធ្វើដំណើរឱ្យមានភាពងាយស្រួលសម្រាប់អ្នកធ្វើដំណើរថ្មើរជើង និងមានការរៀបចំរថយន្តក្រុងយ៉ាងណាឱ្យមានធ្នាអាចយកកង់ស្កូតធ័រដាក់លើរថយន្តក្រុងបាន។
  - រាជរដ្ឋាភិបាលគួរលើកទឹកចិត្តដល់ប្រជាពលរដ្ឋ ជាពិសេសយុវជន ឱ្យប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈ ដោយចាប់ដៃគូជាមួយវិស័យឯកជន ដូចជាហាងកាហ្វេ ក្នុងការផ្តល់ជាគូប៉ុងបញ្ចុះតម្លៃដល់អ្នកដែលបានប្រើប្រាស់មធ្យោបាយសាធារណៈតាមរយៈការសន្សំពិន្ទុជាដើម។
  - រៀបចំឱ្យមានជម្រើសមធ្យោបាយសាធារណៈច្រើនដូចជា រថយន្តក្រុងសាធារណៈ កង់សាធារណៈដែលប្រជាពលរដ្ឋអាចជិះសម្រាប់ការធ្វើដំណើររយៈពេលខ្លីបាន និងរថភ្លើងលើអាកាសជាដើម។
- **បញ្ហាកកស្ទះចរាចរណ៍**
  - ធ្វើឱ្យប្រសើរឡើងនូវមធ្យោបាយធ្វើដំណើរសាធារណៈ ពីព្រោះថា ដើម្បីដោះស្រាយបញ្ហានៅក្នុងរយៈពេលវែង និងប្រកបដោយនិរន្តរភាព រាជរដ្ឋាភិបាលត្រូវតែសិក្សាទៅលើប្រព័ន្ធមធ្យោបាយធ្វើដំណើរសាធារណៈឱ្យមានប្រសិទ្ធភាព និងភាពងាយស្រួលដល់អ្នកប្រើប្រាស់ ដូចជាបន្ថែមខ្សែធ្វើដំណើរ ពន្លឿនពេលវេលាក្នុងការធ្វើដំណើរ។

- រៀបចំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ដើម្បីកាត់បន្ថយការកកស្ទះចរាចរណ៍ ដូចជារៀបចំសណ្ដាប់ធ្នាប់តាមដងផ្លូវកុំឱ្យមានការប្រើប្រាស់ចិញ្ចើមផ្លូវខុសច្បាប់ ដូចជាការលក់ដូរលើផ្លូវ ការចតរថយន្តលើចិញ្ចើមផ្លូវសាធារណៈជាដើម។
- រៀបចំសេវាមូលដ្ឋានរបស់ទីក្រុងឱ្យស្ថិតនៅជិតៗគ្នាក្នុងចម្ងាយដែលអាចថ្មើរជើងបាន ឬស្ថិតនៅចម្រុះគ្នា (Mixed-Used Facilities) ដូចជាផ្សារទំនើប អាហារដ្ឋាន សាលារៀន ការិយាល័យ កន្លែងរស់នៅ មន្ទីរពេទ្យ ដើម្បីកាត់បន្ថយកុំឱ្យមានការធ្វើដំណើរឆ្ងាយ។
- សិក្សាពីលទ្ធភាពក្នុងការសាងសង់ស្ពានអាកាស សម្រាប់រំដោះបញ្ហាកកស្ទះចរាចរណ៍នៅតាមតំបន់មួយចំនួន ជាពិសេសគឺនៅតាមផ្លូវប្រសព្វនានា ជាឧទាហរណ៍ នៅផ្លូវបំបែកទួលគោកជាដើម។

- **ចំណតរថយន្ត**
  - រាជរដ្ឋាភិបាលគួរតែសិក្សាអំពីលទ្ធភាពនៃការសាងសង់ចំណតរថយន្តក្រោមដី សម្រាប់បម្រើដល់ការប្រើប្រាស់ជាសាធារណៈបន្ថែមទៀត ដើម្បីបំពេញតម្រូវការ ក៏ដូចជាដើម្បីបញ្ចៀសនូវការចតយានយន្តខុសច្បាប់លើចិញ្ចើមផ្លូវ។
- **ផ្លូវធ្វើដំណើរថ្មើរជើង**
  - ត្រូវរៀបចំផ្លូវដំណើរថ្មើរជើងដែលមានគុណភាព ដែលមានការរួមបញ្ចូលនូវសកម្មភាពប្រាស្រ័យទាក់ទងជាមួយមនុស្សជុំវិញ និងអ្នកប្រើប្រាស់ផ្លូវផ្សេងទៀត (Interaction along the street) ទើបអាចបង្កើតភាពទាក់ទាញឱ្យមនុស្សចង់ថ្មើរជើង ព្រមទាំងបង្កើតបរិយាកាសដែលប្រកបដោយភាពរស់រវើក និងសុវត្ថិភាព។ ជាឧទាហរណ៍ ការរៀបចំផ្លូវដែលអាចអនុញ្ញាតឱ្យមានការលក់ដូរ (Street Vendor) លើខឿនផ្លូវធ្វើដំណើរថ្មើរជើង ដែលអាជ្ញាធរក៏អាចសិក្សាផងដែរពីករណីសិក្សានៅបណ្ដាប្រទេសនៅអឺរ៉ុប ដែលទទួលបានភាពជោគជ័យក្នុងការរៀបចំចិញ្ចើមផ្លូវសាធារណៈ ប្រកបដោយគុណភាព និងប្រសិទ្ធភាព ដូចជានៅទីក្រុង Copenhagen នៃប្រទេសដេនម៉ាក (Denmark)។
  - អនុវត្តទ្រឹស្តី Human Scale សម្រាប់ការសាងសង់អគារ ពោលគឺគួរលើកទឹកចិត្តឱ្យមានការរចនាអគារដោយគិតគូរពីមនុស្សដែលនៅជុំវិញ (Life Between Buildings) ដោយធ្វើឱ្យមនុស្សនៅលើអគារអាចមើលមកមនុស្សដែលកំពុងថ្មើរជើង ហើយមនុស្សដែលកំពុងដើរនៅលើដងផ្លូវនឹងមានអារម្មណ៍ថាមានសុវត្ថិភាព ដោយមានអារម្មណ៍ថាមានមនុស្សនៅមើលជុំវិញ។
- **សួនបៃតង**
  - បង្កើនទីធ្លាបៃតងនៅក្នុងទីក្រុងដូចជាសួនសាធារណៈ សួនជម្រាបទឹក និងរុក្ខវិថី ដែលនាំមកនូវភាពបៃតងនៅក្នុងទីក្រុង។ ជាឧទាហរណ៍ នៅក្នុងប្រទេសថៃមានឧទ្យានមួយនៅជូឡាឡុងកន មាន

សួនបៃតងដែលមានដីសើម (Wetland) និងអាងស្តុកទឹកដើម្បីផ្ទុកទឹកភ្លៀងនៅពេលមានការជន់លិច។ ដូច្នេះ សួននេះបានដើរតួជាសួនបៃតងសាធារណៈផង និងជាកន្លែងបញ្ចៀសទឹកភ្លៀងផង។

- **ផទិកាទីក្រុង**
  - អាជ្ញាធរគួររៀបចំវេទិកាទីក្រុងសម្រាប់ប្រជាជន ដើម្បីឱ្យពួកគាត់ផ្តល់ជាមតិយោបល់ចំពោះតម្រូវការដែលពួកគាត់ចង់បាន។ ជាឧទាហរណ៍នៅទីក្រុង Vancouver នៃប្រទេសកាណាដា បានចុះស្ទង់មតិសិក្សាពីតម្រូវការប្រជាជន ព្រមទាំងរៀបចំគេហទំព័រសម្រាប់ប្រជាជនដែលអាចចូលទៅបំពេញសំណូមពរ ឬតម្រូវការតាមប្រព័ន្ធអ៊ិនធើណេតបាន។
  - បង្កើនស្តង់ដារ និងកែលម្អកម្រិតធនធានមនុស្សរបស់មន្ត្រីរាជការក្នុងជួររដ្ឋាភិបាលដែលមានជំហរធ្វើផែនការសម្រាប់ទីក្រុង។
- **បញ្ហាកាកសំណល់**
  - អាជ្ញាធរគួរយកចិត្តទុកចិត្តអប់រំដល់ប្រជាពលរដ្ឋអំពីការបែងចែកកាកសំណល់តាមប្រភេទ ដូចជាកាកសំណល់កែច្នៃបាន កាកសំណល់ផ្ទះបាយ និងកាកសំណល់អេឡិចត្រូនិច ជាដើម។ ការធ្វើបែបនេះបាន លុះត្រាតែ អាជ្ញាធរយកចិត្តទុកដាក់ក្នុងការបង្កើននូវធុងសំរាមសាធារណៈសម្រាប់ញែកកាកសំណល់ទាំងអស់នោះ។
  - ម្យ៉ាងវិញទៀត អាជ្ញាធរគួរបន្តការលើកទឹកចិត្តចំពោះការកាត់បន្ថយការប្រើប្រាស់ផ្លាស្ទិច ដោយជំនួសវិញនូវការប្រើប្រាស់ថង់បរិស្ថាន (Eco-Bags)។
- **និរន្តរភាពសង្គម**
  - ធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាបណ្តុះបណ្តាលវិជ្ជាជីវៈ (TVET) ឱ្យត្រូវនឹងតម្រូវការទីផ្សារ ដើម្បីឱ្យយុវជនអាចត្រៀមខ្លួនចូលប្រឡូកនៅក្នុងទីផ្សារការងារបច្ចេកទេសជំនាញបាន។
  - ធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធក្នុងការប្រមូលទិន្នន័យ ដើម្បីឱ្យរដ្ឋាភិបាលធ្វើការសម្រេចចិត្តបានល្អប្រសើរដោយផ្អែកលើទិន្នន័យជាក់ស្តែង។
  - ធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសាធារណៈ និងធានាឱ្យមានសមភាព និងសមធម៌សម្រាប់មនុស្សគ្រប់រូប ជាពិសេសសម្រាប់ក្រុមមនុស្សងាយរងគ្រោះ។
  - បង្កើតផែនការសម្របនឹងការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ។
  - ធ្វើឱ្យប្រសើរឡើងនៅតាមតំបន់ដែលមិនទាន់អភិវឌ្ឍ ឬតំបន់អនាធិបតេយ្យ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទឹក និងអគ្គិសនី រួមជាមួយការបង្កើតកម្មវិធីលំនៅឋានជាពិសេសលំនៅឋានតម្លៃសមរម្យដើម្បីលើកកម្ពស់កម្រិតជីវភាពរបស់ពួកគេ។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- ច្បាប់ ស្តីពី ការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ១៩៩៤
- ច្បាប់ ស្តីពី ផ្លូវថ្នល់ លេខ នស/រកម/០៥១៤/០០៨ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៤
- អនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពី លិខិតអនុញ្ញាតសាងសង់
- អនុក្រឹត្យលេខ ២២៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពី លិខិតអនុញ្ញាតសាងសង់គ្រប់ប្រភេទ
- អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពី នគរូបនីយកម្ម រាជធានី ក្រុង និង ទីប្រជុំជន
- ប្រកាសលេខ ២៣៣ ព.ណបល.ប្រក ចុះថ្ងៃទី ១៤ កក្កដា ២០១៦ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់សាខាកាំកុងត្រូលរាជធានី-ខេត្ត
- ប្រកាសលេខ ១៣០៩ អបស/ឱអបស ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២ ស្តីពី បែបបទ និងលក្ខខណ្ឌសម្រាប់ផ្តល់វិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ នៅតាមភោជនីយដ្ឋាន និងអាហារដ្ឋាន
- លិខិតជម្រាបលេខ ១៤៤៥ ដនស ចុះថ្ងៃទី ១៩ មិថុនា គ.ស. ២០១៧ ស្តីពី ការកំណត់ឆ្លាគម្លាតនគរូបនីយកម្មចំពោះសំណង់មានកម្ពស់ខ្ពស់
- សេចក្តីសម្រេចលេខ ០៣៩ សសរ ស្តីពី ការដាក់ឱ្យប្រើប្រាស់ប្លង់ស្តាបត្យកម្មចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង និងគន្លងផ្លូវទោចក្រយាន សម្រាប់សាធារណជន និងជនពិការ
- សារាចរណែនាំលេខ ០៣ សរ ស្តីពី ការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាមរាជធានី ទីក្រុង និងទីប្រជុំជន
- សេចក្តីណែនាំ លេខ ០០៧/១៧ សណន.ច ចុះថ្ងៃទី ០៨ សីហា ២០១៧ ស្តីពី ការដោះស្រាយចរាចរណ៍ និងរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ
- សេចក្តីណែនាំ លេខ ០១៣/១៨ សណន ចុះថ្ងៃទី ០៧ ធ្នូ ២០១៨ ស្តីពី ការរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ និងការប្រើប្រាស់ចិញ្ចើមផ្លូវសាធារណៈទាំងអស់នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ

## គោលនយោបាយ

- គោលនយោបាយជាតិស្តីពីលំនៅឋាន , ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានទទួលឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០១៤

- សៀវភៅ New Urban Agenda Illustrated , អង្គការ UN-Habitat បោះពុម្ព ឆ្នាំ២០២០

**ផែនការ**

- សេចក្តីព្រាងក្របខណ្ឌយុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍក្រុង , ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ឆ្នាំ ២០១៥
- ផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំ ២០២០-២០២៤, ក្រុមប្រឹក្សារាជធានីភ្នំពេញ ឆ្នាំ២០២០
- ផែនការយុទ្ធសាស្ត្រទីក្រុងបៃតង សម្រាប់ទីក្រុងភ្នំពេញ ២០១៧ - ២០២៦ , វិទ្យាស្ថានអភិវឌ្ឍន៍បៃតង សកល ឆ្នាំ២០១៦
- ផែនការណែនាំ ស្តីពី ការចាត់តាំងអនុវត្តគោលនយោបាយ "ភូមិ-ឃុំមានសុវត្ថិភាព" លេខ ០២២ ជក ចុះថ្ងៃទី១០ សីហា ២០១២

**សេចក្តីជូនដំណឹង**

- សេចក្តីជូនដំណឹងរបស់រដ្ឋបាលរាជធានីភ្នំពេញ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ស្តីពី ការចាប់ផ្តើម អនុវត្តការផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង នៅរាជធានីភ្នំពេញដោយប្រតិបត្តិករ ថ្មី
- សេចក្តីជូនដំណឹង ចុះថ្ងៃទី ១៨ កុម្ភៈ ២០១៩ ស្តីពី ការរៀបចំសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ តាមបណ្តោយមហាវិថីព្រះនរោត្តម

**សៀវភៅ**

- វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត
- សៀវភៅ នីតិនគរូបនីយវិទ្យា , បណ្ឌិត អ៊ុន សកក្កដា បោះពុម្ព ឆ្នាំ២០២០
- សៀវភៅ ប្រវត្តិនគរូបនីយកម្មនៅកម្ពុជា , បណ្ឌិត អ៊ូ វ៉ឌី ឆ្នាំ បោះពុម្ព ឆ្នាំ២០១២ ទំព័រទី ១០

**របាយការណ៍**

- របាយការណ៍ ស្តីពី ការអភិវឌ្ឍទីក្រុង រាជធានីភ្នំពេញ ប្រទេសកម្ពុជា , ក្រុមការងារធនាគារពិភពលោក
- របាយការណ៍ ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព សម្រាប់រាជធានីភ្នំពេញ ២០១៨–២០៣០ , វិទ្យាស្ថាន អភិវឌ្ឍន៍បៃតងសកល (GGGI) ឆ្នាំ ២០១៨
- សៀវភៅ Cambodia National Report For Habitat III Preparation , អគ្គនាយកដ្ឋានលំនៅឋាន បោះពុម្ព ឆ្នាំ ២០១៦
- ព្រឹត្តិបត្រសាលារាជធានីភ្នំពេញ លេខ៣៥ ខែកញ្ញា ឆ្នាំ២០១៧

- Maintaining High Growth: Cambodia Econmic Update , World Bank Group បោះពុម្ពឆ្នាំ ២០១៥
- របាយការណ៍ របស់ធនាគារជាតិនៃកម្ពុជា ឆ្នាំ ២០១៨
- Cambodia: Country Poverty Analysis 2014 , ADB បោះពុម្ពឆ្នាំ២០១៤
- Climate change vulnerability mapping for Southeast Asia Report, Yusuf, A., និង Francisco, H. ឆ្នាំ2009
- Phnom Penh: City of Water, សមាគមជាងត្នោត ឆ្នាំ២០១២
- ការកែទម្រង់ការគ្រប់គ្រងសំណល់រឹង នៅទីក្រុងភ្នំពេញ , មូលនិធិអាស៊ី វិទ្យាស្ថានអភិវឌ្ឍន៍ក្រៅប្រទេស ឆ្នាំ២០១៦
- របាយការណ៍ The Phnom Penh Urban Poor Assessment , រដ្ឋបាលរាជធានីភ្នំពេញ បោះពុម្ពឆ្នាំ ២០១២ ទំព័រទី ៥
- របាយការណ៍ វឌ្ឍនភាពពីការសិក្សាគម្រោងធ្វើឱ្យប្រសើរឡើងនៃប្រព័ន្ធលូទឹកកខ្វក់ និងទឹកភ្លៀងក្នុងតំបន់ទីប្រជុំជនរាជធានីភ្នំពេញ , JICA បោះពុម្ពខែវិច្ឆិកា ឆ្នាំ២០១៥
- របាយការណ៍ប្រចាំឆ្នាំរបស់អគ្គិសនីកម្ពុជា ឆ្នាំ២០១៤
- របាយការណ៍ ស្តីពីហានិភ័យគ្រោះមហន្តរាយនៃនគរូបនីយកម្ម ភាពងាយរងគ្រោះនៃតំបនក្រីក្រក្នុងក្រុងពីការលិចទឹកក្នុងទីក្រុង និងផលប៉ះពាល់ផ្សេងទៀត , អង្គការ People In Need (PIN) បោះពុម្ពឆ្នាំ ២០១៥


## គេហទំព័រ


- គេហទំព័រ Ecological Products Certification៖ <https://www.ekoloji.com/km/ekoloji/surdurulebilirlik-nedir/>
- គេហទំព័រអង្គការសហប្រជាជាតិ៖ <https://bit.ly/sustainability_united-nation>
- គេហទំព័រអង្គការសហប្រជាជាតិ៖ <https://www.un.org/ecosoc/en/sustainable-development>
- គេហទំព័រអង្គការសហប្រជាជាតិ៖ <https://sdgs.un.org/goals/goal11>
- គេហទំព័រសាលារាជធានីភ្នំពេញ៖ <http://phnompenh.gov.kh/en/about-us/organization-chart/>

- គម្រោង ស្តីពី ការតាមដានគុណភាពខ្យល់នៅកម្ពុជា ឆ្នាំ ២០១៦ , គេហទំព័រ៖ <http://aqicn.org/country/cambodia>
- សេចក្តីជូនដំណឹងអំពីស្ថានភាពគុណភាពខ្យល់នៅក្នុងរាជធានីភ្នំពេញ, គេហទំព័រ៖ <https://www.moe.gov.kh/index/6143>
- គេហទំព័រ គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត៖ http://www.cambodiacleancity.gov.kh/kh

# ឧបសម្ព័ន្ធ

# មាតិកាឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធរូបភាព

- ផែនទីនៃការពង្រីកទីក្រុងភ្នំពេញពីឆ្នាំ ១៨៦៧ ដល់ឆ្នាំ ១៩៩៣
- ប្លង់សុរិយោដីទីក្រុងភ្នំពេញ
- ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ឆ្នាំ២០៣៥
- ផែនទីតំបន់បៃតង និងលំហធ្លាសាធារណៈ
- ដងផ្លូវមហាវិថីនរោត្តមដែលត្រូវរៀបចំ, ប្លង់ពុះមហាវិថីព្រះនរោត្តម
- រូបភាពតថភាពតំណាងតាមដងមហាវិថីនរោត្តម
- សកម្មភាពលក់ដូរ និងចតយានយន្តខុសច្បាប់នៅលើចិញ្ចើមផ្លូវសាធារណៈ
- ហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍទីក្រុង
- គោលការណ៍អនុវត្តអនាម័យល្អ
- ធុងបែងចែកសំរាម និងធុងសំរាមអេឡិចត្រូនិច
- កង់សាធារណៈ, កង់ស្លូតផ័រ
- សួនបៃតងជូឡាឡុងកន

## ២. ឧបសម្ព័ន្ធគតិយុត្ត

- ច្បាប់ ស្តីពី ការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ១៩៩៤
- ច្បាប់ ស្តីពី ផ្លូវថ្នល់ លេខ នស/រកម/០៥១៤/00៨ ចុះថ្ងៃទី0៤ ខែឧសភា ឆ្នាំ២០១៤
- អនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពី លិខិតអនុញ្ញាតសាងសង់
- អនុក្រឹត្យលេខ ២២៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពី លិខិតអនុញ្ញាតសាងសង់គ្រប់ប្រភេទ
- អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី0៣ ខែមេសា ឆ្នាំ២០១៥ ស្តីពី នគរូបនីយកម្ម រាជធានី ក្រុង និង ទីប្រជុំជន
- លិខិតជម្រាបលេខ ១៤៤៥ ដនស ចុះថ្ងៃទី ១៩ មិថុនា គ.ស. ២០១៧ ស្តីពី ការកំណត់ធ្លាគម្លាត នគរូបនីយកម្មចំពោះសំណង់មានកម្ពស់ខ្ពស់
- សេចក្តីណែនាំ លេខ ០០៧/១៧ សណន.ច ចុះថ្ងៃទី ០៨ សីហា ២០១៧ ស្តីពី ការដោះស្រាយ ចរាចរណ៍ និងរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ
- សេចក្តីណែនាំ លេខ ០១៣/១៨ សណន ចុះថ្ងៃទី ០៧ ធ្នូ ២០១៨ ស្តីពី ការរៀបចំសណ្តាប់ធ្នាប់តាមដង ផ្លូវ និងការប្រើប្រាស់ចិញ្ចើមផ្លូវសាធារណៈទាំងអស់នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ

# ឧបសម្ព័ន្ធរូបភាព

ផែនទីនៃការពង្រីកទីក្រុងភ្នំពេញពីឆ្នាំ ១៨៦៧ ដល់ឆ្នាំ ១៩៩៣


ឆ្នាំ ១៨៦៧


ឆ្នាំ ១៨៩០


ឆ្នាំ ១៩១០


ឆ្នាំ ១៩២២


ឆ្នាំ ១៩៤៧


ឆ្នាំ ១៩៥៣


ឆ្នាំ ១៩៥៨


ឆ្នាំ ១៩៦៣


ឆ្នាំ ១៩៩៣

ប្លង់សុរិយោដីទីក្រុងភ្នំពេញ

**រូបទី១៧ : ប្លង់អភិវឌ្ឍន៍ទីក្រុងភ្នំពេញពីឆ្នាំ១៨៧៦ ដល់ ឆ្នាំ១៩៥៨**

COM 1367 / AOM 20605




**Le développement de Phnom-Penh de 1876 à 1958**

1. 1876. — 2. 1885. — 3. 1910. — 4. 1922. — 5. 1937. — 6. 1942. — 7. 1958.

**ប្រភព:** ដកស្រង់ចេញពីសៀវភៅ លោក Michel Igout : Phnom Penh décors et stratégies géographiques sur un espace urbain en crise, 25 février 1993.



www.elibraryofcambodia.org

**រូបទី១៨: ប្លង់សុរិយោដីក្រុងភ្នំពេញ មាត្រដ្ឋាន ១/២៥ ០០០ ធ្វើនៅឆ្នាំ១៩២២**




**ប្រភព:** ដកស្រង់ពីសៀវភៅលោក Michel Igout បោះពុម្ពឆ្នាំ 1993 : Phnom Penh d'Hier à Aujourd'hui, ទំព័រ ៨៤។



www.elibraryofcambodia.org

# ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ឆ្នាំ២០៣៥



## 5.4 Public Parks + Open Space

Compounding the issues of lake infilling is the lack of park space or open space to absorb rainy season waters. The inner *kahns* (districts) are home to a series of formal parks and gardens but they are often hardscaped, formally planted and home to decorative, rather than functional water features (Figure 16 and 17).



*Figure 16:*
*Phnom Penh 4 inner kahns. Public Parks and green space shown in green. Map drawn by author through survey.*



*Figure 17:*
*Parks in Phnom Penh. Top to Bottom: Sihanouk Boulevard, Sisowath, Russian Boulevard, Monivong Boulevard. Photos by author.*



ដងផ្លូវមហាវិថីនរោត្តមដែលត្រូវរៀបចំ




ប្លង់ពុះមហាវិថីព្រះនរោត្តម



រូបភាពតថភាពតំណាងតាមដងមហាវិថីនរោត្តម



សកម្មភាពលក់ដូរ និងចតយានយន្តខុសច្បាប់នៅលើចិញ្ចើមផ្លូវសាធារណៈ

# ហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍទីក្រុង

រូបភាពទី៩៖ យន្តការហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍទីក្រុង




តារាងទី ៤៖ ហិរញ្ញប្បទានអភិវឌ្ឍន៍បៃតង - ហានិភ័យ

| ប្រភេទនៃហានិភ័យ | ឧទាហរណ៍ទូទៅ |
|---|---|
| ហានិភ័យនយោបាយ | • មិនមានបរិយាកាសនយោបាយស្ថិតស្ថេរ ការព្រួយបារម្ភពីសន្តិសុខ<br>• ការផ្លាស់ប្តូរនៃរដ្ឋបាលថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ក្នុងការគាំទ្រគម្រោងវិនិយោគបៃតង |
| ហានិភ័យបទបញ្ញត្តិ | • គោលនយោបាយដែលជួយគាំទ្រការអភិវឌ្ឍដែលមិនមានភាពបៃតង (ឧទាហរណ៍ការអនុគ្រោះឬឧបត្ថម្ភទៅលើការប្រើប្រាស់ប្រេងឥន្ធនៈផូស៊ីល)<br>• មិនមានគោលនយោបាយគាំទ្រគ្រប់គ្រាន់ ការផ្លាស់ប្តូរបទបញ្ញត្តិ<br>• ក្របខណ្ឌបទបញ្ញត្តិមិនមានភាពរឹងមាំ និងការអនុវត្តនៅមានកម្រិត |
| ហានិភ័យបច្ចេកវិទ្យា | • ការប្រើប្រាស់បច្ចេកវិទ្យាមិនបានពេញសមត្ថភាពការខ្វះខាតនូវជំនាញបច្ចេកវិទ្យានៅក្នុងប្រទេស<br>• ហេដ្ឋារចនាសម្ព័ន្ធគាំទ្រមិនមានគ្រប់គ្រាន់ (ឧទាហរណ៍ ការចែកចាយ) |
| ហានិភ័យឥណទាន | • លទ្ធភាពសងនៃភាគីខ្ចីឥណទាន ហានិភ័យនៃការមិនសង<br>• អ្នកប្រើប្រាស់ចុងក្រោយជាអ្នកបង់សេវាសាធារណៈ |
| ហានិភ័យផ្នែកទីផ្សារហិរញ្ញវត្ថុ | • ការដល់ការកំណត់មុននៃតម្លៃទីផ្សារហិរញ្ញវត្ថុ ការប្រែប្រួលនៃតម្លៃអចលនទ្រព្យក្នុងទីផ្សារហិរញ្ញវត្ថុ<br>• ការកើនឡើងចុះនៃតម្លៃហិរញ្ញវត្ថុ |

# គោលការណ៍អនុវត្តអនាម័យល្អ





ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ក្រសួងសុខាភិបាល
Ministry of Health
Directorate General for Health

វិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ
CERTIFICATE OF GOOD HYGIENE PRACTICE

THE MINISTRY OF HEALTH CERTIFIED THAT RESTAURANT NAMED MALIS IS RESPONSIBLE BY Mr. DARC ARNAUDROLAND JACQUES

LOCATED SANGKAT TONLEBASSAC KHAN CHAMKAR MON PHNOM PENH

HAS COMPLIED WITH THE PRAKAS NUMBER 1309 DGH/DDF DATED ON 26 NOVEMBER 2012 AND AWARDED GRADE (A) BY THE MINISTRY OF HEALTH. THE CERTIFICATE

CONTINUES IT'S VALIDITY OF 02 YEARS STATING FROM 28 SEPTEMBER 2017 TO 28 SEPTEMBER 2019

## ធុងបែងចែកសំរាម និងធុងសំរាមអេឡិចត្រូនិច






## កង់ស្កូតជ័រ (Scooter)



## កង់សាធារណៈ



# សួនបៃតងជូឡាឡុងកន






LAYOUT PLAN



SECTION A

# ឧបសម្ព័ន្ធគតិយុត្ត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

........

# ច្បាប់

## ស្តីពី

# ការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់

ព.ស ២៥៣៨ គ.ស ១៩៩៤

# ច្បាប់
# ស្ដីពី
# ការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់

## ជំពូកទី ១
## កម្មវត្ថុ

មាត្រា ១.-

ច្បាប់ស្ដីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ មានកម្មវត្ថុជំរុញអោយមានការរៀបចំតែលំអទីក្រុងនិងតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធានាកិច្ចអភិវឌ្ឍន៍សុខដុមនៃប្រទេស ក្នុងស្មារតី :

- គោរពប្រយោជន៍រួមនិងប្រយោជន៍បុគ្គលផង គោរពសិទ្ធិឯកជនផង គោរពបទបញ្ញាច្បាប់ផងនិងត្រួតពិនិត្យការសាងសង់ផង ។
- ធានាការអភិវឌ្ឍន៍សំដៅរកលំនឹងរវាងទីក្រុងនិងតំបន់ជនបទ ផ្អែកទៅលើភូមិសាស្ត្រនិងលក្ខណៈពិសេសនៃជនបទនីមួយៗ ។
- ធានាលើកតំលៃសម្បត្តិធម្មជាតិ សម្បត្តិវប្បធម៌និងធានាការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច វិស័យទេសចរណ៍និងរក្សាបាននូវគុណភាពបរិដ្ឋាន ។

មាត្រា ២.-

ច្បាប់រៀបចំទឹកដី នគរូបនីយកម្មនិងសំណង់នេះ ត្រូវសំអាងទៅលើកម្មសិទ្ធិដែលអនុលោមទៅតាមច្បាប់ភូមិបាលបច្ចុប្បន្ន ។ ក្នុងករណីដែលច្បាប់ភូមិបាលត្រូវកែប្រែឬផ្លាស់ប្ដូរ ច្បាប់ស្ដីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់នឹងត្រូវកែច្នៃអោយស្របទៅតាមច្បាប់ភូមិបាលនេះដែរ ។

មាត្រា ៣.-

ដើម្បីសំរេចនូវបំណងដែលបានចែងខាងលើនេះ ត្រូវបង្កើតអោយមានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ដែលមានសមាជិកនិងសំណើការតែងតាំងនឹងរៀបចំដោយអនុក្រឹត្យ ។

ចំពោះរាជធានីភ្នំពេញ គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់សំរាប់ក្រុងភ្នំពេញមួយត្រូវបង្កើត ។ គណៈកម្មាធិការនេះដឹកនាំដោយប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ហើយដែលមានប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងភ្នំពេញឬអភិបាល អភិបាលរង ព្រមទាំងអង្គភាពបច្ចេកទេស ដែលមានសមត្ថកិច្ចចូលរួមជាសមាជិកផងដែរ ។ សមាសភាពច្បាស់លាស់ព្រមទាំងដំណើរការនៃគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ សំរាប់ក្រុងភ្នំពេញត្រូវកំរិតដោយអនុក្រឹត្យ ។

ចំពោះខេត្ត ក្រុងនានា ត្រូវបង្កើតអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ដែលដឹកនាំដោយអភិបាលខេត្ត ក្រុង និងអង្គភាពបច្ចេកទេសខេត្ត ក្រុង ដែលមានសមត្ថកិច្ចចូលរួមជាសមាជិកផង ។ សមាសភាពច្បាស់លាស់ព្រមទាំងដំណើរការនៃអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ត្រូវកំណត់ដោយសេចក្តីសំរេចរបស់ប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ក្រោយពីមានការយល់ព្រមរបស់គណៈកម្មាធិការជាតិនេះ ។

## ជំពូកទី ២
## ឯកសារទាក់ទងនឹងការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់

មាត្រា ៤.-

ឯកសារទាំងឡាយ ដែលទាក់ទងនឹងការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ត្រូវរៀបចំតាមករណីនីមួយៗ អោយសមស្របទៅតាមស្ថានភាព លក្ខណៈពិសេសនៃទឹកដី ខេត្ត ក្រុង តំបន់ក្នុងស្មារតីការពារដល់បេតិកភណ្ឌ ដល់បរិដ្ឋានការពារធនធានធម្មជាតិ ព្រមទាំងធានាដល់អភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច ។

មាត្រា ៥.-

គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់រាជធានីភ្នំពេញឬអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ខេត្ត ក្រុងនីមួយៗត្រូវគូសប្លង់គោលដើម្បីធ្វើការរៀបចំនិងអភិវឌ្ឍន៍នៃរាជធានី ខេត្ត ក្រុងរបស់ខ្លួន ។ ប្លង់គោលនេះត្រូវមានការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់និងកំណត់ដោយអនុក្រឹត្យ ។

ដើម្បីការពារនូវបេតិកភណ្ឌ ការពារបរិដ្ឋាននិងដើម្បីធានាអភិវឌ្ឍន៍សេដ្ឋកិច្ចចំពោះតំបន់ពិសេសណាមួយដែលគណៈរដ្ឋមន្ត្រីបានកំណត់ គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ មានភារៈរៀបចំប្លង់គោលសំរាប់តំបន់ពិសេសនោះដាក់ជូនគណៈរដ្ឋមន្ត្រីអនុម័ត ។

# ជំពូកទី ៣
## ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់

មាត្រា ៦.-

ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ ត្រូវរៀបចំឡើងសំរាប់រាជធានី ខេត្ត ក្រុង ។ ប្លង់នេះត្រូវមានការគោរពពីសំណាក់ឯកជនក៏ដូចជាអាជ្ញាធរសាធារណៈក្នុងកិច្ចការសាងសង់របស់ខ្លួន ។

មាត្រា ៧.-

ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ ត្រូវតែបញ្ជាក់អោយច្បាស់លាស់អំពីតំបន់ដែលត្រូវប្រើប្រាស់សំរាប់ការពារជាតិ សំរាប់កសិកម្ម សំរាប់ពាណិជ្ជកម្ម សំរាប់ឧស្សាហកម្ម សំរាប់ សិប្បកម្ម សំរាប់វប្បធម៌ សំរាប់ទេសចរណ៍ សំរាប់សាសនា ព្រមទាំងសំរាប់សំណង់នៃរដ្ឋបាលនិងបរិក្ខាសាធារណៈ ។ ប្លង់នេះកំណត់ផងដែរនូវលទ្ធភាពសំរាប់សាងសង់ ។

មាត្រា ៨.-

ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ត្រូវគោរពតាមប្លង់គោល ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់នេះ ។

មាត្រា ៩.-

ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់សំរាប់រាជធានីនិងខេត្ត ក្រុងនីមួយៗត្រូវមានការទទួលយល់ព្រមពីគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់រាជធានី ឬ អនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ខេត្ត ក្រុង រួចត្រូវមានការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ទៀត ។ ប្លង់ទាំងអស់ត្រូវមានការទទួលគោរពពីឯកជន ក៏ដូចជាអាជ្ញាធរសាធារណៈទាំងពួងដែរ ។

មាត្រា ១០.-

រាជរដ្ឋាភិបាលរៀបចំបទបញ្ញត្តិពិសេសនិងសេវាភាពនគរូបនីយកម្មដើម្បីការពារនិងលើកតម្លៃរមណីយដ្ឋានឬអចលនវត្ថុណាដែលនឹងផ្តល់នូវអត្ថប្រយោជន៍ខាងផ្នែក បុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាពឬបច្ចេកទេស ។ បញ្ជីអចលនវត្ថុឬ

នៅពេលពិនិត្យឃើញមានសំណង់ខុសឆ្គង ការដ្ឋានត្រូវបញ្ឈប់ ហើយជាយថាហេតុ សម្ភារៈនិងឧបករណ៍សំណង់នៅទីនោះ ត្រូវទទួលរឹបអូសតាមបង្គាប់តុលាការ ។ ក្នុងករណីដែលអ្នកសាងសង់ទទួលរងគ្រោះដោយមិនមែនជាកំហុសរបស់ខ្លួន អ្នករងគ្រោះអាចប្រើសិទ្ធិរបស់ខ្លួនដើម្បីប្តឹងទៅតុលាការទារជម្ងឺចិត្ត ។

មាត្រា ២២.-

ម្ចាស់សំណង់ មុនពេលវាយកំទេចសំណង់របស់ខ្លួនដែលមានស្រាប់ ត្រូវមានលិខិតអនុញ្ញាតរុះរើពីអាជ្ញាធរមានសមត្ថកិច្ចជាមុនសិន ។

បែបបទនៃការរុះរើវាយកំទេចសំណង់នឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

ការអនុញ្ញាតអោយរុះរើវាយកំទេចសំណង់អាចត្រូវបដិសេធបាន ក្នុងលក្ខណៈដែលការរុះរើវាយកំទេចសំណង់នោះមានទាក់ទិននឹងបញ្ហាសង្គមកិច្ច បច្ចេកទេសនិងបេតិកភណ្ឌ ដែលរដ្ឋបានកត់ត្រា។

មាត្រា ២៣.-

បទបញ្ញត្តិទាំងឡាយណាដែលមាននៅក្នុងច្បាប់ពីមុន ស្តីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃ ច័ន្ទ ទី ២៣ ខែឧសភា ឆ្នាំ១៩៩៤ នាសម័យប្រជុំ
រដ្ឋសភាលើកទី ២ នីតិកាលទី ១ ។

ភ្នំពេញ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ ១៩៩៤
ប្រធានរដ្ឋសភាស្តីទី

លោយ ឌីរេះ

រដ្ឋសភា
ចូល
លេខ ១៧៣៦
ថ្ងៃទី២១/៥ ឆ្នាំ២០១៤ ម៉ោង...
បញ្ជូនទៅ ...

# ព្រះរាជក្រម

នស/រកម/០៥១៤/០០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខនស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីផ្លូវថ្នល់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៤ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

**មាត្រា ២៩.–**

ការប្រើប្រាស់ផ្លូវថ្នល់និងសកម្មភាពផ្សេងៗ ពាក់ព័ន្ធនឹងផ្លូវថ្នល់តាមដងផ្លូវនៅក្នុងរាជធានី ក្រុង និងទីប្រជុំជន ត្រូវអនុវត្តដូចតទៅ ៖

ក- ចិញ្ចើមផ្លូវនិងផ្លូវថ្មើរជើងត្រូវប្រើប្រាស់សម្រាប់តែគោលបំណង ក្នុងការធ្វើចរាចរណ៍ដោយថ្មើរជើង ។

ខ- ចិញ្ចើមផ្លូវនិងផ្លូវថ្មើរជើងអាចយកទៅប្រើប្រាស់សម្រាប់គោលបំណងផ្សេងទៀតបានស្របតាមបញ្ញត្តិនៃមាត្រា ២៨ នៃច្បាប់នេះ ។

គ- មិនត្រូវអនុវត្តសកម្មភាពដូចខាងក្រោម ៖

- ចតរថយន្ត ឬយានជំនិះមិនត្រឹមត្រូវ តាមដងផ្លូវ ចិញ្ចើមផ្លូវ និងផ្លូវសម្រាប់ថ្មើរជើងខុសពីទីតាំងកំណត់
- សាងសង់របារកាត់ទទឹង ឬទួលបន្ថយល្បឿន ឬវត្ថុប្រហាក់ប្រហែលពីលើផ្លូវថ្នល់ដោយគ្មានការអនុញ្ញាត
- ធ្វើសកម្មភាពផ្សេងទៀតផ្ទុយពីច្បាប់នេះ ។

**មាត្រា ៣០.–**

ដើម្បីធានាដល់ការធ្វើចរាចរណ៍លើផ្លូវល្បឿនលឿន ផ្លូវជាតិ ផ្លូវខេត្ត ប្រកបដោយសុវត្ថិភាព រាល់ការសាងសង់សំណង់ដែលមានច្រកផ្លូវចេញចូលជាប់នឹងផ្លូវថ្នល់ខាងលើនេះ ត្រូវអនុវត្តដូចខាងក្រោម ៖

១- ការសាងសង់សំណង់ដូចជា ស្ថានីយប្រេងឥន្ធនៈ ស្ថានីយហ្គាស កន្លែងលាងយានយន្ត យានដ្ឋាន ឬសំណង់ប្រហាក់ប្រហែលផ្សេងៗទៀត ដែលមានមនុស្សជួបជុំគ្នាមធ្យមត្រូវស្ថិតក្នុងចម្ងាយយ៉ាងតិច ១៥(ដប់ប្រាំ)ម៉ែត្រ ពីខ្សែបន្ទាត់ព្រំដីចំណីផ្លូវ ។

២- ការសាងសង់មជ្ឈមណ្ឌលពាណិជ្ជកម្ម ពហុកីឡដ្ឋាន ទីលានប្រកួត រោងមហោស្រពមន្ទីរពេទ្យ គ្រឹះស្ថានសិក្សា ការរៀបចំផ្សារ ផ្សារណាត់ ពិព័រណ៍ទំនិញ ឬកិច្ចការផ្សេងទៀតដែលមានមនុស្សជួបជុំគ្នាច្រើន ត្រូវស្ថិតក្នុងចម្ងាយយ៉ាងតិចចំផុត៥០(ហាសិប)ម៉ែត្រ ពីខ្សែបន្ទាត់ព្រំដីចំណីផ្លូវថ្នល់ ។

៣- ការកំណត់ដូចមានចែងក្នុងចំណុចទី១ និងទី២ ខាងលើនេះ មិនអនុវត្តចំពោះរាល់សំណង់ដែលបានសាងសង់ពីមុនស្របតាមបទប្បញ្ញត្តិជាធរមានឡើយ ។

៤- ការកំណត់ចម្ងាយដូចមានចែងនៅចំណុចទី១ និងទី២ ខាងលើចំពោះផ្លូវជនបទត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី១២
## អន្តរប្បញ្ញត្តិ

**មាត្រា៧៩ .-**

លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យផ្លូវថ្នល់ ដែលនៅមានជាធរមាននៅមានសុពលភាព រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

**មាត្រា៨០ .-**

ក្រោយពីច្បាប់នេះចូលជាធរមានក្នុងរយៈពេល ០១(មួយ)ឆ្នាំ មន្ទីរពិសោធន៍ពាក់ព័ន្ធវិស័យផ្លូវថ្នល់ដែលបាននិងកំពុងប្រកបអាជីវកម្ម ត្រូវស្នើសុំអាជ្ញាបណ្ណស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

## ជំពូកទី១៣
## អវសានប្បញ្ញត្តិ

**មាត្រា៨១ .-**

ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលមានអានុភាពនៅកាលបរិច្ឆេទនៃការអនុវត្ត ហើយផ្ទុយនឹងបញ្ញត្តិនៃច្បាប់នេះ ត្រូវចាត់ទុកថាគ្មានអនុភាពត្រឹមទំហំដែលផ្ទុយនឹងច្បាប់នេះ ចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៤

**ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

០៧៧.១៤០៥.៥៥៧

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ហត្ថលេខា**

**ត្រាំ អ៊ីវតឹក**

លេខ: ៥៧៩ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# អនុក្រឹត្យ លេខ : ៨៦ អនក្រ.បក

## ស្តីពីលិខិតអនុញ្ញាតសាងសង់

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៨៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៤ នស៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់
- តាមសំណើរបស់ទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌និងវិចិត្រសិល្បៈ រៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- បានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

## ជំពូក ២

## ការបោះទីតាំង និង ទំហំសំណង់

**មាត្រា៣៤ .** _ការបោះទីតាំងជៀបនឹងព្រំដីឡូត៍ជិតខាង

ជៀបនឹងព្រំដីឡូត៍ សំណង់ទាំងឡាយនឹងត្រូវសាងសង់ ឬមួយនៅជាប់នឹងព្រំ ឬមួយជាជញ្ជាំងអឡូសិទ្ធិ ឬមួយនៅចម្ងាយអប្បបរមា ២ម ពីព្រំ ។ ចន្លោះ ២ម នេះ ត្រូវទុកអោយនៅទំនេរកុំមានសំណង់អ្វីឡើយ ។

ហាមមិនអោយបោះទ្វារឬបង្អួច នៅលើជញ្ជាំងអឡូសិទ្ធិឬជញ្ជាំងជាប់ព្រំ ។

ចំពោះសំណង់ជាប់ព្រំ ឬ សំណង់ជាជញ្ជាំងអឡូសិទ្ធិ នឹងមានកំណត់ក្នុង សេចក្តីណែនាំអនុវត្តរបស់គណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្មនិង សំណង់ តាមសំណើរបស់ខេត្ត-ក្រុង ។

ត្រូវបានចាត់ទុកជាបន្ទប់រស់នៅ រាល់បន្ទប់ទាំងអស់លើកលែងតែផ្ទះបាយ បន្ទប់អនាម័យ បន្ទប់សេវាផ្សេងៗ និងចន្លោះដើរក្នុងអគារ ។ បទបញ្ញត្តិនេះត្រូវ ដាក់អោយអនុវត្តផងដែរចំពោះសណ្ឋាគារ ។

ក្នុងករណីនេះ រាល់បន្ទប់ដេក ក៏ដូចជារាល់បន្ទប់ទទួលភ្ញៀវ សុទ្ធតែត្រូវចាត់ ទុកថាជាបន្ទប់រស់នៅ ។

បទបញ្ញត្តិនេះ ក៏ត្រូវដាក់អោយអនុវត្តផងដែរ ចំពោះកន្លែងធ្វើការ ។ ក្នុង ករណីនេះ រាល់បន្ទប់ដែលមានមុខងារជាការិយាល័យ ឬ រោងជាងប្រើប្រាស់ជា ទម្លាប់ ឬ ជាប្រចាំថ្ងៃ ត្រូវចាត់ទុកដូចជាបន្ទប់រស់នៅដែរ លើកលែងតែបន្ទប់មិន ត្រូវការជាចាំបាច់នូវពន្លឺថ្ងៃ តាមមុខងារឬតាមប្រភេទរបស់វា ដូចជាបន្ទប់កុំព្យូទ័រ បន្ទប់ពិសោធន៍ ស្ទូឌីយោភាពយន្ត ។ល។

សាលាក្រុង ឬ សាលាខេត្ត អាចមានសិទ្ធិអោយបិទរាល់ច្រកប្រហោងណា ដែលពុំគោរពតាមចម្ងាយដូចបានរៀបរាប់ខាងលើនេះ ។

ចំពោះអគារមានពីមុនស្រាប់ ដែលពុំគោរពតាមបទបញ្ញត្តិដូចបានរៀបរាប់ ខាងលើនេះទេ សាលាក្រុង ឬ សាលាខេត្ត អាចទាមទារអោយបង្កើតរបាំងការពារ កុំអោយមានគំហើញត្រង់ទៅលើដីឡូត៍អ្នកជិតខាង ។

របាំងការពារទាំងនេះ អាចជាជញ្ជាំងមានប្រឡោះខ្យល់ ផ្ទាំងឈើ ឬអ្វីៗផ្សេងទៀត ដែលពុំរាំងខ្ទប់ដំណើរខ្យល់បក់ចេញចូលក្នុងបន្ទប់រស់នៅ ។

ចាត់ទុកជាបង្អួច រាល់ប្រហោងនានាដែលបណ្តាលអោយមានគំហើញត្រង់ឆ្ពោះទៅលើអ្នកជិតខាង ។ ក្នុងករណីណាក៏ដោយ គេអាចប្រើប្រាស់បានរាល់របាំងធ្វើពីឈើ ឬ បេតុង ស្លាបព្រីលចាក់ប៊ើក ធ្វើពីឈើ ឬ កញ្ចក់ស្រអាប់ និងស្លាបព្រីលនៅនឹងថ្កល់ ។

មាត្រា៣៥ ._ផ្ទៃបាត

ចំពោះផ្ទះល្វែង និងអគារលំនៅដ្ឋានសមូហភាព ផ្ទៃបាតសំណង់ធៀបទៅនឹងផ្ទៃក្រឡារបស់ដីឡូតិ៍ ពុំអាចលើសពី ៧៥% ឡើយ ។

ចំពោះផ្ទះជាលំនៅដ្ឋាន ផ្ទៃបាតសំណង់នោះពុំអាចលើសពី ៥០% នៃផ្ទៃក្រឡាដីឡូតិ៍ឡើយ ។

ផ្ទៃក្រឡាដីឡូតិ៍ ដែលនៅសល់ពីការសាងសង់ ត្រូវរៀបចំជាសួនដោយដីជ្រាបទឹក អោយបានយ៉ាងតិចពាក់កណ្តាលផ្ទៃក្រឡានេះ ។

ចំពោះអគារដែលមានយ៉ាងតិច ១៥លំនៅ សណ្ឋាគារ អគារការិយាល័យ និងអគារឧស្សាហកម្ម ផ្ទៃបាតសំណង់ពុំអាចលើសពី ៥០% នៃផ្ទៃក្រឡាដីឡូតិ៍ឡើយ ។

ផ្ទៃក្រឡាដែលនៅសល់ពីសំណង់ នឹងត្រូវរៀបចំជាសួនដោយដីជ្រាបទឹកអោយបានយ៉ាងតិចពាក់កណ្តាលផ្ទៃក្រឡានេះ ។

សាលាក្រុង និង សាលាខេត្ត ត្រូវកំណត់តំបន់រៀបចំក្រុង ដែលត្រូវយកបទបញ្ញាខាងលើនេះមកអនុវត្ត ហើយនឹងត្រូវកំណត់បទបញ្ញត្តិពិសេស ចំពោះស្ថានភាពជាក់ស្តែង ។

មាត្រា៣៦ ._ប្លង់កំពស់

សាលាក្រុង និង សាលាខេត្តនីមួយៗ នឹងលើកគំរោងប្លង់កំពស់ក្នុងរយៈពេលមួយឆ្នាំ ក្រោយពីបានការអនុម័តលើអនុក្រឹត្យនេះរួច ដោយកំណត់អោយតំបន់នីមួយៗនៃក្រុងកំពស់អតិបរមានៃសំណង់ ។

ប្លង់កំពស់នេះត្រូវគិតដល់ :

• កំពស់មធ្យម បច្ចុប្បន្នតាមសង្កាត់នីមួយៗ ។

• លក្ខណៈសំខាន់នៃតំបន់ (ពាណិជ្ជកម្ម លំនៅដ្ឋាន ឧស្សាហកម្មនៅកណ្តាលក្រុង ឬ ជាយក្រុង ដីចាក់បំពេញ ឬ អត់ ការប្រើប្រាស់ទាក់ទងទៅនឹងហេដ្ឋារចនាសម្ព័ន្ធ ។ល។) ។

• ប្រភេទនៃសំណង់ (ផ្ទះល្វែង ភូមិគ្រឹះ គ្រឹះស្ថាន ឃ្លាំងស្តុកទំនិញ និងអគារឧស្សាហកម្ម... ។ល។) ។

ប្លង់កំពស់នេះ ត្រូវបានទទួលការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្មនិងសំណង់ ហើយផ្សព្វផ្សាយជាសាធារណៈ ។

**មាត្រា៣៧** ._ការការពារប្រាង្គប្រាសាទ និងទេសភាព

សាលាក្រុង និងសាលាខេត្តនីមួយៗ អាចកំណត់កំពស់អតិបរមាទាបជាងកំពស់អតិបរមាក្នុង <ប្លង់កំពស់> ដើម្បីការពារបូជនីយស្ថានប្រវត្តិសាស្ត្ររមណីយដ្ឋានធម្មជាតិ ក៏ដូចជាកន្លែងនៅជិតៗប្រាង្គប្រាសាទប្រវត្តិសាស្ត្រ ឬ ដើម្បីរក្សាទុកនូវទស្សនីយ៍នៃប្រាង្គប្រាសាទ និងទស្សនីយ៍ដ៏ស្ដឹមស្ដៃ ។

ការបន្ថយកំពស់នេះ នឹងត្រូវផ្សព្វផ្សាយជាសាធារណៈ និងប្រាប់ដល់អ្នកសុំលិខិតអនុញ្ញាតសាងសង់មុនពេលដាក់សំណុំលិខិតស្នើសុំ ។

## ជំពូក ៣

## និក្ខេបនៃសំណង់

**មាត្រា៣៨** ._លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ បើសំណង់ដែលគ្រោងនោះមានទីតាំងស្ថាបត្យកម្ម (Architecture) ទំហំ ឬ ទិដ្ឋភាពក្រៅអាចនាំអោយប៉ះពាល់ដល់លក្ខណៈ ឬ ផលប្រយោជន៍របស់ទីតាំងនៅជុំវិញ ប៉ះពាល់ដល់ទេសភាពធម្មជាតិ ឬ ទីក្រុង ភាពស្ងប់របស់ទីសក្ការៈបូជា រមណីយដ្ឋានប្រវត្តិសាស្ត្រ ឬបុរាណសាស្ត្រ រាជវាំង និង រាជប្រាង្គប្រាសាទ ។

**មាត្រា៣៩** ._លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ បើលក្ខណៈសំណង់នោះមិនធានាសុខមាលភាព បន្ទប់ស្នាក់នៅ ឬ បន្ទប់ធ្វើការនីមួយៗ ត្រូវអោយមានខ្យល់ចេញ–ចូល ហើយត្រូវមានបង្អួចមួយយ៉ាងតិច ។

ផ្ទៃក្រឡាបញ្ចូលពន្លឺថ្ងៃសំរាប់បន្ទប់នីមួយៗ ត្រូវមានយ៉ាងតិច ១,៥០ម$^2$ ។

**មាត្រា៤៧.–** គំរិតស្របច្បាប់នៃ <សន្ទស្សន៍ប្រើប្រាស់> ពុំត្រូវអនុវត្តឡើយ ចំពោះសំណង់ដែលពុំតម្រូវអោយមានលិខិតអនុញ្ញាតសាងសង់ ចំពោះគ្រឹះស្ថានសាធារណៈ និងចំពោះអគាររដ្ឋបាលសាធារណៈសំរាប់បំរើផ្ទាល់មុខ ជាកន្លែងធ្វើការសំរាប់ស្ថាប័នសាធារណៈ ។

នាយករដ្ឋមន្ត្រី អាចសំរេចលើកលែងការអនុវត្តន៍គំរិតស្របច្បាប់នៃ <សន្ទស្សន៍ប្រើប្រាស់> ចំពោះបណ្តាតំបន់រៀបចំពិសេស បន្ទាប់ពីបានយោបល់ពីគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្មនិងសំណង់ ។

<វាសនដ្ឋានសង្គម> ទាំងឡាយអាចទទួលនូវការលើកលែងមិនអោយបង់ពន្ធអាករ តាមសេចក្តីសំរេចរបស់អភិបាលខេត្ត–ក្រុង បន្ទាប់ពីបានទទួលការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ។

## ជំពូក ៥

## បទបញ្ញាពិសេស សំរាប់អនុវត្តលើភាគខ្លះ នៃដែនដី

**មាត្រា៤៨.–** ជាការបន្ថែមដល់បទបញ្ញាទូទៅនៃការប្រើប្រាស់ដី–ធ្លី ការណែនាំមួយចំនួនសំរាប់ការរៀបចំតំបន់ និងបទបញ្ញានគរូបនីយកម្មពិសេសមួយចំនួន អាចត្រូវតាក់តែងឡើងដោយអនុក្រឹត្យដែលអាចមានរហូតដល់ការហាមមិនអោយសាងសង់នៅក្នុង <តំបន់ចាប់អារម្មណ៍> ដូចជា ឆ្នេរសមុទ្រ មាត់ច្រាំងទន្លេ និងបឹងធំៗ ។ រាល់ឯកសារ <នគរូបនីយកម្មមូលដ្ឋាន> និងប្លង់ខេត្តនៃតំបន់ហាមមិនអោយមានសំណង់ ដែលចែងក្នុងមាត្រា ៣២ វគ្គទី ២ នៃអនុក្រឹត្យនេះត្រូវទុកជាការណែនាំទាំងនេះ និងការហាមជាយថាហេតុមិនអោយសាងសង់ ។

**មាត្រា៤៩ .–** បទបញ្ញត្តិទាំងឡាយមានពីមុនដែលផ្ទុយនឹងអនុក្រឹត្យនេះ ចាត់ទុកជានិរាករណ៍ ។

**មាត្រា៥០.–** ទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌ និងវិចិត្រសិល្បៈ រៀបចំទឹកដីនគរូបនីយកម្មនិងសំណង់ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង អភិបាលខេត្ត សមាជិកគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្មនិងសំណង់ និងក្រសួងស្ថាប័ន ពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមតួនាទីចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

អ៊ុង ហួត ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២២៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## លិខិតអនុញ្ញាតសាងសង់

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

១៤. **សៀវភៅបន្ទុក** សំដៅដល់កម្រងឯកសារបច្ចេកទេសសម្រាប់បម្រើដល់ការអនុវត្តការងារសាងសង់ ឬរុះរើ មានជាអាទិ៍ផែនការការងារ សេចក្ដីណែនាំបច្ចេកទេស វិធីសាស្ត្រ និងឯកសារបច្ចេកទេសដទៃទៀត។

១៥. **សំណង់បេតិកភណ្ឌ វប្បធម៌ ប្រវត្តិសាស្ត្រ** សំដៅដល់សំណង់ជាកេរដំណែលបន្សល់ទុកពីមនុស្សជំនាន់មុនដែលមានចរិតវិទ្យាសាស្ត្រ វប្បធម៌ ប្រវត្តិសាស្ត្រ បុរាណវិទ្យា សិល្បៈ សាសនា ដែលឆ្លុះបញ្ចាំងពីដំណាក់កាលនៃការវិវត្តរបស់អរិយធម៌ និងដែលបានចុះបញ្ជីសារពើភណ្ឌ បេតិកភណ្ឌស្របតាមច្បាប់ស្ដីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌។

១៦. **សំណង់មិនមែនអគារ** សំដៅដល់សំណង់ដែលសាងសង់ឡើងភ្ជាប់នឹងដីឬអចលនវត្ថុដទៃទៀតសម្រាប់ទ្រទ្រង់បន្ទុកដែលត្រូវបានសិក្សាឡើងមិនមែនសម្រាប់មនុស្សស្នាក់នៅឬប្រើប្រាស់ជានិរន្តរ៍ មានជាអាទិ៍បង្គោលអង់តែនទូរសព្ទ បង្គោលអង់តែនស្ថានីយវិទ្យុឬទូរទស្សន៍ សំណង់ពាក់ព័ន្ធនឹងការគ្រប់គ្រងសកម្មភាពផ្នែកដោនស្ទ្រីម បង្គោលអគ្គិសនី ជងទង់ ប៉ម ខ្លោងទ្វារ អាងស្ដុកទឹកខ្ពស់ពីដី ស្តូប បដិមា កន្ត្រកវិល។

១៧. **សំណង់លំនៅឋាន** សំដៅដល់សំណង់ដែលមានមុខងារប្រើប្រាស់ជាទីលំនៅអចិន្ត្រៃយ៍។

១៨. **អគារ** សំដៅដល់សំណង់ដែលសាងសង់ឡើងភ្ជាប់នឹងដីសម្រាប់ទ្រទ្រង់បន្ទុកដែលត្រូវបានសិក្សាឡើងសម្រាប់មនុស្សស្នាក់នៅឬប្រើប្រាស់ជានិរន្តរ៍ មានជាអាទិ៍សំណង់លំនៅឋាន សណ្ឋាគារ អគារការិយាល័យ មន្ទីរពេទ្យ អគារសិក្សា បណ្ណាល័យ រោងភាពយន្ត សារមន្ទីរ សាលមហោស្រព ផ្សារ រោងចក្រ ស្ថានីយអ្នកដំណើរ។

១៩. **អាជ្ញាធរមានសមត្ថកិច្ច** សំដៅដល់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

២០. **ឯកសារបច្ចេកទេស** សំដៅដល់គម្រោងប្លង់ស្ថាបត្យកម្ម គម្រោងប្លង់គ្រឿងផ្គុំសំណង់ គម្រោងប្លង់រុះរើ គម្រោងប្លង់ប្រព័ន្ធមេកានិក អគ្គិសនី ឬទឹក លិខិតបញ្ជាក់អនុលោមភាព វិញ្ញាបនបត្រប្រើប្រាស់សំណង់ ឯកសារសិក្សាភូគព្ភសាស្ត្រ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ឯកសារសិក្សាសមិទ្ធិលទ្ធកម្ម សៀវភៅបន្ទុកនៃការងារសាងសង់ និងគម្រោងប្លង់បច្ចេកទេសដទៃទៀត។

## ជំពូកទី២
## សមត្ថកិច្ច

**មាត្រា៤ .-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចគ្រប់គ្រងសំណង់គ្រប់ប្រភេទ។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចផ្ដល់លិខិតអនុញ្ញាតសាងសង់ និងលិខិតអនុញ្ញាតរុះរើចំពោះសំណង់ឬការងារ ដូចខាងក្រោម៖

- សំណង់ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបលើសពី៣ ០០០(បីពាន់)ម៉ែត្រក្រឡា
- ការងារសាងសង់ឡើងវិញជាថ្មី ការងារសាងសង់បន្ថែម ឬការងារកែប្រែសំណង់ដែលមានស្រាប់ ដែលមានផ្ទៃក្រឡាកម្រាលសំណង់ចាស់ឬកផ្ទៃក្រឡាកម្រាលសំណង់ថ្មី សរុបលើសពី៣ ០០០ (បីពាន់)ម៉ែត្រក្រឡា
- អគារដែលមានកម្ពស់ខ្ពស់ជាង១១(ដប់មួយ)ជាន់ឡើងទៅរួមទាំងជាន់ផ្ទាល់ដី
- សំណង់ដែលមានជាន់ក្រោមដីក្នុងជម្រៅជ្រៅជាង៥(ប្រាំ)ម៉ែត្រ
- ជញ្ជាំងទប់ដីដែលមានកម្ពស់ខ្ពស់ជាង៥(ប្រាំ)ម៉ែត្រ
- ឋបនីយភណ្ឌដែលអាចបង្កគ្រោះថ្នាក់ដោយអគ្គិភ័យដូចជាស្ថានីយឬដេប៉ូស្តុក លក់ ឬចែកចាយប្រេងឥន្ធនៈ ឧស្ម័ន ឬផលិតផលគេលសិលាដទៃទៀត ពាងឬស៊ីទែនស្តុកប្រេងឥន្ធនៈ ឧស្ម័ន សារធាតុងាយឆេះ ឬផលិតផលគេលសិលាដទៃទៀត និងរោងចក្រដែលមានផលិតផលងាយឆេះ
- អាងតម្កល់ឬស្តុកទឹកដែលមានកម្ពស់ខ្ពស់ជាង១៥(ដប់ប្រាំ)ម៉ែត្រ ឬមានចំណុះលើសពី៥០(ហាសិប)ម៉ែត្រគូប
- សំណង់សម្រាប់បម្រើវិស័យកីឡា ទេសចរណ៍ និងវប្បធម៌ មានជាអាទិ៍ពហុកីឡដ្ឋាន ទីលានវាយកូនហ្គោល ទីលានកីឡាប្រណាំង សួនកម្សាន្ត អាងហែលទឹក សារមន្ទីរ សាលមហោស្រព សាលសន្និសីទ រោងភាពយន្ត
- សំណង់នៅក្នុងតំបន់ការពារបរិស្ថានធម្មជាតិ បេតិកភណ្ឌវប្បធម៌ ប្រវត្តិសាស្ត្រ ឬតំបន់ការពារផ្សេងទៀត
- អគារ ប៉ម ឬសំណង់នៅក្នុងស្ថានីយអ្នកដំណើរតាមរថយន្ត ស្ថានីយអយស្ម័យយាន កំពង់ផែ អាកាសយានដ្ឋាន និងស្ថានីយរ៉ារីអគ្គិសនី ដែលមិនមែនជាផ្នែកនៃហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ឬផ្នែកនៃសំណង់ការងារទឹក
- សំណង់អគារ ប៉ម ឬខ្លោងទ្វារនៅតាមច្រកទ្វារអន្តរជាតិ
- បង្គោលអង់តែនទូរសព្ទនិងបង្គោលអង់តែនស្ថានីយវិទ្យុឬទូរទស្សន៍
- សំណង់មិនមែនអគារដទៃទៀតដែលមានកម្ពស់ខ្ពស់ជាង៣០(សាមសិប)ម៉ែត្រ។

**មាត្រា៥ .-**

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដោយមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្តជាសេនាធិការ មានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតអនុញ្ញាតរុះរើ ចំពោះសំណង់ឬការងារ ដូចខាងក្រោម៖

- សំណង់ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាងឬស្មើ៣ ០០០(បីពាន់)ម៉ែត្រក្រឡា និង មានកម្ពស់ទាបជាងឬស្មើ១១(ដប់មួយ)ជាន់រួមទាំងជាន់ផ្ទាល់ដី ដោយគ្មានឬមានជាន់ក្រោមដីក្នុង

ជម្រៅភក់ជាងឬស្មើ៥(ប្រាំ)ម៉ែត្រ លើកលែងសំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

- ការងារសាងសង់ឡើងវិញជាថ្មី ការងារសាងសង់បន្ថែម ឬការងារកែប្រែសំណង់ដែលមានស្រាប់ ដែលមានផ្ទៃក្រឡាកម្រាលសំណង់ចាស់ បូកផ្ទៃក្រឡាកម្រាលសំណង់ថ្មីសរុបលើសពី៥០០(ប្រាំរយ) ម៉ែត្រក្រឡា និងតិចជាងឬស្មើ៣ ០០០(បីពាន់)ម៉ែត្រក្រឡា
- ជញ្ជាំងទប់ដីដែលមានកម្ពស់ទាបជាងឬស្មើ៥(ប្រាំ)ម៉ែត្រ
- របងថ្មឬបេតុងដែលមានកម្ពស់ខ្ពស់ជាង៣(បី)ម៉ែត្រ
- សំណង់មិនមែនអគារផ្សេងទៀតដែលមានកម្ពស់ទាបជាងឬស្មើ៣០(សាមសិប)ម៉ែត្រ។

**មាត្រា៦ .-**

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាសេនាធិការ មានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតអនុញ្ញាតរុះរើ ចំពោះសំណង់ឬការងារដូចខាងក្រោម៖

- សំណង់លំនៅឋានដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាងឬស្មើ៥០០(ប្រាំរយ)ម៉ែត្រក្រឡានិងមានកម្ពស់ទាបជាងឬស្មើ៤(បួន)ជាន់រួមទាំងជាន់ផ្ទាល់ដី និងគ្មានជាន់ក្រោមដី
- ការងារសាងសង់សំណង់លំនៅឋានឡើងវិញជាថ្មី ការងារសាងសង់បន្ថែម ឬការងារកែប្រែសំណង់លំនៅឋានដែលមានស្រាប់ ដែលមានផ្ទៃក្រឡាកម្រាលសំណង់ចាស់បូកផ្ទៃក្រឡាកម្រាលសំណង់ថ្មីសរុបលើសពីទំហំផ្ទៃក្រឡាកម្រាលសំណង់ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ និងតិចជាងឬស្មើ៥០០(ប្រាំរយ)ម៉ែត្រក្រឡា
- របងថ្មឬបេតុងដែលមានកម្ពស់ទាបជាងឬស្មើ៣(បី)ម៉ែត្រ។

**មាត្រា៧ .-**

រាជរដ្ឋាភិបាលឬស្ថាប័នតំណាងដែលបានទទួលសិទ្ធិប្រទាន មានសមត្ថកិច្ចផ្តល់ការអនុញ្ញាតឱ្យសាងសង់ឬរុះរើ ចំពោះសំណង់ដូចខាងក្រោម៖

- សំណង់ដែលជាការសម្ងាត់របស់ជាតិ មានជាអាទិ៍សំណង់សម្រាប់បោះពុម្ពប្រាក់ក្រដាស បណ្ណ តម្កល់ និងរក្សាទុកប្រាក់ វត្ថុ
- សំណង់សម្រាប់បម្រើដល់សន្តិសុខជាតិនិងការការពារជាតិ មានជាអាទិ៍សំណង់លេណដ្ឋាន ឃ្លាំងស្តុកអាវុធនិងគ្រឿងយុទ្ធភណ្ឌ និងសំណង់បម្រើដល់ការប្រយុទ្ធ។

## ជំពូកទី១២
## អវសានប្បញ្ញត្តិ

**មាត្រា៥៣ .-**

អនុក្រឹត្យលេខ៨៦ អនក្រ.បក. ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពីលិខិតអនុញ្ញាតសាងសង់ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១ រោច ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

**សម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## នគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា២និងមាត្រា៥នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ផ្នែកទី១
## អំពីប្រភេទដីអាចសាងសង់បាន

**មាត្រា២០ .–**

ប្រភេទដីអាចសាងសង់បាន ត្រូវបានបែងចែកជាតំបន់ ដូចខាងក្រោម៖

១- តំបន់លំនៅឋាន រួមមាន៥(ប្រាំ)ប្រភេទ៖

- តំបន់លំនៅឋានដាច់ពីគ្នា ដែលមានកម្ពស់ទាប(ផ្ទះ ភូមិគ្រឹះ ឬពាក់កណ្តាលភូមិគ្រឹះ)
- តំបន់លំនៅឋានជាប់គ្នា ដែលមានកម្ពស់ទាប(ផ្ទះល្វែងឬផ្ទះជាប់គ្នា)
- តំបន់លំនៅឋានដែលមានកម្ពស់មធ្យម
- តំបន់លំនៅឋានដែលមានកម្ពស់ខ្ពស់
- តំបន់លំនៅឋានចម្រុះ។

២- តំបន់ពាណិជ្ជកម្ម រួមមាន២(ពីរ)ប្រភេទ៖

- តំបន់ពាណិជ្ជកម្ម
- តំបន់ពាណិជ្ជកម្មចម្រុះ។

៣- តំបន់ឧស្សាហកម្ម រួមមាន៣(បី)ប្រភេទ៖

- តំបន់ឧស្សាហកម្ម
- តំបន់ឧស្សាហកម្មស្រាល
- តំបន់ឧស្សាហកម្មចម្រុះ។

៤- តំបន់ចម្រុះ

៥- តំបន់ដឹកជញ្ជូន

៦- តំបន់ទេសចរណ៍

៧- តំបន់រដ្ឋបាលនិងសេវាសាធារណៈ

៨- តំបន់លំហសាធារណៈនិងផ្ទៃបៃតង

៩- តំបន់វប្បធម៌និងសាសនា

១០- តំបន់ផ្សេងៗមួយចំនួនទៀត ស្របតាមភូមិសាស្ត្រជាក់ស្តែង។

ការបែងចែកតំបន់ក្នុងប្រភេទដីអាចសាងសង់បាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២១ .–**

ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមាគិតជាភាគរយសម្រាប់ប្រភេទដីអាចសាងសង់បាននៅទីក្រុង ត្រូវបានកំណត់ដូចខាងក្រោម :

១- តំបន់លំនៅឋាន៖

- តំបន់លំនៅឋានដាច់ពីគ្នា ដែលមានកម្ពស់ទាប មិនឲ្យលើសពី៥០%នៃផ្ទៃដីឡូត៍
- តំបន់លំនៅឋានជាប់គ្នា ដែលមានកម្ពស់ទាប មិនឲ្យលើសពី៧៥%នៃផ្ទៃដីឡូត៍
- តំបន់លំនៅឋាន ដែលមានកម្ពស់មធ្យម មិនឲ្យលើសពី៦០%នៃផ្ទៃដីឡូត៍
- តំបន់លំនៅឋាន ដែលមានកម្ពស់ខ្ពស់ មិនឲ្យលើសពី៦០%នៃផ្ទៃដីឡូត៍
- តំបន់លំនៅឋានចម្រុះ មិនឲ្យលើសពី៦៥%នៃផ្ទៃដីឡូត៍

២- តំបន់ពាណិជ្ជកម្មៈ

- តំបន់ពាណិជ្ជកម្ម មិនឲ្យលើសពី៧៥%នៃផ្ទៃដីឡូត៍
- តំបន់ពាណិជ្ជកម្មចម្រុះ មិនឲ្យលើសពី៧០%នៃផ្ទៃដីឡូត៍។

៣- តំបន់ឧស្សាហកម្មៈ

- តំបន់ឧស្សាហកម្ម មិនឲ្យលើសពី៦០%នៃផ្ទៃដីឡូត៍
- តំបន់ឧស្សាហកម្មស្រាល មិនឲ្យលើសពី៦០%នៃផ្ទៃដីឡូត៍
- តំបន់ឧស្សាហកម្មចម្រុះ មិនឲ្យលើសពី៦០%នៃផ្ទៃដីឡូត៍។

៤- តំបន់ចម្រុះ មិនឲ្យលើសពី៧០%នៃផ្ទៃដីឡូត៍។

៥- តំបន់ដឹកជញ្ជូន មិនឲ្យលើសពី៦០%នៃផ្ទៃដីឡូត៍។

៦- តំបន់ទេសចរណ៍ មិនឲ្យលើសពី៥០%នៃផ្ទៃដីឡូត៍។

៧- តំបន់រដ្ឋបាលនិងសេវាសាធារណៈ មិនឲ្យលើសពី៦០%នៃផ្ទៃដីឡូត៍។

៨- តំបន់លំហសាធារណៈនិងផ្ទៃបៃតង មិនឲ្យលើសពី១០%នៃផ្ទៃដីឡូត៍។

៩- តំបន់វប្បធម៌និងសាសនា មិនឲ្យលើសពី៥០%នៃផ្ទៃដីឡូត៍។

១០- តំបន់ផ្សេងៗមួយចំនួនទៀត មិនឲ្យលើសពី៥០%នៃផ្ទៃដីឡូត៍។

ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ខាងលើនេះ មិនយកមកអនុវត្តនៅតំបន់លំនៅឋានណាមានផែនការប្រើប្រាស់ដីអនុម័តជាផ្លូវការរួចហើយមុនអនុក្រឹត្យនេះចូលជាធរមាន។ ក្នុងស្មារតីនេះ អាជ្ញាធរមានសមត្ថកិច្ចត្រូវអនុវត្តតាមផែនការប្រើប្រាស់ដីនោះ។

ចំពោះករណីសំណង់ថ្មី សាងសង់នៅលើដីមួយកន្លែងដែលមានអគារចាស់មួយឬច្រើន ហើយគ្មានគម្រោងរុះរើចេញពេលនោះទេ ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ត្រូវគណនាដោយថែមផ្ទៃក្រឡានៃសំណង់ចាស់ទៅលើផ្ទៃក្រឡានៃសំណង់ថ្មី។

ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ ត្រូវរៀបចំឲ្យមានសួនច្បារជ្រាបទឹកយ៉ាងតិច៣០(សាមសិប)ភាគរយនៃផ្ទៃដីដែលនៅសល់ពីការសាងសង់នេះ។

បន្ថែមលើសួនច្បារជ្រាបទឹក គ្រប់ដីឡូត៍ស្នើសុំការសាងសង់ ត្រូវកំណត់ឲ្យដាំដើមឈើស្របតាមបទដ្ឋានបច្ចេកទេស ដើម្បីបង្កើនផ្ទៃក្រឡាបៃតងក្នុងទីក្រុង និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុសកល។

ផ្ទៃក្រឡាដីឡូត៍១៥០(មួយរយហាសិប)ម៉ែត្រក្រឡា ត្រូវដាំដើមឈើឲ្យបានយ៉ាងតិច១(មួយ)ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ។ ក្នុងការគណនា បើលទ្ធផលជាចំនួនទសភាគ ចំនួនដើមឈើត្រូវកំណត់យកចំនួនគត់ដែលមានតម្លៃធំជាងបន្ទាប់នៃលទ្ធផល។

ការកំណត់និងការគណនាផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍និងបទដ្ឋានលម្អិតនៃការរៀបចំផ្ទៃបៃតង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្លង់ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍នៃរាជធានីនិងក្រុង ស្រុក ខណ្ឌ ត្រូវផ្តួចផ្តើម រៀបចំដូចនីតិវិធីនៃប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីនិងសម្រេចដាក់ឱ្យប្រើប្រាស់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

**មាត្រា២២ .-**

សន្ទស្សន៍ប្រើប្រាស់ដីត្រូវកំណត់ដោយអនុបាតរវាងផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការនិងផ្ទៃក្រឡាដីឡូត៍ដែលសំណង់នោះតាំងនៅ។

កាលណាសំណង់ថ្មីមួយត្រូវបានសាងសង់នៅលើដីមួយកន្លែងដែលមានអគារចាស់មួយឬច្រើន ហើយគ្មានគម្រោងរុះរើចេញពេលនោះទេ សន្ទស្សន៍ប្រើប្រាស់ដីត្រូវគណនាដោយថែមផ្ទៃក្រឡានៃសំណង់ចាស់ទៅលើផ្ទៃក្រឡានៃសំណង់ថ្មី។

សន្ទស្សន៍ប្រើប្រាស់ដីអតិបរមានៅក្នុងប្រភេទដីអាចសាងសង់បាននៅទីក្រុង ត្រូវកំណត់ដូចខាងក្រោម៖

| | |
|---|---|
| ១- តំបន់លំនៅឋាន : | |
| - តំបន់លំនៅឋានដាច់ពីគ្នា ដែលមានកម្ពស់ទាប | មិនឲ្យលើសពី១,៥ |
| - តំបន់លំនៅឋានជាប់គ្នា ដែលមានកម្ពស់ទាប | មិនឲ្យលើសពី១,៥ |
| - តំបន់លំនៅឋាន ដែលមានកម្ពស់មធ្យម | មិនឲ្យលើសពី៣,០ |
| - តំបន់លំនៅឋាន ដែលមានកម្ពស់ខ្ពស់ | មិនឲ្យលើសពី៥,០ |
| - តំបន់លំនៅឋានចម្រុះ | មិនឲ្យលើសពី៥,០។ |
| ២- តំបន់ពាណិជ្ជកម្ម : | |
| - តំបន់ពាណិជ្ជកម្ម | មិនឲ្យលើសពី១២ |
| - តំបន់ពាណិជ្ជកម្មចម្រុះ | មិនឲ្យលើសពី១០។ |
| ៣- តំបន់ឧស្សាហកម្ម : | |
| - តំបន់ឧស្សាហកម្ម | មិនឲ្យលើសពី៣,០ |
| - តំបន់ឧស្សាហកម្មស្រាល | មិនឲ្យលើសពី៣,០ |
| - តំបន់ឧស្សាហកម្មចម្រុះ | មិនឲ្យលើសពី៣,០។ |
| ៤- តំបន់ចម្រុះ | មិនឲ្យលើសពី១០។ |
| ៥- តំបន់ដឹកជញ្ជូន | មិនឲ្យលើសពី៣,០។ |
| ៦- តំបន់ទេសចរណ៍ | មិនឲ្យលើសពី៥,០។ |
| ៧- តំបន់រដ្ឋបាលនិងសេវាសាធារណៈ | មិនឲ្យលើសពី៥,០។ |
| ៨- តំបន់លំហសាធារណៈនិងផ្ទៃបៃតង | មិនឲ្យលើសពី០,៣។ |
| ៩- តំបន់វប្បធម៌និងសាសនា | មិនឲ្យលើសពី២,០។ |
| ១០- តំបន់ផ្សេងៗ មួយចំនួនទៀត | មិនឲ្យលើសពី៥,០។ |

ការកំណត់សន្ទស្សន៍ប្រើប្រាស់ដីត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២៣ .-**

ដើម្បីធានាការរៀបចំផែនការរូបវន្តទីក្រុង ការគ្រប់គ្រងទីក្រុង ការអភិវឌ្ឍទីក្រុង ហេដ្ឋារចនាសម្ព័ន្ធទីក្រុង ការពង្រីកទីក្រុង និងការប្រើប្រាស់ដីក្នុងទីក្រុងប្រកបដោយប្រសិទ្ធភាព ដង់ស៊ីតេប្រជាជនអតិបរមាសម្រាប់ការពង្រីកប្រភេទដីអាចសាងសង់បានត្រូវកំណត់យ៉ាងតិច១២០(មួយរយម្ភៃ)នាក់ក្នុងមួយហិកតា។

## ផ្នែកទី២
## ប្រភេទដីកម្រិតការសាងសង់

**មាត្រា២៤ .-**

ប្រភេទដីកម្រិតការសាងសង់ ត្រូវបានបែងចែកជាតំបន់ ដូចខាងក្រោម៖

១- តំបន់កសិកម្ម

២- តំបន់ព្រៃឈើ

៣- តំបន់ធនធានទឹក

៤- តំបន់ការពារ។

៥- តំបន់ផ្សេងៗមួយចំនួនទៀត ស្របតាមភូមិសាស្ត្រជាក់ស្តែង។

គម្រោងអភិវឌ្ឍនិងការសាងសង់នៅក្នុងតំបន់នេះត្រូវគោរពតាមនីតិវិធីនិងក្របខណ្ឌគតិយុត្តជាធរមាននិងតម្រូវឲ្យមានលិខិតអនុញ្ញាតប្តូរប្រភេទនៃការប្រើប្រាស់ដីឲ្យទៅជាប្រភេទដីអាចសាងសង់បានជាមុន។

មានតែតំបន់កសិកម្មប៉ុណ្ណោះដែលអាចអនុញ្ញាតឲ្យសាងសង់សំណង់លំនៅឋានផ្ទាល់ខ្លួនបានដែលពុំមានលក្ខណៈអាជីវកម្ម និងអាចសាងសង់រោងសិប្បកម្ម រោងចក្រសម្រាប់គោលដៅកសិកម្មបានដោយមិនបាច់ធ្វើការកែប្រែទៅជាប្រភេទដីអាចសាងសង់បាន លើកលែងតែតំបន់ណាដែលមានបទដ្ឋានគតិយុត្តកំណត់ដោយឡែក។

ការកំណត់ប្រភេទដីកម្រិតការសាងសង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២៥ .-**

ផលធៀបរវាងផ្ទៃក្រឡាបាតសំណង់និងផ្ទៃដីឡូត៍អតិបរមាគិតជាភាគរយ នៅក្នុងប្រភេទដីកម្រិតការសាងសង់នៅទីក្រុង ត្រូវកំណត់៣០(សាមសិប)ភាគរយ។

កាលណាសំណង់ថ្មីមួយត្រូវបានសាងសង់នៅលើដីមួយកន្លែងដែលមានអគារចាស់មួយឬច្រើន ហើយគ្មានគម្រោងរុះរើចេញពេលនោះទេ ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ ត្រូវគណនាដោយថែមផ្ទៃក្រឡានៃសំណង់ចាស់ទៅលើផ្ទៃក្រឡានៃសំណង់ថ្មី។

ផ្ទៃដីដែលនៅសល់ពីការសាងសង់ក្នុងដីឡូត៍ ត្រូវរៀបចំឲ្យមានសួនច្បារដែលអាចជ្រាបទឹកយ៉ាងតិច៥០(ហាសិប)ភាគរយនៃផ្ទៃដីដែលនៅសល់ពីការសាងសង់នេះ។

ផ្ទៃក្រឡាដីឡូត៍១០០(មួយរយ)ម៉ែត្រក្រឡាត្រូវដាំដើមឈើឲ្យបានយ៉ាងតិច១(មួយ)ដើម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ។ ក្នុងការគណនាបើលទ្ធផលជាចំនួនទសភាគ ចំនួនដើមឈើត្រូវកំណត់យកចំនួនគត់ដែលមានតម្លៃធំជាងបន្ទាប់នៃលទ្ធផល។

**មាត្រា២៦ .-**

សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាសម្រាប់ប្រភេទដីកម្រិតការសាងសង់នៅទីក្រុង ត្រូវកំណត់ត្រឹម១,៥(មួយកន្លះ)។

កាលណាសំណង់ថ្មីមួយ ត្រូវបានសាងសង់នៅលើដីមួយកន្លែងដែលមានអគារចាស់មួយឬច្រើន ហើយគ្មានគម្រោងរុះរើចេញពេលនោះទេ សន្ទស្សន៍ប្រើប្រាស់ដីត្រូវគណនាដោយថែមផ្ទៃក្រឡានៃសំណង់ចាស់ ទៅលើផ្ទៃក្រឡានៃសំណង់ថ្មី។

## ផ្នែកទី៣
## អំពីបទប្បញ្ញត្តិរួមសម្រាប់ប្រភេទដីអាចសាងសង់បាន
## និងប្រភេទដីកម្រិតការសាងសង់

**មាត្រា២៧ .-**

លក្ខណ្ឌបរិស្ថាននៃការងារនគរូបនីយកម្មនិងសំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**មាត្រា២៨ .-**

ផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ មិនគិតបញ្ចូលផ្ទៃក្រឡាកម្រាលសំណង់ជាន់ក្រោមដី ជាន់ផ្ទាល់ដីដែលមានតែសសរតែមានរៀបជញ្ជាំង ផ្ទៃក្រឡាកម្រាលសំណង់គម្របជណ្ដើរ ផ្ទៃក្រឡាកម្រាលសំណង់លំហក្រោមដំបូលដែលមានកម្ពស់តិចជាង១,៨០(មួយក្បៀសប្រាំបី)ម៉ែត្រ ផ្ទៃក្រឡាលំហផ្ដល់ពន្លឺ សួនច្បារខាងក្នុងអគារ និងផ្ទៃក្រឡាកម្រាលសំណង់ដែលបម្រើសុខុមាលភាពសហគមន៍ក្នុងអគារលំនៅឋាន។

ការគណនាសន្ទស្សន៍ប្រើប្រាស់ដី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្លង់សន្ទស្សន៍ប្រើប្រាស់ដីនៃរាជធានីនិងក្រុង ស្រុក ខណ្ឌ ត្រូវផ្ដួចផ្ដើមរៀបចំដូចនីតិវិធីនៃប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី និងសម្រេចដាក់ឱ្យប្រើប្រាស់ដោយសេចក្ដីសម្រេចរបស់ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

**មាត្រា២៩ .-**

ក្នុងករណីដែលម្ចាស់សំណង់ស្នើសុំសាងសង់លើសពីកម្រិតអតិបរមានៃសន្ទស្សន៍ប្រើប្រាស់ដីដូចបានចែងក្នុងមាត្រា២២និងមាត្រា២៦នៃអនុក្រឹត្យនេះ ម្ចាស់សំណង់ត្រូវបង់ប្រាក់ជូនរដ្ឋជាមុន។ ថវិកាដែលបានមកពីការបង់ប្រាក់ពីការសាងសង់លើសសន្ទស្សន៍នៃការប្រើប្រាស់ដីនេះមួយចំណែកត្រូវបង់ចូលថវិការដ្ឋ មួយចំណែកទៀតត្រូវផ្ដល់ជូនទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមួយចំណែកទៀតត្រូវផ្ដល់ជូនរដ្ឋបាលថ្នាក់ក្រោមជាតិដែលសំណង់នោះតាំងនៅ។

ចំនួនទឹកប្រាក់ដែលត្រូវបង់ជូនរដ្ឋនិងការបែងចែកថវិកា ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ការស្នើសុំសាងសង់លើសពីកម្រិតអតិបរមានៃសន្ទស្សន៍ប្រើប្រាស់ដីដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើមិនត្រូវបានអនុញ្ញាតជូនឡើយ ក្នុងករណីការស្នើសុំសាងសង់នោះមានផលប៉ះពាល់ជាអវិជ្ជមានដល់សុវត្ថិភាព សុខុមាលភាព សោភណភាព សណ្ដាប់ធ្នាប់សាធារណៈ សុខដុមនីយកម្ម និងបរិស្ថាន។

**មាត្រា៣០ .-**

កម្ពស់អគារនៅទីក្រុង ត្រូវកំណត់ដោយផ្អែកលើមូលដ្ឋានតំបន់ ប្រភេទអគារ ទំហំដីឡូត៍ ទំហំទទឹងផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលសំណង់នោះតាំងនៅ និងលើលក្ខខណ្ឌសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន ភូមិសាស្ត្រ វប្បធម៌ ជាសុកភាព សុខភាព និងសោភណភាព ស្របតាមទីតាំងភូមិសាស្ត្រជាក់ស្ដែងរបស់ខ្លួន និងអនុវត្តតាមវិធីសាស្ត្រណាមួយ ដូចខាងក្រោម៖

១- វិធីសាស្ត្រទី១ : ការកំណត់កម្ពស់ជាម៉ែត្រ ឬ

- អគារកម្ពស់ទាប ត្រូវបានកំណត់កម្ពស់អតិបរមាត្រឹមជាន់ផ្ទាល់ដី ជាន់ទី១ និងជាន់ទី២
- អគារកម្ពស់មធ្យម ត្រូវបានកំណត់កម្ពស់ចាប់ពីជាន់ទី៣ដល់ជាន់ទី១១
- អគារកម្ពស់ខ្ពស់ ត្រូវបានកំណត់កម្ពស់ចាប់ពីជាន់ទី១២ឡើងទៅ។

២- វិធីសាស្ត្រទី២ : ការកំណត់កម្ពស់តាមសន្ទស្សន៍ប្រើប្រាស់ដី ឬ

- ការកំណត់កម្ពស់តាមសន្ទស្សន៍ប្រើប្រាស់ដី ដូចមានចែងនៅក្នុងមាត្រា២២ មាត្រា២៦ និង មាត្រា២៧ នៃអនុក្រឹត្យនេះ។

៣- វិធីសាស្ត្រទី៣ : ការកំណត់កម្ពស់តាមប្លង់ទ្រេត ឬ

- អគារកម្ពស់ទាប ត្រូវបានអនុវត្តក្នុងករណីដែលទំហំទទឹងផ្លូវតូចជាងឬស្មើ៩(ប្រាំបួន)ម៉ែត្រ ដោយកម្ពស់អតិបរមាត្រឹមប្លង់ទ្រេត តាមសមាមាត្ររវាងកម្ពស់អគារ និងទំហំទទឹងផ្លូវ ជាមួយនឹងធ្លាគម្លាត ស្មើនឹងចំនួន (ក)
- អគារកម្ពស់មធ្យម ត្រូវបានកំណត់កម្ពស់អតិបរមាត្រឹមប្លង់ទ្រេត តាមសមាមាត្ររវាងកម្ពស់អគារ និងទំហំទទឹងផ្លូវ ជាមួយនឹងធ្លាគម្លាត ស្មើនឹងចំនួន (ខ)
- អគារកម្ពស់ខ្ពស់ ត្រូវបានកំណត់កម្ពស់អតិបរមាត្រឹមប្លង់ទ្រេត តាមសមាមាត្ររវាងកម្ពស់អគារ និងទំហំទទឹងផ្លូវ ជាមួយនឹងធ្លាគម្លាត ស្មើនឹងចំនួន (គ)។

៤- វិធីសាស្ត្រទី៤ : ការកំណត់កម្ពស់អគារ ដោយប្រើប្រាស់វិធីសាស្ត្រខាងលើពីរឬបីរួមគ្នា។

កម្ពស់អតិបរមានិងអប្បបរមាតាមជាន់នីមួយៗនៃអគារ ត្រូវកំណត់ក្នុងប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ស្របទៅតាមប្រភេទនៃការប្រើប្រាស់អគារ និងតាមទីតាំងភូមិសាស្ត្រ។ ទោះជាយ៉ាងណាកម្ពស់អគារអប្បបរមាសម្រាប់មួយជាន់ៗកំណត់ត្រឹម២,៨ម៉ែត្រ សម្រាប់អគារស្នាក់នៅ។

ប្លង់កម្ពស់អគារនៃរាជធានី និងក្រុង ស្រុក ខណ្ឌ ត្រូវផ្តួចផ្តើមរៀបចំ ដូចនីតិវិធីនៃប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី និងសម្រេចដាក់ឱ្យប្រើប្រាស់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

ចំនួន (ក) (ខ) និង(គ) នឹងត្រូវកំណត់ដាក់ឱ្យប្រើប្រាស់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

ការកំណត់កម្ពស់នៃអគារ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣១ .-**

ធ្លាគម្លាតអគារក្នុងដីឡូត៍ពីព្រំដីកាន់កាប់ស្របច្បាប់ ត្រូវបានកំណត់ដូចខាងក្រោម៖

ចំពោះទីតាំងដែលមានប្លង់ធ្លាគម្លាតស្រាប់ បទប្បញ្ញត្តិប្រើប្រាស់ដីត្រូវកំណត់ធ្លាគម្លាតអគារក្នុងដីឡូត៍ពីព្រំដីកាន់កាប់ស្របច្បាប់ ស្របតាមប្លង់តម្រង់ជួរមានស្រាប់ស្របច្បាប់ ឬតាមផែនការប្រើប្រាស់ដីដែលបានធ្វើការព្យាករសម្រាប់លទ្ធភាពពង្រីកផ្លូវ នាពេលអនាគត។

ចំពោះទីតាំងដែលពុំមានប្លង់ធ្លាគម្លាតស្រាប់ បទប្បញ្ញត្តិប្រើប្រាស់ដីត្រូវកំណត់ធ្លាគម្លាតអគារក្នុងដីឡូត៍ពីព្រំដីកាន់កាប់ស្របច្បាប់ ស្របតាមបទដ្ឋានដូចខាងក្រោម៖

១- អគារកម្ពស់ទាប
- ធ្លាគម្លាតខាងមុខយ៉ាងតិច៤(បួន)ម៉ែត្រ។ គម្លាតនេះ អាចកំណត់យ៉ាងតិច២(ពីរ)ម៉ែត្រ ក្នុងករណីចាំបាច់នៃតំបន់ពាណិជ្ជកម្មនិងតំបន់ចម្រុះ និងក្នុងករណីសំណង់គ្មានជញ្ជាំង និងមានតែសសរ ហើយជាន់ផ្ទាល់ដីត្រូវបានប្រើប្រាស់សម្រាប់ថ្មើរជើងសាធារណៈ
- ធ្លាគម្លាតខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច២(ពីរ)ម៉ែត្រ។

២- អគារកម្ពស់មធ្យម
- ប្រភេទទី១ : អគារមានកម្ពស់ចាប់ពីជាន់ទី៣ដល់ជាន់ទី៨
- ធ្លាគម្លាតខាងមុខយ៉ាងតិច៤(បួន)ម៉ែត្រ។ គម្លាតនេះអាចកំណត់យ៉ាងតិច២(ពីរ)ម៉ែត្រ ក្នុងករណីចាំបាច់នៃតំបន់ពាណិជ្ជកម្មនិងតំបន់ចម្រុះ និងក្នុងករណីសំណង់គ្មានជញ្ជាំង និងមានតែសសរ ហើយជាន់ផ្ទាល់ដីត្រូវបានប្រើប្រាស់សម្រាប់ថ្មើរជើងសាធារណៈ
- ធ្លាគម្លាតខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច២(ពីរ)ម៉ែត្រ។

-ប្រភេទទី២ : អគារមានកម្ពស់ចាប់ពីជាន់ទី៩ដល់ជាន់ទី១១

- ធ្លាគម្លាតខាងមុខយ៉ាងតិច៥(ប្រាំ)ម៉ែត្រ។ គម្លាតនេះ អាចកំណត់យ៉ាងតិច២,៥(ពីរម៉ែត្រកន្លះ)ម៉ែត្រ ក្នុងករណីចាំបាច់នៃតំបន់ពាណិជ្ជកម្មនិងតំបន់ចម្រុះ និងក្នុងករណីសំណង់គ្មានជញ្ជាំងនិងមានតែសសរហើយជាន់ផ្ទាល់ដីត្រូវបានប្រើប្រាស់សម្រាប់ថ្មើរជើងសាធារណៈ

- ធ្លាគម្លាតខាងក្រោយនិងចំហៀងសងខាងយ៉ាងតិច២,៥(ពីរម៉ែត្រកន្លះ)ម៉ែត្រ។

ក្នុងតំបន់ពាណិជ្ជកម្មនិងតំបន់ចម្រុះ ត្រូវរៀបចំឲ្យមានច្រកផ្លូវដើរដែលមានដំបូលសមស្របឬក្នុងអគារសម្រាប់សាធារណៈ ដែលមានទំហំទទឹងយ៉ាងតិច២(ពីរ)ម៉ែត្រ ដើម្បីលើកទឹកចិត្តដល់ថ្មើរជើង។

បទដ្ឋានបច្ចេកទេសកំណត់គម្លាតអប្បបរមាក្នុងដីឡូត៍បន្ថែមពីការកំណត់ខាងលើ សម្រាប់ប្រភេទដីអាចសាងសង់បាន និងប្រភេទដីកម្រិតការសាងសង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

ប្លង់ធ្លាគម្លាតអគារនៃរាជធានីនិងក្រុង ស្រុក ខណ្ឌ ត្រូវផ្តួចផ្តើមរៀបចំ និងសម្រេចដាក់ឲ្យប្រើប្រាស់ដូចនីតិវិធីនៃប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី។

**មាត្រា៣២ .-**

បទដ្ឋានទំហំដីឡូត៍បច្ចេកទេស ត្រូវបានកំណត់ឡើង ដើម្បីជានាការរៀបចំផែនការរូបវន្តទីក្រុង ការគ្រប់គ្រងទីក្រុង ការអភិវឌ្ឍទីក្រុង ការអភិវឌ្ឍរចនាសម្ព័ន្ធ និងការអភិវឌ្ឍដី ឲ្យមានសោភណភាព មានសណ្តាប់ធ្នាប់ និងមានប្រសិទ្ធភាព។

ទំហំដីឡូត៍បច្ចេកទេសអប្បបរមា សម្រាប់តំបន់លំនៅឋាន ត្រូវបានកំណត់តាមប្រភេទ ដូចខាងក្រោម៖

១- តំបន់លំនៅឋានមានកម្ពស់ទាប

- តំបន់លំនៅឋានដាច់ពីគ្នា(ភូមិគ្រឹះឬពាក់កណ្តាលភូមិគ្រឹះ) មានទំហំដីយ៉ាងតិច១០ម x ២០ម
- តំបន់លំនៅឋានជាប់គ្នា(ផ្ទះល្វែងឬផ្ទះជាប់គ្នា) មានទំហំដីយ៉ាងតិច៤ម x ១៥ម។

២- តំបន់លំនៅឋានមានកម្ពស់មធ្យម

- ប្រភេទទី១(ពីជាន់ទី៣ដល់ជាន់ទី៨) មានទំហំដីយ៉ាងតិច១៥ម x ២៥ម
- ប្រភេទទី២(ពីជាន់ទី៩ដល់ជាន់ទី១១) មានទំហំដីយ៉ាងតិច២០ម x ៣០ម។

៣- តំបន់លំនៅឋានមានកម្ពស់ខ្ពស់

- ប្រភេទទី១(ពីជាន់ទី១២ដល់ជាន់ទី១៨) ទំហំដីឡូត៍ចាប់ពី១៥០០ម²ឡើងទៅ
- ប្រភេទទី២(ពីជាន់ទី១៩ឡើងទៅ) ទំហំដីឡូត៍ចាប់ពី៣០០០ម²ឡើងទៅ

ការកំណត់ទំហំដីឡូត៍បច្ចេកទេសខាងលើនេះ មិនយកមកអនុវត្តចំពោះទំហំដីឡូត៍ដែលមានរួចហើយ និងដែលមានទំហំតូចជាងការកំណត់ខាងលើនេះ។

ទំហំដីឡូត៍បច្ចេកទេសអប្បបរមា សម្រាប់តំបន់លំនៅឋានផ្សេងទៀត តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម និងតំបន់កសិកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣៣ .-**

ការប្តូរប្រភេទនៃការប្រើប្រាស់ដីពីប្រភេទដីកម្រិតការសាងសង់ទៅជាប្រភេទដីអាចសាងសង់បាន ត្រូវធ្វើតាមរយៈ៖

- ការផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលក្នុងការបង្កើតឲ្យមានទីក្រុងឬទីប្រជុំជនថ្មី និងផែនការអភិវឌ្ឍក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា

- ការផ្តួចផ្តើមរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ក្នុងទស្សនៈជំនាញ ដើម្បីបំពេញតម្រូវការនៃកំណើនប្រជាជន ការអភិវឌ្ឍសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គមកិច្ច
- ការផ្តួចផ្តើមរបស់អាជ្ញាធររាជធានី ខេត្ត និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត អាស្រ័យតាមតម្រូវការនៃកំណើនប្រជាជន ដែលមានដង់ស៊ីតេប្រជាជនក្នុងប្រភេទដីអាចសាងសង់បាន លើសពីកម្រិតអតិបរមា ដូចមានចែងក្នុងមាត្រា២៣
- ការស្នើសុំរបស់ម្ចាស់ដីឬអ្នកវិនិយោគ ក្នុងគោលបំណងធ្វើការអភិវឌ្ឍដីពិតប្រាកដ និងស្របតាមលក្ខណៈបច្ចេកទេសនៃនគរូបនីយកម្ម។

ការស្នើសុំប្តូរប្រភេទនៃការប្រើប្រាស់ដី ពីប្រភេទដីកម្រិតការសាងសង់មកជាប្រភេទដីអាចសាងសង់បាន អាចធ្វើទៅបាន លុះត្រាតែមានការធ្វើផែនការប្រើប្រាស់ដីសម្រាប់ដីដែលសុំប្តូរ និងផែនការរចនាសម្ព័ន្ធរូបវន្តសាធារណៈឲ្យបានច្បាស់លាស់និងបានយល់ព្រមពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

ដើម្បីស្នើសុំប្តូរប្រភេទនៃការប្រើប្រាស់ដី សាមីសំណើត្រូវរៀបចំគម្រោងផែនការមេអភិវឌ្ឍ និងសាងសង់ឲ្យមានផ្ទៃដីសម្រាប់បណ្តាញផ្លូវថ្នល់ ឲ្យបានយ៉ាងតិច២៥(ម្ភៃប្រាំ)ភាគរយនៃផ្ទៃដីសរុបក្នុងប្រភេទដីអាចសាងសង់បាន និងផ្ទៃក្រឡាលំហសាធារណៈនិងផ្ទៃបៃតង១០(ដប់)ភាគរយនៃផ្ទៃដីសរុបឬ១០(ដប់)ម៉ែត្រក្រឡា សម្រាប់មនុស្សម្នាក់។

ការប្តូរប្រភេទនៃការប្រើប្រាស់ដីដែលទាក់ទងនឹងដីរដ្ឋ ត្រូវអនុវត្តតាមច្បាប់ នីតិវិធី និងបទដ្ឋានគតិយុត្តជាធរមាន។

នីតិវិធីនិងបែបបទនៃការរៀបចំឯកសារស្នើសុំប្តូរប្រភេទនៃការប្រើប្រាស់ដី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣៤ .-**

ចំនួនចំណតរថយន្តសម្រាប់អគារក្នុងដីឡូត៍ ត្រូវមានគ្រប់គ្រាន់តាមតម្រូវការនៃប្រភេទអគារនីមួយៗ ហើយត្រូវស្ថិតនៅក្រៅពីផ្លូវសាធារណៈ និងទីតាំងសាធារណៈ។

ចំនួនចំណតរថយន្តអប្បបរមាសម្រាប់អគារក្នុងដីឡូត៍ ត្រូវបានកំណត់ដូចខាងក្រោម៖

១- អគារលំនៅឋានរួមមាន៖

| | | |
|---|---|---|
| - លំនៅឋានដាច់(ភូមិគ្រឹះ និង ពាក់កណ្តាលភូមិគ្រឹះ) | ផ្ទៃក្រឡាកម្រាល១០០ម² | ត្រូវមានចំណតរថយន្តតូច១កន្លែង |
| - លំនៅឋានជាប់(ផ្ទះល្វែង និង ផ្ទះជាប់គ្នា) | ផ្ទៃក្រឡាកម្រាល១២០ម² | ត្រូវមានចំណតរថយន្តតូច១កន្លែង |
| - អគារស្នាក់នៅរួមប្រភេទប្រណីត | ផ្ទៃក្រឡាកម្រាល១០០ម² | ត្រូវមានចំណតរថយន្តតូច១កន្លែង |
| - អគារស្នាក់នៅរួមប្រភេទមធ្យម | ផ្ទៃក្រឡាកម្រាល១២០ម² | ត្រូវមានចំណតរថយន្តតូច១កន្លែង |
| - អគារស្នាក់នៅរួមប្រភេទធម្មតា | ផ្ទៃក្រឡាកម្រាល១៥០ម² | ត្រូវមានចំណតរថយន្តតូច១កន្លែង។ |

២- អគារពាណិជ្ជកម្ម រួមមាន៖

| | | |
|---|---|---|
| - ភោជនីយដ្ឋាន ភេសជ្ជដ្ឋាន និងក្លឹបកម្សាន្ត | ផ្ទៃក្រឡាកម្រាល២០ម² | ត្រូវមានចំណតរថយន្តតូច១កន្លែង |
| | និងផ្ទៃក្រឡាកន្លែងរាំ១ម² | ត្រូវមានចំណតរថយន្តតូច១កន្លែង |
| - ផ្សារទំនើប | ផ្ទៃក្រឡាកម្រាល៥០ម² | ត្រូវមានចំណតរថយន្តតូច១កន្លែង |
| - ផ្សារ ឬ កន្លែងលក់ដូរ | ផ្ទៃក្រឡាកម្រាល៥០ម² | ត្រូវមានចំណតរថយន្តតូច១កន្លែង |

- អគារពាណិជ្ជកម្មផ្សេងៗ ផ្ទៃក្រឡាកម្រាល៥០ម² ត្រូវមានចំណតរថយន្តតូច១កន្លែង។

៣- អគារឧស្សាហកម្ម រួមមាន៖

- អគាររោងចក្រ ផ្ទៃក្រឡាកម្រាល២៥០ម² ត្រូវមានចំណតរថយន្តតូច១កន្លែង និងក្រឡាផ្ទៃកម្រាល១២៥០ម²ត្រូវមានចំណតរថយន្តធំ១កន្លែង
- អគារឃ្លាំងផ្ទុកទំនិញផ្ទាល់ខ្លួន ផ្ទៃក្រឡាកម្រាល៤០០ម²ត្រូវមានចំណតរថយន្តតូច១កន្លែង និង ផ្ទៃក្រឡាកម្រាល២០០០ម²ត្រូវមានចំណតរថយន្តធំ១កន្លែង។

៤- អគារសិក្សាធិការ អប់រំ និងកីឡា រួមមាន៖

- អគារគ្រឹះស្ថានឧត្តមសិក្សា ផ្ទៃក្រឡាកម្រាល១០០ម² ត្រូវមានចំណតរថយន្តតូច១កន្លែង
- អគារគ្រឹះស្ថានមធ្យមសិក្សា ផ្ទៃក្រឡាកម្រាល២០០ម² ត្រូវមានចំណតរថយន្តតូច១កន្លែង
- អគារគ្រឹះស្ថានបឋមសិក្សា ផ្ទៃក្រឡាកម្រាល៣០០ម² ត្រូវមានចំណតរថយន្តតូច១កន្លែង
- មជ្ឈមណ្ឌលកីឡា ផ្ទៃក្រឡាកម្រាល១០០ម² ត្រូវមានចំណតរថយន្តតូច១កន្លែង។

៥- អគារសុខភាព រួមមាន៖

- អគារមន្ទីរពេទ្យ ផ្ទៃក្រឡាកម្រាល១០០ម² ត្រូវមានចំណតរថយន្តតូច១កន្លែង
- ក្លឹបហាត់ប្រាណនិងសុខភាព ផ្ទៃក្រឡាកម្រាល១២០ម² ត្រូវមានចំណតរថយន្តតូច១កន្លែង។

៦- អគារសាលមហោស្រព សាលប្រជុំ ពិធី និងរោងភាពយន្ត រួមមាន៖

- អគារមហោស្រព រោងភាពយន្ត សាលជួបជុំ និងពិធី ផ្ទៃក្រឡាកម្រាល៣០ម² ត្រូវមានចំណតរថយន្តតូច១កន្លែង និងផ្ទៃក្រឡាកម្រាល៣០០ម²ត្រូវមានចំណតរថយន្តធំ១កន្លែង។

៧- អគារសណ្ឋាគារនិងផ្ទះសំណាក់ រួមមាន៖

- អគារសណ្ឋាគារ ចំនួនបន្ទប់៥បន្ទប់ ត្រូវមានចំណតរថយន្តតូច១កន្លែង និងចំនួនបន្ទប់៣០បន្ទប់ ត្រូវមានចំណតរថយន្តធំ១កន្លែង
- អគារផ្ទះសំណាក់ ចំនួនបន្ទប់១០បន្ទប់ ត្រូវមានចំណតរថយន្តតូច១កន្លែង និងចំនួនបន្ទប់៣០បន្ទប់ ត្រូវមានចំណតរថយន្តធំ១កន្លែង។

៨- អគារការិយាល័យសាធារណៈនិងការិយាល័យឯកជន រួមមាន៖

- អគាររដ្ឋបាលនិងការិយាល័យឯកជន ផ្ទៃក្រឡាកម្រាល ១០០ម² ត្រូវមានចំណតរថយន្តតូច១កន្លែង។

៩- ស្ថានីយប្រេងឥន្ធនៈ រួមមាន៖

- ស្ថានីយប្រេងឥន្ធនៈ ផ្ទៃក្រឡាកម្រាល១០ម² ត្រូវមានចំណតរថយន្តតូច១កន្លែង និងផ្ទៃក្រឡាកម្រាល១០០ម²ត្រូវមានចំណតរថយន្តធំ១កន្លែង។

១០- អគារការិយាល័យដឹកជញ្ជូន រួមមាន៖

- អគារការិយាល័យដឹកជញ្ជូន ផ្ទៃក្រឡាកម្រាល១០០ម² ត្រូវមានចំណតរថយន្តតូច១កន្លែង និងផ្ទៃក្រឡាកម្រាល៥០០ម²ត្រូវមានចំណតរថយន្តធំ១កន្លែង។

១១- អគារផ្សេងៗរួមមាន៖

- អគារផ្សេងៗ ផ្ទៃក្រឡាកម្រាល១៥០ម² ត្រូវមានចំណតរថយន្តតូច១កន្លែង និងផ្ទៃក្រឡាកម្រាល៥០០ម²ត្រូវមានចំណតរថយន្តធំ១កន្លែង។

ចំនួនចំណតរថយន្តសម្រាប់អគារក្នុងដីឡូត៍ដែលបានកំណត់ខាងលើនេះ ជាចំនួនអប្បបរមាដែលត្រូវមានជាចាំបាច់ សម្រាប់ការអភិវឌ្ឍនិងការសាងសង់នៅព្រះរាជាណាចក្រកម្ពុជា។ ក្នុងការគណនា បើលទ្ធផលជាចំនួនទសភាគ ចំនួនចំណតនេះត្រូវយកចំនួនគត់ដែលមានតម្លៃធំជាងបន្ទាប់នៃលទ្ធផល។

ក្នុងករណីអគារបម្រើមុខងារចម្រុះ ការគណនាចំនួនចំណតរថយន្តសម្រាប់អគារក្នុងដីឡូត៍ ត្រូវគណនាតាមប្រភេទមុខងារនីមួយៗ ហើយបូកសរុបបញ្ចូលគ្នា ទើបទទួលបានចំនួនចំណតសរុប សម្រាប់អគារទាំងមូល។

ការរៀបចំចំណតយានយន្តនៅទីសាធារណៈនិងឯកជនត្រូវមានចំណតសម្រាប់ជនពិការនិងជនងាយរងគ្រោះ។

បទដ្ឋានចំណតយានយន្ត ទំហំចំណត និងលក្ខណៈបច្ចេកទេសសម្រាប់ចំណតក្នុងដីឡូត៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ចំពោះបទដ្ឋានកំណត់ទីតាំងចំណតយានយន្តនិងទំហំចំណតសម្រាប់ចំណតសាធារណៈក្នុងរាជធានី ក្រុង និងទីប្រជុំជន ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

ការចេញលិខិតអនុញ្ញាតសាងសង់ណាមួយចំពោះប្រភេទអគារខាងលើ ត្រូវគោរពតាមបទប្បញ្ញត្តិចំនួនចំណតអប្បបរមានៃមាត្រា៣៣នេះ។

## ជំពូកទី៦

## ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់ផ្តល់សេវាជូនសាធារណជន និងលំហសាធារណៈ

**មាត្រា៣៥ .-**

ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់ផ្តល់សេវាជូនសាធារណជន និងលំហសាធារណៈមានដូចខាងក្រោម៖

១- ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ រួមមាន៖

- បណ្តាញផ្លូវសាធារណៈ
- បរិក្ខារសាធារណៈ ដូចជាប្រព័ន្ធទឹកស្អាត ប្រព័ន្ធលូបង្ហូរទឹកកខ្វក់ លូទឹកភ្លៀង បណ្តាញអគ្គិសនី បណ្តាញទូរគមនាគមន៍។ល។
- ប្រព័ន្ធគ្រប់គ្រងកាកសំណល់រឹងនិងរាវ ដូចជា ទីលានចាក់សំរាម រោងចក្រកែច្នៃសំរាម ប្រព័ន្ធលូអាងប្រព្រឹត្តកម្មទឹកកខ្វក់។ល។
- ប្រព័ន្ធគ្រប់គ្រងអគ្គិភ័យនិងហានិភ័យផ្សេងៗ។

២- សំណង់សម្រាប់ផ្តល់សេវាជូនសាធារណជនរួមមាន៖

- អគាររដ្ឋបាលសាធារណៈ អគារសិក្សាសាធារណៈ មន្ទីរពេទ្យសាធារណៈ
- ចំណតយានយន្តសាធារណៈ ចំណតរថយន្តក្រុង ចំណតរថយន្តឈ្នួល ស្ថានីយរថភ្លើងសម្រាប់អ្នកដំណើរ ស្ថានីយចែកចាយទំនិញ ផែស្ងួត មជ្ឈមណ្ឌលផ្គត់ផ្គង់ភស្តុភាកម្ម។ល។ ត្រូវរៀបចំសម្រាប់មនុស្សទូទៅនិងជនពិការ និងមិនត្រូវស្ថិតនៅលើចិញ្ចើមផ្លូវសាធារណៈសម្រាប់ថ្មើរជើងឡើយ។

៣- លំហសាធារណៈរួមមាន៖

- សួនច្បារសាធារណៈ កន្លែងក្មេងលេង កន្លែងហាត់ប្រាណ ទីលានកីឡា ទីលានកម្សាន្ត។

ការរៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់ផ្តល់សេវាជូនសាធារណជននិងលំហសាធារណៈ ត្រូវរៀបចំសម្រាប់មនុស្សទូទៅរួមទាំងជនពិការនិងជនងាយរងគ្រោះ។

នៅពេលដំណើរការអនុវត្តគម្រោងអភិវឌ្ឍនានា ដើម្បីផលប្រយោជន៍សាធារណៈដែលប៉ះពាល់ដល់កម្មសិទ្ធិឯកជនស្របច្បាប់ ការដកហូតកម្មសិទ្ធិមួយផ្នែកឬទាំងស្រុង ត្រូវអនុវត្តតាមច្បាប់អស្សាមិករណ៍។

**មាត្រា៨៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**អ៊ឹម ឈុនលឹម**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៨៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ: ១៤៤៩ ដនស

ថ្ងៃ ចន្ទ ១០កើត ខែជេស្ឋ ឆ្នាំរកា ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមិថុនា គ.ស. ២០១៧

**ជម្រាបមក**

**លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត**

**កម្មវត្ថុ:** ការកំណត់ឆ្លាតម្លាតនគរូបនីយកម្មចំពោះសំណង់មានកម្ពស់ខ្ពស់

**យោង:** -អនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់

-អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **លោកប្រធានមន្ទីរ** ជ្រាបថា ដើម្បីធានាបាន គុណភាព ប្រសិទ្ធភាព និងចីរភាពនៃការអភិវឌ្ឍនគរូបនីយកម្ម ក្រសួងសូមណែនាំបន្ថែមអំពីការកំណត់ឆ្លាតម្លាតនគរូបនីយកម្មចំពោះសំណង់ដែលមានកម្ពស់ខ្ពស់ស្ថិតនៅតាមបណ្តោយមហាវិថីនៃរាជធានី ក្រុង និងទីប្រជុំជន ដូចខាងក្រោម÷

**១-ប្រភេទទី ១ : អគារមានកម្ពស់ចាប់ពីជាន់ទី ៣១ឡើងទៅ** : ត្រូវរក្សាឆ្លាតម្លាតខាងមុខយ៉ាងតិច ១០ (ដប់) ម៉ែត្រ និងឆ្លាតម្លាតខាងក្រោយ និងចំហៀងសងខាងយ៉ាងតិច ៤ (បួន)ម៉ែត្រ។

**២-ប្រភេទទី ២ : អគារមានកម្ពស់ចាប់ពីជាន់ទី ២១ ដល់ជាន់ទី ៣០** : ត្រូវរក្សាឆ្លាតម្លាតខាងមុខយ៉ាងតិច ៨ (ប្រាំបី) ម៉ែត្រ និងឆ្លាតម្លាតខាងក្រោយ និងចំហៀងសងខាងយ៉ាងតិច ៣,៥ (បីម៉ែត្រកន្លះ)។

**៣-ប្រភេទទី ៣ : អគារមានកម្ពស់ចាប់ពីជាន់ទី ១២ ដល់ជាន់ទី ២០** : ត្រូវរក្សាឆ្លាតម្លាតខាងមុខយ៉ាងតិច ៦ (ប្រាំមួយ) ម៉ែត្រ និងឆ្លាតម្លាតខាងក្រោយ និងចំហៀងសងខាងយ៉ាងតិច ៣ (បី)ម៉ែត្រ។

អាស្រ័យហេតុនេះ សូម **លោកប្រធានមន្ទីរ** ចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់**

ជា សុផារ៉ា

**<u>កន្លែងទទួល</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- គ្រប់សាលារាជធានី ខេត្ត
- គ្រប់អគ្គនាយកដ្ឋានជំនាញ និងអគ្គាធិការដ្ឋាននៃក្រសួងដនស "ដើម្បីជូនជ្រាប"
- ឯកសារ កាលប្បវត្តិ

អាសយដ្ឋាន : ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ។
ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានីភ្នំពេញ
លេខ : ០០៧/១៧ សណន.ច

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០១៧

## សេចក្តីណែនាំ
## ស្តីពី
## ការដោះស្រាយចរាចរណ៍ និងរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ

ក្នុងរយៈពេលកន្លងមកនេះ រដ្ឋបាលរាជធានីភ្នំពេញពិនិត្យឃើញថា បងប្អូនប្រជាពលរដ្ឋមួយចំនួនដែលជាម្ចាស់លំនៅដ្ឋាន ម្ចាស់សហគ្រាស ម្ចាស់ហាង ម្ចាស់អាជីវកម្ម មន្ទីរពេទ្យ សាលារៀន ស្ថាប័នរដ្ឋ និងគ្រឹះស្ថានឯកជនផ្សេងទៀត បាននឹងកំពុងប្រើប្រាស់ទ្រូងផ្លូវ ចិញ្ចើមផ្លូវ និងដាយផ្លូវមិនទាន់បានសមស្របទាំងស្រុង ឬដោយបំពានលើបទប្បញ្ញត្តិច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន ជាពិសេសបំពានលើបទប្បញ្ញត្តិមួយចំនួននៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ និងបទដ្ឋានគតិយុត្តដែលអនុវត្តក្នុងវិស័យនគរូបនីយកម្ម និងសំណង់។ អំពើរំលោភបំពានទាំងនោះមានជាអាទិ៍ ការយកទ្រូងផ្លូវ ចិញ្ចើមផ្លូវ និងដាយផ្លូវធ្វើជាចំណតយានជំនិះ ការតសំយ៉ាប ការហ៊ុំព័ទ្ធយកចិញ្ចើមផ្លូវ ការយកផ្លូវថ្មើរជើង ឬចិញ្ចើមផ្លូវធ្វើទីតាំងការដ្ឋានទុកដាក់សម្ភារៈ ឬដាក់តាំងបង្ហាញទំនិញ ឬប្រកបអាជីវកម្ម ផ្សេងៗជាលក្ខណៈឯកជន ដែលបង្កឱ្យមានការកកស្ទះចរាចរណ៍ និងជះឥទ្ធិពលអវិជ្ជមានដល់សណ្តាប់ធ្នាប់សាធារណៈ និងសោភណភាពរាជធានីភ្នំពេញ។

អនុវត្តតាមស្មារតីនៃកិច្ចប្រជុំគណៈបញ្ជាការឯកភាពកាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៧ រដ្ឋបាលរាជធានីភ្នំពេញសម្រេចជ្រើសយកផ្លូវសំខាន់ៗចំនួន ១១ខ្សែ ធ្វើជាអាទិភាពគំរូ សម្រាប់អនុវត្តវិធានការដោះស្រាយចរាចរណ៍ និងរៀបចំសណ្តាប់ធ្នាប់សាធារណៈ មុននឹងបន្តអនុវត្តចំពោះបណ្តាទីតាំងផ្សេងៗទៀតក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ។ ផ្លូវអាទិភាពគំរូទាំងនោះរួមមាន៖ ១- មហាវិថីសហព័ន្ធរុស្ស៊ី, ២- មហាវិថីព្រះមុនីវង្ស, ៣- មហាវិថីកម្ពុជាក្រោម, ៤- មហាវិថីម៉ៅសេទុង, ៥- មហាវិថីព្រះសីហនុ និងមហាវិថីនេរុហ៍, ៦- មហាវិថីព្រះនរោត្តម, ៧- មហាវិថីសម្តេចមុនីរ៉េត, ៨- ផ្លូវឧកញ៉ាទេពផន, ៩- មហាវិថីហ្សាលនីហ្គោល, ១០- មហាវិថីយោធពលខេមរភូមិន្ទ (ផ្លូវ២៧១) និងផ្លូវឧកញ៉ាឃ្លាំងមឿង (ផ្លូវលេខ៧០) និង ១១- តិវិថីព្រះស៊ីសុវត្ថិ។

ដូចនេះ ដើម្បីដោះស្រាយចរាចរណ៍ និងរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវអាទិភាពខាងលើ រដ្ឋបាលរាជធានីភ្នំពេញ ដាក់ចេញនូវសេចក្តីណែនាំដូចខាងក្រោម៖

**ក. ចំពោះបងប្អូនប្រជាពលរដ្ឋ ម្ចាស់លំនៅដ្ឋាន ម្ចាស់អាជីវកម្មដ្ឋាន ម្ចាស់ការដ្ឋាន មន្ទីរពេទ្យ សាលារៀនវិស័យឯកជន អគារសាធារណៈ និងអ្នកប្រើប្រាស់ផ្លូវថ្នល់ ត្រូវអនុវត្តដូចខាងក្រោម៖**

១. ហាមចតយានយន្តគ្រប់ប្រភេទនៅលើទ្រូងផ្លូវ។

៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

២. ហាមដាច់ខាតមិនឱ្យម្ចាស់ការដ្ឋានសំណង់គ្រប់ប្រភេទ ធ្វើការហ៊ុំមព័ទ្ធការដ្ឋានលើចិញ្ចើមផ្លូវលើសពី១/៣ (មួយភាគបី) និងឬប្រើប្រាស់ទ្រូងផ្លូវដើម្បីទុកដាក់សម្ភារៈសំណង់របស់ខ្លួន ដូចជា ដែក ខ្សាច់ គ្រួស ថ្ម ជាដើម។

៣. រថយន្តដឹកទំនិញធំៗ រថយន្តកុងតឺន័រ រថយន្តបាញ់បេតុង និងរថយន្តក្រឡុកស៊ីម៉ង់ត៍ ត្រូវចេញ-ចូល គោរពតាមការណែនាំរបស់រដ្ឋបាលរាជធានីភ្នំពេញ និងចៀសវាងការប្រើប្រាស់ទ្រូងផ្លូវ ក្នុងការលើកដាក់ ផ្ទេរទំនិញ និងបាញ់បេតុង។ ក្នុងករណីចៀសវាងមិនបាន ត្រូវអនុវត្តការលើកដាក់ទំនិញ និងការបាញ់បេតុង ចាប់ពីម៉ោង២១:០០នាទី រហូតដល់ម៉ោង០៦:០០នាទីព្រឹក។

៤. ការរៀបចំសម្ភារៈ ទំនិញ ម៉ូតូ និងរថយន្តដាក់តាំងលក់ អាចប្រើប្រាស់ចំណែកចិញ្ចើមផ្លូវត្រឹម ១/៣ (មួយភាគបី) ជាលក្ខណៈបណ្ដោះអាសន្នតែប៉ុណ្ណោះ ដោយទុក២/៣ (ពីរភាគបី) សម្រាប់ថ្មើរជើង និងបម្រើឱ្យការងារសណ្ដាប់ធ្នាប់ និងចរាចរណ៍។

៥. រាល់ការប្រើប្រាស់ចិញ្ចើមផ្លូវជាទីតាំងផ្ញើកង់ ម៉ូតូ មិនត្រូវឱ្យលើសពី១/៣ (មួយភាគបី) ឡើយ។

**ខ. ចំពោះគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌទាំង១២ ត្រូវអនុវត្តដូចខាងក្រោម៖**

១. ត្រូវចុះធ្វើការអប់រំណែនាំដល់ប្រជាពលរដ្ឋ ដែលបាននឹងកំពុងប្រើប្រាស់ទ្រូងផ្លូវ ចិញ្ចើមផ្លូវដោយរំលោភបំពាន ដោយប្រើប្រាស់វិធីសាស្ត្រទន់ភ្លន់ តែម៉ឺងម៉ាត់ ឱ្យចូលរួមអនុវត្តតាមស្មារតីនៃសេចក្ដីណែនាំនេះ។ ក្នុងករណីនៅតែមិនអនុវត្តតាមការណែនាំនេះ មន្ត្រីអនុវត្តត្រូវធ្វើកំណត់ហេតុ និងចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន។

២. ត្រូវណែនាំដល់ម្ចាស់ទីតាំងភោជនីយដ្ឋាន និងម្ចាស់ទីតាំងអាជីវកម្មនានាឱ្យគោរពតាមខ្លឹមសារនៃសេចក្ដីណែនាំនេះ ក្នុងករណីពុំព្រមអនុវត្តតាម អាជ្ញាធរខណ្ឌត្រូវសហការជាមួយកម្លាំងមានសមត្ថកិច្ច និងជំនាញពាក់ព័ន្ធធ្វើការផាកពិន័យតាមច្បាប់ និងអាចឈានទៅបិទទីតាំងអាជីវកម្ម។

៣. ត្រូវធ្វើការណែនាំ និងធ្វើកំណត់ហេតុឱ្យបានត្រឹមត្រូវជាមួយម្ចាស់ការដ្ឋានដែលរំលោភបំពានទ្រូងផ្លូវ និងចិញ្ចើមផ្លូវ ក្នុងករណីមិនរាងចាល ត្រូវផ្អាកការដ្ឋាននោះភ្លាម។

៤. ត្រូវចុះល្បាត និងឃ្លាំមើលជាប្រចាំចំពោះរថយន្តដឹកទំនិញធំៗ រថយន្តកុងតឺន័រ រថយន្តបាញ់បេតុង និងរថយន្តក្រឡុកស៊ីម៉ង់ត៍ និងត្រូវមានវិធានការឱ្យបានម៉ឺងម៉ាត់ក្នុងករណីការចេញ-ចូលរាជធានីភ្នំពេញខុសពីសេចក្ដីណែនាំរបស់រដ្ឋបាលរាជធានីភ្នំពេញ។

៥. ត្រូវអនុវត្តការងារតាមការណែនាំខាងលើនេះ ឱ្យបានត្រឹមត្រូវ ហ្មត់ចត់ និងទន់ភ្លន់ និងត្រូវរាយការណ៍ប្រចាំសប្ដាហ៍អំពីលទ្ធផលនៃការងារនេះ មកគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានីភ្នំពេញឱ្យបានទៀងទាត់ និងទាន់ពេលវេលា។

**គ. ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ និងបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញត្រូវ៖**

១. បន្ថែមកម្លាំងនគរបាលចរាចរណ៍ ដោះស្រាយបញ្ហាចរាចរណ៍តាមគោលដៅដែលមានការកកស្ទះនៅចន្លោះម៉ោងមមាញឹក គឺម៉ោង ០៧:៣០នាទី ដល់ម៉ោង ០៨:៣០នាទី, ម៉ោង ១១:៣០នាទី ដល់ម៉ោង ១២:៣០នាទី និងម៉ោង ១៧:០០នាទី ដល់ម៉ោង ១៨:៣០នាទី។

២. រៀបចំរថយន្តស្ទូច ដើម្បីសហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌទាំង១២ ដើម្បីអនុវត្តវិធានការច្បាប់។

ទទួលបានសេចក្តីណែនាំនេះ ប្រជាពលរដ្ឋ គ្រឹះស្ថានឯកជន ស្ថាប័នសាធារណៈ និងអ្នកប្រើប្រាស់ផ្លូវ មានរយៈពេល ០២ (ពីរ)សប្តាហ៍ គិតចាប់ពីថ្ងៃចេញសេចក្តីណែនាំនេះ ដើម្បីធ្វើការកែសម្រួល និងរៀបចំទីតាំងរបស់ខ្លួនឱ្យស្របតាមស្មារតីនៃសេចក្តីណែនាំនេះ។

នាយករដ្ឋបាលសាលារាជធានីភ្នំពេញ អភិបាលខណ្ឌទាំង១២ ស្នងការនគរបាលរាជធានីភ្នំពេញ មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ បងប្អូនប្រជាពលរដ្ឋ អ្នកប្រើប្រាស់ផ្លូវទាំងអស់ត្រូវរួមអនុវត្តសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាព ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
  "ដើម្បីជូនជ្រាប"
- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
- រដ្ឋបាលខណ្ឌទាំង ១២
- មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីរាជធានីភ្នំពេញ
  "ដើម្បីអនុវត្ត"
- គ្រប់ប្រព័ន្ធផ្សព្វផ្សាយ
  "ដើម្បីជួយផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**

លេខ : ០១៣/១៩ សណន

# សេចក្តីណែនាំ

## ស្តីពី

## ការរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ និងការប្រើប្រាស់ចិញ្ចើមផ្លូវសាធារណៈទាំងអស់ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ

ក្រោយការដាក់ចេញនូវសេចក្តីណែនាំលេខ **០០៧/១៧ សណន.ច** ចុះថ្ងៃទី០៨ **ខែសីហា ឆ្នាំ២០១៧** ស្តីពី ការដោះស្រាយចរាចរណ៍ និងរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ដោយបានសម្រេចជ្រើសយកផ្លូវសំខាន់ៗចំនួន **១១ ខ្សែ** ដើម្បីធ្វើជាគំរូសម្រាប់អនុវត្តវិធានការរួចមក **រដ្ឋបាលរាជធានីភ្នំពេញ** កត់សម្គាល់ឃើញថា ជាបណ្តើរៗបងប្អូនប្រជាពលរដ្ឋ អ្នកប្រើប្រាស់ផ្លូវផ្ទាល់ និងភាគីពាក់ព័ន្ធទាំងអស់ បានយល់ដឹងអំពីព្រំដែននៃកម្មសិទ្ធិ និងអ្វីជាប្រយោជន៍សាធារណៈ ដោយបានកែប្រែទម្លាប់ និងឥរិយាបទនៃការប្រើប្រាស់ចិញ្ចើមផ្លូវសាធារណៈ ហើយងាកមកចូលរួមជាមួយអាជ្ញាធរមានសមត្ថកិច្ច ក្នុងការរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ និងទទួលបានការគាំទ្រពីមហាជនដ៏ច្រើនលើសលប់ **ដែលនេះ** គឺជាកម្លាំងចិត្តយ៉ាងធំធេងសម្រាប់រដ្ឋបាលរាជធានីភ្នំពេញ។

ចំពោះមុខ ដើម្បីពង្រីកវិសាលភាពនៃការអនុវត្ត ស្របតាម**មាត្រា ៥** និង**មាត្រា ២៩** នៃច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ឈានទៅរក្សាបានសណ្តាប់ធ្នាប់របៀបរៀបរយតាមដងផ្លូវ សម្រួលលំហូរចរាចរណ៍ លើកកម្ពស់សោភ័ណភាពទីក្រុង និងដើម្បីតម្រង់ទិសការប្រើប្រាស់ចិញ្ចើមផ្លូវក្នុងរាជធានីភ្នំពេញ ឱ្យចំទិសដៅសម្រាប់ប្រយោជន៍សាធារណៈ **រដ្ឋបាលរាជធានីភ្នំពេញ** សម្រេចដាក់ចេញនូវសេចក្តីណែនាំ ស្តីពីការរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ និងប្រើប្រាស់ចិញ្ចើមផ្លូវសាធារណៈទាំងអស់ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ដូចខាងក្រោម៖

### ១- គោលការណ៍ទូទៅ

ចិញ្ចើមផ្លូវ អាចយកទៅប្រើប្រាស់សម្រាប់បម្រើសកម្មភាពក្នុងគោលបំណង ដូចខាងក្រោម៖

- **ទី១៖** បម្រើដល់ការធ្វើចរាចរណ៍ដោយថ្មើរជើង។
- **ទី២៖** បម្រើសកម្មភាព ដូចជា សកម្មភាពវប្បធម៌ កីឡា ការតាំងពិព័រណ៍ និងពិធីបុណ្យផ្សេងទៀត នៅលើដងផ្លូវ ប៉ុន្តែត្រូវមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ទៅតាមកម្រិតនៃពិធី និងតាមភាពចាំបាច់។
- **ទី៣៖** បម្រើសកម្មភាពជីកកប់បណ្តាញក្រោមដី ដូចជា បណ្តាញទឹកស្អាត ប្រព័ន្ធលូ ខ្សែបញ្ជូនអគ្គិសនី បំពង់ទុយោ ខ្សែកាបអុបទិចគ្រប់ប្រភេទ និងបរិក្ខារក្រោមដីផ្សេងៗទៀត។



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

- **ទី៤៖** បម្រើសកម្មភាពសាងសង់ ក្នុងគម្រោងចាំបាច់មួយចំនួន ដូចជា បរិក្ខារបម្រើឱ្យវិស័យការពារជាតិ សន្តិសុខជាតិ បរិក្ខារបម្រើឱ្យការគ្រប់គ្រង ឬ ការសាងសង់ផ្លូវ និងបរិក្ខារសំណង់សេវាសាធារណៈផ្សេងៗទៀត តាមការចាំបាច់។

ក្រៅអំពីសកម្មភាពដូចបានរៀបរាប់ខាងលើ ការប្រើប្រាស់ចិញ្ចើមផ្លូវ ជាប្រយោជន៍ឯកជនទោះក្នុងគោលបំណងណាក៏ដោយ ត្រូវចាត់ទុកជាសកម្មភាពខុសច្បាប់ ប្រសិនបើពុំមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអាជ្ញាធរមានសមត្ថកិច្ច។

## ២- គោលដៅ និងវិសាលភាពអនុវត្ត

សេចក្តីណែនាំនេះ មានគោលដៅកំណត់អំពីវិធានការ នៃការរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ និងប្រើប្រាស់ចិញ្ចើមផ្លូវសាធារណៈទាំងអស់ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ដែលជាមុខងារជាជម្រើសរបស់រដ្ឋបាលរាជធានីភ្នំពេញ ក្នុងន័យដោះស្រាយបញ្ហាការកកស្ទះចរាចរណ៍ លើកកម្ពស់សោភ័ណភាពទីក្រុង និងធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ចិញ្ចើមផ្លូវ ទាំងផ្នែកខាងលើដី និងផ្នែកខាងក្រោមដី សម្រាប់បម្រើប្រយោជន៍សាធារណៈស្របតាមលក្ខណៈបច្ចេកទេស។

សេចក្តីណែនាំនេះ មានវិសាលភាពអនុវត្តចំពោះរាល់សកម្មភាពពាក់ព័ន្ធនឹងការរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ និងប្រើប្រាស់ចិញ្ចើមផ្លូវសាធារណៈទាំងអស់ ក្នុងនោះ រដ្ឋបាលខណ្ឌទាំង១២ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ ព្រមទាំងមន្ទីរ-អង្គភាពពាក់ព័ន្ធទាំងអស់ គឺជាសេនាធិការ របស់សាលារាជធានីភ្នំពេញ ក្នុងការអនុវត្តឱ្យមានប្រសិទ្ធភាពនូវសេចក្តីណែនាំនេះ។

## ៣-វិធានការនៃការអនុវត្ត

**ក-ចំពោះបងប្អូនប្រជាពលរដ្ឋ ម្ចាស់លំនៅឋាន ម្ចាស់អាជីវកម្មដ្ឋាន ម្ចាស់ការដ្ឋាន អ្នកគ្រប់គ្រងមន្ទីរពេទ្យ-គ្រឹះស្ថានអប់រំ-អគារសាធារណៈ វិស័យឯកជន និងអ្នកប្រើប្រាស់ផ្លូវផ្ទាល់ ត្រូវអនុវត្តដូចខាងក្រោម៖**

- ត្រូវចតយានជំនិះគ្រប់ប្រភេទ ដោយគោរពទៅតាមសញ្ញាចរាចរណ៍ផ្លូវគោកនៅតាមទីតាំងនីមួយៗ **ចៀសវាងដាច់ខាតការឈប់ ឬ ចតយានជំនិះនៅកន្លែងហាមឃាត់** ដូចជា នៅលើទ្រូងផ្លូវ-ចិញ្ចើមផ្លូវដែលទុកបម្រុងឱ្យថ្មើរជើង, លើមុខគំនូសឆ្នូតកាត់ទទឹងផ្លូវ, លើផ្លូវសម្រាប់ថ្មើរជើង, កន្លែងបម្រុងទុកសម្រាប់ការឈប់ ឬ ចតនៃយានប្រភេទខ្លះ, នៅគ្រប់ទីកន្លែងដែលធ្វើឱ្យរាំងស្ទះដល់ច្រកចេញ-ចូលការចត ឬ ការឈប់នៃយានដទៃទៀត, លើច្រកចេញ-ចូលនៃអគារសាធារណៈ ឬ កន្លែងឯកជន, ជិតផ្លូវប្រសព្វ ឬ ផ្លូវបត់, ការចតពីរជួរ ឬ ច្រើនជួរទន្ទឹមគ្នា និង នៅកន្លែងដែលមានសញ្ញាហាមឈប់ ឬ ហាមចត ជាដើម
- ហាមដាច់ខាតម្ចាស់ការដ្ឋានសំណង់គ្រប់ប្រភេទ ធ្វើការហ៊ុមព័ទ្ធការដ្ឋានលើចិញ្ចើមផ្លូវលើសពី **១/៣ (មួយភាគបី) និង/ឬ** ប្រើប្រាស់ទ្រូងផ្លូវទុកដាក់សម្ភារសំណង់របស់ខ្លួន ដូចជា ដែក ខ្សាច់ គ្រួស ថ្ម និងសម្ភារជាង ជាដើម
- រថយន្តដឹកទំនិញធុនធំ រថយន្តកុងទីន័រ រថយន្តបាញ់បេតុង និងរថយន្តក្រឡុកស៊ីម៉ង់ ត្រូវចេញ-ចូលរាជធានីភ្នំពេញ ដោយគោរពតាមការណែនាំរបស់រដ្ឋបាលរាជធានីភ្នំពេញ និងចៀសវាងការប្រើប្រាស់ទ្រូងផ្លូវក្នុងការលើកដាក់-ផ្ទេរទំនិញ បាញ់បេតុង ឬ ឈប់សំចតដោយអនាធិបតេយ្យ។ ក្នុងករណីចាំបាច់បម្រើឱ្យការងារសំណង់ **ម្ចាស់ការដ្ឋាន** ត្រូវណែនាំដល់អ្នកបើកបររថយន្តបាញ់បេតុង និងរថយន្តក្រឡុកស៊ីម៉ង់ ត្រូវចតរថយន្តរបស់ខ្លួនឱ្យមានសណ្តាប់ធ្នាប់ ដាក់ផ្លាកសញ្ញាសម្គាល់ការដ្ឋាន និងត្រូវរៀបចំកម្លាំងដើម្បីជួយសម្រួលចរាចរណ៍



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

- ការរៀបចំសម្ភារ ទំនិញ ម៉ូតូ និងរថយន្តដាក់តាំងលក់ អាចប្រើប្រាស់ចិញ្ចើមផ្លូវត្រឹម **១/៣ (មួយភាគបី)** ជាលក្ខណៈបណ្ដោះអាសន្នតែប៉ុណ្ណោះ ដោយទុក **២/៣ (ពីរភាគបី)** សម្រាប់ថ្មើរជើង និងបម្រើឱ្យការងារសណ្ដាប់ធ្នាប់ និងចរាចរណ៍
- រាល់ការប្រើប្រាស់ចិញ្ចើមផ្លូវជាទីតាំងផ្ញើរកង់ម៉ូតូ មិនត្រូវឱ្យលើសពី **១/៣ (មួយភាគបី)** នៃចិញ្ចើមផ្លូវឡើយ
- ចំពោះការធ្វើរោងបុណ្យ រោងអាពាហ៍ពិពាហ៍ និងរោងកម្មវិធីផ្សេងៗ ៖
    + ក្នុងដំណាក់កាលនេះ **រដ្ឋបាលរាជធានីភ្នំពេញ** ទុករយៈពេលសម្បទានត្រឹម**ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩** ជូនបងប្អូនប្រជាពលរដ្ឋដែលមានតម្រូវការប្រើប្រាស់ចិញ្ចើមផ្លូវ និង/ឬ ទ្រូងផ្លូវ អាចធ្វើរោងបុណ្យ រោងអាពាហ៍ពិពាហ៍ និងរោងកម្មវិធីផ្សេងៗបាន ក្នុងនោះ ម្ចាស់កម្មវិធីត្រូវលើកសំណើសុំមកអាជ្ញាធរមូលដ្ឋាន ដោយភ្ជាប់មកជាមួយនូវកិច្ចសន្យា និងគម្រោងប្លង់ច្បាស់លាស់ ដើម្បីពិនិត្យ និងសម្រេចអាស្រ័យទៅនឹងកម្រិតនៃការប្រើប្រាស់ និងភាពចាំបាច់ ប៉ុន្តែ មិនឱ្យលើសពី **១/២ (មួយភាគពីរ)** នៃទ្រូងផ្លូវ និងត្រូវរៀបចំកម្លាំងសមស្របដើម្បីជួយសម្រួលចរាចរណ៍
    + ដោយឡែក ចាប់ពី**ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩** តទៅ **រដ្ឋបាលរាជធានីភ្នំពេញ** តម្រូវឱ្យបងប្អូនប្រជាពលរដ្ឋ ត្រូវរកទីតាំងឯកជន វត្តអារាម-ព្រះវិហារ ឬ ទីតាំងសមស្របណាមួយជំនួសការប្រើប្រាស់ចិញ្ចើមផ្លូវ និង/ឬ ទ្រូងផ្លូវ **ហើយការធ្វើរោងបុណ្យ រោងអាពាហ៍ពិពាហ៍ និងរោងកម្មវិធីផ្សេងៗជាលក្ខណៈឯកជន នៅលើចិញ្ចើមផ្លូវ និង/ឬ ទ្រូងផ្លូវក្នុងរាជធានីភ្នំពេញ គឺមិនអនុញ្ញាតជូនឡើយ។**

**ខ-ចំពោះ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ និងបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ ត្រូវអនុវត្តដូចខាងក្រោម៖**
- បន្ថែមកម្លាំងនគរបាលចរាចរណ៍ ដោះស្រាយបញ្ហាចរាចរណ៍តាមបណ្ដាគោលដៅកកស្ទះ នៅចន្លោះម៉ោងមមាញឹក រួមមាន៖
    + **ពេលព្រឹក** ៖ ម៉ោង **៧:០០នាទី** ដល់ម៉ោង **៨:៣០នាទី** និង ម៉ោង **១១:០០នាទី** ដល់ម៉ោង **១២:៣០នាទី**
    + **ពេលរសៀល** ៖ ម៉ោង **១៣:៣០នាទី** ដល់ម៉ោង **១៤:៣០នាទី** និងម៉ោង **១៧:០០នាទី** ដល់ម៉ោង **១៩:០០នាទី** ។
- ត្រូវរៀបចំផែនការលម្អិត ដើម្បីបំបែកកន្លែងភូមិសាស្ត្រស្មុគស្មាញ ដូចជា មូលដ្ឋានជុំវិញផ្សាររដ្ឋ-ឯកជន ចំណុចផ្លូវប្រសព្វ តំបន់ទីប្រជុំជនធំៗ និងតំបន់កកស្ទះថ្មី
- រៀបចំរថយន្តស្ទូច ដើម្បីសហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌទាំង១២ ដើម្បីអនុវត្តវិធានការច្បាប់។

**គ-ចំពោះ មន្ទីរសាធារណការ និងដឹកជញ្ជូន មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី មន្ទីរព័ត៌មាន និងមន្ទីរ-អង្គភាពជំនាញពាក់ព័ន្ធជុំវិញរដ្ឋបាលរាជធានីភ្នំពេញ ត្រូវអនុវត្តដូចខាងក្រោម៖**
- ត្រូវផ្ដល់ការគាំទ្រផ្នែកបច្ចេកទេស និងត្រូវផ្ដួចផ្ដើមរៀបចំផែនការមេ និងគម្រោងប្លង់ ដើម្បីរៀបចំសណ្ដាប់ធ្នាប់របៀបរៀបរយ ពាក់ព័ន្ធនឹងការប្រើប្រាស់ចិញ្ចើមផ្លូវ និងផ្លូវថ្មើរជើងទាំងអស់ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ។



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

- ត្រូវសហការធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដល់បងប្អូនប្រជាពលរដ្ឋ ម្ចាស់លំនៅឋាន ម្ចាស់អាជីវកម្មដ្ឋាន ម្ចាស់ការដ្ឋាន អ្នកគ្រប់គ្រងមន្ទីរពេទ្យ-គ្រឹះស្ថានអប់រំ-អគារសាធារណៈ វិស័យឯកជន និងអ្នកប្រើប្រាស់ផ្លូវថ្នល់ តាមរយៈប្រព័ន្ធឃោសនា វិទ្យុ ទូរទស្សន៍ ប្រព័ន្ធព័ត៌មានវិទ្យា ការចុះអប់រំផ្ទាល់ វេទិកាសាធារណៈ និងមធ្យោបាយអប់រំផ្សព្វផ្សាយផ្សេងៗទៀត ដើម្បីឱ្យពួកគាត់បានយល់ដឹង និងមានការចូលរួមអនុវត្តសេចក្តីណែនាំនេះ សំដៅធានាការប្រើប្រាស់ចិញ្ចើមផ្លូវ ឱ្យចំទិសដៅសម្រាប់ប្រយោជន៍សាធារណៈ។

**ឃ-ចំពោះគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌទាំង១២ ត្រូវអនុវត្តដូចខាងក្រោម៖**

- ត្រូវបង្កើត **ក្រុមការងាររៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ និងប្រើប្រាស់ចិញ្ចើមផ្លូវសាធារណៈទាំងអស់** ក្នុងភូមិសាស្ត្រនៃខណ្ឌរបស់ខ្លួន ដោយមាន **អភិបាល នៃគណៈអភិបាលខណ្ឌនីមួយៗជាប្រធាន**។ ក្រុមការងារនេះ មានតួនាទី និងភារកិច្ចទទួលខុសត្រូវ ក្នុងការរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ និងត្រូវធានាការប្រើប្រាស់ចិញ្ចើមផ្លូវ ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងសមស្របទៅនឹងសកម្មភាពប្រើប្រាស់ ដូចមានចែងនៅក្នុង **ចំណុចទី២ "គោលការណ៍ទូទៅ"** នៃសេចក្តីណែនាំនេះ
- ត្រូវចុះធ្វើការអប់រំ ណែនាំដល់ប្រជាពលរដ្ឋ ដែលបាននឹងកំពុងប្រើប្រាស់ចិញ្ចើមផ្លូវ និង/ឬ ទ្រូងផ្លូវ ដោយរំលោភបំពាន តាមរយៈការប្រើប្រាស់វិធីសាស្ត្រទន់ភ្លន់តែម៉ឺងម៉ាត់ ដើម្បីឱ្យពួកគាត់ចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះ។ ក្នុងករណីនៅតែមិនអនុវត្តតាមការណែនាំនេះ **មន្ត្រីអនុវត្ត** ត្រូវធ្វើកំណត់ហេតុ ដើម្បីចាត់វិធានការរដ្ឋបាល និងវិធានការច្បាប់ជាធរមាន
- ត្រូវណែនាំដល់ម្ចាស់ទីតាំងភោជនីយដ្ឋាន-អាហារដ្ឋាន និងម្ចាស់អាជីវកម្មដ្ឋាននានា ឱ្យគោរព និងអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះជាប់ជាប្រចាំ។ ក្នុងករណីមិនព្រមអនុវត្តតាម អាជ្ញាធរខណ្ឌត្រូវសហការជាមួយកម្លាំងមានសមត្ថកិច្ច និងជំនាញពាក់ព័ន្ធធ្វើការផាកពិន័យតាមច្បាប់ និងអាចឈានទៅបិទទីតាំងអាជីវកម្ម
- ត្រូវធ្វើការណែនាំ និងធ្វើកំណត់ហេតុឱ្យបានត្រឹមត្រូវ ជាមួយម្ចាស់ការដ្ឋានដែលរំលោភបំពានចិញ្ចើមផ្លូវ និង/ឬ ទ្រូងផ្លូវ ក្នុងករណីមិនរាងចាលត្រូវផ្អាកការដ្ឋាននោះភ្លាម
- ត្រូវចុះល្បាត និងឃ្លាំមើលជាប្រចាំចំពោះរថយន្តដឹកទំនិញធុនធំ រថយន្តកុងទីន័រ រថយន្តបាញ់បេតុង និងរថយន្តក្រឡុកស៊ីម៉ង់ ដោយត្រូវមានវិធានការឱ្យបានម៉ឺងម៉ាត់ ជាពិសេស ត្រូវត្រួតពិនិត្យឡើងវិញចំពោះវិធានការទប់ស្កាត់ការចេញ-ចូលរាជធានីភ្នំពេញ ខុសតម្រាយផ្លូវ និងពេលវេលាអនុញ្ញាត
- ត្រូវរៀបចំផែនការចុះរុះរើការសាងសង់សំណង់ឯកជន ការតសំយ៉ាបដំបូលផ្ទះ ការហ៊ុំព័ទ្ធចិញ្ចើមផ្លូវ និងបញ្ឈប់ការប្រើប្រាស់ចិញ្ចើមផ្លូវដោយរំលោភបំពាន
- ចំពោះការយកចិញ្ចើមផ្លូវ និង/ឬ ទ្រូងផ្លូវ ធ្វើជាទីផ្សារនាពេលកន្លងមក ត្រូវបញ្ឈប់ជាបន្ទាន់ ក្នុងនោះ រដ្ឋបាលខណ្ឌនីមួយៗ ត្រូវចុះរៀបចំសណ្តាប់ធ្នាប់បើកផ្លូវឱ្យធ្វើចរាចរណ៍ឡើងវិញ ដោយត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព ដូចក្នុងករណីបណ្តាផ្លូវជុំវិញ**ផ្សារដើមគ**។ ជាមួយគ្នានេះ រដ្ឋបាលខណ្ឌនីមួយៗ ត្រូវពិនិត្យវាយតម្លៃលក្ខណៈសម្បត្តិផ្សារក្រមួនក្នុងមូលដ្ឋានរបស់ខ្លួន ថាតើគួររៀបចំនៅកន្លែងណា និងត្រូវគ្រប់គ្រងរបៀបណា ដើម្បីភាពសុខដុមរមនាក្នុងមូលដ្ឋាន និងមិនប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

- ត្រូវអនុវត្តការងារតាមការណែនាំខាងលើនេះ ឱ្យបានត្រឹមត្រូវ មឹត់មត់ និងទន់ភ្លន់ ដោយត្រូវរាយការណ៍ប្រចាំសប្តាហ៍ អំពីលទ្ធផលនៃការអនុវត្ត ជូនមកគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានីភ្នំពេញ ឱ្យបានទៀងទាត់ និងទាន់ពេលវេលា។

**រដ្ឋបាលរាជធានីភ្នំពេញ** ទុករយៈពេល **០១ (មួយ) ខែ** គិតចាប់ពីកាលបរិច្ឆេទចេញសេចក្តីណែនាំនេះ ជូនបងប្អូនប្រជាពលរដ្ឋ ម្ចាស់លំនៅឋាន ម្ចាស់អាជីវកម្មដ្ឋាន ម្ចាស់ការដ្ឋាន អ្នកគ្រប់គ្រងមន្ទីរពេទ្យ-គ្រឹះស្ថានអប់រំ-អគារសាធារណៈ វិស័យឯកជន និងអ្នកប្រើប្រាស់ផ្លូវថ្នល់ទាំងអស់ ដើម្បីធ្វើការកែសម្រួល និងរៀបចំទីតាំងរបស់ខ្លួន ឱ្យបានត្រឹមត្រូវស្របតាមខ្លឹមសារណែនាំខាងលើនេះ។

ក្នុងករណីបងប្អូនប្រជាពលរដ្ឋ ម្ចាស់លំនៅឋាន ម្ចាស់អាជីវកម្មដ្ឋាន ម្ចាស់ការដ្ឋាន អ្នកគ្រប់គ្រងមន្ទីរពេទ្យ-គ្រឹះស្ថានអប់រំ-អគារសាធារណៈ វិស័យឯកជន និងអ្នកប្រើប្រាស់ផ្លូវថ្នល់ទាំងឡាយណា មិនចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះ **គណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌទាំង១២ និងមន្ទីរ-អង្គភាពជំនាញពាក់ព័ន្ធ** ត្រូវចាត់វិធានការរដ្ឋបាលរួមមាន បិទអាជីវកម្ម ផ្អាកការដ្ឋាន ដកហូតសម្ភារ រុះរើសំណង់ ។ល។ ក្នុងករណីចាំបាច់ត្រូវចាត់វិធានការច្បាប់ជាធរមាន។

ទទួលបានសេចក្តីណែនាំនេះ នាយករដ្ឋបាលសាលារាជធានីភ្នំពេញ អភិបាល នៃគណៈអភិបាលខណ្ឌទាំង១២ ស្នងការនគរបាលរាជធានីភ្នំពេញ មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ បងប្អូនប្រជាពលរដ្ឋ ម្ចាស់លំនៅឋាន ម្ចាស់អាជីវកម្មដ្ឋាន ម្ចាស់ការដ្ឋាន អ្នកគ្រប់គ្រងមន្ទីរពេទ្យ-គ្រឹះស្ថានអប់រំ-អគារសាធារណៈ វិស័យឯកជន និងអ្នកប្រើប្រាស់ផ្លូវថ្នល់ទាំងអស់ ត្រូវចាត់តាំងអនុវត្តដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃសុក្រ ១០ រោច ខែ កត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ ធ្នូ ឆ្នាំ២០១៨

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

**កន្លែងទទួល៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងសាធារណការ និងដឹកជញ្ជូន

-លេខាធិការដ្ឋាន គ.ជ.អ.ប

-ក្រុមប្រឹក្សារាជធានីភ្នំពេញ

*"ដើម្បីជូនជ្រាបជាព័ត៌មាន"*

-ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ

-បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ

-រដ្ឋបាលខណ្ឌទាំង១២

-មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ

-មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ

-មន្ទីរព័ត៌មានរាជធានីភ្នំពេញ

-មន្ទីរ-អង្គភាពជំនាញពាក់ព័ន្ធ

*"ដើម្បីអនុវត្ត"*

-គ្រប់ប្រព័ន្ធឃោសនា

*"ដើម្បីផ្សព្វផ្សាយ"*

-ឯកសារ-កាលប្បវត្តិ



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

ស.ជ.ណ DP-K02

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានីភ្នំពេញ**
**រដ្ឋបាលខណ្ឌដូនពេញ**
លេខ ២២០/១៩ ស.ក.ណ

# សេចក្តីជូនដំណឹង

## ស្តីពីការរៀបចំសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ តាមបណ្តោយមហាវិថីព្រះនរោត្តម

**យោង:** ស្មារតីអង្គប្រជុំរបស់រដ្ឋបាលរាជធានីភ្នំពេញ ។

ដើម្បីរក្សាបាននូវសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ រដ្ឋបាលខណ្ឌដូនពេញ សូមជូនដំណឹងដល់ម្ចាស់អាជីវកម្ម ស្ថាប័នរដ្ឋ ឯកជន នៅតាមបណ្តោយមហាវិថីព្រះនរោត្តម ដែលបានកំពុងចតរថយន្ត ម៉ូតូ នៅលើចិញ្ចើមផ្លូវ សម្រាប់អ្នកថ្មើរជើង និងសម្រាប់ជនពិការឱ្យបានជ្រាបថា៖ ដើម្បីសោភ័ណ្ឌភាព និងសុវត្ថិភាព សម្រាប់ប្រជាពលរដ្ឋ ក្នុងការធ្វើដំណើរឆ្លងកាត់ ឱ្យជៀសផុតពីការកកស្ទះចរាចរណ៍ រដ្ឋបាលខណ្ឌដូនពេញ សម្រេចដាក់ចេញជាគោលការណ៍ដូចខាងក្រោម៖

១.មិនអនុញ្ញាតឱ្យមានការចតរថយន្ត ម៉ូតូ គ្រប់ប្រភេទនៅលើចិញ្ចើមផ្លូវសាធារណៈ និងផ្លូវសម្រាប់អ្នកថ្មើរជើង (ដែលចំណែកគំនូសពណ៌លឿងមកដល់ជញ្ជាំងផ្ទះប្រជាពលរដ្ឋ ឬរបងស្ថាប័នរដ្ឋ ឯកជន គឺទុកសម្រាប់ជនពិការ ក៏ដូចជារទេះជនពិការធ្វើដំណើរឆ្លងកាត់ និងមួយផ្នែកទៀតពីគំនូសពណ៌លឿងមកដល់ចិញ្ចើមផ្លូវត្រូវរក្សាទុក សម្រាប់ប្រជាពលរដ្ឋ ធ្វើដំណើរឆ្លងកាត់)។

២.នៅខាងមុខទីតាំងអាជីវកម្មរបស់ខ្លួន ត្រូវមានចំណតផ្ទាល់ខ្លួន ដែលមិនត្រូវធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈឡើយ ។

៣.នៅមុខទីតាំងអាជីវកម្មរបស់ខ្លួន រួមទាំងស្ថាប័នរដ្ឋ ឯកជន ត្រូវសំអាតអនាម័យ ឱ្យបានស្អាតជានិច្ច ដើម្បីរួមចំណែកការពារបរិស្ថាន សម្រាប់រាជធានីភ្នំពេញរបស់យើង។

៤.ម្ចាស់ទីតាំងស្ថាប័នរដ្ឋ ឯកជន អាចសុំចតរថយន្ត ម៉ូតូ របស់ខ្លួន តាមគំនូសទីតាំង ដែលមន្ទីរសាធារណការរាជធានីភ្នំពេញបានកំណត់ ។

៥.ក្នុងករណី លោក-លោកស្រី នៅតែមិនអនុវត្តតាមសេចក្តីជូនដំណឹង ក៏ដូចជាការណែនាំរបស់រដ្ឋបាលខណ្ឌដូនពេញទេ នោះរដ្ឋបាលខណ្ឌនឹងចាត់វិធានការ រដ្ឋបាលដោយ ស្ទូចយករថយន្ត ម៉ូតូ មករក្សាទុក នៅរដ្ឋបាលខណ្ឌរយៈពេល ១៥ថ្ងៃ ទើបដោះស្រាយជូន ។

ទទួលបានសេចក្តីជូនដំណឹងនេះ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា លោក-លោកស្រី នឹងសហការជាមួយរដ្ឋបាលខណ្ឌដូនពេញ ក្នុងការអនុវត្តន៍ឱ្យមានប្រសិទ្ធភាព ដើម្បីប្រជាពលរដ្ឋ និងសម្រាប់យើងទាំងអស់គ្នា ៕

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក-លោកស្រី មេត្តាចាត់ចែងតាមការគួរ ។

ថ្ងៃចន្ទ ១៤កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩
**អភិបាល នៃគណៈអភិបាលខណ្ឌដូនពេញ**

សុខ_ពេញវុធ

**ចម្លងជូន**
- សាលារាជធានីភ្នំពេញ
- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
- មន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានីភ្នំពេញ
- ក្រុមប្រឹក្សាខណ្ឌដូនពេញ
- អធិការនគរបាលខណ្ឌដូនពេញ
- មេបញ្ជាការកងរាជអាវុធហត្ថខណ្ឌដូនពេញ
- សង្កាត់-ប៉ុស្តិ៍ទាំង១១
  "ដើម្បីជូនជ្រាប"
- ឯកសារកាលប្បវត្តិ